ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- យោបល់មួយចំនួនស្តីអំពីបញ្ហាសំណងជំងឺចិត្ត
- ការស្វែងរកយុត្តិធម៌នៅកម្ពុជាដែលពិបាកនឹងយល់

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១១៨ ខែតុលា ឆ្នាំ២០០៩

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១១៨ ខែតុលា ឆ្នាំ២០០៩

## មាតិកា

◆យោបល់មួយចំនួនស្ដីអំពីបញ្ហាសំណងជំងឺចិត្ត ....................................១

**ផ្នែកឯកសារ**

◆វិទ្យុកម្ពុជាប្រជាធិបតេយ្យ ............................................................៣

◆ស្រី ណាំៈ តួនាទី សែប នៅកងម៉ារីន ............................................៥

◆អ្នកធ្វើការក្នុងរាជរោងវាំងសម័យខ្មែរក្រហម ..........................................៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ការដាក់ពិរុទ្ធភាពលើខ្លួនឯង និងការពិត ..........................................៩

◆អះអាងថាមានជនបរទេសត្រូវបានដុតទាំងរស់នៅមន្ទីរស-២១ ............១១

◆ដំណើរទស្សនកិច្ចទៅកាន់ប្រទេសស៊ុយអែដ ....................................១៣

◆របាយការណ៍ពីដំណើរទស្សនកិច្ច ...............................................១៦

**ផ្នែកច្បាប់**

◆ការមិនយកចិត្តទុកដាក់ទៅលើការស៊ើបអង្កេត ..............................២៦

◆ហេតុអ្វីបានជាវិប្បដិសារីមិនចោទជាបញ្ហា ..................................៤៤

**វេទិកាពិភាក្សាសាធារណៈ**

◆អ្វីដែលចាំបាច់សម្រាប់គណៈកម្មការស្វែងរកការពិត? .................៥១

◆ការស្វែងរកយុត្តិធម៌នៅកម្ពុជាដែលពិបាកនឹងយល់ ......................៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆អតីតកាលរបស់ម្ដាយខ្ញុំ ........................................................៦០



សិស្ស ចាម-មូស្លីម កំពុងអានសៀវភៅ
“ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ”



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** គ្រី ស៊ុយហៀង, សុខ វណ្ណៈ, ញាណ សុជាតិ, អេង កុកថាយ, ស៊ីរី សាវីណា, ស្បេនស៊ើ ខ្រាខេ, រីហាន អាប៊ីរ៉ាន, លី សុខឃាង, ហ៊ិន សុធានី **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា, ទេស ម៉ារ៉ែម **អ្នកបកប្រែៈ** ជា ផល្លា **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុជាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# យោបល់មួយចំនួនស្តីអំពីបញ្ហាសំណងជំងឺចិត្ត

ខ្ញុំសរសេរលិខិតនេះក្នុងបំណងដើម្បីចែករំលែកនូវយោបល់ខ្លះៗ ជុំវិញការបង្កើតកញ្ចប់ថវិកាសម្រាប់ជនរងគ្រោះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយដែលកញ្ចប់ថវិកានេះត្រូវបានបង្កើតរួចហើយនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ទាំងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងកម្ពុជា និងច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញឆ្នាំ២០០៤ មិនបានចែងអំពីកញ្ចប់ថវិការបៀបនេះទេ ។ ដូច្នេះដើម្បីអាចបង្កើតកញ្ចប់ថវិកានេះបាន កិច្ចព្រមព្រៀងថ្មីមួយត្រូវតែបានបង្កើតឡើងជាមុនសិន ។ ការចរចាបែបនេះគឺជាឧបសគ្គមួយយ៉ាងធំ ដូចដែលបានកើតឡើងរួចហើយនៅក្នុងការចរចាដែលចំណាយពេលច្រើនក្នុងការបង្កើតយន្តការប្រឆាំងអំពើពុករលួយ ។ ជាងនេះទៅទៀតបញ្ហានេះនឹងតម្រូវឲ្យមានការចំណាយពេលវេលាជាច្រើន ព្រមទាំងងាកចេញពីគោលបំណងសំខាន់របស់អង្គជំនុំជម្រះនេះផង ។ សម្រាប់រូបខ្ញុំ គោលបំណងសំខាន់របស់អង្គជំនុំជម្រះនេះមានពីរៈ ១) ចេញសាលក្រមស្តាពរមួយពាក់ព័ន្ធនឹងជនជាប់ចោទ និង ២) ផ្តល់នូវការទទួលស្គាល់ជាផ្លូវការមួយចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា ។

ខ្ញុំយល់ថា កញ្ចប់ថវិកានេះគឺជាយន្តការមិនត្រឹមត្រូវទេក្នុងការសម្រេចឲ្យបាននូវគោលបំណងទីពីរ ។ នៅពេលដែលអង្គជំនុំជម្រះវិសាមញ្ញបញ្ចប់នូវសំណុំរឿងរបស់ខ្លួន បុគ្គលិកផ្នែកអន្តរជាតិនឹងចាកចេញពីប្រទេសកម្ពុជា ។ បើយោងទៅតាមឆន្ទៈរបស់កិច្ចព្រមព្រៀង កញ្ចប់ថវិកានេះនឹងទំនងជាត្រូវគ្រប់គ្រងរួមគ្នាដោយរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ និងប្រហែលជាអាចមានជំនួយពីអង្គការក្រៅរដ្ឋាភិបាល ។ នៅក្នុងបរិយាកាសនយោបាយ និងវប្បធម៌បច្ចុប្បន្នរបស់កម្ពុជា វាមិនអាចធ្វើទៅរួចទេក្នុងការបង្កើតកញ្ចប់ថវិកាមួយដែលត្រូវគ្រប់គ្រងដោយរដ្ឋាភិបាល ឬដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកប្រកបដោយតម្លាភាព និងបានទៅដល់ដៃជនរងគ្រោះ ។ នៅក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កិច្ចខិតខំប្រឹងប្រែងល្អបំផុតទាំងអស់ ត្រូវបានយកមកប្រើប្រាស់ដើម្បីធានាឲ្យបាននូវតម្លាភាពនៃថវិកា និងការជ្រើសរើសបុគ្គលិក ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបរាជ័យតាំងពីពេលចាប់ផ្តើមមកម្ល៉េះ ។ កញ្ចប់ថវិកានេះនឹងដូចគ្នាដែរមិនខាន ។ អំពើពុករលួយទៅលើថវិការបស់ជនរងគ្រោះនឹងបង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់កេរ្តិ៍ឈ្មោះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាងការចោទប្រកាន់អំពីទង្វើមិនប្រក្រតីបច្ចុប្បន្ននេះទៅទៀត ដោយសារថាថវិកានោះគឺមិនមែនត្រឹមតែជាការដោះដូររវាងមន្ត្រីតុលាការនោះទេ ប៉ុន្តែជាការដកយកថវិកាពីជនរងគ្រោះ ។ ការនេះនឹងកាន់តែធ្វើឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដែលថា អ្នករួចរស់ជីវិតលួចពីអ្នករួចរស់ជីវិត ។

បន្ថែមទៅលើការព្រួយបារម្ភអំពីបញ្ហាពុករលួយនេះ កញ្ចប់ថវិកានេះនឹងបង្កឲ្យមានការបែកបាក់នៅក្នុងចំណោមជនរងគ្រោះ ។ បើទោះជាសំណងជំងឺចិត្តជាលក្ខណៈផ្លូវចិត្តជានិមិត្តរូបនិងជាសមូហភាពក៏ដោយ ក៏គេត្រូវតែធ្វើការសម្រេចថាតើបូជនីយដ្ឋានណាមួយដែលត្រូវសង់នៅកន្លែងណា ហើយមិនមែនជនរងគ្រោះប្រមាណ៥លាននាក់ពីរបបនោះសុទ្ធតែអាចទទួលបានផលប្រយោជន៍ទាំងអស់គ្នានោះទេ ។ ជាងនេះទៅទៀត ក៏មិនមានថវិកាណាគ្រប់គ្រាន់សម្រាប់ជួសជុលអ្វីដែលអ្នកនៅរស់ជីវិតទាំងនេះបានបាត់បង់ដែរ ។

ចាប់ពីពេលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ ជនរងគ្រោះខ្លួនឯងបានខិតខំព្យាយាមដើម្បីទទួលបាននូវការផ្សះផ្សាដែលរួមមានទាំងការសាងសង់កន្លែងតម្កល់ឆ្អឹង និងបូជនីយដ្ឋានផ្សេងៗ ។ ជាជាងសាងសង់ថ្មី កិច្ចខិតខំប្រឹងប្រែងកាលពីអតីតកាលអាចត្រូវបានទទួលស្គាល់តាមរយៈការរំឭក ឬការប្រារព្ធពិធីផ្សេងៗ ។ ការសាងសង់ស្លាកទទួលស្គាល់ដែលមិនចំណាយថវិកាច្រើនអាចត្រូវដាក់នៅតាមបូជនីយដ្ឋាន រណ្តៅសាកសព មន្ទីរសន្តិសុខឬការដ្ឋានធ្វើការងារដើម្បីជាការទទួលស្គាល់ទុក្ខលំបាក

របស់អ្នកដែលត្រូវគេរំលោភបំពាន និងសម្លាប់ ។

លទ្ធភាពមួយទៀត ដែលត្រូវបានលើកឡើងប្រាប់ខ្ញុំដោយដើមបណ្តឹងរដ្ឋប្បវេណីម្នាក់គឺបរិច្ចាគប្រអប់សម្រាប់រៃអង្គាសថវិកាទៅឲ្យគ្រប់វត្តទាំងអស់នៅក្នុងប្រទេសដើម្បីឲ្យប្រជាជនតាមមូលដ្ឋាន និងអ្នកមកទស្សនាអាចចូលរួមចំណែកបរិច្ចាគក្នុងនាមជាជនរងគ្រោះមកពីតំបន់នោះ ។ ជាជាងការប្រើប្រាស់របៀបដោះស្រាយពីថ្នាក់លើចុះមកក្រោម ដែលងាយនឹងកើតមានភាពមិនប្រក្រតីរបៀបដោះស្រាយពីថ្នាក់ក្រោមឡើងទៅលើ នឹងអាចជួយធានាថា ថវិកានឹងស្ថិតនៅក្នុងសហគមន៍មូលដ្ឋាន និងអាចធ្វើឲ្យសហគមន៍មានអំណាចក្នុងសម្រេចចិត្តដោយខ្លួនឯងអំពីរបៀបដែលថវិកានេះនឹងត្រូវចំណាយ ។

យោបល់ទីបីគឺអង្គជំនុំជម្រះវិសាមញ្ញអាចផ្តល់នូវការទទួលស្គាល់ជានិមិត្តរូបអំពីឧក្រិដ្ឋកម្មដែលកើតមាននៅក្នុងសហគមន៍មូលដ្ឋាន ។ ញត្តិរណសិរ្សកាលពីទសវត្សរ៍៨០ ដែលមាននិយាយអំពីព្យសនកម្មជាបុគ្គល និងជាក្រុម អាចត្រូវបានប្រើប្រាស់ជាប្រភពមួយសម្រាប់ព័ត៌មាននេះ ។ ជាងនេះទៅទៀត តំបន់នីមួយៗអាចត្រូវបានស្នើសុំឲ្យដាក់ជូននូវញត្តិថ្មីមួយទៀតដែលនៅក្នុងញត្តិនេះមានព័ត៌មានពីឧក្រិដ្ឋកម្ម និងចំនួនជនរងគ្រោះ ។ អង្គជំនុំជម្រះវិសាមញ្ញអាចធ្វើជាលិខិតទទួលស្គាល់ជាផ្លូវការដែលអាចដាក់ព្យួរនៅក្នុងការិយាល័យរដ្ឋាភិបាលដែលគ្រប់ៗគ្នាអាចមើលបាន ។ លិខិតនេះ មិនគួរបញ្ជាក់អំពីការអះអាងជាក់លាក់ណាមួយទេ គឺគ្រាន់តែទទួលស្គាល់នូវការចូលរួមចំណែកធ្វើឲ្យមានការយល់ដឹងច្រើនជាងមុនអំពីរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ។

ចុងបញ្ចប់ ខ្ញុំសូមស្នើសុំឲ្យប្រារព្ធពិធីមួយនៅរាជធានីបុរាណឧត្តុង្គ នៅពេលបញ្ចប់ការកាត់ទោស ។ ព្រះសង្ឃរាប់ពាន់អង្គអាចនិមន្តទៅកាន់កំពូលភ្នំដើម្បីប្រារព្ធពិធីបួងសួងឧទ្ទិសទៅដល់វិញ្ញាណក្ខន្ធជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យព្រលឹងរបស់អ្នកដែលអនិច្ចកម្មទៅបានទៅកាន់សុគតិភព និងដើម្បីឲ្យអ្នកនៅរស់ជីវិតបានធូរស្បើយផ្លូវចិត្ត ។ ទាំងជាតិ និងពិភពលោកទាំងមូលនឹងចាប់អារម្មណ៍អំពីព្រឹត្តិការណ៍សំខាន់នេះ ហើយសកម្មភាពនេះនឹងអាចជួយជួសជុលជំងឺចិត្តដល់ជនរងគ្រោះច្រើនជាងកញ្ចប់ថវិកាដែលពួកគេមិនទំនងជានឹងទទួលបានផលប្រយោជន៍ ។

ការជួសជុលសំណងជំងឺចិត្តណាដែលមានពាក់ព័ន្ធនឹងថវិកានឹងងាយទទួលរងអំពើមិនប្រក្រតីដែលមិនអាចចៀសវាងបានឡើយ ។ លើសពីនេះទៅទៀត ថវិកានឹងមិនអាចផ្សះរបួសរបស់អ្នករួចរស់ជីវិតបានទេ ហើយពួកគេខ្លួនឯងបានដឹងអំពីរឿងនេះច្បាស់ណាស់ ។ ប្រសិនបើប្រាប់អំពីជម្រើសនេះ ប្រជាជននឹងទាមទារឲ្យសាងសង់បូជនីយដ្ឋានមួយថ្មី បើទោះបីជាមានមួយរួចហើយក៏ដោយ ។ ប៉ុន្តែប្រសិនបើបូជនីយដ្ឋានដែលមានរួចហើយត្រូវបានប្រារព្ធពិធីរំឭក ការណ៍នេះនឹងទទួលស្គាល់នូវកិច្ចខិតខំប្រឹងប្រែងកាលពីអតីតកាលឆ្ពោះទៅរកការផ្សះផ្សា និងចៀសវាងការបែកបាក់ ភាពលោភលន់ និងការរំពឹងទុកដែលមិនអាចក្លាយជាការពិត ។

ការផ្សះផ្សាតាមរយៈការប្រើប្រាស់ស្លាកទទួលស្គាល់ប្រអប់បរិច្ចាគថវិកា ញត្តិ និងការប្រារព្ធពិធី ត្រូវបានធ្វើឡើងរួចហើយចាប់តាំងពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យម្ល៉េះ ។ អ្វីដែលខ្វះខាតនោះគឺ ការទទួលស្គាល់ជាផ្លូវការ និងជាអន្តរជាតិ ។ ការផ្តល់ឲ្យនូវការទទួលស្គាល់បែបនេះនឹងអាចផ្តល់ឲ្យនូវភាពស្របច្បាប់ និងពង្រឹងកេរ្តិ៍ដំណែលអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងចំណោមប្រជាជនកម្ពុជា ខុសប្លែកពីកញ្ចប់ថវិកាប៉ុន្មានលានដុល្លារដែលមិនគ្រប់គ្រាន់សូម្បីតែប៉ះប៉ូវ ដល់អ្នករួចរស់ជីវិតសូម្បីតែមួយនាក់ក៏មិនបានផង ។

**ឆាំង យុ**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ ព្រឹក និងម៉ោង៧:០០-៧:៣០ ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ស៊ិន សុធីតា**

# វិទ្យុកម្ពុជាប្រជាធិបតេយ្យៈ សង្គម និង បរិស្ថាន

## *វិទ្យុភ្នំពេញ ស្តីអំពីគម្រោងអនុវត្ត*

អត្ថបទដកស្រង់ចេញពីសេចក្តីអធិប្បាយ «កម្មករបដិវត្តន៍របស់យើងទូទាំងប្រទេសសន្យាថា នឹងបន្តព្យាយាមបំពេញតួនាទីចម្បងរបស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាព និងជាដរាបដើម្បីសម្រេចគម្រោងឆ្នាំ១៩៧៧ ជាស្ថាពរ» ។

បច្ចុប្បន្ន កម្មករបដិវត្តន៍ទូទាំងប្រទេសកំពុងបំពេញតួនាទីចម្បងរបស់ខ្លួននៅតាមរោងចក្រ រោងជាង និងកងការងាររៀងៗខ្លួន ។ កម្មករទាំងនោះបានសាងសង់រោងចក្រថ្មីៗជាច្រើន ហើយបានជួសជុល និងកែប្រែរោងចក្រចាស់ៗដែលពឹងផ្អែកលើវត្ថុធាតុដើមនាំចូលពីបរទេស ឲ្យក្លាយមកជារោងចក្រថ្មីមួយអាចដំណើរការជាមួយនឹងវត្ថុធាតុដើមដែលមានស្រាប់នៅក្នុងស្រុក ។ ស្របពេលជាមួយគ្នានេះដែរ កម្មករបដិវត្តន៍របស់យើងក៏បានយកចិត្តទុកដាក់ទៅលើការពង្រីកសិប្បកម្មផ្សេងៗ ដើម្បីរួមចំណែកពង្រីងកំណើនសេដ្ឋកិច្ចជាតិ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ កម្មករបដិវត្តន៍នៅតាមរោងចក្រផ្សេងៗ និងនៅតាមកងការងារដូចជាកម្មករនៅស្រែអំបិល នៅចម្ការកៅស៊ូ ក្នុងតំបន់ភូមិភាគបូព៌ា និងរោងចក្រមួយចំនួនទៀតនៅក្នុងទីក្រុងភ្នំពេញដែលជាកម្មសិទ្ធិរបស់រដ្ឋ និងជារោងចក្រផលិតសម្ភារៈនិងឧបករណ៍កសិកម្មបានធ្វើសម្រេចតាមគម្រោង និងលើសពីគម្រោងសម្រាប់ឆ្នាំ ១៩៧៧ ដែលរៀបចំដោយបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

នៅពាក់កណ្តាលឆ្នាំនេះដែរ កម្មករបដិវត្តន៍របស់យើងក៏ដូចជាកសិករដែលរួមសហការជាមួយគ្នានឹងកងទ័ពបដិវត្តន៍នៅទូទាំងប្រទេសបានយល់ព្រមថា នឹងបន្តព្យាយាមបន្ថែមទៀតដើម្បីជម្នះនូវរាល់ឧបសគ្គនិងផលវិបាកទាំងអស់ដើម្បីត្រៀមខ្លួនជាមុនក្នុងការសម្រេចឲ្យបាននិងឲ្យលើសពីគម្រោងសម្រាប់ឆ្នាំ ១៩៧៧ ។ វិទ្យុភ្នំពេញស្តីអំពីការស្តុកទុក និងផ្គត់ផ្គង់ប្រេង ដកស្រង់ចេញពីនិទានកថា «កម្មករបដិវត្តន៍របស់យើងនៅកំពង់ផែប្រេងកាតរបស់រដ្ឋក្នុងទីក្រុងភ្នំពេញ កំពុងខិតខំបំពេញកាតព្វកិច្ចរបស់គេ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងប្រុងប្រយ័ត្នក្នុងជួរបដិវត្តន៍» ។

បន្ទាប់ពីប្រទេសកម្ពុជាត្រូវបានរំដោះរួចរាល់ជាស្ថាពរ កម្មករបដិវត្តន៍របស់យើងនៅកំពង់ផែប្រេងកាតរបស់រដ្ឋក្នុងទីក្រុងភ្នំពេញ បានសម្រុកជួសជុលនិងកែច្នៃកំពង់ផែទាំងអស់នោះឡើងវិញ ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងនិងការសិក្សាស្រាវជ្រាវ កម្មករបដិវត្តន៍របស់យើងបានសម្រេចការងារជួសជុល និងកែច្នៃម៉ាស៊ីនគ្រឿងចក្រ ធុងប្រេង និងសម្ភារៈផ្សេងៗទៀត ដែលត្រូវបានបំផ្លាញដោយខ្មាំងសត្រូវ ។

ជាលទ្ធផល ម៉ាស៊ីនគ្រឿងចក្រនិងសម្ភារៈផ្សេងៗទៀតនៅកំពង់ផែទាំងអស់បានចាប់ផ្តើមដំណើរការជាធម្មតាឡើងវិញ ។ កម្មករបដិវត្តន៍របស់យើងមិនត្រឹមតែទទួលបានជោគជ័យក្នុងការធ្វើឲ្យកំពង់ផែមានដំណើរការជាធម្មតាដូចមុនប៉ុណ្ណោះទេ គេក៏បានសម្រេចក្នុងការកែច្នៃម៉ាស៊ីនគ្រឿងចក្រ សម្រាប់បូមប្រេងឲ្យក្លាយជាសម្ភារៈប្រើប្រាស់មួយដែលអាចដំណើរការធម្មតាជាមួយនឹងសមាសភាពប្រើប្រាស់ប្រេងកម្រិតតូចបានដោយមានប្រសិទ្ធភាពខ្ពស់ ដោយមិនចាំបាច់ប្រើឧបករណ៍បន្លាស់ដែលនាំចូលមកពីបរទេស ។ ជាលទ្ធផល កងបូមប្រេងកាតដែលធ្លាប់តែបូមប្រេងបានត្រឹមតែ ៤.០០០លីត្រក្នុងមួយថ្ងៃ ឥឡូវអាចបូមប្រេងបានពីរទៅបីពាន់លីត្របន្ថែមទៀតក្នុងមួយថ្ងៃ ។ កម្មករមួយចំនួនទៀតគ្រប់គ្រងកងបូមប្រេង ដែលបូមប្រេងពីធុងប្រេងនៅតាមផ្លូវរថភ្លើងមកដាក់នៅក្នុងធុងស្តុកប្រេង ខណៈពេលដែលកម្មករដទៃទៀតជាប់រវល់បូមប្រេងដាក់ក្នុងធុងដែលនឹងត្រូវដឹកជញ្ជូនតាមកប៉ាល់កាណូត ទូក ទៅកាន់រោងចក្រ ការដ្ឋាន និងកន្លែងយកថ្ម ។

ចំណែកកម្មករផ្សេងៗទៀត នៅតែបន្តដឹកជញ្ជូនប្រេងឥន្ធនៈតាមរថយន្តដើម្បីចែកចាយតាមមហាវិថីធំៗ ។ ដោយសារ

រថភ្លើងជាច្រើនដែលដឹកធុងប្រេងតែងតែធ្វើដំណើរទៅវិញទៅមកជាញឹកញាប់ ជាហេតុធ្វើឲ្យសកម្មភាពរបស់កម្មករយើងជាប់រវល់ឥតឈប់ឈរនិងគ្មានការពន្យារពេល ពីព្រោះកម្មករយើងបានរកឃើញនូវបច្ចេកទេសថ្មី ដែលអាចបូមនិងស្តុកប្រេងទុកក្នុងល្បឿនលឿន។ សកម្មភាពនេះបានបង្ហាញឲ្យឃើញថា កម្មករបដិវត្តន៍របស់យើងនៅតាមកំពង់ផែប្រេងកាតក្នុងទីក្រុងភ្នំពេញ ដែលសុទ្ធតែជាកូនប្រុសនិងកូនស្រីរបស់ប្រជាជនក្រីក្រ ដែលពីមុនមកមិនធ្លាប់ស្គាល់ឧបករណ៍គ្រឿងចក្រនៅតាមកំពង់ផែប្រេងកាតទាំងអស់នេះ ឥឡូវបានស្គាល់ពីឧបករណ៍ទាំងនោះ និងបានរៀនសូត្រពីបច្ចេកទេសនៃការប្រើប្រាស់ឧបករណ៍ ហើយបច្ចុប្បន្នគេអាចធ្វើការងារគ្រប់ប្រភេទបានដោយខ្លួនឯងទៀតផង។ ខណៈពេលដែលកម្មកររបស់យើងកំពុងបូម ឬដឹកជញ្ជូនប្រេងពីកន្លែងមួយទៅកន្លែងមួយ គេតែងចងចាំក្នុងចិត្តជានិច្ចនូវតម្រូវការសេដ្ឋកិច្ចនិងព្យាយាមមិនឲ្យប្រេងហៀរចេញសូម្បីតែមួយតំណក់។ សញ្ញាបម្រាមភ្លើងឆេះអាចមើលឃើញនៅគ្រប់ទីកន្លែងទាំងអស់ជុំវិញបរិវេណកំពង់ផែប្រេងកាត។ ទោះជាធុងស្តុកប្រេងត្រូវបានលាបពណ៌ប្រាក់នៅពីលើ ដែលជួយចាំងផ្លាតពន្លឺព្រះអាទិត្យចេញក៏ដោយ ក៏បងប្អូនកម្មករយើងនៅតែបាញ់ទឹកពីលើធុងដាក់ប្រេងទាំងនោះ ដើម្បីការពារមិនឲ្យមានផ្ទុះអណ្តាតភ្លើងឡើង។ វិធីការពារភ្លើងឆេះមួយទៀត គឺនៅពេលកំពុងធ្វើការនៅកំពង់ផែប្រេងកាត កម្មករបដិវត្តន៍យើងមិនអាចជក់បារី ឬប្រើប្រាស់សម្ភារៈផ្សេងៗដែលអាចបង្កគ្រោះថ្នាក់ដល់កំពង់ផែឡើយ។ ទន្ទឹមនឹងនេះដែរ ការប្រុងប្រយ័ត្នសំខាន់ផ្សេងទៀតត្រូវបានដាក់ឲ្យអនុវត្តក្នុងករណីការពារភ្លើងឆេះ។

**ទិន្នផល**

***ដំណាំ (របាយការណ៍របស់ចិន)***

ការច្រូតស្រូវស្រាលនៅរដូវវស្សានេះ ជាទូទៅទទួលបានទិន្នផលល្អគ្រប់ទីកន្លែងទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ការប្រមូលទិន្នផលស្រូវស្រាលឥឡូវនេះជិតបញ្ចប់ហើយ។ តំបន់ដែលដាំស្រូវស្រាលក្នុងរដូវនេះសរុបមានទំហំធំជាងឆ្នាំមុន។ ស្រូវស្រាលដែលប្រមូលបានក្នុងរដូវនេះមាននៅខេត្តកំពង់ស្ពឺ មណ្ឌលគិរី ព្រះវិហារ សៀមរាប ឧត្តរមានជ័យ និងខេត្តក្រចេះ ដែលសុទ្ធតែជាកន្លែងពីមុនមកកម្រដាំដំណាំស្រូវ។

***ឧស្សាហកម្មធុនស្រាល***

រោងម៉ាស៊ីនតម្បាញនៅតំបន់បូព៌ា គឺជារោងចក្រមួយក្នុងចំណោមរោងចក្រថ្មីៗដទៃទៀតដែលបានសាងសង់ឡើងដោយកម្មករបដិវត្តន៍ភូមិភាគបូព៌ារបស់យើងតាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ រោងចក្រនេះចាប់ផ្តើមដំណើរការចាប់តាំងពីថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៧ ដោយមានបំពាក់នូវម៉ាស៊ីនកីស្វ័យប្រវត្តិចំនួន៨២គ្រឿង។ ដូច្នេះ ទើបកម្មកររបស់យើងអាចផលិតក្រណាត់បានប្រវែងពី ៧៥០-១.០០០ម៉ែត្រ ក្រណាត់មុងពី ១.៩៥០-២.០០០ម៉ែត្រ និងក្រមាចំនួន ១៨០-២០០ ក្នុងមួយថ្ងៃ។ លើសពីការបំពេញតួនាទីក្នុងការត្បាញ កម្មករបដិវត្តន៍របស់យើងនៅក្នុងរោងតម្បាញនេះកំពុងសាងសង់ និងជួសជុលអគារបន្ថែមទៀត ឬផលិតកីស្វ័យប្រវត្តិឲ្យបានចំនួន ១៣៩កី និងផលិតម៉ាស៊ីនក្រឡឹងចំនួនពីរ រួមទាំងឡរំលាយលោហធាតុចំនួនមួយផងដែរ។ **ឯកសារ D២៩៨០៤**

# សេចក្តីប្រកាសរកប្អូនប្រុស

*នាងខ្ញុំឈ្មោះ នាក់ ហេង សព្វថ្ងៃរស់នៅភូមិភ្នំតូច ឃុំស្តេចគង់ខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត ឪពុកខ្ញុំឈ្មោះ សោម យេន (ស្លាប់) និងម្តាយឈ្មោះ អ៊ុន សឹម (ស្លាប់)។ ខ្ញុំមានបងប្អូនពីរនាក់ គឺខ្ញុំនិងប្អូនប្រុសម្នាក់ទៀតឈ្មោះ នាក់ ធី (បាត់ខ្លួន)។ ខ្ញុំសូមស្វែងរកប្អូនប្រុសឈ្មោះ នាក់ ធី ដែលបាត់ខ្លួនពេលធ្វើជានិរសារនៅព្រំដែនវៀតណាមនៅមុនឆ្នាំ១៩៧៥។ នៅពេលនោះ ធី ទើបតែមានអាយុប្រហែលជា១៨ឬ១៩ឆ្នាំប៉ុណ្ណោះ បានចេញពីផ្ទះទៅធ្វើជានិរសារជាមួយមីងឈ្មោះ ពៅ ជាអ្នកនាំចូល។ ក្រោយមកខ្ញុំក៏បាត់ដំណឹង ធី រហូត។*

*ប្រសិនបើប្អូនបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនណាស្គាល់ ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ព័ត៌មានមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០១៧ ៩២៩ ៩៦១ ឬមេភូមិភ្នំតូចឈ្មោះ មិន ឈុំ ឬទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា។* **សូមអរគុណ**

# ស្រី ណាំ៖ គួនាធី ជាសែបនៅកងម៉ារីន (សេ.អ៊ី.អា បង្កប់ខ្លួននៅកម្ពុជា)

## ជីវប្រវត្តិសង្ខេប

ស្រី ណាំ អាយុ ៨១ឆ្នាំ មានស្រុកកំណើតនៅព្រៃនប់ ឃុំសំរុង ស្រុកព្រៃនប់ ខេត្តកំពត ។ ឪពុកឈ្មោះ អ៊ុង ស្រី (ស្លាប់) ម្តាយឈ្មោះ អ៊ួច សាញ់ មានមុខរបរធ្វើស្រែចម្ការ ។ ស្រី ណាំ មានបងប្អូន៥នាក់គឺ ទីមួយ ស្រី នក គួនាទីជា ពលទោម៉ារីន និង ស្រី ណាំ តួនាទីជា សែបម៉ារីន ចំណែក៣នាក់ទៀត មានរបបជាអ្នកនេសាទត្រី កម្មករដុតនុំ និងម្នាក់ទៀតរស់នៅជាមួយម្តាយ ។ ស្រី ណាំ មានប្រពន្ធឈ្មោះ ឌុប ផៃ និងមានកូនចំនួន៤នាក់ ។

នៅឆ្នាំ១៩៥២ ស្រី ណាំ ចូលបម្រើកងទ័ពនៅខេត្តកំពត មានតួនាទីជាកងកុម្មង់ដូម៉ារីន ។ នៅឆ្នាំ១៩៦១ ស្រី ណាំ បានពាក់សក្តិជាកាប៉ូរ៉ាល់ ហើយក្រោយមកទៀតឋានន្តរសក្តិនេះត្រូវបានដំឡើងពីពាក់កាប៉ូរ៉ាល់ថ្នាក់លេខ១ រហូតដល់ពាក់ជាកាប៉ូរ៉ាល់សែបនៅឆ្នាំ១៩៧០ ។ នៅក្នុងឆ្នាំ១៩៧០ ដដែល ស្រី ណាំ ត្រូវបានលោកស័ក្តិ៤ អាំង គឹមលី បញ្ចូលជាសេ.អ៊ី.អា ក្នុងមូលដ្ឋាននាវាចរ នៅជ្រោយចង្វារ ។ រហូតដល់ឆ្នាំ ១៩៧១ ស្រី ណាំ បានពាក់ដោយ១ជាន់ ហើយនៅឆ្នាំបន្ទាប់ ស្រី ណាំ ក៏បានទៅរៀនមុជទឹកនៅប្រទេសវៀតណាមខាងត្បូងអស់រយៈពេល៦ខែបន្ថែមទៀត ។ នៅឆ្នាំ១៩៧៣ ស្រី ណាំ បានពាក់ដោយ៣ជាន់ ក្រោយមកនៅក្នុងឆ្នាំ១៩៧៤ ស្រី ណាំ បានពាក់សក្តិជាអាត់ស៊ុយដង់ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ស្រី ណាំ បានរត់ភៀសខ្លួនទៅរស់នៅសហរដ្ឋអាមេរិកជាមួយ ស្រី ឌឿន ដែលពាក់ស័ក្តិ៥ ។ នៅសហរដ្ឋអាមេរិកបានរយៈពេល១ឆ្នាំ ស្រី ណាំ ក៏វិលត្រឡប់មកប្រទេសកម្ពុជាវិញនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៦ ។ ប៉ុន្តែ នៅខែមិថុនា ឆ្នាំ១៩៧៦ ស្រី ណាំ ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរក-១៥ ។ នៅទីនោះ ស្រី ណាំ មានបំណងរត់គេចខ្លួនទៅប្រទេសសៀមជាមួយនឹងមនុស្សចំនួន៧នាក់ទៀត ។ ក្រោយមកក៏បែកការណ៍ ស្រី ណាំ ត្រូវបានចាប់ខ្លួនម្តងទៀតនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៦ ហើយឃុំឃាំងនៅមន្ទីរស-២១ (គុកទួលស្លែង) រហូតដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ទើបយកទៅកម្ទេច ។

## ផែនការរបស់ចក្រពត្តិអាមេរិក

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៦ ស្រី ណាំ ទទួលផែនការពីសក្តិ៥ ឈ្មោះ ស្រី ឌឿន នៅរដ្ឋហ៊ីឡាដែលហ៊ីយ៉ា សហរដ្ឋអាមេរិកថា ពួកគេនឹងធ្វើការវាយលុករំដោះប្រទេសកម្ពុជានៅខែឧសភា ឆ្នាំ១៩៧៦ ដោយប្រមូលប្រជាជនដែលរស់នៅប្រទេសបារាំង សហរដ្ឋអាមេរិក និងប្រទេសសៀម មកធ្វើជាកងទ័ព ។ ស្រី ឌឿន និង សោម សារី បានបញ្ជាក់ថា មនុស្ស៣នាក់ត្រូវបានបញ្ជូនមកកាន់ប្រទេសកម្ពុជារួចហើយ រួមមាន សួន, សុក ស៊ីម និង អោក យ៉ាន់ ។ ចំណែកឯ ស្រី ណាំ មានភារកិច្ចបង្កប់ខ្លួននៅក្នុងប្រទេសកម្ពុជាដើម្បីក្តាប់សភាពការណ៍ឲ្យជាប់ទាក់ទងនឹងកន្លែងដែលអ្នកដឹកនាំធំៗស្នាក់នៅ កន្លែងកងទ័ព ចំនួនកងទ័ព និងកន្លែងទុកអាវុធ-គ្រាប់រំសេវ ។ ជាពិសេស ត្រូវពិនិត្យមើលកន្លែងណាដែលអាចចូលបាននិងកន្លែងណាដែលមានឬមិនមានទ័ពបោះទីតាំង ។ នៅពេលក្តាប់សភាពការណ៍បានហើយ ស្រី ណាំ ត្រូវទៅទាក់ទងជាមួយនឹង អោក យ៉ាន់ នៅកំបូល (ខាងលិចពោធិ៍ចិនតុង) ដើម្បីឲ្យ អោក យ៉ាន់ ជូនទៅជួប សុក ស៊ីម នៅថ្នល់ទទឹង ។ បន្ទាប់មកទើបឲ្យ សុក ស៊ីម ជូនទៅជួប សួន នៅត្រពាំងក្រឡឹង ហើយឲ្យ សុក ស៊ីម ជូនបន្តទៅជួប មូល ខេង ពាក់ផ្កាយពីរនៅទល់ដែនសៀម ខេត្តបាត់ដំបង ឬមួយជូនទៅជួប ស្រី ឌឿន និង សោម សារី ផ្ទាល់នៅទល់ដែនសៀម ខេត្តកោះកុង ។ នៅថ្ងៃទី២៧ ខែមីនា ១៩៧៦ ស្រី ណាំ បានធ្វើដំណើរមកដល់ប្រទេសបារាំងដើម្បីទទួលផែនការស្តីពីបញ្ហាវាយចូលប្រទេសកម្ពុជាពី សោម សារី ។ ក្នុងផែនការនេះ បានកំណត់នូវមុខសញ្ញាពីរដែលត្រូវវាយចូលភ្នំពេញ មុខសញ្ញាទី១ ត្រូវវាយចូលចេញពីព្រំដែនខ្មែរ-សៀម កាត់តាមអូរជ្រៅ គឺត្រូវវាយយកខេត្តបាត់ដំបងមុនដើម្បីធ្វើជា

មូលដ្ឋានបង្អែកបន្តមកទៀត វាយចេញពីខេត្តពោធិ៍សាត់ ចូលមកចាប់ដៃគ្នានៅភ្នំពេញ ។ ចំពោះអ្នកដែលទទួលខុសត្រូវមុខសញ្ញាទី១ រួមមានៈ អ៊ិន តាំ, មូល ខ្វេង, ប៉ុក សំអាន, ស បួន, ប៉ុក សំអ៊ឹម និង សក់ ស៊ុតសាខន ។ ចំណែកមុខសញ្ញាទី២ គឺវាយចេញពីខេត្តកោះកុងមុនគេ រួចហើយបន្តវាយយកក្រុងកំពង់សោមមកធ្វើជាមូលដ្ឋានបង្អែកដើម្បីដាក់ទ័ពការពារវាលរេញ ។ បន្ទាប់មកវាយបន្តចូលក្នុងខេត្តកំពត និងកំពង់ស្ពឺ ហើយចុងក្រោយទៅចាប់ដៃគ្នានៅទីក្រុងភ្នំពេញ ។ អ្នកដែលទទួលខុសត្រូវមុខសញ្ញាទី២រួមមានៈ សោម សារី, ស្រី ឌឿន, ច័ន្ទ គ្រីស្នា, តាន់ កៅ, សោម គៀន និង សឹម ធាល ។ ចំណែកកងទ័ព សម្ភារៈ និងសព្វាវុធ សម្រាប់ការវាយប្រហារនេះមានការជ្រោមជ្រែងពីសហរដ្ឋអាមេរិក ប៉ុន្តែអាមេរិកពុំចេញមុខនោះទេ ។ ទន្ទឹមនឹងនេះ ការវាយរំដោះនេះក៏មានការគាំទ្រខាងសម្ភារៈពីប្រទេសកូរ៉េខាងត្បូង សៀម ជប៉ុន និងបារាំងផងដែរ ។ ផែនការវាយប្រហារនេះមានចំនួនពីរលើកគឺ ពីខែឧសភា ឆ្នាំ១៩៧៦ ដល់ខែធ្នូ ឆ្នាំ១៩៧៦ បើវាយមិនឈ្នះ ត្រូវផ្អាកសិន រួចហើយវាយចូលម្តងទៀត គឺពីខែមករា ឆ្នាំ១៩៧៧ ដល់ខែមិថុនា ឆ្នាំ១៩៧៧ ។ ការវាយលុកចូលត្រូវធ្វើជារៀងរាល់ឆ្នាំនៅរដូវប្រាំង រហូតដល់ឆ្នាំ១៩៨០ ទើបឈប់ ។

នៅអំឡុងពេលនោះ មនុស្សដែល ស្រី ណាំ អាចទាក់ទងបានមានដូចជា សាំង សន អតីតទាហានពាក់ស័ក្តិ១នៅខេត្តកំពត តាំង សេ.អ៊ី.អា នៅខេត្តកំពត ឃុន សេ.អ៊ី.អា នៅខេត្តកំពត ព្រុំ ឌឿន ពាក់ស័ក្តិ២ផ្នែកម៉ារីន ខុម ប៉ាង ពាក់ដោយសែបម៉ារីន និង សំគៀត ពាក់ដោយ សែបម៉ារីន ។

## សកម្មភាពនៅភ្នំពេញ

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៦ ស្រី ណាំ បានធ្វើដំណើរមកដល់ទីក្រុងភ្នំពេញវិញ ។ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៦ ស្រី ណាំ បានសរសេរសំបុត្រពីរច្បាប់ផ្ញើតាមរទេះភ្លើង ដោយមួយច្បាប់ផ្ញើទៅសួរសុខទុក្ខប្រពន្ធនៅវាលរេញ ។ ចំណែកសំបុត្រមួយច្បាប់ទៀតផ្ញើទៅឲ្យ សាំង សន (ពាក់ស័ក្តិ១) តាំង (សេ.អ៊ី.អា) និង ឃុន (សេ.អ៊ី.អា) ដោយក្នុងសំបុត្រនោះ ស្រី ណាំ សរសេរសួរសុខទុក្ខផង និងសួរនាំពីស្ថានការណ៍នៅក្នុងមូលដ្ឋានដែលអ្នកទាំងអស់គ្នារស់នៅផង ។ ប្រសិនបើមានបញ្ហាអ្វីកើតឡើង សូមឲ្យទាំងបីនេះជួយផ្តល់ដំណឹង ហើយ ស្រី ណាំ បានប្រាប់ខ្លួនគេរស់នៅ វិទ្យាល័យរុស្ស៊ី ។

រហូតមកដល់ខែមិថុនា ឆ្នាំ១៩៧៦ ស្រី ណាំ ត្រូវបានបញ្ជូនមកមន្ទីរក-១៥វិញ ។ នៅពេលនោះ ស្រី ណាំ បានបបួលបក្ខពួកបានចំនួន៧នាក់ រួមមាន ស៊ិត ទ្រី និង លៀង សុទ្ធតែជានិស្សិតមកពីបារាំង គឹម យា (ពាក់សក្តិ២) គួយ (ទាហាន) និង អ៊ុង ជុយ (ពាក់ស័ក្តិ៤) ដើម្បីរត់ភៀសខ្លួនទៅប្រទេសសៀម ។ ប៉ុន្តែ នៅពេលនោះ ស្រី ណាំ ត្រូវបានចាប់ខ្លួនម្តងទៀត រួចបញ្ជូនមកឃុំខ្លួននៅមន្ទីរស-២១ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៦ ។

ចម្លើយសារភាពរបស់ ស្រី ណាំ ចាប់ផ្តើមសរសេរពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៦ រហូតដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៧៦ ទើបបានរៀបចំវាយអត្ថលីលេខចប់សព្វគ្រប់ ដោយមាន ឃុន ហេង ជាអ្នកសួរ ពិនិត្យ និងកត់ត្រា ។ បន្ទាប់ពីសួរចម្លើយចប់ ស្រី ណាំ ត្រូវបានយកទៅកម្ទេចនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ (ដូចដែលមានបញ្ជាក់នៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានកម្ទេចនៅមន្ទីរស-២១ ពីឆ្នាំ១៩៧៦-១៩៧៨ ជាភ័ស្តុតាំស្រាប់) ។

**គ្រី ស៊ុយហៀង**

# ដំណឹងស្វែងរកឪពុក

ខ្ញុំបាទឈ្មោះ លាក ចាន់ការម្យ អាយុ៣៩ឆ្នាំ រស់នៅភូមិអ្នកលឿង ឃុំអ្នកលឿង ស្រុកពាមរ៍ ខេត្តព្រៃវែង ។ ខ្ញុំបាទសូមប្រកាសស្វែងរកឪពុកឈ្មោះ ម៉ុច ចាន់ណារី ហៅ លាក មានស្រុកកំណើតនៅភូមិបឹងព្រះ ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង ដែលបានបាត់ខ្លួនពីស្រុកពាមជរ ឃុំកោះរកា នៅខែមេសា ឆ្នាំ១៩៧៧ ដោយសារអង្គការបញ្ជូនឲ្យទៅយកអង្ករ ។ ចាប់តាំងពីពេលនោះមកគាត់បាត់ខ្លួនរហូត ។

ដូច្នេះប្រសិនបើអ្នកណាបានដឹង ឬឮឈ្មោះខាងលើនេះ សូមទំនាក់ទំនងមកខ្ញុំបាទតាមអាសយដ្ឋានខាងលើ ឬទូរស័ព្ទលេខ ០១៥ ៦៧៣ ០០០ ឬ ០៩៧ ៨៧៧ ៧០០៦ ។

*សូមអរគុណ!*

# អ្នកធ្វើការក្នុងរាជវាំងសម័យខ្មែរក្រហម

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើង ការបំពាក់បំប៉នឲ្យស្រឡាញ់បដិវត្តន៍និងការអប់រំអំពីគោលនយោបាយខ្មែរក្រហមងាយនឹងជះឥទ្ធិពលដល់ក្មេងៗឲ្យឆាប់ជឿ និងទុកចិត្តលើបដិវត្តន៍របស់អង្គការថានឹងដឹកនាំប្រទេសទៅរកភាពរុងរឿង មហាលោតផ្លោះ មហាអស្ចារ្យណាស់ ។ ជាក់ស្តែងណាស់ វ៉ន ហៅ រិទ្ធ ដែលសព្វថ្ងៃរស់នៅក្នុងឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលនៅក្នុងរបបនោះទើបតែមានអាយុ១៨ឆ្នាំ បានចាកចេញពីផ្ទះទៅចូលបម្រើបដិវត្តន៍ភ្លាម ក្រោយពីឮការឃោសនារបស់អង្គការបដិវត្តរួចមក ។

តាំងពីកុមារភាពដល់ធំដឹងក្តីមក វ៉ន មិនដែលបានចូលសាលាដូចជាក្មេងដទៃទេ ពីព្រោះបន្ទាប់ពីឪពុកម្តាយស្លាប់ចោលអស់ទៅ វ៉ន ត្រូវរស់នៅក្រោមការជួយផ្គត់ផ្គង់ពីបងៗរបស់ខ្លួន ។ ក្រោយពីកងទ័ពទទួលបានជ័យជម្នះនៅឆ្នាំ១៩៧៥ ថ្ងៃមួយ វ៉ន និងសមាជិកដែលធ្វើការនៅក្នុងកងចល័តទាំងអស់ត្រូវបានប្រធានកងប្រាប់ថាឲ្យខិតខំធ្វើការឲ្យបានល្អ ព្រោះអង្គការថ្នាក់លើនឹងចុះមកទស្សនកិច្ចកន្លែងរបស់យើង ។ ពេលនោះ វ៉ន រួមទាំងមិត្តនារីទាំងអស់សប្បាយចិត្តជាខ្លាំង ពីព្រោះចាប់តាំងពីធ្វើការមកមិនដែលបានស្គាល់ថាអង្គការថ្នាក់លើជានរណានោះទេ ។ វ៉ន បានរៀបរាប់ថា នៅថ្ងៃនោះប្រហែលជាម៉ោង៩ព្រឹក គាត់ឃើញមានរថយន្តតូចមួយគ្រឿងបើកចូលមក ដែលក្នុងរថយន្តនោះមានអង្គការថ្នាក់លើម្នាក់ និងកងការពារពីរនាក់មានស្ពាយកាំភ្លើងអង្គុយជាមួយគាត់ ។ ពេលចុះពីលើរថយន្ត ប្រធានកងចល័តនារីបានប្រាប់ថា «នេះជា តាម៉ុក ប្រធានភូមិភាគនិរតី ។ គាត់ចុះមកទស្សនកិច្ចនេះ ដើម្បីមកជ្រើសរើសប្រវត្តិរូបកូនកសិករក្រីក្រមួយចំនួនយកទៅបម្រើអង្គការ ។ អ្នកដែលអង្គការត្រូវការគឺយកទៅធ្វើការនៅភ្នំពេញ» ។ កាលណោះសមាជិកកងចល័តទាំងអស់ភ័យផងអរផង ពីព្រោះមិនដឹងថា តាម៉ុក ជ្រើសរើសចំឈ្មោះអ្នកណាខ្លះ ។ ពេល វ៉ន ឮគេហៅឈ្មោះ គាត់ត្រេកអរជាខ្លាំង ព្រោះគិតក្នុងចិត្តថា នឹងបានទៅស្គាល់ទីក្រុងភ្នំពេញជាមិនខាន ។

ស្អែកឡើង វេលាម៉ោង៨ព្រឹក រថយន្តមួយគ្រឿងបានមកដឹកអ្នកដែលមានឈ្មោះទាំងអស់ទៅធ្វើការនៅភ្នំពេញ ។ ធ្វើដំណើរអស់រយៈពេលជាច្រើនម៉ោង នៅវេលាម៉ោង១១ថ្ងៃត្រង់ រថយន្តក៏មកដល់ខេត្តតាកែវ ដែលនៅទីនោះ វ៉ន បានឃើញមនុស្សមកពីខេត្តផ្សេងៗជាច្រើននាក់ទៀត ។ ស្នាក់នៅខេត្តតាកែវមួយយប់ ព្រឹកឡើងរថយន្តបានបន្តដំណើរកាត់តាមស្រុកបាទី ក្រុងតាខ្មៅ ក្បាលថ្នល់រហូតមកដល់មុខវាំង រួចបន្តដំណើរដោយជិះកាណូតមកឈប់នៅអរិយក្សត្រ ស្រុកល្វាឯម ។

ក្រោយពីដាំបន្លែអស់រយៈពេលមួយឆ្នាំ នៅពាក់កណ្តាលឆ្នាំ១៩៧៦ ស្រាប់តែប្រធានអង្គភាពប្រាប់ថាអង្គការត្រូវការជ្រើសរើសប្រវត្តិរូបជាថ្មីម្តងទៀត ដោយយកតែស្រីក្មេងៗដែលអាយុប្រហែលជា១៥ទៅ១៧ឆ្នាំប៉ុណ្ណោះ ឲ្យទៅបម្រើការនៅក្នុងព្រះរាជវាំង ដែលក្នុងនោះក៏មានឈ្មោះរបស់ វ៉ន ដែរ ។ ដំបូង វ៉ន ត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកដាំផ្កា និងថែទាំផ្កា ។ ប៉ុន្តែនៅធ្វើការបានតែមួយរយៈ វ៉ន ត្រូវបានផ្លាស់មុខងារទៅជាអ្នកលើកម្ហូបអាហារជូនសម្តេច សីហនុ វិញ ដែលម្ហូបអាហារទាំងនោះមានបាយ និងសម្ធម្មតាដូចជាអ្នកធ្វើការក្នុងព្រះរាជវាំងដែរ ដោយក្នុងមួយថ្ងៃសម្តេចទទួលបានតែពីរពេលប៉ុណ្ណោះ គឺពេលថ្ងៃត្រង់ និងពេលល្ងាច ។ ដោយសារតែពេលនោះ វ៉ន មិនដែលបានឃើញសម្តេច សីហនុ ពីមុនមក ដូច្នេះនៅពេលយកម្ហូបអាហារទៅម្តងៗ វ៉ន មិនដែលបាននិយាយភាសាស្តេចឡើយ ដោយប្រើតែពាក្យថា «ហូប» ដូចធ្លាប់ប្រើជាមួយមិត្តរួមការងារទូទៅដែរ ។ ប៉ុន្តែ វ៉ន មិនដែលត្រូវបានសម្តេច ស្តីបន្ទោសអ្វីឡើយចំពោះពាក្យសម្តីសាមញ្ញទាំងនេះទេ ។ មួយរយៈក្រោយមានមកអ្នកយាមខ្សឹបប្រាប់ថា ជាសម្តេច សីហនុ ស្រាប់តែ វ៉ន មានការភ័យខ្លាចជាខ្លាំង ដោយសារកន្លងមកខ្លួនមិនបានប្រើពាក្យត្រឹមត្រូវតាមភាសាស្តេចទេ ។ ចាប់ពីពេលនោះមក វ៉ន បានរៀបចំខ្លួនឲ្យមានរបៀប ហើយបានប្រើពាក្យជាភាសាស្តេចខ្លះៗដែលខ្លួនចេះដឹងខ្លះៗ ។ វ៉ន នៅ

ចាំបានថា ពេលគាត់យកអាហារទៅដល់ម្តងៗ គាត់តែងតែឃើញសម្តេចមិនសូវមានព្រះទ័យសប្បាយរីករាយទេ ដោយគាត់មើលទៅហាក់បីដូចជាកំពុងតែគិតអ្វីមួយ ។ ប៉ុន្តែ វ៉ន មិនហ៊ានសួរ ព្រោះមានតួនាទីត្រឹមតែយកអាហារទៅថ្វាយព្រះអង្គប៉ុណ្ណោះ ។ ដោយសារតែ វ៉ន ជាមនុស្សស្មោះត្រង់ និងអាចទុកចិត្តបាន ថ្ងៃមួយសម្តេច សីហនុ ក៏មានបន្ទូល រឿងរ៉ាវមួយចំនួនប្រាប់គាត់ ។ «មុនមករស់នៅក្នុងព្រះបរមរាជវាំងនេះ អង្គការបានឃុំឃាំងព្រះអង្គចំនួនពីរខែនៅសាលមហោស្រពចតុមុខ» ។ សម្តេច សីហនុ មានបន្ទូលប្រាប់ វ៉ន ដោយសូរសៀងថ្មមៗថា «កូនកុំនៅទីនេះយូរពេកក្រែងមានគេឃើញ» ។ ព្រួដូច្នេះ វ៉ន មិនដែលហ៊ាននៅយូរទេ គាត់តែងតែប្រញាប់ចេញមកវិញភ្លាមនៅពេលចប់ភារកិច្ច ។ វ៉ន នៅចាំបានថា គាត់តែងតែឃើញមានមនុស្សពីរនាក់ផ្សេងទៀតនៅជិតសម្តេច សីហនុ ជានិច្ច ។

ដោយសារធ្វើការនៅនៅទីនេះយូរ វ៉ន និងមិត្តនារីផ្សេងទៀតដែលមានតួនាទីជាអ្នកទទួលភ្ញៀវដូចគ្នាបានលួចសួរកងការពារថា ភ្ញៀវមកពីប្រទេសណាខ្លះ នៅពេលដែលមានរថយន្តតូចចូលមកម្តងៗ? វ៉ន គ្រាន់តែដឹងថាភ្ញៀវទាំងនោះមកពីប្រទេសចិន ប៉ុន្តែមិនដឹងថាភ្ញៀវទាំងនោះមកជួបអ្នកណាទេ ។ វ៉ន នៅចាំបានថា នៅក្នុងព្រះរាជវាំងនេះក៏មានវត្តមានលោក ខៀវ សំផន ដែលមានតួនាទីជាប្រមុខរដ្ឋផងដែរ ដោយគាត់មានតួនាទីជាអ្នកមើលការខុសត្រូវម្ហូបអាហារ សម្រាប់សម្តេច សីហនុ ក្នុងពេលនោះ ។ ប៉ុន្តែ យូរម្តងទើបឃើញលោក ខៀវ សំផន បានទៅមើលដល់រោងបាយ ហើយប្រាប់ថា «មិនបាច់យកម្ហូបអាហារទៅច្រើនពេកទេ ព្រោះយកទៅច្រើននាំតែសល់» ។ ទោះបីជា វ៉ន ឃើញលោក ខៀវ សំផន ឧស្សាហ៍ចេញចូលព្រះរាជវាំងញឹកញាប់ ហើយស្នាក់នៅជាប់វាំងខាងកើតក៏ដោយ ប៉ុន្តែគាត់មិនដឹងថា ខៀវ សំផន មកមាន ការអ្វីដែរ ។ វ៉ន នៅនឹកឃើញរូបរាងរបស់ ខៀវ សំផន ថា ខ្ញុំមើលទៅគាត់មិនមែនជាមនុស្សកាចសាហាវទេ ។ លើសពីនេះទៅទៀត គាត់និយាយរកមិត្តនារីយើងជាធម្មតា មិនដែលប្រើពាក្យគំរោះគំរើយឡើយ ។ រយៈពេលជាងពីរឆ្នាំនៅក្នុងរាជវាំង វ៉ន មិនសូវជួបការលំបាកប៉ុន្មានទេ ហើយក៏មិនដឹងថាបងប្អូននៅតាមស្រុកស្រែរស់ នៅលំបាកវេទនាដោយសារតែខ្វះអាហារនិងការយកមនុស្សទៅសម្លាប់ដែរ ។

នៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៩ វ៉ន បានឃើញរថយន្តប្រហែលជា១០គ្រឿងអមទៅដោយកងយោធាខ្មែរក្រហមជាច្រើននាក់ចូលមកដល់ក្នុងព្រះរាជវាំង ។ ពេលនោះលោក ខៀវ សំផន បានហៅអ្នកធ្វើការក្នុងព្រះរាជវាំងទាំងអស់មកប្រជុំប្រាប់ថា ក្បួនរថយន្តចូលមកថ្ងៃនេះគឺថាសម្តេចត្រូវបានអញ្ជើញទៅប្រទេសចិន ចំណែកអ្នកធ្វើការទាំងអស់ក៏បានទៅដែរ ប៉ុន្តែត្រូវចាំបីបួនថ្ងៃទៀត ។ បីថ្ងៃក្រោយមក ស្រាប់តែមានរថយន្តមួយមកដឹកពួកយើងពិតប្រាកដមែន ប៉ុន្តែមិនបានបើកសំដៅទៅព្រលានយន្តហោះទេ បែរជាធ្វើដំណើរតាមផ្លូវជាតិលេខ៥ កាត់តាមខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង មកទម្លាក់នៅស្រុកបវេលទៅវិញ ព្រោះរថយន្តអស់សាំង ។ នៅទីនេះ មានមនុស្សធ្វើដំណើរច្រើនណាស់ គឺមានប្រជាជនមកពីគ្រប់កន្លែង ទាំងក្មេងទាំងចាស់ ខ្លះទៀតឃើញដេកស្លាប់តាមផ្លូវដោយសារគ្មានអាហារបរិភោគ ។

នៅឆ្នាំ១៩៧៩ ប្រហែលជាខែសីហា វ៉ន បានសម្រេចចិត្តវិលត្រឡប់មកស្រុកកំណើតវិញ ព្រោះគិតថាបើនៅតស៊ូក្នុងព្រៃប្រាកដជាស្លាប់ក្នុងថ្ងៃណាមួយមិនខាន ម្យ៉ាងទៀតឃើញតែមនុស្សកើតជំងឺគ្រុនចាញ់គ្រប់គ្នា ។ នៅឆ្នាំ១៩៧៩-១៩៨០ វ៉ន ទើបតែបានដឹងច្បាស់ថាថារបបខ្មែរក្រហមនេះបានសម្លាប់មនុស្សអស់ប្រហែលជិតពីរលាននាក់ ដោយសារការសម្លាប់ ការបង្អត់អាហារ ការធ្វើការហួសកម្លាំង និងការធ្វើទារុណកម្ម ក្រោយពីឃើញមានភស្តុតាងជាច្រើនដែលបានបន្សល់ទុកនៅមន្ទីរឃុំឃាំងផ្សេងៗដូចជាឆ្អឹងគជាគំនរតាមបណ្តាខេត្តមួយចំនួន ។

សព្វថ្ងៃនេះ ស្ថានភាពរស់នៅ វ៉ន ជួបការលំបាកជាខ្លាំង ព្រោះរស់នៅក្នុងផ្ទះខ្ទមតូចមួយសង់ផ្ទាល់ដី ដំបូលប្រក់ស្លឹកត្នោត និងជញ្ជាំងស្លឹកមានទទឹងប្រហែលជាបួនម៉ែត្របួនជ្រុងនៅក្នុងផ្ទះមានគ្រែឫស្សីចាស់មួយសម្រាប់សម្រាកពេលយប់ ហើយថែមទាំងត្រូវខិតខំរកលុយដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារទៀតដែលមានប្តីជាជនពិការជើងម្ខាងនិងកូនចំនួន៧នាក់ ។ ជាចុងក្រោយនេះ វ៉ន បានរំពឹងថាមិនដឹងពេលណាមានវាសនាបានជួបសម្តេចម្តងទៀតទេ និងថាតើសម្តេចនៅចាំមុខគាត់ដែលឬអត់ ។ «ខ្ញុំសូមជូនពរព្រះអង្គឲ្យមានសុខភាពល្អ កម្លាំងមាំមួន អាយុយឺនយូរ គ្រាន់ជាម្លប់សម្រាប់កូនចៅតរៀងទៅ» ។ **សុខ ខណ្ណៈ**

# ការដាក់ពិរុទ្ធភាពលើខ្លួនឯង និងការពិត

នៅអង្គសវនាការពោរពេញទៅដោយប្រតិកម្មយ៉ាងខ្លាំង ខណៈពេលដែល គក ស្រស់ អតីតសន្តិសុខយាមមន្ទីរស-២១ បាននិយាយថាខ្លួនបានដឹងតិចតួចណាស់ទាក់ទិននឹងបទពិសោធន៍របស់ខ្លួនក្នុងនាមជាសន្តិសុខយាមគុក ។ អ្នកតាមដាននៅក្នុងអង្គសវនាការមានអារម្មណ៍មិនពេញចិត្តនៅពេលដែលសាក្សីបដិសេធមិនបង្ហាញពីការដឹងឮរបស់ខ្លួនចំពោះព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ ។ ស្ត្រីម្នាក់ដែលចូលរួមស្តាប់អង្គសវនាការកាលពីព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ហើយសូមមិនឲ្យបញ្ចេញឈ្មោះ បាននិយាយថា «ខ្ញុំដឹងថាសាក្សីរូបនេះនឹងនិយាយថា «ខ្ញុំមិនចាំទេ» ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះគឺថា គក ស្រស់ បានអះអាងថាគាត់មិនបានដឹងថាអ្នកទោសត្រូវបានបញ្ជូនទៅសម្លាប់ទេ» ។

ថ្ងៃនេះ សាក្សីត្រូវបានតម្រូវឲ្យរៀបរាប់ពីបទពិសោធន៍របស់ខ្លួនកាលពីសាមសិបឆ្នាំមុនដល់ចៅក្រមជាតិ អន្តរជាតិ និង សហព្រះរាជអាជ្ញា ។ សាក្សីបានចូលទៅអង្គុយនៅកន្លែងសម្រាប់សាក្សីខាងស្តាំដៃជនជាប់ចោទដែលសាក្សីមិនធ្លាប់បានឃើញអស់រយៈពេលជាងសាមសិបឆ្នាំកន្លងមកហើយ ។ ចំណែកនៅខាងក្រោយសាក្សីគឺជាជនរស់រានមានជីវិតពីរបបខ្មែរក្រហម និងកូនចៅរបស់គេ ។

សម្រាប់វេទិកាសាក្សីនៅថ្ងៃនេះ អ្វីដែល គក ស្រស់ បានចងចាំច្បាស់បំផុតគឺម៉ោងយាមនៅក្នុង និងក្រៅមន្ទីរស-២១ដែល



គក ស្រស់ ផ្តល់សក្ខីកម្មនៅអង្គសវនាការ

គាត់តែងតែដើរត្រួតពិនិត្យនៅក្នុងនិងជុំវិញបរិវេណគុកជារៀងរាល់ខែ ។ ខណៈពេលដែលសហព្រះរាជអាជ្ញាបានបង្ហាញសំណង់អគារនៃមន្ទីរស-២១ដែលថតពីលើ គក ស្រស់ បានចង្អុលបង្ហាញនៅលើកញ្ចក់កុំព្យូទ័រពីអគារដែលគាត់បានដើរត្រួតពិនិត្យមើលជាញឹកញាប់ ។ វាគឺជាអគារ ស៊ី ដែលស្ថិតនៅក្នុងចំណោមអគារទាំងប្រាំនៃអតីតវិទ្យាល័យមួយដែលត្រូវបានគេប្រែក្លាយទៅជាគុកដ៏ធំជាងគេបង្អស់ក្នុងឆ្នាំ១៩៧៦ ។

យ៉ាងណាមិញ គក ស្រស់ មិនបានចាំនូវព្រឹត្តិការណ៍សំខាន់ៗដែលជនរស់រានមានជីវិតបានដឹងតាំងពីយូរហើយនោះទេ ។ ជនរស់រានមានជីវិតគ្រប់រូបទាំងអស់ចង់ដឹងពីរបៀបដែលមន្ទីរស-២១ដំណើរការក្រោមការគ្រប់គ្រងរបស់ ឌុច ក្នុងរបបខ្មែរក្រហមយ៉ាងខ្លាំង ។ គក ស្រស់ បានសង្ឃឹមថាគាត់នឹងរៀបរាប់ជូនអង្គសវនាការពីព័ត៌មានផ្សេងៗឲ្យកាន់តែច្រើនតាមតែអាចធ្វើទៅបាន ពីព្រោះថា គក ស្រស់ គឺជាសាក្សីដ៏សំខាន់ដែលបានចំណាយពេលប្រហែលបួនឆ្នាំដើម្បីបម្រើបដិវត្តន៍ ។ ហើយប្រធានបទដែលត្រូវធ្វើការស៊ើបអង្កេតនៅថ្ងៃនេះគឺដំណើរការនៅមន្ទីរ-២១ ។ ដោយមិនអាចចាំបន្តទៀតបាន ចៅក្រម ឡាវ៉ើញ បានបើកសំឡេងមីក្រូ ហើយសួរ គក ស្រស់ នូវសំណួរមួយចំនួនអំពីជីវិតប្រចាំថ្ងៃនៅមន្ទីរស-២១ ក្នុងការបំពេញភារកិច្ចជាសន្តិសុខយាមគុក ។ គក ស្រស់ បានឆ្លើយថាការងារប្រចាំថ្ងៃរបស់គាត់មានសភាពធម្មតា ។ មិនត្រឹមតែអ្នកតាមដាននៅក្នុងអង្គសវនា ការប៉ុណ្ណោះទេដែលចង់ដឹងពីអត្ថន័យនៃពាក្យការងារ «ធម្មតា» សូម្បីតែ ចៅក្រម ឡាវ៉ើញ ក៏ចង់ដឹងពីនិយមន័យនៃពាក្យនេះដែរ ដោយហេតុនេះ ចៅក្រម ឡាវ៉ើញ បានឲ្យ គក ស្រស់ បញ្ជាក់ឲ្យច្បាស់ថាតើពាក្យ «ធម្មតា» នោះមានន័យដូចម្តេច? គក ស្រស់ មិនអាចរៀបរាប់ពីការងារដាក់លាក់ដែលគាត់បានបំពេញក្រៅពីភារកិច្ចយាមខាងក្នុងនិងខាងក្រៅអគារ ស៊ី ឡើយ ។ ដោយសារតែ គក ស្រស់ មិនអាចផ្តល់នូវចម្លើយដ៏ច្បាស់លាស់ ចៅក្រម ឡាវ៉ើញ បានបន្តសួរទៅកាន់ គក ស្រស់ ថា គាត់ ចង់ធ្វើការងារ «ធម្មតា» នៅទីនោះម្តងទៀតដែរឬទេ ប្រសិនបើគាត់ត្រូវបានផ្តល់ឱកាសឲ្យធ្វើការងារ

*នោះម្តងទៀត ។ គក ស្រស់ បានឆ្លើយយ៉ាងលឿនថា «ទេ! ខ្ញុំនឹងមិនធ្វើការងារនោះម្តងទៀតទេ» ។*

## បញ្ហាច្បាប់

*មុននឹងផ្តល់សក្ខីកម្ម លោកប្រធានចៅក្រមបានប្រាប់សាក្សីពីសិទ្ធិតាមផ្លូវច្បាប់របស់ខ្លួន ដែលថាសាក្សីអាចមានសិទ្ធិមិនឆ្លើយនឹងសំណួរណាដែលសាក្សីគិតថាអាចមានផលប៉ះពាល់លើខ្លួនឬប្រសិនបើ សាក្សីមិនដឹងពីចម្លើយពិតប្រាកដឬមិនបាច់ឆ្លើយក៏បាន ។ បន្ទាប់មក លោកប្រធានចៅក្រមក៏បានប្រាប់សាក្សីឲ្យចៀសវាងឆ្លើយនឹងសំណួរណាដែលអាចដាក់ពិរុទ្ធភាពលើខ្លួនឯង ។ តាមទស្សនៈខ្ញុំផ្ទាល់ ខ្ញុំគិតថាទោះបីជាលក្ខខណ្ឌ «ការដាក់ពិរុទ្ធភាពលើខ្លួនឯង» គឺជាលក្ខខណ្ឌច្បាប់ដ៏ត្រឹមត្រូវក៏ដោយ ក៏លក្ខខណ្ឌនេះអាចធ្វើឲ្យសាក្សីមិននិយាយការពិតទាក់ទិននឹងឧក្រិដ្ឋកម្មកម្រិតធ្ងន់ដែលសាក្សីបានឃើញផ្ទាល់ភ្នែកដែរ ។ បន្ថែមលើនេះ លក្ខខណ្ឌ «ដាក់ពិរុទ្ធភាពលើខ្លួនឯង» អាចរារាំងនិងឃាត់សាក្សីមិនឲ្យនិយាយពីបទពិសោធន៍របស់ខ្លួនថែមទៀត ។ ដូច្នេះសាក្សីបានជ្រើសរើសមិនផ្តល់ចម្លើយពីព្រោះសាក្សីមានការព្រួយបារម្ភថាខ្លួនគេអាចនឹងជាប់ទោសប្រសិនបើខ្លួនរៀបរាប់រឿងរ៉ាវច្រើនដល់តុលាការ ។*

## ប្រវត្តិសាស្ត្រត្រូវបានកប់ចោល

*យើងមិនដឹងថាតើ គក ស្រស់ បានចងចាំ ឬថាគាត់មិនចង់ឆ្លើយមែនដែរឬយ៉ាងណាទេ ។ ដោយសារតែ គក ស្រស់ ភាគច្រើនមិនបានឆ្លើយនឹងសំណួរ ចៅក្រម ខាតវ៉ៃយត៍ ចាប់ផ្តើមសួរសំណួរដោយផ្អែកលើបទសម្ភាសន៍ដែលអ្នកនិពន្ធលោក ដេវីដ ឆេនល័រ បានសរសេរក្នុងសៀវភៅរបស់គាត់ដែលមានឈ្មោះថា «សំឡេងពីមន្ទីរស-២១ៈ ភាពភ័យរន្ធត់ និងប្រវត្តិសាស្ត្រក្នុងគុកសម្ងាត់នៃរបប ប៉ុល ពត» ។ គោលបំណងរបស់ចៅក្រម ខាតវ៉ៃយត៍ ដើម្បីផ្ទៀងផ្ទាត់ចម្លើយរបស់ គក ស្រស់ ដែលឆ្លើយទៅកាន់សំណួររបស់ចៅក្រមនិងសហព្រះរាជអាជ្ញាក្នុងសាលសវនាការ ។ លើសពីនេះទៀត គក ស្រស់ បានបដិសេធចម្លើយមួយភាគធំដែលអ្នកនិពន្ធ ដេវីដ ឆេនល័រ បានសរសេរពីរឿងរ៉ាវដែលគាត់បានរៀបរាប់នៅក្នុងបទសម្ភាសន៍របស់ខ្លួន ជាមួយនឹង លោក ដេវីដ ឆេនដល័រ កាលពីដប់ឆ្នាំមុន ។ ការបដិសេធរបស់ គក ស្រស់ បណ្តាលឲ្យមានភាពច្របូកច្របល់ថាតើ គក ស្រស់ ពិតជាមិនបានចាំពីរឿងរ៉ាវដែលខ្លួនបានប្រាប់លោក ដេវីដ ឆេនល័រ មែនឬមួយក៏ គក ស្រស់ មិនចង់និយាយនៅក្នុងសាលសវនាការឬក៏លោក ដេវីដ ឆេនល័រ សរសេរនូវអ្វីដែលមិនត្រឹមត្រូវ? ក្នុងនាមជាអ្នកស្រាវជ្រាវម្នាក់ លោក ដេវីដ ឆេនល័រ មានទំនួលខុសត្រូវផ្នែកគុណធម៌ក្នុងការសរសេរព័ត៌មានពិតដែលគាត់បានដកស្រង់ចេញពីបទសម្ភាសន៍នោះ ។ ជាមួយគ្នានេះ គក ស្រស់ បាននិយាយ ថាគាត់មិនអាចចាំបានថាគាត់បានប្រាប់អ្វីខ្លះដល់លោក ដេវីដ ឆេនល័រ កាលពីដប់ឆ្នាំកន្លងទៅនោះទេ ពីព្រោះថា «វាបានកន្លងមកអស់រយៈពេលយូរមកហើយ» ។*

## ការចងចាំ

*គក ស្រស់ បានអះអាងថាគាត់បានរងទុក្ខវេទនា និងមានភាពភ័យខ្លាចថាគាត់នឹងត្រូវជាប់ឃុំឃាំងដូចសន្តិសុខយាមគុកនៅមន្ទីរស-២១ដទៃទៀតដែរ ទោះបីជាគាត់ខិតខំព្យាយាមបំពេញភារកិច្ច មិនឲ្យមានកំហុសអ្វីក៏ដោយ ។ គក ស្រស់ បាននិយាយថា គាត់ចង់រត់គេចខ្លួន ប៉ុន្តែមិនដឹងថាត្រូវរត់ទៅកន្លែងណា ។ ដូច្នេះទុក្ខវេទនាដែលគាត់ធ្លាប់ឆ្លងកាត់អាចនាំឲ្យ គក ស្រស់ មិនចងចាំនូវបទពិសោធន៍ដែលគាត់បានទទួលទេ ។ ដោយសារតែ គក ស្រស់ មិនអាចចាំនូវព័ត៌មានជាច្រើន ចៅក្រម ឡាវើញ បានសួរ គក ស្រស់ ថា «តើអ្នកមានការលំបាកដើម្បីរំឭកនូវការចងចាំរបស់អ្នកមែនឬទេ? ។ គក ស្រស់ បានឆ្លើយតបនឹងសំណួរបន្ទាប់របស់ចៅក្រម ឡាវើញ ដោយនិយាយថា គាត់មិនភ័យខ្លាច ឬការគៀប-សង្កត់ពីនរណាម្នាក់ឡើយទាក់ទិននឹងការផ្តល់ចម្លើយពីនេះ ។ បន្ទាប់មក ចៅក្រមបានបន្តសួរថាតើ គក ស្រស់ នៅចាំទេថាគាត់បានស្បថនឹងនិយាយតែការពិតមុននឹងផ្តល់សក្ខីកម្មនេះ ។ គក ស្រស់ បានឆ្លើយថាគាត់ចាំ ។*

## ឌុច បានធ្វើការជំទាស់

*ជិតដល់ពេលបញ្ចប់ការផ្តល់សក្ខីកម្មរបស់ គក ស្រស់ នៅក្នុងសាលសវនាការ ឌុច បានក្រោកឈរឡើង ហើយនិយាយថា គក ស្រស់ អាចនឹងចាំពីបទពិសោធន៍របស់ខ្លួន ច្រើនជាងនេះ ប្រសិនបើ គក ស្រស់ ជាសន្តិសុខយាមមន្ទីរស-២១មែន ។ ឌុច បានជំទាស់នឹង គក ស្រស់ ដោយនិយាយថា គក ស្រស់ មិនមែនជាសន្តិសុខយាមមន្ទីរស-២១ពិតប្រាកដទេ ដោយហេតុផលថា គក ស្រស់ មិនអាចចងចាំព្រឹត្តិការណ៍ដែលគាត់មិនគួរភ្លេច ហើយគាត់*

ស្គាល់តែ ប៉េង ប៉ុណ្ណោះ ដែលមនុស្សទូទៅស្គាល់ជាសាធារណៈ ។ ជាមួយគ្នានេះ ឌុច ក៏បាននិយាយថា ខ្លួនមិនដែលស្គាល់ គក ស្រស់ សោះ តាំងពីគាត់ធ្វើការជាប្រធានមន្ទីរស-២១ ហើយ ឌុច មិនអាចទទួលស្គាល់ គក ស្រស់ ទេព្រោះគ្មានភ័ស្តុតាងអ្វីទាំងអស់ ។ ការជំទាស់របស់ ឌុច ឆ្លុះបញ្ចាំងឲ្យឃើញថា ឌុច ចង់ឲ្យ គក ស្រស់ រៀបរាប់នូវរឿងរ៉ាវដែល គក ស្រស់ បានឃើញ និងធ្លាប់ឆ្លងកាត់ និងប្រាប់តុលាការពីដំណើរប្រតិបត្តិការរបស់មន្ទីរស-២១ ។ អ្នកចូលរួមតាមដានអង្គសវនាការបានគាំទ្រការជំទាស់របស់ ឌុច ហើយក៏មានបំណងចង់ឲ្យ គក ស្រស់ បង្ហាញប្រាប់ពីដំណើរប្រតិបត្តិការរបស់មន្ទីរស-២១ តាមរយៈបទពិសោធន៍របស់ខ្លួនក្នុងនាមជាសន្តិសុខយាមមន្ទីរស-២១ ដើម្បីជួយឲ្យមានការបំភ្លឺប្រវត្តិសាស្ត្រក្នុងពេលនេះបន្ថែមទៀត ។ ជាអកុសល ដំណើរការតុលាការនៅពេលព្រឹកបានបញ្ចប់ទៅយ៉ាងខ្លី ហើយរឿងរ៉ាវប្រវត្តិសាស្ត្រអំពីមន្ទីរស-២១ តាមរយៈទស្សនៈរបស់ គក ស្រស់ ក្នុងពេលនេះត្រូវបានលាក់បាំងជារៀងរហូត ។ សាធារណជនអាចវិនិច្ឆ័យបានថាតើ គក ស្រស់ ពិតជាមិនបានចងចាំនូវអ្វីដែលខ្លួនបានធ្វើ ឬគាត់មានការព្រួយបារម្ភជាមួយនឹង«ការដាក់ពិរុទ្ធភាពលើខ្លួនឯងប្រយ៉ាងណា» ។

**ញាណ សុជាតិ**

# អះអាងថាមានជនបរទេសត្រូវបានដុតទាំងរស់នៅមន្ទីរស-២១

«ខ្ញុំជឿថាគ្មាននរណាហ៊ានល្មើសនឹងបញ្ជារបស់ខ្ញុំទេ» នេះជាសម្តីរបស់ ឌុច ដែលបានអះអាង ប្រាប់អង្គសវនាការបន្ទាប់ពីបានស្តាប់សក្ខីកម្មរបស់ ជៀម សឿ ជាអតីតអ្នកយាមនៅមន្ទីរស-២១ ដែលបានរៀបរាប់ប្រាប់អង្គសវនាការថា កងការពារបីនាក់បានយកអ្នកទោសជាជនបរទេសទៅដុតទាំងរស់នៅក្នុងមន្ទីរស-២១ ស្ថិតក្រោមការគ្រប់គ្រងរបស់គាត់នៅក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ។

ជៀម សឿ អាយុ៥២ឆ្នាំ មានមុខរបរធ្វើស្រែ និងឡើងត្នោត ។ នៅក្នុងអំឡុងឆ្នាំ១៩៧០-៧៥ ជៀម សឿ បានចូលធ្វើជាកងឈ្លបនៅខេត្តកំពង់ឆ្នាំង ដើម្បីប្រឆាំងជាមួយកងទ័ពលន់ នល់ ។ ក្រោយពីរំដោះបានភ្នំពេញនៅឆ្នាំ១៩៧៥ ជៀម សឿ ត្រូវបានឈ្មោះ ចាន់ ជ្រើសរើសឲ្យមកហ្វឹកហាត់យោធានៅព្រែកហូក្បែរតាខ្មៅ ។ ជៀម សឿ ត្រូវរៀនហាត់បាញ់កាំភ្លើង រាវមីន និងដោះគ្រាប់បែកក្នុងគោលបំណងទៅវាយជាមួយនឹងកងទ័ពវៀតណាម ។

បន្ទាប់ពីហ្វឹកហាត់ចប់ ជៀម សឿ ត្រូវបានជ្រើសរើសឲ្យមកធ្វើការនៅមន្ទីរស-២១ ដោយមានតួនាទីជាអ្នកយាមការពារនៅផ្នែកខាងក្រៅ (ខាងលិចមន្ទីរស-២១) ក្រោមការគ្រប់គ្រងរបស់ ប៉េង ជាប្រធានកងរយ ។ ជៀម សឿ ត្រូវយាមរយៈពេល១២ម៉ោងក្នុងមួយថ្ងៃ ដែលក្នុងមួយក្រុមមានគ្នា១២នាក់ យាមនៅបីជ្រុងជុំវិញបរិវេណគុកទួលស្លែងគឺខាងជើង ខាងលិច និងខាងត្បូង ។ ក្រៅពីការងារយាម ជៀម សឿ ត្រូវដាំបន្លែសម្រាប់អង្គភាពថែមទៀត ។

ពេលយាម ជៀម សឿ បានឃើញរថយន្តដឹកមនុស្សចូល ប៉ុន្តែមិនដឹងថារថយន្តនោះជារបស់មន្ទីរស-២១ ឬអង្គភាពខាងណាទេ ហើយក្នុងរយៈពេលបីទៅបួនថ្ងៃទើបឃើញរថយន្តដឹកមកម្តង ដោយពេលខ្លះដឹកចូលយប់ ពេលខ្លះដឹកចូលពេលថ្ងៃ ។

ក្រោយពីចៅក្រម យ៉ា សុខន បានសួរសំណួរមួយចំនួនអំពីការងាររបស់គាត់នៅក្នុងមន្ទីរស-២១ សំណួរជាច្រើនពីគ្រប់ភាគីក៏ចាប់ផ្តើមផ្តោតទៅលើការអះអាងរបស់ ជៀម សឿ ដែលបានប្រាប់អង្គសវនាការថា គាត់បានឃើញកងការពារចំនួនបីនាក់នៅមន្ទីរ



ជៀម សឿ ផ្តល់សក្ខីកម្មនៅអង្គសវនាការ

នេះបណ្តើរអ្នកទោសជនជាតិបរទេសម្នាក់ចូលមកក្នុងបរិវេណគុ ។ បន្ទាប់មក គាត់បានឃើញកងការពារ៣នាក់នោះបញ្ជាឲ្យអ្នកទោសអង្គុយចុះ រួចយកកង់ឡានប្រេកពីលើក្បាលអ្នកទោសរួចដុតទាំងរស់ ។ កន្លែងដុតស្ថិតនៅតាមបណ្តោយផ្លូវក្រាលកៅស៊ូពីស្តាតអូឡាំពិកមកផ្សារទួលទំពូង ដោយពេលនោះគាត់ស្ថិតនៅចម្ងាយប្រហែល ២០ម៉ែត្រពីអ្នកទោស ។

ដោយសារការរៀបរាប់របស់គាត់មានភាពមិនច្បាស់លាស់ ចៅក្រមក៏បានសួរសំណួរសាក្សី ជៀម សឿ អំពីពេលវេលាដែលគាត់យាមនៅពេលនោះ ។ ជៀម សឿ បាននិយាយថាគាត់យាមរយៈពេល១២ម៉ោងចាប់ពីម៉ោង៦ព្រឹកដល់ម៉ោង១២ថ្ងៃ ។ នៅពេលសួរថាតើ ប្រហែលម៉ោងប៉ុន្មានទើបឆេះកង់ឡានអស់ ជៀម សឿ បានប្រាប់ថា គាត់មិនច្បាស់នោះទេ ព្រោះគ្មាននាឡិកាសម្រាប់មើល ប៉ុន្តែពេលដែលយាមនោះ គាត់មិនទាន់ឃើញអ្នកទោសឆេះសុសនៅឡើយទេ ព្រោះត្រូវផ្លាស់វេនយាមជាមួយកងការពារផ្សេងទៀត ។ នៅពេលដល់វេនយាមរបស់គាត់នៅថ្ងៃបន្ទាប់ គាត់បានឃើញខ្លួន និងជើងរបស់អ្នកទោសឆេះឡើងខ្មៅដោយរោលនឹងផ្សែង ។ សាកសពរបស់ជនបរទេសនោះមិនត្រូវបានសែងយកចេញទៅទីណាទេ គឺទុកនៅទីនោះអស់រយៈពេលជាច្រើនថ្ងៃ ក្រោយមកទៀត ទើបយកទៅកប់ ។

ពេលដែលចៅក្រមផ្តល់ឱកាសទៅឲ្យ ឌុច ធ្វើកំណត់សម្គាល់ទៅលើសក្ខីកម្មរបស់ ជៀម សឿ ឌុច បានរៀបរាប់ថា គាត់ពិតជាបានចេញបញ្ជាឲ្យដុតខ្មោចពិតមែន ប៉ុន្តែមិនមែនទាំងរស់ទេ ព្រោះគាត់ជឿថាគ្មានអ្នកណាហ៊ានល្មើសនឹងបញ្ជារបស់គាត់ទេ ។ បន្ទាប់មក ឌុច បានធ្វើការប្រៀបធៀបជាមួយសក្ខីកម្មរបស់ ហ៊ឹម ហ៊ុយ ដែលបានអះអាងអំពីការដុតអ្នកទោសដែរ ដូច្នេះគាត់បានប្រាប់ចៅក្រមថា បើតាមការផ្តល់សក្ខីកម្មរបស់ ហ៊ឹម ហ៊ុយ គឺច្បាស់លាស់ច្រើនព្រោះជាអ្នកទទួលភារកិច្ចផ្ទាល់ ។ ម៉្យាងវិញទៀត នៅពេលដែលឮថា ជៀម សឿ ថាទើបតែស្គាល់ ហ៊ឹម ហ៊ុយ នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនេះប៉ុណ្ណោះ ដូច្នេះសក្ខីកម្មរបស់គាត់មិនសូវមានទម្ងន់ប៉ុន្មានទេ ។ ចុងក្រោយ ឌុច រៀបរាប់ថា បើដុតអ្នកទោសបរទេសមានតែពីរនាក់ មិនមែនម្នាក់ទេគឺពេលដែលគាត់បានរាយការណ៍ទៅ នួន ជា ថាជនជាតិបរទេសនៅយូរហើយ នៅពេលនោះ នួន ជា ប្រាប់ទៅគាត់វិញថា ឲ្យជនបរទេសទាំងនោះគួរយកចេញទៅហើយត្រូវដុតឲ្យម៉ត់កុំឲ្យសល់អ៊ីទាំងអស់ ។ ដូច្នេះទើបគាត់ហ៊ានបញ្ជាមកឲ្យហ៊ី ដុតអ្នកទោសបរទេសនោះ ។

**ផា ផល្លា និង សោម ប៊ុនថន**



រូបថតជនរងគ្រោះនៅមន្ទីរស-២១



# ដំណើរទស្សនកិច្ចទៅកាន់ប្រទេសស៊ុយអែដ ដើម្បីចូលរួមពិធីតាំងពិព័រណ៍

## “អាហារពេលល្ងាចជាមួយ ប៉ុល ពត”

ការតាំងពិពរណ៍នេះ ត្រូវបានរៀបចំឡើងដោយវេទិកាឯកសាររស់របស់ប្រទេសស៊ុយអែដ ដែលបានចាប់ផ្តើមឡើងនៅវេលាម៉ោង៤រសៀល ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ ។ ពិព័រណ៍នេះបានទាក់ទាញភ្ញៀវមកចូលរួមប្រមាណ២០០នាក់ ក្នុងនោះរួមមានសមាជិកអ្នកកាសែតស៊ុយអែដ មន្ត្រីរដ្ឋាភិបាលមកពីក្រសួងវប្បធម៌ មន្ត្រីមកពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែដ សាស្ត្រាចារ្យ និស្សិត និងសាធារណជន ។ ដោយមានការចូលរួមពីរដ្ឋមន្ត្រីក្រសួងវប្បធម៌របស់ប្រទេសស៊ុយអែដ ការបើកពិព័រណ៍នេះកាន់តែគួរឲ្យមានការចាប់អារម្មណ៍ដោយមានវត្តមានរបស់លោកស្រីរដ្ឋមន្ត្រី ។ នៅទីនេះគ្មានទោចក្រយានយន្តនិងផ្លូវហាមឃាត់ដូចដែលយើងបានឃើញនៅក្នុងប្រទេសកម្ពុជាឡើយ ។ ប្រសិនបើនរណាម្នាក់មិនធ្លាប់បានឃើញលោកស្រីពីមុនមកទេ វាពិបាកក្នុងការមើលឲ្យដឹងថា រដ្ឋមន្ត្រីដែលមានតួនាទីខ្ពស់បែបនេះស្ថិតនៅក្នុងចំណោមមហាជន ។ លោក ហ្គុនណា បឺយស្ត្រម បាននិយាយថាអស់រយៈពេលប៉ុន្មានឆ្នាំមកហើយដែលរដ្ឋមន្ត្រីមានតួនាទីខ្ពស់ៗបែបនេះ បានធ្វើការនៅក្នុងវិមានរដ្ឋាភិបាលរបស់ប្រទេសស៊ុយអែដ ដែលមានទីតាំងស្ថិតនៅភាគខាងជើងនៃទីក្រុងហ្គុមឡាស្តេន ហើយដើរទៅធ្វើការដោយគ្មានអង្គរក្សតាមការពារ ។ នេះជាចំណាប់អារម្មណ៍មួយដែលថាប្រទេសស៊ុយអែដគឺជារដ្ឋសង្គមនិយមមួយដែលពោរពេញទៅដោយសេវាសុខុមាលភាព ជាជាងអ្នកដទៃបានគិត ។

ជាការពិត ប្រទេសស៊ុយអែដមានកម្មវិធីសុខុមាលភាពសង្គមដ៏ល្អមួយដែលបម្រើដោយស្មើភាពសម្រាប់ប្រជាជនស៊ុយអែដ ។ នេះប្រហែលជាឧទាហរណ៍ដ៏ល្អមួយសម្រាប់ប្រទេសកម្ពុជាដែលបានទទួលរងគម្លាតសេដ្ឋកិច្ចសង្គមដ៏ធំមួយពីសំណាក់ប្រជាជន ។ អ្នកដឹកនាំខ្មែរក្រហមបានជឿជាក់ថា កម្លាំងជំរុញដែលស្ថិតនៅពីក្រោយបដិវត្តន៍របស់ខ្មែរក្រហម និងកិច្ចខិតខំប្រឹងប្រែងរបស់អ្នកបដិវត្តន៍ខ្មែរក្រហមមួយចំនួន គឺជាគម្លាតដ៏ធំមួយរវាងអ្នកមាននិងអ្នកក្រ អ្នកមានអំណាចនិងកសិករ រាជវង្សនិងប្រជាជនសាមញ្ញ ព្រមទាំងរវាងទីប្រជុំជននិងទីជនបទ ។ ខ្មែរក្រហមមានគោលបំណងលុបបំបាត់គម្លាតទាំងនេះចោល ប៉ុន្តែវិធីសាស្ត្រនៃការលុបបំបាត់និងភាពខ្វះមនសិការចំពោះប្រជាជននៅក្នុងប្រទេសបានបង្កឲ្យមានការបំផ្លិចបំផ្លាញដល់ប្រទេសជាតិទាំងមូល ។ នេះជាពេលវេលាមួយដែលប្រទេសកម្ពុជាចង់ទទួលបាននូវសិទ្ធិស្មើគ្នាក្នុងន័យបដិវត្តន៍ ប៉ុន្តែត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរ ។

ការតាំងពិព័រណ៍នៅក្នុងទីក្រុងស្តុកខូម ទាក់ទងនឹង ប៉ុល ពត ដោយវេទិកាឯកសាររស់ គឺមិនមែនកើតឡើងដោយចៃដន្យនោះទេ ។ ទោះបីជាប្រទេសស៊ុយអែដស្ថិតនៅឆ្ងាយក៏ដោយ ក៏ប្រទេសនេះធ្លាប់មានទំនាក់ទំនងដ៏យូរអង្វែងជាមួយប្រទេសកម្ពុជា ចាប់តាំងពីប្រទេសស៊ុយអែដចាប់ផ្តើមទាញយកផលប្រយោជន៍ពីព្រឹត្តិការណ៍សិទ្ធិមនុស្សអន្តរជាតិ ជាពិសេសគឺបាតុកម្មសង្គ្រាមប្រឆាំងវៀតណាម ។ ប្រទេសស៊ុយអែដ គឺជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើនដែលមានទំនាក់ទំនងការទូតជាមួយនឹងកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងខែសីហា ឆ្នាំ១៩៧៨ គណៈប្រតិភូជនជាតិស៊ុយអែដមួយក្រុម ដែលមកពី «សមាគមមិត្តភាពកម្ពុជា-ស៊ុយអែដ» បានមកទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជា ។ ហ្គុនណា បឺយស្ត្រម គឺជាភ្ញៀវម្នាក់ក្នុងចំណោមបួននាក់នៅក្នុងក្រុម ហើយគាត់និងសមាជិកបីនាក់ទៀត ក៏ត្រូវបានអនុញ្ញាតឲ្យទទួលទានអាហារពេលល្ងាចជាមួយ ប៉ុល ពត នៅថ្ងៃចុងក្រោយនៃដំណើរទស្សនកិច្ច ។ អ្នកទាំងនោះគឺជាភ្ញៀវមួយក្រុមក្នុងចំណោមភ្ញៀវជនជាតិបរទេសមួយចំនួនផ្សេងទៀត ដែលត្រូវបានអញ្ជើញមកទស្សនកិច្ចនៅក្នុងកម្ពុជាប្រជាធិបតេយ្យចាប់តាំងពីខ្មែរក្រហម

កាន់កាប់អំណាចនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ។

គណៈប្រតិភូទាំងនោះ គឺជាភ្ញៀវមួយក្រុមក្នុងចំណោមភ្ញៀវផ្សេងទៀតដែលជឿជាក់លើបដិវត្តន៍ខ្មែរក្រហម ។ គណៈប្រតិភូនេះ បានគាំទ្រខ្មែរក្រហមនៅមុនពេលដែលក្រុមនេះបានមកធ្វើទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជាទៅទៀត ហើយវាជាការលំបាកខ្លាំងណាស់សម្រាប់ក្រុមគណៈប្រតិភូក្នុងការជឿ ទោះបីជានៅក្នុងរយៈពេលនៃការធ្វើទស្សនកិច្ចនោះ ខ្មែរក្រហមហាក់ដូចជាបានរៀបចំទុកជាមុននៅមុនពេលដែលក្រុមនេះបានទៅដល់ក៏ដោយ ។ អ្នកភូមិជនជាតិកម្ពុជាម្នាក់បាននិយាយថា «គណៈប្រតិភូមិនអាចមើលឃើញនូវចំណុចអាក្រក់របស់ខ្មែរក្រហមឡើយ ។ ខ្មែរក្រហមឲ្យសម្លៀកបំពាក់ទៅដល់ប្រជាជនដែលមានសុខភាពល្អដើម្បីមកបង្ហាញខ្លួន នៅមុនពេលដែលគណៈប្រតិភូមកដល់ ហើយបានរៀបចំទុកមុនរួចជាស្រេច» ។ ហ៊ុនណា បឹយស្រ្តម បានព្យាយាមមកបកស្រាយថា យើងមិនអាចមើលឃើញប្រទេសកម្ពុជានៅក្នុងភាពងងឹតឡើយ និងសុំឲ្យមានការលើកលែងទោសឲ្យខ្លួនគាត់ សម្រាប់ការជឿទៅលើបដិវត្តន៍ដ៏អស្ចារ្យមួយនេះ ។

ទោះបីជាមានរូបថតមួយចំនួនបញ្ជាក់ពីបដិវត្តន៍កុម្មុយនីស្តនៅកន្លែងផ្សេងៗក៏ដោយ ក៏ «ការបរិភោគអាហារពេលល្ងាចជាមួយ ប៉ុល ពត» គឺផ្តោតជាសំខាន់ពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូស៊ុយអែដ និងទំនាក់ទំនងរបស់ប្រទេសស៊ុយអែដជាមួយនឹងខ្មែរក្រហម ។ ក្នុងនាមជាអ្នកព្យាបាលជំងឺផ្លូវចិត្តម្នាក់ដែលធ្វើការនៅក្នុងមជ្ឈមណ្ឌលស្តារនីតិសម្បទាមួយសម្រាប់អ្នកញៀនថ្នាំនិងគ្រឿងស្រវឹង នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៨ ហ៊ុនណា បឹយស្រ្តម បានសម្រេចចិត្តមកប្រទេសកម្ពុជាជាលើកទីមួយ ចាប់តាំងពីដំណើរទស្សនកិច្ចដ៏យូរអង្វែងកាលពី៣០ឆ្នាំមុន ។ សម្រាប់ហ៊ុនណា បឹយស្រ្តម នេះគឺជាដំណើរទស្សនកិច្ចមួយសម្រាប់ភ្ជាប់ទំនាក់ទំនង បង្ហាញពីវិប្បដិសារី និងសុំការលើកលែងទោសពីប្រជាជនកម្ពុជា ។ ហ៊ុនណា បឹយស្រ្តម បានសរសេរនៅកាសែតរបស់ស៊ុយអែដនៅក្នុងឆ្នាំ១៩៧៩ ដោយបានទទួលស្គាល់កំហុសរបស់គាត់ដែលគាំទ្រខ្មែរក្រហម ប៉ុន្តែគាត់មិនធ្លាប់បានសុំទោសប្រជាជនកម្ពុជាដោយផ្ទាល់ឡើយ ។ នៅក្នុងដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា ហ៊ុនណា បឹយស្រ្តម បានបង្ហាញពីរូបថតដែលគាត់បានថតកាលពីអំឡុងពេលដែលគាត់មកទស្សនកិច្ចនៅក្នុងឆ្នាំ១៩៧៨ នៅក្នុងការតាំងពិព័រណ៍ជាអចិន្ត្រៃយ៍និងចល័តមួយ ។ ហ៊ុនណា បឹយស្រ្តម បាននិយាយនៅចំពោះមុខប្រជាជនកម្ពុជានៅក្នុងសិក្ខាសាលាចំនួនបីនៅក្នុងទីក្រុងភ្នំពេញ ខេត្តកំពង់ចាម និងខេត្តបាត់ដំបង អំពីដំណើរទស្សនកិច្ចរបស់គាត់និងបានសុំទោសប្រជាជនទាំងនោះដោយផ្ទាល់ ។

វេទិកាឯកសាររស់ និងមជ្ឈមណ្ឌលឯកសារកម្ពុជាមានកិត្តិយសដើម្បីរៀបចំដំណើរទស្សនកិច្ចនេះ ។ ការតាំងពិព័រណ៍នៅវេទិកាឯកសាររស់នៅក្នុងទីក្រុងស្តុកខូម ប្រទេសស៊ុយអែដ គឺជាការតាំងពិព័រណ៍មួយផ្សេងទៀតដែលមានគោលបំណងបង្ហាញដោយផ្ទាល់នៅចំពោះមុខប្រជាជនស៊ុយអែដ ។ វាជាការតាំងពិព័រណ៍បែបអប់រំនិងរស់រវើកមួយ ។ ផ្ទុយមកវិញ មានការរិះគន់មួយចំនួនក្នុងចំណោមកាសែតស៊ុយអែដដែលប្រឆាំងនឹងការតាំងពិព័រណ៍នេះ ដាក់ស្តែងគេហទំព័រយូធូបបានចេញផ្សាយការរិះគន់



នៅពេលដែលឯកសាររស់បានចាប់ផ្តើមនៅបីបួនថ្ងៃមុនការតាំងពិព័រណ៍ ។ ក្នុងនាមជាប្រជាជនកម្ពុជាមួយរូប ខ្ញុំមានអារម្មណ៍ថាការពិភាក្សាផ្នែកនយោបាយអំពីថាតើរដ្ឋាភិបាលប្រទេសស៊ុយអែដគួរតែសិក្សាពីអំពើឃោរឃៅដែលធ្វើឡើងនៅក្នុងរបបប្រល័យពូជសាសន៍ប្រព្រឹត្តដោយរដ្ឋាភិបាលកុម្មុយនីស្ត វាអាចបណ្តាលឲ្យមានការមិនទទួលស្គាល់ការឈឺចាប់និងទុក្ខវេទនារបស់ជនរងគ្រោះឬទេ ។ នេះគឺជាអ្វីដែលបានកើតឡើងចំពោះប្រទេសកម្ពុជា


សាលពិព័រណ៍រូបភាព

នៅអំឡុងទសវត្សរ៍៨០ នៅពេលដែលកម្ពុជាប្រជាធិបតេយ្យត្រូវបានគេទទួលស្គាល់ថាជារដ្ឋាភិបាលស្របច្បាប់របស់ប្រទេសកម្ពុជាតំណាងឲ្យជនរងគ្រោះនៅអង្គការសហប្រជាជាតិ ។ ពិចារណាខ្លួនឯងទៅ វាពិតជាមិនសមហេតុផលទេ ។

សមាជិកបីនាក់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺលោក អេង កុកថាយ ស៊ីរិ សាវីណា និង សើ សាយ្យាណា រួមទាំងលោក ប៊ូ ម៉េង និងលោក ហ៊ុយ វណ្ណៈ មានកិត្តិយសដែលបានទទួលការអញ្ជើញដោយវេទិកាឯកសាររស់ឲ្យចូលរួមក្នុងការតាំងពិព័រណ៍ ។ លោក ប៊ូ ម៉េង គឺជាអ្នកនៅរស់ម្នាក់ក្នុងចំណោមអ្នកនៅរស់រានមានជីវិតមួយចំនួនពីគុកស-២១ដ៏អសោចនៃរបបខ្មែរក្រហម ដែលប្រជាជនប្រមាណ១៤.០០០នាក់ត្រូវបានសម្លាប់ ។ លោក ហ៊ុយ វណ្ណៈ ជាអ្នកសារព័ត៌មានរបស់វិទ្យុអាស៊ីសេរី និងជាអ្នកនិពន្ធសៀវភៅដែលរៀបរាប់អំពីជីវិត និងបទពិសោធន៍របស់ ប៊ូ ម៉េង ដែលនៅរស់រានមានជីវិតពីគុកស-២១ ដែលនឹងចេញផ្សាយនៅពេលខាងមុខ ។ ភ្ញៀវទាំងប្រាំរូបបានមកចូលរួមនៅក្នុងការពិភាក្សាបន្ទាប់ពីការបើកពិធីតាំងពិព័រណ៍ ។ ភ្ញៀវទាំងប្រាំរូបនេះក៏បានជួបជាមួយបុគ្គលិករបស់វេទិកាឯកសាររស់ដែរ ។ លោក ប៊ូ ម៉េង ត្រូវបានសម្ភាសន៍ដោយទូរទស្សន៍ស៊ុយអែដ និងអ្នកសារព័ត៌មានផ្សេងទៀត ។ លោក ប៊ូ ម៉េង ក៏បានពិពណ៌នាពីរូបគំនូររបស់គាត់ទៅកាន់អ្នកមកចូលរួមទស្សនាការតាំងពិព័រណ៍ជាច្រើន ។ លោក ហ៊ុយ វណ្ណៈ ក៏បានជួយសហការក្នុងការរៀបរាប់នេះដែរដែលមានលោក អេង កុកថាយ ជាអ្នកបកប្រែ ។

លោកសាស្ត្រាចារ្យ ដេវីដ ឆេនល័រ ក៏ត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងការតាំងពិព័រណ៍នេះដែរ ។ លោកបានផ្តល់កិច្ចអត្ថាធិប្បាយមួយថ្ងៃមុនពេលលោក ប៊ូ ម៉េង រៀបរាប់អំពីបទពិសោធន៍របស់ខ្លួន ទាក់ទងនឹងរបបខ្មែរក្រហមប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងស្ថានភាពនយោបាយសង្គមរបស់កម្ពុជាជាទូទៅ ។ យើងមានមោទកភាពដែលបានជួបលោកនៅក្នុងទីក្រុងស្តុកខូម ។ លោក អេង កុកថាយ សើ សាយ្យាណា និង ស៊ីរិ សាវីណា បានជួបជាមួយក្រុមអប់រំប្រធានគម្រោងប្រវត្តិសាស្ត្រផ្ទាល់មាត់និងសមាជិករបស់វេទិកាឯកសាររស់ ។ សមាជិកក្រុមទាំងអស់ក៏មានឱកាសល្អបានទៅទស្សនាសាលាបង្រៀនភាពយន្តនិងការិយាល័យលើកលែងទោសអន្តរជាតិនៅទីក្រុងស្តុកខូម ។ នៅអំឡុងពេលទស្សនាអ្នកទាំងនេះបានបង្ហាញពីការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងរៀបរាប់ដោយសង្ខេបអំពីសារសំខាន់នៃការងារដែលស្ថាប័នទាំងនោះកំពុងដំណើរការ ។ យើងមានសេចក្តីសោមនស្សរីករាយ ដែលបានទទួលការអញ្ជើញពី អេសស្កិល ហ្វ្រែង អ៊ីរីខា អារ៉ូណូវីត ប៊ូស្ស លីងឃីស និងសមាជិករបស់វេទិកាឯកសាររស់ឲ្យចូលរួមក្នុងពិធីតាំងពិព័រណ៍នេះ ។ **អេង កុកថាយ**

# របាយការណ៍ពីដំណើរទស្សនកិច្ចដើម្បីយុត្តិធម៌ និងការអប់រំអំពើប្រល័យពូជសាសន៍

## ថ្ងៃទី១៦-១៨ ខែសីហា ឆ្នាំ២០០៩

ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ប្រជាជនសរុបចំនួន៤៥៩នាក់ មកពីខេត្ត-ក្រុង នានាទូទាំងប្រទេស ចូលរួមក្នុងដំណើរទស្សនកិច្ចមួយដែលអាចឲ្យអ្នកចូលរួមទទួលបាននូវវគ្គបណ្តុះបណ្តាល-អប់រំដើម្បីទទួលបាននូវព័ត៌មានទាក់ទងនឹងការកាត់ក្តីមេដឹកនាំខ្មែរក្រហម ស្តាប់ការរៀបរាប់អំពីបទពិសោធន៍របស់អ្នករួចរស់ជីវិតពីមន្ទីរទារុណកម្ម-សម្លាប់នៅមន្ទីរស-២១ និងទស្សនាល្ខោនថ្មីមួយដែលមានចំណងជើងថា «ទម្លាយភាពស្ងប់ស្ងាត់» ។ អ្នកចូលរួមទាំងអស់ ក៏នឹងមានឱកាសទៅទស្សនានៅសាលាក្តីខ្មែរក្រហម និងចូលរួមសវនាការរបស់ កាំង ហ្កេចអ៊ាវ ហៅ ឌុច (ជាអតីតប្រធានមន្ទីរស-២១) និងធ្វើទស្សនកិច្ចនៅទីតាំងដើម្បីការចងចាំពីអំពើប្រល័យពូជសាសន៍មួយដ៏សំខាន់គឺសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង (មន្ទីរស-២១) ។ ដំណើរទស្សនកិច្ចនេះមានការចូលរួមពីមេដឹកនាំសាសនាចាម-មូស្លីម ៣៥០នាក់ មកពីវិហារចាមចំនួន៣៩៦នាក់ ខ្មែរកម្ពុជាក្រោមចំនួន ១៣នាក់មកពីខេត្តពោធិ៍សាត់ ដូនជី៣០នាក់មកពីខេត្តកំពង់ស្ពឺ និងក្រុងភ្នំពេញ និងអ្នកភូមិមួយចំនួនមកពីខេត្តកណ្តាល តាកែវ កំពង់ចាម និងព្រៃវែង (ដែលភាគច្រើនជាអ្នកដាក់ពាក្យបណ្តឹងធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទៅកាន់តុលាការខ្មែរក្រហម តាមរយៈគម្រោងការចូលរួមរបស់ជនរងគ្រោះនៃមជ្ឈមណ្ឌលឯកសារកម្ពុជា) ។ អ្នកចូលរួមភាគច្រើនធ្លាប់បានចូលរួមក្នុងដំណើរទស្សនកិច្ចដែលមានទំហំធំកាលពីឆ្នាំ២០០៦ និងការអញ្ជើញមកជាក្រុមតូចៗដើម្បីទស្សនាសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដំណើរទស្សនកិច្ចនេះមានសារប្រយោជន៍ ពីព្រោះវាមិនត្រឹមតែបានលើកកម្ពស់តួនាទីជនរងគ្រោះនៅតុលាការខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែនឹងអនុញ្ញាតឲ្យអ្នកចូលរួមបានមើលឃើញដោយផ្ទាល់ភ្នែកថា តើសវនាការមានដំណើរការដូចម្តេចខ្លះ? ហើយថែមទាំងផ្តល់ឱកាសដល់ជនរងគ្រោះធ្វើការចែករំលែកចំណេះដឹងទាក់ទងនឹងប្រវត្តិសាស្ត្រនិងធ្វើយ៉ាងណាដើម្បីថែរក្សាប្រវត្តិសាស្ត្រនេះផង ។

ភាពចម្រុះគ្នានេះបានធ្វើឲ្យតួនាទីរបស់អ្នកចូលរួមក្នុងការបញ្ជូនព័ត៌មានដែលទទួលបានតាមរយៈដំណើរទស្សនកិច្ចនេះមានប្រសិទ្ធិភាពខ្ពស់ ។ មេដឹកនាំសាសនាចាម-មូស្លីម ទូន និងហាកិម គឺជាមនុស្សសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មាន ពីព្រោះគាត់ជាអ្នកដែលទទួលបានការគោរព និងមានចំណេះដឹងនៅក្នុងសហគមន៍ ។ ទូន គឺជាគ្រូបង្រៀនសាសនាដល់សមាជិកសហគមន៍ និងធ្វើការនៅក្នុងវិហារសាសនាអ៊ិស្លាម ។ ទូន បង្រៀនភាសាចាម និងគម្ពីរកូរ៉ានដល់កុមារា-កុមារី ។ ចំណែក ហាកិម ឬ «ចៅក្រម» ទទួលបន្ទុកមើលការខុសត្រូវលើសហគមន៍និងធ្វើការសម្រុះសម្រួលជម្លោះក្នុងសហគមន៍ ។ គម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំដែលចាប់ផ្តើមនៅឆ្នាំ២០០៤ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការជាមួយវិហារអ៊ិស្លាមទូទាំងប្រទេសក្នុងគម្រោងផ្សេងៗគ្នា រួមមានការសម្ភាសជាមួយមេដឹកនាំសាសនាជនជាតិចាម-មូស្លីម និងស្ត្រីចាម-មូស្លីម អំពីបទពិសោធន៍ជីវិតឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ ក្នុងគោលបំណងថាជនជាតិភាគតិចនឹងមានសំឡេងទៅដល់ពិភពលោកខាងក្រៅ ។

ខ្មែរកម្ពុជាក្រោមពីខេត្តពោធិសាត់ដែលបានចូលរួមក្នុងដំណើរទស្សនកិច្ចនេះតំណាងឲ្យក្រុមជនជាតិភាគតិចមួយក្រុមទៀតដែលបានទទួលរងការបាត់បង់ជីវិតយ៉ាងធ្ងន់ធ្ងរនៅក្រោមរបបខ្មែរក្រហម ។ អ្នកភូមិបានសំណើសុំមកចូលរួមដំណើរទស្សនកិច្ចនេះពីព្រោះពួកគាត់មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះកម្មវិធីនេះ ហើយថែមទាំងចង់បង្ហាញពីបទពិសោធន៍ដ៏ជូរចត់របស់គាត់ដើម្បីមកស្វែងយល់បន្ថែមពីសវនាការ ឌុច និងបទពិសោធន៍

របស់ជនរងគ្រោះដទៃទៀត ។ កន្លងមកក្រុមខ្មែរកម្ពុជាក្រោមបានចូលរួមក្នុងកម្មវិធីរបស់គម្រោងឯកសាររស់ ។ ខ្មែរក្រោមទទួលរងនូវការរំលោភបំពានពីខ្មែរក្រហម ហើយការចូលរួមរបស់គាត់មានឥទ្ធិពលក្នុងការរក្សាបទពិសោធន៍របស់គាត់ឲ្យនៅមានជីវិតជានិច្ច ។ ដោយសារតែមានលក្ខណៈលាយចម្រុះគ្នានៃអ្នកមកចូលរួមក្នុងដំណើរទស្សនកិច្ចនេះបានធ្វើឲ្យកម្មវិធីនេះមានភាពរំភើប និងមានលក្ខណៈ ពិសេស ។

## វគ្គបណ្តុះបណ្តាលមុនពេលចូលរួមក្នុងសវនាការ

នៅថ្ងៃទីមួយនៃដំណើរទស្សនកិច្ច អ្នកភូមិបានរៀបចំមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានបុគ្គលិកនិងអ្នកស្ម័គ្រចិត្តនៅរង់ចាំស្វាគមន៍និងចែកបាយកញ្ចប់ជូន ។ ក្រុមគម្រោងចូលរួមរបស់ជនរងគ្រោះដាក់ពាក្យបណ្តឹងក៏នៅទីនោះដើម្បីរង់ចាំជួយបំពេញឯកសារពាក្យបណ្តឹងរបស់អ្នកភូមិដែលនៅមានការខ្វះចន្លោះ ។ ក្រុមគម្រោងក៏នៅចាំប្រគល់លិខិតទទួលស្គាល់ពាក្យបណ្តឹងរបស់តុលាការខ្មែរក្រហមទៅឲ្យអ្នកដាក់ពាក្យបណ្តឹងដែលតុលាការបានទទួលស្គាល់ ។ នៅរសៀលថ្ងៃនោះ អ្នកចូលរួមទាំងអស់បានធ្វើដំណើរតាមរថយន្តក្រុងទៅសាលប្រជុំរបស់វិទ្យាស្ថានជាតិអប់រំ ជាកន្លែងដែលអ្នកចូលរួមត្រូវស្តាប់បទបង្ហាញរបស់ប្រធានគម្រោងមជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកដែលរួចរស់ជីវិតពីរបបខ្មែរក្រហម ។

លោក លី សុខឃាង បានបើកការប្រជុំដោយធ្វើកិច្ចស្វាគមន៍ចំពោះអ្នកចូលរួម ព្រមទាំងរៀបរាប់ពីគោលបំណងរបស់ដំណើរទស្សនកិច្ចនេះ ។ លោក សុខឃាង បានជំរុញឲ្យអ្នកចូលរួមទាំងអស់ជួយធ្វើការផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីដំណើរទស្សនកិច្ចនេះទៅកាន់សមាជិកសហគមន៍របស់ខ្លួនផង ។ បន្ទាប់មកលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារបានធ្វើការស្វាគមន៍ក្រុមអ្នកចូលរួម ។ លោក ឆាំង យុ បានសង្កត់ធ្ងន់ទៅលើសារសំខាន់របស់សវនាការកាត់ក្តីមេដឹកនាំខ្មែរក្រហម និងតួនាទីដ៏សំខាន់របស់ជនរងគ្រោះនៅក្នុងដំណើរការនេះ ។ លោកក៏បានធ្វើការផ្តែផ្តាំអ្នកចូលរួមទាំងអស់ឲ្យយកចិត្តទុកដាក់ចំពោះដំណើរការកាត់ក្តីនិងរក្សាសណ្តាប់ធ្នាប់នៅក្នុងបន្ទប់សវនាការ ។ បន្ទាប់មកលោកនាយកមជ្ឈមណ្ឌលបានធ្វើការពិភាក្សាទៅលើកម្រងល្ខោនខ្មែរថ្មីមួយដែលនឹងសម្តែង



ប្រជាជនខ្មែរ-មូស្លីមចូលរួមស្តាប់ការពន្យល់របស់បុគ្គលមជ្ឈមណ្ឌលអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរការតុលាការខ្មែរក្រហម

ជូនទស្សនានៅល្ងាចនោះ ដែលមានចំណងជើងថា «ទម្លាយភាពស្ងប់ស្ងាត់» ។ លោក ឆាំង យុ ក៏បានលើកទឹកចិត្តអ្នកចូលរួមក្នុងក្រុមទាំងអស់ឲ្យចោទជាសំណួរនិងលើកជាមតិយោបល់ចំពោះការសម្តែងនេះ ។ បន្ទាប់មក លោក វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការរៀបរាប់ពីសកម្មភាពថ្មីៗរបស់សាលាក្តីខ្មែរក្រហមនិងសវនាការ ឌុច ។ លោកបានរៀបរាប់ពីរចនាសម្ព័ន្ធរបស់តុលាការ មុខងារនិងបុគ្គលិកធ្វើការ រួមបញ្ចូលទាំងបុគ្គលិកដែលមានពាក់ព័ន្ធនៅក្នុងសវនាការ ឌុច ប្រវត្តិរូបសង្ខេបរបស់ ឌុច និងតួនាទីរបស់គាត់ក្នុងសម័យខ្មែរក្រហម ។

កញ្ញា សូ ហ្វារីណា ប្រធានគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំបានចាប់ផ្តើមបទបង្ហាញរបស់ខ្លួនជាមួយពាក្យស្វាគមន៍ជាភាសាចាម ទៅដល់ ទូន ហាកិម និងក្រុមផ្សេងៗទៀតនៅក្នុងសាលប្រជុំ។ កញ្ញា សូ ហ្វារីណា បានសង្ខេបពីគោលបំណង និងសកម្មភាពជាមួយនឹងសហគមន៍ ចាម-មូស្លីមដើម្បីពង្រីកចំណេះដឹងអំពីអំពើសាហាវយង់ឃ្នងរបស់ខ្មែរក្រហមប្រឆាំងនឹងសហគមន៍ចាម ។ កញ្ញា សូ ហ្វារីណា បានធ្វើការពិភាក្សាទៅលើគម្រោងរបស់ខ្លួនដែលបានបោះពុម្ពផ្សាយរឿងរ៉ាវរបស់ ចាម និងក្រុមជនជាតិភាគតិចដទៃទៀតដូចជា ចារ៉ាយ ទំពួន ក្អួយ...ជាដើម នៅក្នុងទស្សនាវដ្តី ។ គម្រោងនេះគ្រោងនឹងបង្កើតគេហទំព័រសម្រាប់សហគមន៍ចាម-មូស្លីមក្នុងគោលបំណងចែករំលែកព័ត៌មានគ្នាទៅវិញទៅមក រៀនសូត្រពីវប្បធម៌ និងសិក្សាពីឧក្រិដ្ឋកម្មប្រឆាំងនឹងក្រុមចាម-មូស្លីម ព្រមទាំងធ្វើការផ្លាស់ប្តូរទំនាក់ទំនងគ្នារវាងសហគមន៍ចាម និងក្រុមមូស្លីមនៅលើពិភពលោក ។ គម្រោងទាំងនេះមានគោលបំណងឲ្យសំឡេងរបស់ក្រុមជនជាតិភាគតិចបានឮទៅដល់ពិភពលោកខាងក្រៅ និងអនុញ្ញាតឲ្យសហគមន៍ជាតិ និងអន្តរជាតិយល់ដឹងអំពីការលំបាកនិងទុក្ខវេទនារបស់ចាម-មូស្លីមនិងក្រុមជនជាតិភាគតិចដទៃទៀតនៅក្រោមរបបខ្មែរក្រហម ។ នៅចុងបញ្ចប់គម្រោងនេះនឹងប្រើប្រាស់ការសម្ភាសដែលបានធ្វើជាមួយជនរងគ្រោះសម័យខ្មែរក្រហម ជាពិសេសជាមួយស្ត្រីដើម្បីសរសេរសៀវភៅមួយអំពីបទពិសោធន៍របស់ចាម-មូស្លីមនៅក្រោមរបបខ្មែរក្រហម ។ កញ្ញា សូ ហ្វារីណា បានបញ្ជាក់ថាការចងក្រងរឿងរ៉ាវរបស់ក្រុមដែលមានភាពទន់ខ្សោយនឹងជួយឲ្យគាត់មាន



លោក ឆាំង យុ និយាយទៅកាន់ ឆង ចាន់ផល អតីតកុមារដែលរួចរស់ជីវិតពីគុ

សំឡេងហើយប្រែក្លាយការឈឺចាប់និងកំហឹងរបស់សហគមន៍ឲ្យទៅជាការអប់រំសម្រាប់មនុស្សជំនាន់ក្រោយអំពីរឿងរ៉ាវទាំងឡាយដែលបានកើតឡើងទៅលើចាម-មូស្លីមនៅជំនាន់ខ្មែរក្រហម ។

បន្ទាប់មកលោក ឌី ខាំបូលី បានធ្វើការណែនាំអំពីសៀវភៅរបស់លោកដែលមានចំណងជើងថា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និងពិភាក្សាទៅលើការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ លោក ឌី ខាំបូលី បានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យនៅសាលារៀន ដោយសារថាប្រធានបទនេះមានលក្ខណៈរសើបចំពោះប្រជាជនកម្ពុជា ។ ការអប់រំពីអំពើប្រល័យពូជសាសន៍មានអត្ថប្រយោជន៍ពីរសំខាន់ ។ ទីមួយ កំហឹង ឬការសងសឹកអាចនឹងរំសាយប្រសិនបើធ្វើការកែប្រែអំពើឧក្រិដ្ឋកម្មទាំងនេះឲ្យទៅជាមុខវិជ្ជាមួយដើម្បីរៀននៅតាមសាលា ។ ទីពីរ ការសិក្សាប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ អាចជួយកុំឲ្យអំពើបែបនេះកើតឡើងមកជាថ្មីម្តងទៀត ។ លោក ខាំបូលី បានបញ្ជាក់បន្ថែមទៀតថាតុលាការតែមួយមិនអាចការពារអំពើរបបប្រល័យពូជសាសន៍មិនឲ្យកើតឡើងម្តងទៀតបានឡើយ ការអប់រំក៏នឹងជួយរួមចំណែកក្នុង




ដំណើរការដ៏វែងឆ្ងាយក្នុងការផ្សះផ្សា ។

ហ៊ីម ហ៊ុយ ដែលជាអតីតអ្នកយាមគុកទួលស្វែងនិង នង ចាន់ផល ដែលជាកុមាររួចរស់ជីវិតម្នាក់ពីគុកទួលស្វែងបានឡើងរៀបរាប់ពីជីវិតរបស់គាត់ក្នុងមន្ទីរស-២១បន្ទាប់ពីបទបង្ហាញទាំងអស់ត្រូវបានបញ្ចប់ ។ លោក ហ៊ីម ហ៊ុយ បានធ្វើការពិភាក្សាដោយសង្ខេបអំពីបទពិសោធន៍របស់គាត់នៅមន្ទីរស-២១ចាប់ពីពេលដែលគាត់ចូលធ្វើការរហូតដល់ពេលដែលរបបខ្មែរក្រហមដួលរលំ ។ លោក ហ៊ីម ហ៊ុយ បានរៀបរាប់ពីការងារនៅមន្ទីរស-២១ ក្នុងកងចាប់ចងដែលគាត់ទទួលខុសត្រូវក្នុងការបញ្ជូនអ្នកទោសទៅកាន់វាលពិឃាតបឹងជើងឯកនិងការចាប់ខ្លួនអ្នកទោសពីខាងក្រៅទៅមន្ទីរស-២១ ។ លោក ហ៊ីម ហ៊ុយ បានពន្យល់ពីស្ថានភាពនៅក្នុងឆ្នាំ១៩៧៧-៧៨ ជាពេលដែលគាត់ចាប់ផ្តើមសង្កេតឃើញថាបុគ្គលិកមន្ទីរស-២១ជាច្រើននាក់បានបាត់ខ្លួននិងជាប់នៅក្នុងគុកដែលក្រុមគេធ្លាប់ធ្វើការ ។ គាត់បានរំឭកឡើងវិញពីភាពភ័យខ្លាចរៀងរាល់ថ្ងៃដែលតាមលងគាត់ជាប់ជាប្រចាំនៅពេលដែលគាត់កំពុងធ្វើការនៅមន្ទីរស-២១ ។ នៅចុងបញ្ចប់ លោក ហ៊ីម ហ៊ុយ សង្ឃឹមថាសក្ខីកម្មដែលគាត់បានផ្តល់នៅតុលាការនឹងមានសារសំខាន់ក្នុងការនាំយក ឌុច មកទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនេះ ។

បន្ទាប់មកលោក នង ចាន់ផល បានរៀបរាប់ពីសកម្មភាពដែលខ្មែរក្រហមបានចាប់និងបញ្ជូនគាត់ទៅគុកទួលស្វែង ។ លោក នង ចាន់ផល ត្រូវខ្មែរក្រហមបញ្ជូនទៅជាមួយម្តាយនិងប្អូនប្រុសរបស់គាត់ទៅកន្លែងមួយដែលក្រោយមកត្រូវបានគេស្គាល់ថាជាគុកទួលស្វែង ។ គាត់បានរំឭកឡើងវិញដោយលម្អិតនៅពេលដែលម្តាយគាត់ត្រូវខ្មែរក្រហមដាក់ខ្នោះនិងថតរូប ។ លោក នង ចាន់ផល និងប្អូនប្រុសគាត់ត្រូវបានដាក់ឲ្យនៅផ្សេងពីម្តាយរបស់គាត់បន្ទាប់ពីនៅជាមួយគ្នាបានតែមួយយប់ ។ លោក នង ចាន់ផល បានរៀបរាប់ដោយក្រៀមក្រំនិងរំជួលចិត្ត អំពីពេលចុងក្រោយដែលគាត់ជួបម្តាយ ។ គាត់រៀបរាប់ថា «ម្តាយខ្ញុំមើលមកខ្ញុំពីបង្អួចនៃបន្ទប់ដែលគេឃុំឃាំងគាត់ ប៉ុន្តែយើងអត់បាននិយាយគ្នាទេ ព្រោះយើងនៅឆ្ងាយស្តាប់គ្នាមិនឮ» ។ លោក នង ចាន់ផល សង្ឃឹមយ៉ាងមុតមាំថា តុលាការខ្មែរក្រហមនឹងអាចជួយស្វែងរកយុត្តិធម៌ឲ្យគាត់និងជនរងគ្រោះទាំងអស់ដែលបានទទួលរងការឈឺចាប់ក្រោមរបបខ្មែរក្រហម ។ នៅពេលដែលគេសួរគាត់ថាតើគាត់មានអារម្មណ៍យ៉ាងដូចម្តេចដែរនៅពេលផ្តល់សក្ខីកម្មដល់តុលាការ លោក នង ចាន់ផល ឆ្លើយថាមានការពេញចិត្តនឹងការបំភ្លឺសក្ខីកម្មនេះ ។

បន្ទាប់ពីបញ្ចប់បទបង្ហាញ អ្នកសម្របសម្រួល លោក លី សុខឃាង បានលើកទឹកចិត្តឲ្យអ្នកចូលរួមសួរសំណួរ ។ ទូន និងហាកិមមួយចំនួនបានចែករំលែកបទពិសោធន៍គាត់ជាមួយក្រុមទាំងអស់និងសួរសំណួរខ្លះទៅដល់វាគ្មិន ។ សំណួរទីមួយចោទសួរថា តើ ឌុច ទទួលស្គាល់ ហ៊ីម ហ៊ុយ និង នង ចាន់ផល នៅឯសវនាការឬទេ និងតើមានសាក្សីប៉ុន្មាននាក់ទៀតដែល ឌុច ទទួលស្គាល់ ។ សំណួរទីពីរសួរថាតើមេដឹកនាំខ្មែរក្រហមមានវិប្បដិសារីចំពោះទង្វើរបស់ខ្លួនឬទេ? សំណួរទីបី តើសំណងប្រភេទអ្វីខ្លះដែលដើមបណ្តឹងរដ្ឋប្បវេណីទាមទារ? នង ចាន់ផល និង ហ៊ីម ហ៊ុយ បានឆ្លើយនឹងសំណួរអ្នកភូមិដោយរំជួលចិត្តថា ឌុច នឹងមិនទទួលស្គាល់សាក្សីទេ ប្រសិនបើគ្មានឯកសារណាមួយដើម្បីបង្ហាញពីទំនាក់ទំនងរបស់បុគ្គលិកនោះជាមួយនឹងមន្ទីរស-២១ ។ លោក ហ៊ីម ហ៊ុយ បានបន្ថែមទៀតថា ឌុច មិនបានទទួលស្គាល់ហេតុការណ៍ខ្លះទាក់ទងនឹងការងារ

របស់គាត់នៅមន្ទីរស-២១ទេ ។ លោក ហ៊ឹម ហ៊ុយ បញ្ជាក់ថា «ខ្ញុំអាចស្បថឲ្យស្តាប់ថាអ្វីដែលខ្ញុំនិយាយនៅក្នុងសវនាការសុទ្ធតែជាការពិតទាំងអស់ ។ ខ្ញុំមិនបាននិយាយកុហកទេ» ។ សំណួរផ្សេងៗទៀតរួមមាន ១) ហេតុដូចម្តេចទើបមេដឹកនាំខ្មែរក្រហមមិនយល់ពីទឹកចិត្តរបស់ប្រជាជនខ្មែរ ហើយមិននិយាយការពិត? ២) ប្រសិនបើមេដឹកនាំខ្មែរក្រហមមិននិយាយការពិតទាំងអស់ តើតុលាការនឹងធ្វើយ៉ាងដូចម្តេច? ៣) តើមានការកាត់ទោសប្រហារជីវិតសម្រាប់មេដឹកនាំខ្មែរក្រហមដូចជាលោក ខៀវ សំផន ឬទេ? ៤) ហេតុអ្វីខ្មែរក្រហមសម្លាប់មនុស្សច្រើនម្ល៉េះ? ៥) តើឌុចនឹងទទួលបាននូវការកាត់ទោសយ៉ាងដូចម្តេច? ៦) ហេតុអ្វីទើបសហគមន៍អន្តរជាតិមិនធ្វើអន្តរាគមន៍មកលើប្រទេសកម្ពុជាក្នុងអំឡុងនិងក្រោយរបបខ្មែរក្រហម?

បន្ទាប់ពីទទួលទានអាហារពេលល្ងាចរួច អ្នកចូលរួមទាំងអស់បានត្រឡប់ទៅសាលប្រជុំវិញ ដើម្បីបន្តទស្សនាការសម្តែងល្ខោនរឿង «ទម្លាយភាពស្ងប់ស្ងាត់» ។ ល្ខោននេះដកស្រង់នូវបទពិសោធន៍ដ៏ជូរចត់របស់អ្នកដែលរួចរស់ជីវិតពីរបបខ្មែរក្រហមមកបង្ហាញជូនអ្នកចូលរួមទស្សនា ។ ល្ខោននេះចែកចេញជាប្រាំពីរវគ្គនៃខ្លឹមសាររឿងដែលមានលាយបញ្ចូលនូវចម្រៀងប្រពៃណីនិងរឿងនិទានរបស់ខ្មែរ ។ ល្ខោននេះក៏បានដកស្រង់នូវរឿងរ៉ាវមួយចំនួនដែលកើតមានញឹកញាប់ចំពោះជនរងគ្រោះនិងជនដៃដល់ ។ រឿងនេះក៏បានយកទៅសម្តែងនៅតាមតំបន់ជនបទដើម្បីជំរុញឲ្យមានការពិភាក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមក្នុងចំណោមអ្នករស់រានមានជីវិត និងរវាងជនរងគ្រោះនិងជនដៃដល់ដែរ ។ ល្ខោននេះមានគោលបំណងក្នុងការអប់រំ និងផ្លាស់ប្តូរទំនាក់ទំនង និងចំណេះដឹងរវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្មេងជំនាន់ក្រោយ ។ ជាងនេះទៅទៀត យើងសង្ឃឹមថាការសម្តែងល្ខោននេះនឹងរួមចំណែកទៅដល់ការសះស្បើយពីរបួសផ្លូវចិត្តនិងការផ្សះផ្សាគ្នាដែលជាផ្លូវឆ្ពោះទៅកាន់សង្គមមួយដែលមានស្ថិរភាពនិងសន្តិភាព ។

កញ្ញា សើ សាយព្យាណា ជាប្រធានគម្រោងផ្សព្វផ្សាយតាមរយៈសិស្ស និងលោក ឆាំង យុ បានធ្វើការណែនាំល្ខោនថ្មីនិងបានលើកទឹកចិត្តអ្នកចូលរួមទាំងអស់ឲ្យមានការពិភាក្សាគ្នា ។ បន្ទាប់មកលោក ប៊ុនរិទ្ធ មកពីសមាគមសិល្បៈអម្រឹតា បានសង្ខេបសាច់រឿងល្ខោន និងសូមអភ័យទោសចំពោះកង្វះខាតទាក់ទងនឹងការតុបតែងឆាកនិងការហាត់សម្តែង ។ លោក ឆាំង យុ បានរំឭកទៅដល់អ្នកចូលរួមទាំងអស់ឲ្យសម្តែងមតិយោបល់ទាក់ទងនឹងចម្រៀងនៅក្នុងល្ខោន ។ ក្រៅពីអ្នកចូលរួមក្នុងដំណើរទស្សនកិច្ច



ការសម្តែងល្ខោនរឿង ទម្លាយភាពស្ងប់ស្ងាត់

មន្ត្រីមកពីអង្គជំនុំជម្រះវិសាមញ្ញក៏បានចូលរួមនៅក្នុងការសម្តែងល្ខោននោះដែរ ។

នៅពេលដែលមានការសម្តែងល្ខោន ពេលខ្លះទស្សនិកជនសើចនឹងកាយវិការរបស់តួសម្តែងស្ងា និងពេលខ្លះទៀតអ្នកទស្សនាមានការរំជួលចិត្តនឹងសាច់រឿងមួយចំនួនដែលធ្វើឲ្យពួកគាត់នឹងឃើញពីអតីតកាលដ៏ឈឺចាប់របស់គាត់ ។ នៅពេលដែលតួសម្តែងម្នាក់រាយការណ៍ពីឈ្មោះមិត្តភក្តិ និងសាច់ញាតិរបស់ខ្លួនទៅឲ្យអ្នកសួរចម្លើយដើម្បីចៀសផុតពីការធ្វើទារុណកម្ម ទស្សនិកជនម្នាក់បានងាកមកប្រាប់ខ្ញុំថាល្ខោននេះពិតជាបានជ្រើសរើសនូវសាច់រឿងពិតដែលកើតមាននៅក្នុងរបបខ្មែរក្រហម ។ អ្នកភូមិម្នាក់នោះបានបន្តពន្យល់ខ្ញុំថា ដោយសារតែមិនចង់ឲ្យខ្មែរក្រហមវាយធ្វើបាប ទើបជនរងគ្រោះត្រូវតែនិយាយឈ្មោះទាំងអស់ដែលពួកគេនឹកឃើញទោះជាគេដឹងថារឿងនេះនឹងធ្វើឲ្យជីវិតអ្នកទាំងនោះស្ថិតក្នុងសភាពគ្រោះថ្នាក់ក៏ដោយ ។ នៅចុងបញ្ចប់នៃល្ខោននេះ អ្នកភូមិម្នាក់មកពីខេត្តតាកែវឈ្មោះ សាន្ត សុខ បានឡើងបញ្ចេញមតិរបស់គាត់ទាក់ទងនឹងល្ខោននេះ ។ លោក សាន្ត សុខ ប្រាប់យើងថា គាត់មានអារម្មណ៍រំភើបនៅពេលដែលបានទស្សនាល្ខោននេះហើយគាត់ក៏សំណូមពរឲ្យថតល្ខោននេះដើម្បីដាក់បញ្ចាំងនៅតាមទូរទស្សន៍និងផ្សាយតាមវិទ្យុដើម្បីឲ្យប្រជាជនខ្មែរទូទាំងប្រទេសអាចឆ្លុះបញ្ចាំងពីបទពិសោធន៍ផ្ទាល់ខ្លួន និងចែករំលែកបទពិសោធន៍នេះឲ្យទៅកូនចៅរបស់ខ្លួនដែរ ។ ទាក់ទងទៅនឹងអត្ថន័យរបស់បទចម្រៀង ចក់ ធឿង ជាអ្នកភូមិម្នាក់មកពីខេត្តកណ្តាល មានយោបល់ថា «បទចម្រៀងនេះពិតជាមានន័យណាស់សម្រាប់ការផ្សះផ្សាជាតិ ។ បទនេះមានអត្ថន័យក្នុងការកន្ត្រាក់អារម្មណ៍អ្នកស្តាប់ឲ្យធ្វើដំណើរឆ្ពោះទៅអនាគត និងណែនាំប្រជាជនឲ្យរស់នៅជាមួយគ្នាប្រកបដោយភាពសុខដុមរមនា» ។ នៅចុងបញ្ចប់នៃកម្មវិធីថ្ងៃនោះ ស្ត្រីម្នាក់ដែលជាចាម-មូស្លីមនិងជាអ្នកចូលរួមក្នុងកម្មវិធីបានបញ្ចេញនូវការរំភើបចិត្តដែលបានទស្សនានូវល្ខោនថ្មីនេះ ។ គាត់បានឆ្លៀតឱកាសនោះចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ជាមួយអ្នកចូលរួមផ្សេងទៀតនៅក្នុងប្រជុំនោះ ហើយនិយាយថាគាត់មានការធូរស្បើយចិត្តមួយកម្រិតដែលមានឱកាសនិយាយពីបទពិសោធន៍ផ្ទាល់ខ្លួនទៅអ្នកដទៃទៀត ។

## ការឃ្លាំមើលសវនាការឌុច

កម្មវិធីថ្ងៃទីពីរគឺការតាមដានមើលសវនាការ ឌុច ។ អ្នកចូលរួមទាំងអស់បានធ្វើដំណើរតាមរថយន្តក្រុងទៅកាន់សាលសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅជាយក្រុងភ្នំពេញ ។ អ្នកចូលរួមទាំងអស់បានអង្គុយនិងមើលដំណើរការសវនាការដោយយកចិត្តទុកដាក់ ហើយរង់ចាំមើល ឌុច ដែលជាប្រធានគុកទួលស្លែងឡើងនិយាយ ។ ឌុច ត្រូវគេនាំមកកាត់ទោសតាំងពីខែមីនា ឆ្នាំ២០០៩ម្ល៉េះ ។ នៅសប្តាហ៍នេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីបីរូបដែលបានចែករំលែកការឈឺចាប់ផ្ទាល់ខ្លួនជាមួយនឹងសវនាការ ។ អ្នកម្តាយឈ្មោះ ម៉ាទីន ឡីហ្វ៊ើរ្វ និងកូនស្រីឈ្មោះ អ៊ុក នារី ត្រូវអង្គជំនុំជម្រះអញ្ជើញមកអានសក្ខីកម្មរបស់ខ្លួន ។ ឡីហ្វ៊ើរ្វ បានរៀបរាប់ពីភាពអស់សង្ឃឹមរបស់ខ្លួនក្រោយពីស្វាមីរបស់គាត់ អ៊ុក កេត ត្រឡប់ពីបរទេសមកកាន់ប្រទេសកម្ពុជាវិញ តាមការអញ្ជើញរបស់ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ។ អ្នកស្រីបាត់អស់ក្តីសង្ឃឹមក្នុងការស្វែងរកស្វាមី ។ កូនស្រីរបស់គាត់ឈ្មោះ អ៊ុក នារី បានរំឭកពីបទពិសោធន៍របស់គាត់ក្នុងការស្វែងរករូបថតឪពុកនៅមន្ទីរស-២១ថាជារឿងមួយដ៏គួរឲ្យរន្ធត់នៅក្នុងជីវិតរបស់នាង ។

នៅពេលរសៀល ចៅក្រមបានអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីទីបី ឈ្មោះ រ៉ូប៊ើត ហាមីល មកពីប្រទេសញូវហ្សឺលែន មកធ្វើសក្ខីកម្ម ។ បងប្រុសរបស់ រ៉ូប៊ើត ហាមីល ឈ្មោះ ឃើរី ហាមីល ត្រូវខ្មែរក្រហមចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរស-២១ក្នុងពេលដែលគាត់កំពុងធ្វើដំណើរតាមសមុទ្រនៅតំបន់អាស៊ីអាគ្នេយ៍ ។ គាត់បានរៀបរាប់ពីការឈឺចាប់ដែលគ្រួសារគាត់ទាំងមូលត្រូវទទួលរង ។ ប្អូនប្រុសរបស់ ឃើរី ឈ្មោះ ចន បានលោតសម្លាប់ខ្លួនពីប្រាំងថ្មនៅពេលដែលដឹងថាប្អូនប្រុសរបស់គាត់ត្រូវគេសម្លាប់ ។ បន្ទាប់ពីដើមបណ្តឹងនីមួយៗបានឡើងធ្វើសក្ខីកម្ម ឌុច បានឡើងធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន ។ ឌុច បានទទួលស្គាល់ដើមបណ្តឹងទាំងបីរូប និងបានបង្ហាញពីភាពអាណិតអាសូរចំពោះការឈឺចាប់និងការបាត់បង់អ្នកជាទីស្រឡាញ់ដែលដើមបណ្តឹងទាំងបីរូបបានឆ្លងកាត់ ។ លើសពីនោះទៅទៀតដូចដែលគាត់បានបង្ហាញនៅសវនាការមុនៗដែរ ឌុច ទទួលយកនូវរាល់ការទទួលខុសត្រូវ ហើយយល់ព្រមទទួល

ស្គាល់រាល់ទណ្ឌកម្មដែលតុលាការសម្រេច ។

## ប្រតិកម្មអ្នកចូលរួមចំពោះសវនាការ ឌុច



ប្រជាជនខ្មែរ-មូស្លីម ឈររង់ចាំចូលរួមសវនាការកាត់ទោស ឌុច

បន្ទាប់ពីតាមដានការប្រព្រឹត្តទៅនៃអង្គសវនាការពេញមួយថ្ងៃមក ប្រតិកម្មរបស់អ្នកចូលរួមចំពោះ ឌុច មានភាពប្លែកៗពីគ្នា ។ រូន អែល អាយុ៥៣ឆ្នាំ ដែលជាហាកិមម្នាក់មកពីខេត្តកំពង់ចាម បានចូលបម្រើខ្មែរក្រហមទាំងបង្ខិតបង្ខំ ។ រូន អែល និយាយថា គាត់ចង់ឲ្យសវនាការនេះធ្វើឲ្យ ឌុច ទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋទាំងឡាយ ។ គាត់បន្ថែមថា «ជីវិតខ្ញុំគឺប្រៀបដូចជាក្អមដែលបែកហើយ ។ យើងមិនអាចផ្គុំម្ចុក្អមនេះឡើងវិញដូចដើមទេ ។ អ្វីដែលខ្ញុំចង់ឃើញបំផុតនោះគឺអ្នកដែលទទួលខុសត្រូវចំពោះជីវិតរបស់ប្រជាជនខ្មែរត្រូវតែទទួលទណ្ឌកម្ម» ។ ដូនជីម្នាក់មកពីក្រុមដូនជី ក៏មានយោបល់ស្រដៀងគ្នានេះដែរ ។ លោកយាយ អ៊ុំ ស៊ុន្នូន អាយុ៦៨ឆ្នាំ មកពីវត្តសំពៅមាស បានទទួលនូវបទពិសោធន៍ឈឺចាប់យ៉ាងខ្លាំងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គាត់បានរៀបរាប់ដោយទឹកភ្នែកពីរឿងរ៉ាវដែលសមាជិកគ្រួសាររបស់គាត់បានបាត់បង់ជីវិតទៅហើយខ្លួនគាត់ក៏ត្រូវធ្វើការទាំងថ្ងៃទាំងយប់ ។ ក៏ប៉ុន្តែការឈឺចាប់ទាំងនេះត្រូវបានរំសាយក្រោយពេលដែលគាត់បានចូលសាសនាព្រះពុទ្ធ ។ ទ្រឹស្តីក្នុងសាសនាព្រះពុទ្ធបានអប់រំមនុស្សឲ្យរក្សាចិត្តស្ងប់ស្ងាត់ហើយលះបង់នូវគំនិតសងសឹក ។ នៅពេលដែលសួរគាត់ថាតើគាត់ចង់បានអ្វីពីការកាត់ទោសនេះ លោកយាយឆ្លើយថា «ខ្ញុំចង់ឃើញ ឌុច និងមេដឹកនាំខ្មែរក្រហមដទៃទៀតសារភាពនូវឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តមកលើប្រជាជនខ្មែរដើម្បីឲ្យជនរងគ្រោះអាចរំសាយចិត្តហើយព្រលឹងរបស់អ្នកស្លាប់អាចទៅកាន់សុគតិភព» ។ លោកយាយបានបង្ហាញពីកង្វល់ថាមេដឹកនាំខ្មែរក្រហមដែលមានវ័យចំណាស់ទៅហើយនិងកំពុងតែជាប់ក្នុងឃុំបណ្តោះអាសន្នអាចនឹងស្លាប់មុនពេលដែលការពិតត្រូវបានរកឃើញ ។

ក្រោយពីទទួលទានអាហារពេលល្ងាចរួច ដំណើរទស្សនកិច្ចនេះមានបន្ថែមនូវកម្មវិធីមួយទៀតសម្រាប់អ្នកចូលរួមទាំងអស់ ។ អ្នកចម្រៀង ជាម ចាន់សុវណ្ណារី ត្រូវបានអញ្ជើញឲ្យឡើងច្រៀងចម្រៀង «ឱ!ភ្នំពេញអើយ» ។ អ្នកចូលរួមទាំងអស់បានប្រើប្រាស់ឱកាសនេះដើម្បីប្រមូលផ្តុំគ្នាចែករំលែកគំនិតយោបល់អំពីការកាត់ទោសខ្មែរក្រហម ។ និស្សិតជនជាតិចាមម្នាក់មកពីខេត្តកំពតមានសេចក្តីក្លាហានឡើងបញ្ចេញយោបល់ដំបូងគេ ។ នាងចាប់ផ្តើមនិយាយដោយសេចក្តីសប្បាយរីករាយយ៉ាងខ្លាំងក្នុងការចូលរួមកម្មវិធីនេះ ។ ទោះបីជានាងកើតក្រោយរបបខ្មែរក្រហមក៏ដោយក៏នាងមានការអាណិតអាសូរយ៉ាងខ្លាំងចំពោះជនរងគ្រោះដែលបានឆ្លងកាត់ការឈឺចាប់និងទុក្ខវេទនាទាំងអស់នេះដែរ ។ ទោះជាយ៉ាងនេះក៏ដោយ នៅពេលដែលនាងបានចូលរួមសង្កេតនៅក្នុងសវនាការហើយឃើញ ឌុច នៅថ្ងៃនេះ នាងមិនអាចចែកឲ្យដាច់ថាតើគួរតែបន្ទោសគាត់ ចំពោះអ្វីដែលបានកើតឡើងនៅមន្ទីរស-២១ឬក៏អភ័យទោសឲ្យគាត់ចំពោះការទទួលស្គាល់កំហុសរបស់គាត់ ។ ហា ដីម ដែលជាជនជាតិចាមមូស្លីមមកពីខេត្តកំពតនិងជាជនរងគ្រោះម្នាក់បានឆ្លើយតបយ៉ាងមុតមាំថា ឌុច ត្រូវតែទទួលខុសត្រូវនូវរាល់



ប្រជាជនខ្មែរ-មូស្លីម ឈររង់ចាំចូលរួមសវនាការកាត់ទោស ឌុច

ទង្វើដែលគាត់បានប្រព្រឹត្តនិងយល់ព្រមចំពោះទណ្ឌកម្មទាំងអស់ ទោះជាការដាក់ទណ្ឌកម្មនោះជាទោសជាប់ឃុំមួយជីវិតក៏ដោយ ។ មកទល់សព្វថ្ងៃ ហា ជីម នៅមិនទាន់យល់ពីគោលបំណងរបស់កម្ពុជាប្រជាធិបតេយ្យថាតើរបបនេះចង់ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសសន្តិភាពឬក៏ជាថ្នុកឈាម ។ គាត់បានថ្លែងឲ្យដឹងថាគាត់នឹងមិនអាចអភ័យទោសឲ្យ ឌុច ឬក៏បក្សពួករបស់ ឌុច ទេ ហើយគាត់បានសំណូមពរទៅសាលាក្ដីសុំឲ្យដាក់ទណ្ឌកម្ម ឌុច ឲ្យស្របទៅតាមច្បាប់ ។

មុននឹងកម្មវិធីនៅថ្ងៃនោះបញ្ចប់លោក មាស ចាន់ថន ជាខ្មែរកម្ពុជាក្រោមមកខេត្តពោធិ៍សាត់បានឡើងឈរនៅមុខអ្នកចូលរួមទាំងអស់ហើយធ្វើការបកស្រាយការយល់ឃើញរបស់គាត់ ។ ដូចគ្នានឹង ហា ជីម ដែរ មាស ចាន់ថន ចង់ឲ្យតុលាការខ្មែរក្រហមជួយរកចម្លើយទៅនឹងសំណួរដែលសួរដោយមនុស្សជាច្រើនថាហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្សច្រើនម្ល៉េះ ជាពិសេសគឺការកាប់សម្លាប់ខ្មែរកម្ពុជាក្រោម ។ គាត់បានបន្ថែមទៀតថា «អ្នកដែលមានអត្តសញ្ញាណជាខ្មែរក្រោមសុទ្ធតែជាមុខសញ្ញារបស់ខ្មែរក្រហម» ។ មាស ចាន់ថន បន្ថែមថាបន្ទាប់ពីបានទស្សនារឿង «ទម្លាយភាពស្ងប់ស្ងាត់» បទពិសោធន៍ដ៏ឈឺចាប់របស់គាត់ដែលបានកប់នៅក្នុងការចងចាំរបស់គាត់ត្រូវរំឭកមកវិញជាថ្មី ។ លោក មាស ចាន់ថន បានបញ្ជាក់ថា «បទពិសោធន៍និងការឈឺចាប់ដ៏ជូរចត់របស់ខ្មែរក្រោមនឹងមិនងាយរលុបបាននោះទេ» ។ នៅពេលរៀបបញ្ចប់លោក មាស ចាន់ថន បានសំណូមពរថារឿងល្ខោននេះត្រូវគេថតចម្លងទុកជាកុនឯកសាររួចហើយផ្ញើទៅឲ្យអ្នកផ្សេងទៀតដើម្បីឲ្យការចងចាំពីរបបខ្មែរក្រហមនៅមានជីវិតជានិច្ច ។ លោក មាស ចាន់ថន សង្ឃឹមថា ការធ្វើដូច្នេះនឹងជួយជំរុញឲ្យអ្នកដែលជាជនដៃដល់មកនិយាយការពិត ហើយសារភាពពីទោសកំហុសរបស់ខ្លួននៅចំពោះមុខជនរងគ្រោះ ។


ដូនជីកំពុងមើលរូបថតអ្នកទោសនៅមន្ទីរស-២១

**ការធ្វើទស្សនកិច្ចនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង**

គោលដៅចុងក្រោយរបស់ដំណើរទស្សនកិច្ចនេះគឺការទៅទស្សនានៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ ទីតាំងដែលបន្សល់ទុកនូវរូបថតរបស់អ្នកទោសរាប់រយសន្លឹកនិងឧបករណ៍ធ្វើទារុណកម្មនេះគឺជាគ្រឿងទាក់ទាញដ៏មានឥទ្ធិពលដើម្បីរំឭកឡើងវិញនូវការចងចាំរបស់អ្នករស់រានមានជីវិត ។ ទោះបីជាមិនមែនជាលើកទីមួយសម្រាប់ពួកគាត់ក្នុងការមកទស្សនានៅទួលស្លែងនេះក៏ដោយ ក៏អ្នកចូលរួមមួយចំនួនមានការក្រៀមក្រំនិងរំជួលចិត្តខ្លាំងដែរ ។ អ្នកចូលរួមទាំងអស់មានការរន្ធត់ចិត្តចំពោះរូបថតទាំងឡាយរបស់ជនរងគ្រោះ ។ អ្នកចូលរួមជាច្រើនព្យាយាមពិនិត្យមើលរូបថតម្ដងមួយៗដើម្បីសម្គាល់ក្រែងមានរូបថតណាមួយដែលពួកគាត់ស្គាល់ ។ អ្នកស្រី សំ ស៊ីណែត អាយុ៨៦ឆ្នាំមកពីខេត្តកំពង់ធំបានបាត់បង់សមាជិកគ្រួសារទាំងអស់នៅក្នុងរបបខ្មែរក្រហមរួមទាំងជីតារបស់គាត់ដែលត្រូវខ្មែរក្រហមសម្លាប់នៅគុកទួលស្លែងផង ។ គាត់បានដាក់ពាក្យបណ្ដឹងដើម្បីក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណីនៅតុលាការខ្មែរក្រហម ។ គាត់បានធ្វើដំណើរមកភ្នំពេញជាច្រើនដង ក្រោមការអញ្ជើញរបស់មជ្ឈមណ្ឌលឯកសារដើម្បីទទួលព័ត៌មានថ្មីៗទាក់ទងនឹងតុលាការ ។ អ្នកស្រី សំ ស៊ីណែត ក៏ធ្លាប់ធ្វើដំណើរទៅសារមន្ទីរទួលស្លែងជាច្រើនលើកដែរដើម្បីរកមើលរូបថតជីតារបស់គាត់ ប៉ុន្តែការខិតខំប្រឹងប្រែងរបស់គាត់មិនដែលបានសម្រេចទាល់តែសោះរហូតដល់សព្វថ្ងៃ ។ នៅទួលស្លែង សំ ស៊ីណែត ដើរយឺតៗទៅមកៗក្នុងសាលដាក់តាំងរូបថតនៅអគារ «ខ» ដើម្បីពិនិត្យមើលរូបថត ។ ចុងក្រោយគាត់បានរក

ឃើញរូបជីតារបស់គាត់ ។ នៅបន្ទប់ជាំបូងបង្អស់នៃអគារ«ខ» សំ ស៊ីណែត បានចង្អុលទៅរូបថតរបស់បុរសវ័យកណ្តាលម្នាក់ដែលមានទឹកមុខស្លូតបូត ប៉ុន្តែភ័យខ្លាចដែលគាត់ជឿជាក់ថា រូបនោះគឺជារូបថតរបស់ជីតាគាត់ ។ ទឹកភ្នែកបានហូរពេញកែវភ្នែក អ្នកស្រី សំ ស៊ីណែត ហើយបានចាប់ផ្តើមរៀបរាប់រឿងរ៉ាវរបស់គាត់ ។

ហ៊ាច គឹម ជាអ្នកជីកដីធ្វើផ្ទះនៅមុនរបបខ្មែរក្រហម ។ អ្នកស្រី សំ ស៊ីណែត បានរស់នៅនិងចម្រើនវ័យជាមួយគាត់រហូតដល់ខ្មែរក្រហមវាយចូលក្នុងរាជធានី ។ នៅសម័យខ្មែរក្រហម សំ ស៊ីណែត និងជីតាបានរស់នៅជុំគ្នាជាមួយគ្រួសារពូមីងនិងគ្រួសារផ្ទាល់របស់គាត់ ។ ក្រោយមកមិនយូរប៉ុន្មាន ជីតានិងគ្រួសាររបស់គាត់ទាំងអស់ត្រូវខ្មែរក្រហមបញ្ជូនចេញពីភូមិលើកលែងតែ សំ ស៊ីណែត ម្នាក់ ។ សំ ស៊ីណែត មិនដែលបានទទួលដំណឹងពីគ្រួសាររបស់គាត់ម្តងទៀតទេ ។ ស៊ីណែត បានរៀបរាប់ពីពេលដែលគាត់ចាប់ផ្តើមដឹងថាជីតានិងគ្រួសាររបស់គាត់ត្រូវមកបញ្ចប់ជីវិតនៅគុកទួលស្លែង ។ គាត់និយាយថា «នៅឆ្នាំ១៩៨៩ មិត្តភក្តិរបស់ម្តាយខ្ញុំបានប្រាប់ខ្ញុំឲ្យស្វែងរកព័ត៌មានពីពួកគាត់ និងរូបថតរបស់គាត់នៅទួលស្លែង ។ កាលនោះ ខ្ញុំមិនបានយកចិត្តទុកដាក់ខ្លាំងក្នុងការស្វែងរកបងប្អូនទេ ។ ទើបតែនៅពេលនេះ ដែលខ្ញុំអាចពិនិត្យមើលយ៉ាងល្អិតល្អន់នៅគ្រប់រូបថតទាំងអស់ហើយរកឃើញគាត់នៅទីនោះ ។ ខ្ញុំនៅរកមើលរូបថតពូមីងរបស់ខ្ញុំទៀត» ។

អ្នកចូលរួមម្នាក់ទៀតមកពីខេត្តស្វាយរៀងបានរកឃើញរូបថតរបស់អ្នកជិតខាងគាត់ម្នាក់ដោយចៃដន្យនៅទីនោះ នៅពេលគាត់រកមើលក្រែងមានរូបថតសាច់ញាតិរបស់គាត់សេសសល់នៅក្នុងគុកទួលស្លែងដែរ ។ ក្នុងចំណោមរូបថតស-ខ្មៅរបស់ស្ត្រីៗសក់ខ្លីនៅក្នុងផ្ទាំងកញ្ចក់ យើងឃើញមានរូបថតរបស់ ប៉ែន ធឿន ដែលជាអ្នកជិតខាងរបស់ អ៊ុម ពិសិដ្ឋ ។ លោក អ៊ុម ពិសិដ្ឋ បានពិពណ៌នាពីអ្នកស្រី ប៉ែន ធឿន ដែលសព្វថ្ងៃប្តូរឈ្មោះជា ឆាយ ធឿន ថាជាមនុស្សស្ងប់ស្ងាត់និងចេះជួយទុក្ខធុរៈរបស់អ្នកដទៃ ។ ធឿន បានចូលបម្រើខ្មែរក្រហមកាលពីឆ្នាំ១៩៧៤ ។ គាត់រៀបការជាមួយកម្មាភិបាលខ្មែរក្រហមម្នាក់ក្រោមការរៀបចំរបស់អង្គការនៅសម័យនោះ ។ ក្រោយមកខ្មែរក្រហមបានបញ្ជូនគាត់ឲ្យទៅធ្វើការនៅមន្ទីរស-២១ ។ លោក អ៊ុម ពិសិដ្ឋ បានប្រាប់យើងថា គាត់មានចម្ងល់យ៉ាងខ្លាំងចង់ដឹងថាតើ ធឿន ធ្វើការងារអ្វីខ្លះនៅសម័យខ្មែរក្រហម ប៉ុន្តែគាត់មិនដែលប្រាប់ពីរឿងរ៉ាវលម្អិតទាក់ទងទៅនឹងការងាររបស់គាត់ទេ ។ លោក អ៊ុម ពិសិដ្ឋ បានថតរូបថតរបស់ ធឿន ហើយសន្យាថានឹងយកទៅបង្ហាញគាត់នៅពេលគាត់ត្រឡប់ទៅវិញ ។

នៅទីវាលកណ្តាលបរិវេណសារមន្ទីរទួលស្លែង ដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមបានជួបជាមួយមន្ត្រីថ្នាក់ខ្ពស់មកពីការិយាល័យអ្នកតំណាងប្រជាជនសហរដ្ឋអាមេរិក ចន ឃើរី ដែលជាអ្នកគាំទ្រសាលាក្តីខ្មែរក្រហម ។ លោក ជី ទេរិទ្ធិ ដែលជាប្រធានគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងបានណែនាំដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មកជួបមន្ត្រីទាំងនោះ ហើយពន្យល់ពីរបៀបដែលក្រុមដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតុលាការទទួលស្គាល់ក្នុងករណី ឌុច ។ នៅពេលដែលមន្ត្រីសួរថាតើដើមបណ្តឹងរដ្ឋប្បវេណីចង់បានអ្វីពីតុលាការនេះ គាត់បានឆ្លើយយ៉ាងខ្លីថា «យើងចង់ដឹងថាតើមានរឿងអ្វីខ្លះដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម» ។ នៅពេលដែលសួរពួកគាត់ថាតើពួកគាត់មានអារម្មណ៍យ៉ាងដូចម្តេចនៅពេលឃើញ ឌុច ស្ថិតនៅក្នុងសវនាការ អ្នកភូមិបានឆ្លើយថា «យើងមានអារម្មណ៍ខឹងខ្លាំងណាស់ចំពោះគាត់ ប៉ុន្តែយើងក៏មានចិត្តត្រេកអរដែរដែលតុលាការអាចនាំយកគាត់មកកាត់ទោសបាន» ។

ដំណើរទស្សនកិច្ចនេះត្រូវបានកាសែតក្នុងស្រុកនិងអន្តរជាតិមួយចំនួនសរសេរសាច់រឿងដកស្រង់ ក្នុងនោះមានកាសែតរស្មីកម្ពុជា និងកាសែតអន្តរជាតិ អាសូស៊ីអេត ប្រេស ។ ក្រុមការងារទស្សនាវដ្តី និងក្រុមកុនរបស់មជ្ឈមណ្ឌលឯកសារបានធ្វើបទសម្ភាសន៍ជាមួយអ្នកភូមិប្អូនប្រាំនាក់អំពីបទពិសោធន៍ពិតឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យនិងបានសរសេរអត្ថបទសម្រាប់ចុះផ្សាយក្នុងទស្សនាវដ្តីស្វែងរកការពិត ។ ទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ត្រូវបានចែកជូនទៅដល់អ្នកចូលរួមទាំងអស់ ។

ដំណើរទស្សនកិច្ចនេះបានរំឭកឡើងវិញនូវការចងចាំដ៏ឈឺចាប់របស់ជនរងគ្រោះ ។ ស្ត្រីជនជាតិចាម-មូស្លីមមកពីខេត្តកំពង់ឆ្នាំងបាននិយាយនៅទួលស្លែងថានៅពេលគាត់បានឃើញរូបភាព

អ្នកទោសស្លាប់នៅលើកម្រាលឥដ្ឋហាក់ដូចជាធ្វើឲ្យបទពិសោធន៍ពីអតីតកាលរបស់គាត់កាលពីរបបខ្មែរក្រហមរស់រវើកឡើងវិញ ។ មានម្តងនោះ ខ្មែរក្រហមបានបញ្ជាគាត់ឲ្យចូលទៅប្រមូលយកសាកសពទាហាននៅសមរភូមិមុខ ។ គាត់មានការភ័យខ្លាច និងក្រៀមក្រំយ៉ាងខ្លាំង ។ ទោះជាយ៉ាងនេះក៏ដោយ អារម្មណ៍កំហឹងឈឺចាប់របស់អ្នកចូលរួមក្នុងកម្មវិធីត្រូវបានរំសាយនៅពេលដែលគាត់បានឃើញ ឌុច នៅក្នុងសវនាការ ។ ការដែល ឌុច ទទួលស្គាល់សាច់ញាតិរបស់ជនរងគ្រោះនៅមន្ទីរស-២១ នៅសវនាការថ្ងៃនោះបានជួយ បន្ធូរអារម្មណ៍និងផ្លូវចិត្តរបស់អ្នកចូលរួមមួយចំនួន ។ អ្នកស្រី ចាន់ ភាព និង ឡុង ម៉ារី មកពីខេត្តកណ្តាលបានបញ្ជាក់ពីភាពអាណិតអាសូរយ៉ាងជ្រាលជ្រៅរបស់គាត់ចំពោះជនរងគ្រោះនិងដើមបណ្តឹងរដ្ឋប្បវេណីដែលបានឡើងធ្វើសក្ខីកម្មនៅថ្ងៃនោះ ។ អ្នកស្រី ក៏បានធ្វើការកត់សម្គាល់ដែរថា ឌុច បានទទួលស្គាល់នូវកំហុសហើយ ។ ទស្សនៈបែបនេះបែរជាមិនបានទទួលការយល់ស្របពីអ្នកចូលរួមក្នុងកម្មវិធីដទៃទៀត ជាពិសេសអ្នកចូលរួមដែលមានសាច់ញាតិបងប្អូនស្លាប់នៅគុកទួលស្លែង ។ ជនរងគ្រោះទាំងនោះមានការពិបាកក្នុងការអភ័យឲ្យដល់ ឌុច ។

ដំណើរទស្សនកិច្ចនេះបានអប់រំអ្នកចូលរួមទាំងអស់ឲ្យយល់ដឹងពីដំណើរការរបស់សាលាក្តីខ្មែរក្រហមនិងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលពួកគាត់នឹងធ្វើការចែករំលែកព័ត៌មានទាំងអស់នេះទៅដល់ប្រជាជននៅតាមភូមិឃុំនិងក្មេងៗជំនាន់ក្រោយទៀត ។ ជាពិសេសកម្មវិធីនេះនឹងលើកទឹកចិត្តដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហមទាំងអស់ ជាពិសេសក្រុមជនជាតិភាគតិចដែលមានសំឡេងតិចតួចតែបានរងគ្រោះធ្ងន់ធ្ងរមានឱកាសនិយាយពិភាក្សាពីបទពិសោធន៍ផ្ទាល់ខ្លួននិងសម្តែងមតិទាក់ទងនឹងសាលាក្តីខ្មែរក្រហម ។ មកទល់នឹងពេលនេះមិនទាន់មានជនសង្ស័យណាម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍នៅឡើយទេ ។ រឿងរ៉ាវរបស់ក្រុមជនជាតិភាគតិចដូចជាចាម-មូស្លីម និងខ្មែរកម្ពុជាក្រោមមានសារសំខាន់ចំពោះព្រះរាជអាជ្ញាប្រសិនបើមានការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ។

## ឧបសគ្គ

ដំណើរទស្សនកិច្ចទ្រង់ទ្រាយធំនេះបានពើបប្រទះនូវឧបសគ្គមួយចំនួន ។ បញ្ហាទីមួយពាក់ព័ន្ធទៅនឹងការចែកបាយជូនអ្នកភូមិ ។ អ្នកភូមិមួយចំនួនរអ៊ូរទាំចំពោះបាយទឹកនៅថ្ងៃដំបូងនិងថ្ងៃទីពីរដែលមកយឺត ។ បន្ថែមពីលើនោះទៅទៀត អ្នកភូមិខ្លះមិនសូវជាស៊ាំជាមួយនឹងអាហារកញ្ចប់ដែលជាមូលហេតុធ្វើឲ្យគាត់ឈឺ ។ បុគ្គលិកនិងអ្នកស្ម័គ្រចិត្តទាំងអស់ព្យាយាមកាត់បន្ថយបញ្ហាឈឺថ្កាត់ដោយជួយកំដរពួកគាត់ទាំងនៅលើរថយន្តក្រុងនិងនៅពេលត្រឡប់មកវិញ ។ យើងបានផ្តល់ជូនថ្នាំឈឺក្បាលខ្លះទៅឲ្យអ្នកដែលមិនស្រួលខ្លួន ។ បញ្ហាទីពីរគឺការដឹកជញ្ជូន ។ អ្នកចូលរួមទាំងអស់មិនត្រូវបានចង្អុលបង្ហាញឲ្យជិះលើរថយន្តក្រុងណាមួយឲ្យបានច្បាស់លាស់ទេធ្វើឲ្យមានការច្របូកច្របល់នៅពេលឡើងជិះលើរថយន្តក្រុង ។ បញ្ហាទីបី គឺការប៉ាន់ប្រមាណខុសតម្លៃខុសក្នុងការធ្វើដំណើររបស់ខេត្តមួយចំនួន ។ បញ្ហានេះធ្វើឲ្យអ្នកដែលធ្វើដំណើរមកពីតំបន់ឆ្ងាយៗមានការខកចិត្ត ដោយសារតែថវិកាដែលបានផ្តល់ជូនមិនគ្រប់គ្រាន់ក្នុងការចំណាយធ្វើដំណើរ ។ ឧបសគ្គចុងក្រោយសម្រាប់ដំណើរទស្សនកិច្ចនេះគឺថាអ្នកចូលរួមដែលជាជនជាតិចាម-មូស្លីមយល់ថា កម្មវិធីសម្រាប់ដំណើរទស្សនកិច្ចនេះមានលក្ខណៈចង្អៀតខ្លាំង ។ អ្នកចូលរួមដែលជាចាម-មូស្លីម ស្នើមកថានៅទស្សនកិច្ចលើកក្រោយទៀតសូមឲ្យទុកពេលវេលាខ្លះឲ្យជនជាតិចាម-មូស្លីមធ្វើការថ្វាយបង្គំទៅតាមតម្រូវការរបស់សាសនាផង ។ នៅក្នុងដំណើរទស្សនកិច្ចទ្រង់ទ្រាយធំលើកក្រោយៗទៀត យើងនឹងធ្វើឲ្យប្រាកដថាឧបសគ្គទាំងនេះនឹងត្រូវបានលើកយកមកដោះស្រាយ ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារ និងអ្នកស្ម័គ្រចិត្តទាំងអស់ត្រូវតែឆ្លើយតបភ្លាមៗទៅនឹងស្ថានភាពជាក់ស្តែង ហើយត្រូវចេះទំនាក់ទំនងគ្នាទៅវិញទៅមកដើម្បីកាត់បន្ថយឧបសគ្គទាំងអស់នេះ ។ ទោះបីជាយ៉ាងនេះក៏ដោយ ដំណើរទស្សនកិច្ចនេះប្រព្រឹត្តទៅយ៉ាងរលូនដោយមានមតិកែលំអប្រកបដោយអត្ថប្រយោជន៍ ព្រមទាំងមានការចូលរួមយ៉ាងល្អប្រសើរពីអ្នកចូលរួមទាំងអស់ ។ ទោះជាកម្មវិធីនៅថ្ងៃទីមួយមានភាពរវល់ខ្លាំងបន្តិចក៏ដោយ ក៏សកម្មភាពនៅថ្ងៃនោះប្រព្រឹត្តទៅតាមកម្មវិធីនិងទទួលការចាប់អារម្មណ៍ខ្លាំងពីអ្នកចូលរួមកម្មវិធីដែរ ។ ជាពិសេសជាងនោះទៅទៀតគឺការសម្តែងល្ខោនដែលទទួលការគាំទ្រយ៉ាងច្រើនកុះករពីអ្នកចូលរួមក្នុងកម្មវិធី ។

**ស៊ុំ សាវីណា**

# ការមិនយកចិត្តទុកដាក់ទៅលើការស៊ើបអង្កេតក្នុងអំឡុងពេលសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖ "ខ្សែវីដេអូមន្ទីរ ស-២១" ឆ្នាំ១៩៧៩ និង នង ចាន់ផល ក្មេងដែលនៅរស់

ខ្សែវីដេអូខ្មៅសបង្ហាញពីមន្ទីរឃុំឃាំងរបស់ខ្មែរក្រហម ដែលមានលេខកូដ «ស-២១» នេះជាមន្ទីរឃុំឃាំងដែលប្រជាជនកម្ពុជាប្រមាណ១៤,០០០នាក់ត្រូវបានសម្លាប់និងធ្វើទារុណកម្ម ។ «ខ្សែវីដេអូមន្ទីរស-២១» បានបង្ហាញរបងមុខនិងក្រោយរបងដែលមានលួសបន្លាជាច្រើនខ្សែព័ទ្ធនៅពីលើខ្ទុមឈើមួយដែលមិនឃើញមាននៅពេលបច្ចុប្បន្ន អគារ ក ខ និង គ ដែលមើលទៅឃើញដើមដូងនិងវាលកប់ខ្មោចនិងកន្លែងលក់សំបុត្រចូលទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងបច្ចុប្បន្ន ។ មន្ទីរស-២១ មានរូបរាងដូចកាលពីដើមឆ្នាំ១៩៧៩ដែរ ។ ទោះជាយ៉ាងនេះក៏ដោយ ខ្សែវីដេអូមន្ទីរស-២១ដែលថតដោយ ហូ វ៉ាន់តៃ ដែលជាអ្នកថតរូបជនជាតិវៀតណាម បានបង្ហាញពីទិដ្ឋភាពដែលមានសាកសពស្អុយរលួយនៅជាប់ខ្នោះលើគ្រែដែកនិងទាហានវៀតណាមពីរនាក់ជាមួយនឹងទារកពីរនាក់និងក្មេងពីរនាក់ដែលត្រូវបានរកឃើញនៅមន្ទីរស-២១ ។ ក្រៅពីខ្សែវីដេអូមន្ទីរស-២១ នៅមានខ្សែវីដេអូពីររឿងទៀតដែលមានរូបថតទាំងអស់៧០រូប ។ រូបថតទាំងនោះបានបង្ហាញពីទារកផ្សេងទៀតដែលធ្វើឲ្យចំនួនក្មេងនិងកុមារកំព្រាដែលនៅរស់ទាំងអស់មានចំនួន៥នាក់ ។ ទារកម្នាក់បានស្លាប់ភ្លាមៗដោយសារអស់កម្លាំងបន្ទាប់វៀតណាមបានរកឃើញក្មេងៗទាំងនោះ ខណៈពេលដែលមានក្មេងកំព្រាពីរនាក់ផ្សេងទៀតដែលមិនដឹងជាមកពីកន្លែងណា ។ ទោះជាយ៉ាងនេះក្តី ក្មេងធំៗពីរនាក់ដែលមាននៅក្នុងខ្សែវីដេអូនោះនៅមានជីវិតនៅឡើយបន្ទាប់ពី៣០ឆ្នាំកន្លងមក ហើយអ្នកទាំងពីរបានលេចមុខសាជាថ្មី ។ នង ចាន់ផល ដែលជាក្មេងម្នាក់ក្នុងចំណោមនោះបានផ្តល់សក្ខីកម្មនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅពេលសវនាការ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលជាប្រធានមន្ទីរស-២១ ។ ខ្សែវីដេអូមន្ទីរស-២១ ដែលអង្គជំនុំជម្រះទទួលបាន នៅពេលថ្មីៗនេះមិនត្រូវបានចាក់បង្ហាញទាំងស្រុងនៅពេលសវនាការទេដោយសារតែមានការព្រួយបារម្ភទៅលើការជាប់ពាក់ព័ន្ធនិងយថាភាពរបស់ភាពយន្តនោះ ។ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានសម្រេចមិនទទួលស្គាល់ខ្សែវីដេអូមន្ទីរស-២១ ។

**ខ្សែវីដេអូមន្ទីរស-២១ ឆ្នាំ១៩៧៩ ដែលជា «ខ្សែភាពយន្តដកស្រង់របស់វៀតណាម»**

ពីឆ្នាំ១៩៧៨-១៩៨៨ ហូ វ៉ាន់តៃ ជាអ្នកគ្រប់គ្រងការិយាល័យខ្សែភាពយន្តនៅស្ថានីយទូរទស្សន៍ក្រុងហូជីមិញ ប្រទេសវៀតណាម ។ នៅឆ្នាំ១៩៧៩ ហូ វ៉ាន់តៃ បានមកដល់



កម្ពុជាដើម្បីចូលរួមជាមួយនឹងចលនារបស់ទាហានវៀតណាមនិងដើម្បីបង្កើតខ្សែភាពយន្តឯកសារពីរឿងដែលបានដកស្រង់ជាបន្តបន្ទាប់ ។ នៅខែកុម្ភៈ ឆ្នាំ២០០៩ ឡុង ដានី បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបសម្ភាសន៍លោក ហូ វ៉ាន់តៃ នៅទីក្រុងហូជីមិញ ។ យោងទៅតាមបទសម្ភាសន៍នេះបានឲ្យដឹងថានៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ ហូ វ៉ាន់តៃ បានរកឃើញមន្ទីរស-២១ ខណៈពេលដែលគាត់នៅក្នុងឡានជាមួយអ្នកបើកឡាននិងជំនួយការរបស់គាត់ ។ ក្លិនដ៏ស្អុយអសោចដែលភាយចេញពីមន្ទីរស-២១ បានធ្វើឲ្យអ្នកទាំងនោះទៅដល់សាលារៀនមួយ ។ បន្ទាប់ពីបានរកឃើញកុមារកំព្រានិងក្មេងៗនៅកន្លែងមួយខាងក្រោយមន្ទីរស-២១ ហូ វ៉ាន់តៃ បានប្រាប់អ្នកបើកឡានឲ្យទូរស័ព្ទប្រាប់ទាហានវៀតណាម ពីព្រោះក្មេងៗទាំងនោះមានសភាពអស់កម្លាំងខ្លាំងណាស់ ។ ទាហានវៀតណាមបានយកក្មេងៗទាំងនោះចេញពីមន្ទីរស-២១ ហើយបានឲ្យទាហាននារីមើលថែទាំងអ្នកទាំងនោះ ។ ទាហានកម្ពុជាក៏មានវត្តមាននៅមន្ទីរ ស-២១ នៅដើមខែមករាឆ្នាំ១៩៧៩ដែរ ដាក់ស្ដែងគឺ លោក ខាង សារិន ។ បន្ទាប់មក ហូ វ៉ាន់តៃ បានបន្តថតខ្សែភាពយន្តនៅមន្ទីរស-២១ ដោយចាប់ផ្ដើមពីសាកសពក្នុងបន្ទប់តូចនៅជាន់ក្រោមទៅជាន់ខាងលើដែលមានគ្រែ និងបន្ទប់ធំ ។ ហូ វ៉ាន់តៃ បានរំឭកថានៅក្នុងបន្ទប់មួយនៅជាន់លើមានមាន់ធាត់ៗកំពុងចឹកស៊ីសាកសពដែលស្លាប់នៅលើគ្រែ ។

ខ្សែភាពយន្តដកស្រង់នៅមន្ទីរស-២១ និងរូបថតត្រូវបានរក្សាទុកនៅស្ថានីយទូរទស្សន៍នៅទីក្រុងហូជីមិញ ហើយច្បាប់ចម្លងត្រូវបានរក្សានៅបណ្ណសារដ្ឋានរដ្ឋរបស់វៀតណាម ។ ហូ វ៉ាន់តៃ បានបន្ថែមទៀតថានៅឆ្នាំ១៩៧៩ យោធាវៀតណាមបានយកខ្សែភាពយន្តកម្ពុជាប្រជាធិបតេយ្យជាច្រើនពីកម្ពុជាទៅវៀតណាម ។

នៅដើមទសវត្សរ៍៩០ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានដឹងពីខ្សែភាពយន្តដកស្រង់ដែលថតនៅមន្ទីរស-២១ភ្លាមៗបន្ទាប់ពីខ្មែរក្រហមបានចាកចេញពីមន្ទីរឃុំឃាំងនោះ ។ នៅដើមឆ្នាំ២០០០ នីក ឌុនលប់ អ្នកសារព័ត៌មានបានប្រគល់រូបភាពសាកសពមួយចំនួននៅក្នុងមន្ទីរស-២១ ទៅឲ្យលោក ឆាំង យុ ។ ឌុនលប់ ក៏បានប្រាប់ លោក ឆាំង យុ ថារដ្ឋាភិបាលវៀតណាមមានខ្សែវីដេអូដែលថតនៅមន្ទីរស-២១ កាលពីដើមខែមករា ឆ្នាំ១៩៧៩ ។ លោក ឆាំង យុ បានស៊ើបសួរអំពីខ្សែភាពយន្តនោះ ហើយគាត់ត្រូវបានគេប្រាប់ថាកម្ពុជាមានច្បាប់ចម្លងខ្សែភាពយន្តនោះដែលរក្សានៅបណ្ណសារដ្ឋានបក្សរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាដែលមានទីតាំងនៅភ្នំពេញ ។ ប៉ុន្តែច្បាប់ចម្លងនៃខ្សែភាពយន្តនោះមិនដែលត្រូវបានរកឃើញឡើយ ។ បណ្ណសារដ្ឋានសាធារណរដ្ឋប្រជាមានិតកម្ពុជាបានប្រាប់លោក ឆាំង យុ ថា ខ្សែវីដេអូនោះបានបាត់ក្នុងអំឡុងពេលបោះឆ្នោតដែលរៀបចំឡើងដោយអាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ។

បន្ទាប់ពីអង្គជំនុំជម្រះចាប់ដំណើរការនៅឆ្នាំ២០០៦ ការិយាល័យសហព្រះរាជអាជ្ញាបានចាប់ផ្ដើមការស៊ើបអង្កេតជនសង្ស័យនៅឆ្នាំ២០០៦ ដល់ខែសីហាឆ្នាំ២០០៧ ។ ក្នុងអំឡុងពេលស៊ើបអង្កេតនៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រគល់ច្បាប់ចម្លងខ្សែភាពយន្តដែលមានពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យដែលក្នុងនោះរួមមានខ្សែភាពយន្ត១៩៥រឿង និង២៣១ឌីវីឌី ទៅឲ្យការិយាល័យសហព្រះរាជអាជ្ញា ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ដោយមិនដឹងពីមូលហេតុសហព្រះរាជអាជ្ញាកម្ពុជា អ្នកស្រី ជា លាង បានទាក់ទងជាមួយលោក ឆាំង យុ ជំនួសលោក ក្រេក អេតឆេសាន់ ដើម្បីស្នើសុំខ្សែភាពយន្តទាំង៥នោះ ។ មេធាវីការពារក្ដីក៏ស្នើសុំភាពយន្តនោះពីលោក ឆាំង យុ ដែរ ។ លោក ឆាំង យុ ក៏បានស្នើឲ្យលោកអេតឆេសាន់ ចែករំលែកខ្សែភាពយន្តនោះទៅអ្នកស្រី ជា លាង និងមេធាវីការពារក្ដី ។ ក្នុងអំឡុងពេលស្រាវជ្រាវខ្សែភាពយន្តទាំង៥នោះ ការិយាល័យសហព្រះរាជអាជ្ញាបានបាត់ខ្សែភាពយន្តចំនួន២៧ ក្នុងចំណោមខ្សែភាពយន្ត១៩៥ ។ ពីរសប្ដាហ៍ក្រោយមកនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៨ ខ្សែភាពយន្តត្រូវបានរៀបចំទុកដាក់នៅការិយាល័យសហព្រះរាជអាជ្ញា នៅខែមីនា ឆ្នាំ២០០៨ ការិយាល័យសហចៅក្រមស៊ើបអង្កេតអាចរកមើលខ្សែភាពយន្តនៅការិយាល័យសហព្រះរាជអាជ្ញាបាន ហើយខ្សែភាពយន្តបន្ទាប់ត្រូវបានដាក់ទៅក្នុងសំណុំរឿងក្នុងអំឡុងពេលស៊ើបអង្កេត ។

ក្នុងអំឡុងពេលស៊ើបអង្កេត លោក ឆាំង យុ និងការិយាល័យសហព្រះរាជអាជ្ញាបានជួបប្រជុំជាមួយគ្នារៀងរាល់សប្ដាហ៍នៅ

ថ្ងៃព្រហស្បតិ៍ ។ នៅពេលប្រជុំមួយនៅឆ្នាំ២០០៧ លោក ឆាំង យុ បានប្រាប់លោក វីលៀម ស្មីត ព្រះរាជអាជ្ញារងអំពីខ្សែភាពយន្តខ្មែរក្រហមនៅប្រទេសបារាំង ខ្សែភាពយន្តខ្មែរក្រហមគឺជាកម្មសិទ្ធិរបស់រដ្ឋាភិបាលវៀតណាម រីឯឯកសារជាក្រដាសជាកម្មសិទ្ធិរបស់បណ្ណសារដ្ឋានសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ លោក ឆាំង យុ បានប្រគល់អាសយដ្ឋានបណ្ណសារដ្ឋានរដ្ឋនៅប្រទេសវៀតណាមនិងបណ្ណសារដ្ឋានសាធារណរដ្ឋប្រជាមានិតកម្ពុជានៅភ្នំពេញទៅឲ្យការិយាល័យសហព្រះរាជអាជ្ញា ។ បន្ទាប់មក លោក វីលៀម ស្មីត បានប្រគល់អាសយដ្ឋាន និងព័ត៌មានអំពីខ្សែភាពវីដេអូមន្ទីរស-២១នោះទៅឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ។ យោងទៅតាមការសន្ទនារវាងលោក ឆាំង យុ និង ក្រេក អេតឆេសាន់ អ្នកស៊ើបអង្កេតរបស់ការិយាល័យសហព្រះរាជអាជ្ញាបានឲ្យដឹងថា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើការទាក់ទងជាមួយបណ្ណសារដ្ឋានរដ្ឋវៀតណាម ប៉ុន្តែមិនមានការឆ្លើយតប នេះបង្ហាញឲ្យឃើញថាវៀតណាមមិនចង់ធ្វើសហការជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតទេ ។ ទោះជាយ៉ាងណាក៏ដោយ ការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតគឺជាការសម្ងាត់ ដូច្នេះព័ត៌មានទាំងអស់ដែលទាក់ទងនឹងកិច្ចខំប្រឹងប្រែងដើម្បីទទួលបានខ្សែវីដេអូនេះមិនត្រូវបានគេដឹងជាសាធារណៈទេ ។ នៅពេលដែលមានគេសួរ លោក ក្រេក អេតឆេសាន់ ដើម្បីបញ្ជាក់ពីអ្វីដែលលោកបាននិយាយជាមួយលោក ឆាំង យុ អំពីថាតើការិយាល័យសហចៅក្រមស៊ើបអង្កេតបានទាក់ទងជាមួយនឹងបណ្ណសារដ្ឋានសាធារណរដ្ឋប្រជាមានិតកម្ពុជានិងបណ្ណសារដ្ឋានវៀតណាមដែរឬក៏អត់ គាត់មិនអាចធ្វើការបញ្ជាក់ឬបដិសេធថាការសន្ទនានោះមិនបានកើតមានទេ ពីព្រោះការស៊ើបអង្កេតត្រូវធ្វើឡើងជាសម្ងាត់ ។

ដោយដឹងថាខ្សែវីដេអូមាននៅបណ្ណសារដ្ឋានរដ្ឋវៀតណាម លោក ឆាំង យុ បានបង្ហាញការចាប់អារម្មណ៍ចំពោះរដ្ឋាភិបាលវៀតណាមទៅលើខ្សែវីដេអូមន្ទីរស-២១ ។ នៅពេលដែលលោក ឡុង ដានី ប្រធានគម្រោងការជំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើដំណើរទៅវៀតណាមជាមួយលោក អេង កុកថាយ នាយកស្រាវជ្រាវនិងនាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅខែវិច្ឆិកា ឆ្នាំ២០០៨ លោក ឆាំង យុ បានឲ្យអ្នកទាំងពីរធ្វើការស៊ើបសួររដ្ឋាភិបាលវៀតណាមអំពីខ្សែវីដេអូមន្ទីរស-២១ ។ អ្នកទាំងពីរបានរកឃើញព័ត៌មានទាក់ទងនឹងវីដេអូនោះ ហើយចាប់ផ្តើមធ្វើការចរចាជាមួយបណ្ណសារដ្ឋានរដ្ឋវៀតណាមអំពីការប្រគល់ខ្សែភាពយន្តច្បាប់ដើមមកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅពេលជាមួយគ្នានោះ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ អង្គជំនុំជម្រះបានចេញដីកាឲ្យសហព្រះរាជអាជ្ញាដាក់បញ្ជីរូបភាពដែលជាវត្ថុតាងដាក់ស្តែងនិងដាក់បញ្ជីឯកសារថ្មីដែលគេចង់ដាក់ទៅក្នុងសំណុំរឿង ។ ថ្ងៃចុងក្រោយដែលសហព្រះរាជអាជ្ញាអាចដាក់បញ្ជីឈ្មោះសាក្សី និងឯកសារបន្ថែមគឺថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ ដែលជាបុណ្យណូអែល ។ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់បញ្ជីភស្តុតាងចុងក្រោយដែលក្នុងនោះសហព្រះរាជអាជ្ញា បានអះអាងថាគេមិនមានបំណងដាក់រូបភាពដាក់ស្តែងដើម្បីយកមកបង្ហាញទេ ប៉ុន្តែគេមានបំណងស្នើឲ្យមានភស្តុតាងដែលជាឯកសារស្មុគ្រស្មាញ... 

ដែលជាឯកសារស្តេនរួមមានរូបថតនិងវីដេអូឲ្យមាននៅក្នុងសំណុំរឿង ។ អ្នកទាំងនោះមិនបាននិយាយអំពីវីដេអូមន្ទីរស-២១ដើមភាពយន្តខ្មែរក្រហមនៅប្រទេសបារាំងនិងភាពយន្តផ្សេងទៀតនៅវៀតណាមឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកស៊ើបអង្កេតនៅការិយាល័យសហចៅក្រមស៊ើបអង្កេតដឹងថាទិដ្ឋភាពខ្លះនៅក្នុងភាពយន្តឯកសាររបស់ ចេម ជីវ៉ាន់ ដែលមានចំណងជើងថា «កម្ពុជា» ដែលត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងហើយនោះគឺដកស្រង់ចេញពីខ្សែវីដេអូមន្ទីរស-២១ដែលជារបស់រដ្ឋាភិបាលវៀតណាម ។

នៅពេលជាមួយគ្នានេះ កិច្ចចរចារវាងមជ្ឈមណ្ឌលឯកសារកម្ពុជានិងវៀតណាមហាក់ដូចជាមានផ្លែផ្កា ហើយនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ លោក ឆាំង យុ បានធ្វើដំណើរទៅទីក្រុងហូជីមិញដើម្បីយកច្បាប់ចម្លងវីដេអូមន្ទីរស-២១ដែលប្រទេសវៀតណាមផ្តល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅថ្ងៃដដែល មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រាប់ទៅសារព័ត៌មានអន្តរជាតិដែលរួមមាន ក្យូដូ និងវិទ្យុអាស៊ីសេរីថា ខ្លួនបានទទួលខ្សែភាពយន្តដកស្រង់ និងរូបថតរាប់ពាន់សន្លឹកពីរដ្ឋាភិបាលវៀតណាម ។ បណ្ណសារដ្ឋានរដ្ឋវៀតណាមបានប្រគល់ភាពយន្តដកស្រង់រយៈ

ពេល៤៧០នាទីដែលថតក្នុងរវាងឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៨៤ មកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលក្នុងនោះរួមមានខ្សែវីដេអូមន្ទីរស-២១ដែរ ។ នៅពេលដែលលោក ឆាំង យុ បានលើកឡើងពីសារសំខាន់នៃខ្សែភាពយន្តដកស្រង់ជាសាធារណៈ «ភាពយន្តឯកសារខ្លះដែលអាចយកមកធ្វើជាភស្តុតាងនៅអង្គជំនុំជម្រះមិនទាន់ត្រូវបានយកមកប្រើប្រាស់ ឬវិភាគនៅឡើយទេ ។ ក្នុងអំឡុងពេលនៅវៀតណាម លោក ឆាំង យុ ក៏បានទាក់ទងជានឹងមួយអ្នកផលិតវីដេអូមន្ទីរស-២១ ហូ វ៉ាន់តៃ ដែរ នាំឲ្យមានការធ្វើបទសម្ភាសន៍ដែលធ្វើឡើងដោយ ឡុង ដានី នៅខែមករា ឆ្នាំ២០០៩ នៅទីក្រុងហូជីមិញ ។

ដោយដឹងថាមជ្ឈមណ្ឌលឯកសារកម្ពុជាមានវីដេអូមន្ទីរស-២១ នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចាត់ឲ្យអ្នកស៊ើបអង្កេតរបស់ខ្លួន ក្រេក អេតឆេសាន់ មកពិនិត្យមើលខ្សែភាពយន្តដកស្រង់ និងស្វែងយល់ពីតម្លៃរបស់វា ។ នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០០៩ អ្នកស៊ើបអង្កេត អេតឆេសាន់ និងជំនួយការព្រះរាជអាជ្ញាជាន់ខ្ពស់ លោក តាន់ សេណារ៉ុង ពិនិត្យមើលខ្សែភាពយន្តដកស្រង់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានសម្រេចថាខ្សែវីដេអូមានទំនាក់ទំនងនឹងសំណុំរឿង០០១ និង០០២ ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ២០០៩ ការិយាល័យសហព្រះរាជអាជ្ញាបានស្នើសុំខ្សែវីដេអូមន្ទីរស-២១ ។ លោក ឆាំង យុ បានចម្លងច្បាប់ចម្លងមួយឲ្យទៅការិយាល័យសហព្រះរាជអាជ្ញានៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ ។ បន្ទាប់មកការិយាល័យសហចៅក្រមស៊ើបអង្កេតក៏បានស្នើសុំភាពយន្តដកស្រង់ថ្មីមួយទៀត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រាប់ទៅការិយាល័យសហចៅក្រមស៊ើបអង្កេតថាខ្លួនបានចម្លងគ្រប់ខ្សែភាពយន្តអស់ហើយ ដូច្នេះវាគួរតែអាចស្វែងរកបាននៅការិយាល័យសហព្រះរាជអាជ្ញា ។

នៅពេលដាក់សារណានៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានស្នើឲ្យអង្គជំនុំជម្រះទទួលយកខ្សែវីដេអូមន្ទីរស-២១ធ្វើជាភស្តុតាង ។ ការិយាល័យសហព្រះរាជអាជ្ញាលើកឡើងពីវិធានផ្ទៃក្នុង៣៩របស់អង្គជនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថាអង្គជំនុំជម្រះមានលទ្ធភាពពន្យារពេលថ្ងៃផុតកំណត់ដាក់ឯកសារឬដាក់សារណាយឺតពេល ។ ការិយាល័យសហព្រះរាជអាជ្ញាក៏បានលើកឡើងពីវិធាន៩២ នៃវិធានផ្ទៃក្នុងដែលកំណត់ថាគ្រប់ភាគីអាចដាក់សារណាជាលាយលក្ខណ៍អក្សរនៅគ្រប់ពេលមុនពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោល «ពីភស្តុតាងដែលអាចបញ្ជាក់ពីការពិត» ។ សហព្រះរាជអាជ្ញារងអន្តរជាតិ វីលៀម ស្មីត បាននិយាយថា «ដោយសារបញ្ហាភស្តុតាងនេះមិនទាន់ត្រូវបានរកឃើញរហូតដល់ថ្ងៃមានការបង្ហាញឯកសារនិងរូបភាពថ្មី ដូច្នេះអង្គជំនុំជម្រះអាចចាត់ឲ្យមានវិធានការបែបនេះនិងអនុញ្ញាតឲ្យមានការដាក់ឯកសារបន្ថែម ។ សារណានោះបានបន្ថែមទៀតថា «សហព្រះរាជអាជ្ញាមិនបានដឹងពីវិធីដើម្បីយកខ្សែវីដេអូនោះរហូតដល់បានដំណឹងថាមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលខ្សែវីដេអូនោះពីរដ្ឋាភិបាលវៀតណាម ។ បន្ទាប់ពីស្វែងយល់ពីខ្សែវីដេអូ ការិយាល័យសហព្រះរាជអាជ្ញាបានអះអាងថាខ្លួនបានខិតខំប្រឹងប្រែងយកខ្សែវីដេអូនោះមក និងពិនិត្យមើលវាដើម្បីស្វែងរកភស្តុតាងដើម្បីយកមកបង្ហាញអង្គជំនុំជម្រះ ។ ការិយាល័យសហព្រះរាជអាជ្ញាបានអះអាងថាខ្សែវីដេអូមានសារសំខាន់សម្រាប់បញ្ជាក់បន្ថែមទៅលើសក្ខីកម្មរបស់សាក្សីនិងឯកសារដែលប្រមូលបានក្នុងអំឡុងពេលស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតបង្ហាញថាកូនៗរបស់កម្មាភិបាលខ្មែរក្រហមដែលត្រូវបានយកមកឃុំជាមួយឪពុកម្តាយនៅមន្ទីរស-២១ ដើម្បីបង្ហាញពីស្ថានភាពនៅមន្ទីរស-២១ នៅខែមករា ឆ្នាំ១៩៧៩ និងដើម្បីបង្ហាញភស្តុតាងនៃអគារដែលបានបាត់បង់ ។

ក្នុងសវនាការបឋម ឌុច នៅថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៩ អង្គជំនុំជម្រះមិនបានអនុញ្ញាតឲ្យព្រះរាជអាជ្ញាដាក់បញ្ចូលវីដេអូចូលទៅក្នុងភស្តុតាងទេ ។ ទោះបីជាលោក កា សាវុត្ថ មេធាវីការពារក្តី ឌុច បានអះអាងកាលពីមុនថាខ្សែភាពយន្តដកស្រង់មិនបានបង្ហាញពីការចោទប្រកាន់ថ្មីទេ ដូច្នេះវាមិនអាចប៉ះពាល់នឹងសំណុំរឿងប្រឆាំងនឹងកូនក្តីលោកឡើយ ។ ក្នុងសវនាការបឋមលោក សាវុត្ថ បានបដិសេធសារណាដែលនឹងដាក់ខ្សែភាពយន្តដកស្រង់មកធ្វើជាភស្តុតាងដោយសំអាងលើហេតុផលមួយចំនួន ។ ទី១) មេធាវីការពារក្តីបានអះអាងថាខ្សែវីដេអូ និងសាក្សីដែលមានសក្ខានុពលថ្មីគួរតែត្រូវបានពិនិត្យដោយយកចិត្តទុកដាក់ដោយ

សហចៅក្រមស៊ើបអង្កេតដែលបានចំណាយពេលមួយឆ្នាំដើម្បីរៀបចំសំណុំរឿងនិងបញ្ចប់ការស៊ើបអង្កេតរយៈពេល១០ខែអំពីករណី ឌុច នៅខែឧសភា ឆ្នាំ២០០៨ ។ ទី២) លោក សាវុត្ថ បានអះអាងថា ខ្សែវីដេអូនោះត្រូវបានប្រគល់ឲ្យដោយវៀតណាម «វីដេអូនេះមានជាប់ពាក់ព័ន្ធនឹងនយោបាយដែលអាចបិទបាំងការពិត» ហើយហេតុផលដែលយើងមិនអាចទទួលខ្សែភាពយន្តដកស្រង់គឺថាខ្សែភាពយន្តនេះត្រូវបានបង្កើតឡើងដោយសាធារណរដ្ឋសង្គមនិយមវៀតណាម» ។ លោក សាវុត្ថ បានបន្ថែមទៀតថា អ្នកថតវីដេអូមន្ទីរស-២១ ជនជាតិវៀតណាមគួរតែត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះដើម្បីបញ្ជាក់ពីការពិត ។ ជាទីបញ្ចប់ ដោយបង្ហាញពីភាពងឿងឆ្ងល់ថាក្មេងៗដែលមាននៅក្នុងខ្សែវីដេអូមិនមែនជាក្មេងដែលនៅរស់ពីមន្ទីរស-២១ លោក សាវុត្ថ បានចោទជាសំណួរថាតើក្មេងៗអាចរួចផុតពីបញ្ជារបស់ ឌុច ឲ្យសម្លាប់មនុស្សទាំងអស់នៅមន្ទីរស-២១ នៅពេលដែលវៀតណាមចូលមកដល់ទីក្រុងដោយរបៀបណា? «ហេតុអ្វីបានជាមានតែក្មេងនៅក្នុងវីដេអូនោះ? យើងដឹងហើយថាមិនមានក្មេងនៅសល់ពីមន្ទីរស-២១ទេ ។ លោកបាននិយាយថា «ក្មេងៗទាំងនោះត្រូវបានយកទៅសម្លាប់អស់ទៅហើយ» ។ លោកបន្តទៀតថា «តើក្មេងដែលមិនមានអាហារហូបរយៈពេល៧ថ្ងៃ៧យប់អាចនៅរស់ដោយរបៀបណា»? បើក្មេងៗស្លាប់អស់ហើយ ហេតុអ្វីបានជាគេមានរូបរាងនៅក្នុងវីដេអូនោះ»?

នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ មានសេចក្តីសម្រេចឲ្យមានការដាក់ភស្តុតាងថ្មីនិងធ្វើសេចក្តីណែនាំទៅគ្រប់ភាគី ។ ដោយការិយាល័យសហព្រះរាជអាជ្ញាបានអះអាងទៅអង្គជំនុំជម្រះថា «សហព្រះរាជអាជ្ញាមិនបានដឹងពីវត្តមានរបស់ភស្តុតាងនោះមុនពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលវីដេអូនោះ» ។ អង្គជំនុំជម្រះបញ្ជាក់ទៅលើការអះអាងនេះថា «សហព្រះរាជអាជ្ញាពិតជាមិនអាចទទួលយកខ្សែភាពយន្តដកស្រង់ដែលពាក់ព័ន្ធបានទេ» ។ ជាងនេះទៅទៀត អង្គជំនុំជម្រះបានអះអាងថា «សហព្រះរាជអាជ្ញាមានឱកាសដាក់វីដេអូនោះពីព្រោះវាជាភស្តុតាងដែលមានការជាប់ពាក់ព័ន្ធ» ។ អង្គជំនុំជម្រះប្រកាសសម្រេចទទួលយកវីដេអូមន្ទីរស-២១ ដោយសារតែខ្សែវីដេអូអាចជាភស្តុតាងសម្រាប់អង្គបុរេជំនុំជម្រះ ។

ក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលដោយសហព្រះរាជអាជ្ញានៅថ្ងៃទីពីរនៃសវនាការដែលត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ព្រះរាជអាជ្ញាបានបង្ហាញវីដេអូមួយរបស់ លោក ជេមស៍ ជីរ៉េន ដែលមានចំណងជើងថា «កម្ពុជា» នៅអង្គជំនុំជម្រះ ។ វីដេអូនេះរួមមានខ្សែវីដេអូខ្លីដែលដកស្រង់ចេញពីវីដេអូមន្ទីរស-២១ ។ លោក ហ្វ្រង់ស័រ រូហ្ស មេធាវីការពារក្តីអន្តរជាតិរបស់ ឌុច បានបដិសេធការដាក់បង្ហាញវីដេអូនេះ ពីព្រោះវីដេអូមន្ទីរស-២១នៅមិនទាន់ត្រូវបានសម្រេចនៅឡើយទេ ។ អង្គជំនុំជម្រះក៏ស្នើឲ្យការិយាល័យសហព្រះរាជអាជ្ញាបញ្ជាក់ថាតើ «វីដេអូដកស្រង់នេះគឺជាវីដេអូថ្មី ឬជាវីដេអូចាស់ដែលមាននៅក្នុងសំណុំរឿង»? សហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូប៊ើត ប៉ុទី បានឆ្លើយតបដោយបញ្ជាក់ទៅអង្គជំនុំជម្រះថា «រាល់ភស្តុតាងដែលយកមកបង្ហាញនៅថ្ងៃនេះគឺមាននៅក្នុងសំណុំរឿង ។ ដូច្នេះវាអាស្រ័យទៅលើអង្គជំនុំជម្រះសម្រេចថាភស្តុតាងណាត្រូវទទួលការសម្រេចឲ្យប្រើ ហើយវាអាស្រ័យទៅលើអង្គជំនុំជម្រះដែលជាអ្នកផ្តល់ទម្ងន់ទៅឲ្យភស្តុតាង ។ ដោយមិនពេញចិត្តនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញាលោក ហ្វ្រង់ស័រ រូហ្សឆ្លើយតបថា «សហព្រះរាជអាជ្ញាបង្ហាញខ្សែភាពយន្តនេះគឺដើម្បីគោលបំណងមួយស្រដៀងនឹងអ្វីដែលពាក់ព័ន្ធនឹងការធ្វើពាក្យបណ្តឹង ។ លោក ហ្វ្រង់ស័រ រូហ្ស បន្តទៀតថា «យើងមានពេលមួយឆ្នាំកន្លះដើម្បីធ្វើការស៊ើបអង្កេតជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា» ។ ឯកសារមួយចំនួនត្រូវបានយកមកជជែកនិងពិភាក្សាក្នុងអំឡុងពេលស៊ើបអង្កេត ។ ប៉ុន្តែឯកសារមួយចំនួនមិនមែនឯកសារដែលត្រូវយកមកជជែកតទល់គ្នា» ។ លោក ហ្វ្រង់ស័រ រូហ្ស បានបញ្ចប់ដោយអះអាងថា «ប៉ុន្មានថ្ងៃមុនពេលចាប់ផ្តើមសវនាការ សហព្រះរាជអាជ្ញាបានប្រកាសថា គេបានរកឃើញឯកសារសំខាន់ខ្លះដែលចង់យកមកធ្វើការចោទប្រកាន់ ។ ឥឡូវយើងឃើញអ្វីខ្លះ? យើងដឹងថាសហព្រះរាជអាជ្ញាមានឯកសារដែលមិនអាចយកមកតទល់ក្នុងអំឡុងពេលស៊ើបអង្កេត ។ នោះគឺខ្សែភាពយន្តដូចគ្នា! វីដេអូដកស្រង់ដូចគ្នា! នេះមិនមែនជាការកាត់ក្តីដោយយុត្តិធម៌ទេ ។ អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់

ទៅលើភាពមិនយល់ស្របរបស់មេធាវីការពារក្តី ប៉ុន្តែបានសម្រេចថាការមិនយល់ស្របនេះមានលក្ខណៈមិនសមស្របទេនៅពេលនេះ ។

នៅពេលដែលសួរអំពីភាពស្រដៀងគ្នារបស់វីដេអូដែលមាននៅក្នុងសំណុំរឿងនិងវីដេអូមន្ទីរស-២១ លោក ឆាំង យុ បានបកស្រាយថាចំណែកឬផ្នែកខ្លះដែលទាក់ទងនឹងរបបខ្មែរក្រហមនៅទសវត្សរ៍៨០របស់វីដេអូស-២១ ត្រូវបានយកមកប្រើប្រាស់ដោយមិនមានការអនុញ្ញាតរបស់រដ្ឋាភិបាល ។ ហេតុដូច្នេះ ផ្នែកដកស្រង់ខ្លះដែលមានក្នុងវីដេអូដែលដាក់បញ្ចូលទៅក្នុងសំណុំរឿងស្រដៀងនឹងវីដេអូស-២១ ។ អ្នកស៊ើបអង្កេតនៃការិយាល័យសហព្រះរាជអាជ្ញាក៏បានដឹងពីរឿងនេះដែរ ។

នៅពេលដែលកុមារដែលនៅរស់ នង ចាន់ផល បានផ្តល់សក្ខីកម្មនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានស្នើឲ្យមានការបង្ហាញវីដេអូ មន្ទីរស-២១ ។ មេធាវីការពារក្តីបានប្រឆាំងនឹងការពិតរបស់វីដេអូ ។ នៅថ្ងៃនោះ អង្គជំនុំជម្រះបានអះអាងថា អង្គជំនុំជម្រះមិនទាន់សម្រេចឲ្យបង្ហាញខ្សែភាពយន្តដកស្រង់ទាំងអស់នៅឡើយទេ ។ ទោះបីជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាបានស្នើឲ្យ នង ចាន់ផល មើលវីដេអូ ស-២១ ហើយធ្វើការវាយតម្លៃទៅលើការពិតដោយអះអាងថាខ្សែភាពយន្តដកស្រង់មានការជាប់ពាក់ព័ន្ធគ្រប់ករណី ហើយអាចផ្តល់ភ័ស្តុតាងដែលបង្ហាញពីស្ថានភាពនៅមន្ទីរស-២១ អ្នកសម្លាប់និងឧបករណ៍ធ្វើទារុណកម្ម ។ អង្គជំនុំជម្រះបានអះអាងថា នឹងធ្វើសេចក្តីសម្រេចទៅលើវីដេអូ ស-២១នៅថ្ងៃក្រោយ ។

ដោយសារតែអង្គសវនាការមានជំហរខាងលើនេះ នៅរសៀលថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ ចៅក្រម ស៊ីលវៀ ខាត់វ៉្រាយត៍ បានអនុញ្ញាតឲ្យមានការបញ្ចាំងរូបភាពនឹងថ្កល់មួយរបស់មន្ទីរស-២១ ។ រូបភាពនឹងថ្កល់នោះបានបង្ហាញពីក្មេងស្រាតពីរនាក់ដែលឈរនៅពីមុខទាហានវៀតណាម និងទាហានខ្មែរជាស្រ្តីមួយក្រុម ។ នង ចាន់ផល បានបង្ហាញថា គាត់និងប្អូនប្រុសរបស់គាត់គឺជាក្មេងនៅក្នុងខ្សែវីដេអូនោះ ប៉ុន្តែកាលពីពេលនោះគាត់មិនដឹងថាគាត់ត្រូវបានថតវីដេអូទេ ។

បន្ទាប់ពីសេចក្តីសម្រេចកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ទាក់ទងទៅនឹងខ្សែវីដេអូរបស់វៀតណាម មិនទំនងសោះដែលថាខ្សែភាពយន្តដើមនៅមន្ទីរស-២១ (ឬខ្សែភាពយន្តរូបភាពដែលយកមកពីមន្ទីរស-២១) នឹងត្រូវយកមកបញ្ចាំងនៅក្នុងសាលសវនាការទេ ។ សម្រាប់ករណី០០១ ការបញ្ចាំងកុនអំពីមន្ទីរស-២១នេះ ពិតជាមិនអាចកើតមានទេ ។ ក៏ប៉ុន្តែ សម្រាប់ករណី០០២ តាមមើលទៅ ការិយាល័យចៅក្រមស៊ើបអង្កេតអាចនឹងយកខ្សែវីដេអូនៅមន្ទីរស-២១នេះមកបញ្ចាំងបាន ។

## កុមារដែលរួចរស់ជីវិតពីមន្ទីរស-២១ ការចងក្រងឯកសារទាក់ទងនឹងកុមារដែលរួចរស់ជីវិត

ខ្សែវីដេអូមន្ទីរស-២១ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទើបនឹងទទួលបាននាពេលថ្មីៗនេះ មិនមែនជាភ័ស្តុតាងដំបូងស្តីអំពីកុមារដែលសល់ជីវិតពីមន្ទីរស-២១នោះទេ ។ ភ័ស្តុតាងនិងឯកសារមួយចំនួនអំពីកុមាររួចរស់ជីវិតពីមន្ទីរស-២១បានចេញមកដំបូងនៅពេលដែលតុលាការប្រជាជនបដិវត្តន៍កម្ពុជាប្រព្រឹត្តទៅនៅខែសីហា ឆ្នាំ១៩៧៩ ដែលបានផ្តន្ទាទោសប៉ុលពត និងអៀង សារី ដោយកំបាំងមុខពីបទប្រល័យពូជសាសន៍ ។ ឯកសាររបស់តុលាការប្រជាជនបដិវត្តន៍កម្ពុជាត្រូវបានបោះពុម្ពផ្សាយនៅក្នុងឯកសារតុលាការប្រជាជនបដិវត្តកម្ពុជាធ្វើនៅភ្នំពេញដើម្បីកាត់ទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍នៃ បន ប៉ុល ពត និង អៀង សារី (ខែសីហា ១៩៧៩) ដែលរៀបរៀងឡើងដោយ «ក្រុមអ្នកច្បាប់កម្ពុជា» និងក្រោយមកត្រូវបានបោះពុម្ពផ្សាយក្នុងសៀវភៅអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ។ ឯកសារតុលាការប្រជាជនបដិវត្តន៍កម្ពុជាដែលបានបញ្ចូលទៅក្នុងប្រភពទាំងពីរនេះមានបញ្ជាក់នូវការបំភ្លឺរបស់សាក្សីស្តីអំពីរបបខ្មែរក្រហម ។ ជាឧទាហរណ៍ របាយការណ៍ស៊ើបអង្កេតរបស់តុលាការប្រជាជនបដិវត្តន៍កម្ពុជាបានបញ្ជាក់ពីកុមាររួចរស់ជីវិតពីមន្ទីរស-២១ «កុមារម្នាក់ឈ្មោះផល» ។ ក្នុងចំណោមរឿងផ្សេងៗជាច្រើនទៀត នង ចាន់ផល បានបំភ្លឺនៅតុលាការប្រជាជនបដិវត្តន៍កម្ពុជាថា «ខ្ញុំឈ្មោះ នង ចាន់ផល អាយុ១០ឆ្នាំ ឪពុកខ្ញុំឈ្មោះ ចិន និងម្តាយខ្ញុំឈ្មោះ យ៉ូវ ត្រូវ ប៉ុល ពត សម្លាប់ ។ ខ្ញុំមានប្អូនប្រុស២នាក់ នង ចាន់លី អាយុ៨ឆ្នាំ និងម្នាក់ទៀតដែលទើបអាយុបាន៥ខែ ស្លាប់នៅគុកទួលស្លែង ។ ខ្ញុំត្រូវគេចាប់បញ្ជូនទៅគុកទួលស្លែងជាមួយម្តាយនិងប្អូនប្រុសទាំងពីររបស់ខ្ញុំ» ។

នៅក្នុងការសម្ភាសន៍ជាមួយ នង ចាន់ផល នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ចាន់ផល បានប្រាប់យើងថា គាត់បានដឹងពីការបំភ្លឺរបស់គាត់នៅតុលាការប្រជាជនបដិវត្តន៍កម្ពុជានៅដើមទសវត្សរ៍៨០ ។ បន្ទាប់ពីបានឃើញសេចក្តីបំភ្លឺរបស់ ផល នៅក្នុងសៀវភៅសង្ខេបពីតុលាការប្រជាជនបដិវត្តន៍កម្ពុជាឆ្នាំ១៩៧៩ បងប្រុសរបស់ នង ចាន់ផល នៅខេត្តតាកែវ បានមកស្វែងរក នង ចាន់ផល នៅមណ្ឌលកុមារកំព្រានៅទីក្រុងភ្នំពេញ ។ ក្រោយមក នង ចាន់ផល និងបងប្រុសរបស់គាត់បានជួបជុំគ្នាវិញក្រោយពីបានរស់នៅបែកគ្នាកាលពីជំនាន់ខ្មែរក្រហម ។

នង ចាន់ផល បានទទួលស្គាល់ថា គាត់បានចូលរួមផ្តល់បទសម្ភាសន៍មិនដូវការជាច្រើនបន្ទាប់ពីគាត់ត្រូវបានសង្គ្រោះចេញពីមន្ទីរស-២១ ប៉ុន្តែគាត់មិនបានផ្តល់សក្ខីកម្មចំពោះមុខតុលាការប្រជាជនបដិវត្តន៍កម្ពុជានោះទេ ហើយគាត់ក៏មិនដឹងថាគាត់បានជួយបំភ្លឺនៅពេលសវនាការឆ្នាំ១៩៧៩នោះដែរ ។ ៣០ឆ្នាំក្រោយមក នៅពេលធ្វើបទសម្ភាសន៍នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ នង ចាន់ផល បានអានសក្ខីកម្មដែលដកស្រង់ចេញពីតុលាការប្រជាជនបដិវត្តន៍កម្ពុជាជាលើកទីមួយ ។ ការអង្កេតរបស់គាត់ទាក់ទងនឹងសក្ខីកម្មនេះមានដូចតទៅៈ ទី១) សក្ខីកម្មកាលពីឆ្នាំ១៩៧៩ មានលក្ខណៈលម្អិតខ្លាំង ប៉ុន្តែ នង ចាន់ផល មិនចាំថាគាត់ពិតជាបានផ្តល់នូវការពិពណ៌នាពីបទពិសោធន៍របស់គាត់លម្អិតដូច្នេះឡើយ ។ ទី២) ចេញពីអ្វីដែលគាត់ចាំបាន ការពិតនិងភាពស៊ីគ្នានៅក្នុងសក្ខីកម្មមានតិចតួចបំផុត ប្រៀបធៀបទៅនឹងអ្វីដែលគាត់ចាំបាន ។ នង ចាន់ផល បានកត់សម្គាល់នូវភាពស៊ីគ្នាខ្លះដូចជាកំណត់សម្គាល់របស់គាត់ជាពិសេសទៅលើ អគារ«គ» និងការសម្រាកនៅជាន់ទីពីរ ។ ទោះជាយ៉ាងនេះក៏ដោយ ចាន់ផល មិនដែលត្រូវគេបង្ហាញនូវរូបភាពសាកសព «ម្តាយរបស់គាត់ដែលពុំមានពោះវៀន» ហើយគាត់ក៏មិនដែលត្រូវគេធ្វើទារុណកម្មប្វាយដំ និងមិនដែលឃើញអ្នកទោសណាម្នាក់ត្រូវគេ «ត្រូវជ្រមុជចូលក្នុងទឹក» ហើយក៏មិនដែលឃើញអ្នកណាម្នាក់ត្រូវគេសម្លាប់



ទាហានវៀតណាម និង កុមារដែលរួចផុតជីវិតពីគុកទួលស្លែង

ដែរ ។ នង ចាន់ផល កត់សម្គាល់បន្តទៀតថា សេចក្តីបំភ្លឺរបស់គាត់ប្រហែលជានឹងលាយជាមួយនឹងសេចក្តីបំភ្លឺរបស់អ្នករួចរស់ជីវិតដទៃទៀត ។

ជី ទេវិទ្ធិ អ្នកធ្វើបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារ បានកត់សម្គាល់ថា ការស៊ើបអង្កេតដែលមិនសូវមានគុណភាពនៅឆ្នាំ១៩៧៩ និងការណ៍ដែលអ្នកនិពន្ធរបស់ឯកសារចងក្រងមិនបានបញ្ចេញឈ្មោះខ្លួនឯងតែបែរជាដាក់ថា «ក្រុមអ្នកច្បាប់កម្ពុជា» ទៅវិញនោះ បានបង្កើតឲ្យមានចម្ងល់ចំពោះភាពត្រឹមត្រូវរបស់សក្ខីកម្ម ។ នង ចាន់ផល បានបន្ថែមថាសក្ខីកម្មរបស់គាត់ប្រហែលជាបានមកពីសំណួរនាំមុខដែលបានចោទសួរទៅគាត់ ហើយគាត់មិនបានយល់ច្បាស់ដោយសារកាលនោះគាត់នៅក្មេងពេក គាត់បានឆ្លើយយល់ព្រមទៅគេវិញ ។ ជាងនេះទៅទៀត វាអាចទៅរួចដែលថាសេចក្តីបំភ្លឺរបស់ចាន់ផល ត្រូវបានផ្លាស់ប្តូរបុព្វន្ធើសដោយចេតនាដើម្បីធានាឲ្យបាននូវការផ្តន្ទាទោសចំពោះ ប៉ុល ពត និង អៀង សារី ។ ឧទាហរណ៍ របាយការណ៍ស៊ើបអង្កេតរបស់តុលាការប្រជាជនបដិវត្តន៍កម្ពុជាបានបញ្ជាក់នូវសេចក្តីអះអាងរបស់ នង ចាន់ផល យ៉ាងច្បាស់ថា «រាល់ពេលដែលពួកប៉ុលពតនឹងគាត់តែងតែវ៉ៃយើងដោយគ្មានត្រាប្រណីឡើយ ។ ពេលខ្ញុំនៅក្នុងគុក ខ្ញុំឃើញក្រុម ប៉ុល ពត ធ្វើទារុណកម្មយ៉ាងសាហាវឃោរឃៅបំផុតមកលើអ្នកទោស» ។ បន្ទាប់ពីធ្វើទារុណកម្មមកលើអ្នកទោសរួចមក នង ចាន់ផល បន្តថា «ក្រុម ប៉ុល ពត បែរជាផ្ទុះសំណើចយ៉ាងរីករាយ» ។ នៅពេលនោះភាសាដែល នង ចាន់ផល បានប្រើប្រាស់ស្តាប់ទៅដូចជាភាសាបែបឃោសនាយ៉ាងលង់ស្ទុងជាងភាសាដែលក្មេងម្នាក់ផ្តល់នូវសក្ខីកម្មអំពីបទពិសោធន៍របស់ខ្លួននៅមន្ទីរ ស-២១ ទៅទៀត ។ ការចងក្រងនូវការបំភ្លឺបែបនេះធ្វើឲ្យរឿងរ៉ាវរបស់ នង ចាន់ផល មានភាពគួរឲ្យជឿជាក់បានដែលថាគាត់នៅរស់ពីមន្ទីរស-២១ ។

ខ្សែវីដេអូពិតប្រាកដរបស់កុមាររងគ្រោះនៅមន្ទីរស-២១ បានលេចរូបរាងនៅក្នុងភាពយន្តឯកសារ «ឆ្នាំសូន្យៈ កម្ពុជាស្លាប់ដោយស្ងៀមស្ងាត់» នៅពេលដែលរឿងនេះកំពុងតែដាក់បញ្ចាំងតាមទូរទស្សន៍នៅខែតុលា ឆ្នាំ១៩៧៩ ។ អ្នករួចរស់ជីវិតពីគុកទួលស្លែងបួននាក់ ដែលរួមមានវ៉ាន់ ណាត និងអ៊ីង ប៊ិច ត្រូវបានបង្ហាញជាមួយនឹងកុមារដែលត្រូវបានដឹងច្បាស់ថាជាកុមាររួចរស់ជីវិតពីស-២១ចំនួន៤នាក់ ។ ជាមួយគ្នានោះ ខ្សែភាពយន្ត «កុមារកម្ពុជា»ដែលផលិតដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានៅទសវត្សរ៍៨០ ក៏មានរូបភាពរបស់កុមារដែលរួចរស់ជីវិតពីស-២១ដែរ ។

ក្រោយពីខ្មែរក្រហមដួលរលំទៅ ទឹកខ្មែងនិងអត្តសញ្ញាណរបស់កុមាររួចរស់ពីស-២១ត្រូវបានគេស្គាល់ ។ ក្រោយពីចាន់ផលត្រូវបានបញ្ជូនទៅមណ្ឌលកុមារកំព្រា គណៈប្រតិភូបានធ្វើទស្សនកិច្ចនៅមណ្ឌលនោះនិងស្នើសុំមើលទឹកខ្មែងដែល ផលជាប់ឃុំឃាំងនៅមន្ទីរស-២១ ។ ចាន់ផល បានធ្វើជាមគ្គុទេសក៍នាំគណៈប្រតិភូមើលជុំវិញស-២១ និងរំឭកឡើងវិញនូវរឿងរ៉ាវដែលបានកើតឡើងចំពោះគាត់ ។

## ការត្រឡប់មកវិញរបស់ នង ចាន់ផល

ទោះជាយ៉ាងណាក៏ដោយ អស់រយៈជាច្រើនឆ្នាំទឹកខ្មែងនិងអត្តសញ្ញាណរបស់កុមារដែលរស់រានមានជីវិតបានរលុបបាត់បង់ទៅ បន្សល់ទុកនូវតែការចងចាំ ឯកសារ រូបថត និងខ្សែវីដេអូប៉ុណ្ណោះ ។ នៅពេល លោក ឆាំង យុ ចាប់ផ្តើមធ្វើការស្រាវជ្រាវទៅលើមន្ទីរស-២១ក្នុងទ្រង់ទ្រាយធំនៅឆ្នាំ២០០០ គាត់ចាប់ផ្តើមយល់បន្តិចម្តងៗអំពីកុមារដែលរស់រានមានជីវិតពីមន្ទីរនោះ ។ មិនត្រឹមតែប៉ុណ្ណោះលោក ឆាំង យុ ថែមទាំងបានជំរុញឲ្យអ្នកផលិតខ្សែភាពយន្តជនជាតិខ្មែរបារាំងលោក រិទ្ធី ប៉ាន់ ថតខ្សែភាពយន្តអំពីមន្ទីរស-២១ព្រមទាំងបញ្ចូលរឿងរ៉ាវរបស់កុមារដែលសល់ជីវិតពីមន្ទីរស-២១ផង ប្រសិនបើគាត់អាចស្វែងរករឿងរ៉ាវនេះបាន ។ កុមារម្នាក់ក្នុងចំណោមកុមាររងគ្រោះ នង ចាន់ផល ត្រូវបានគេរកឃើញ ។ ប៉ុន្តែនៅពេលដែលខ្សែភាពយន្តឯកសារឆ្នាំ២០០៣របស់ រិទ្ធី ប៉ាន់ៈ ស-២១ៈ ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហមបានប្រមូលនូវអតីតអ្នកជាប់ឃុំឃាំង និងឆ្មាំគុកមកជួបគ្នាឡើងវិញ ប៉ុន្តែលោក រិទ្ធី ប៉ាន់ មិនបានបញ្ចូលកុមារនោះទៅក្នុងសាច់រឿងទេ ។

បន្ទាប់ពីមជ្ឈមណ្ឌលឯកសារទទួលបាននូវខ្សែវីដេអូស-២១ពីរដ្ឋាភិបាលវៀតណាមនៅខែវិច្ឆិកា ឆ្នាំ២០០៨ មជ្ឈមណ្ឌលបានចាប់ផ្តើមធ្វើការស្រាវជ្រាវថ្មីមួយដោយបំពាក់ជាមួយរូបថត

របស់កុមារដែលធ្លាប់ជាប់នៅមន្ទីរឃុំឃាំងស-២១ ដែលបច្ចុប្បន្ននេះអាចមានអាយុចន្លោះពី៤០-៥០ឆ្នាំ និងអាចផ្តល់នូវភ័ស្តុតាង ផ្ទាល់ចំពោះឧក្រិដ្ឋកម្មដែលបានកើតមាននៅមន្ទីរស-២១ ។ ទោះជាយ៉ាងនេះក៏ដោយ វាមិនមែនដោយសារតែខ្សែវីដេអូស-២១ដែលទើបទទួលបានថ្មី ឬការប្រឹងប្រែងជាថ្មីម្តងទៀតរបស់មជ្ឈមណ្ឌលឯកសារទេដែលធ្វើឲ្យកុមារដែលសល់ជីវិតពីស-២១ លេចមុខត្រឡប់មកវិញ ។ តាមពិត គឺនៅដើមខែកុម្ភៈឆ្នាំ២០០៩ ការផ្សាយរបស់ទូរទស្សន៍និងវិទ្យុបានធ្វើឲ្យ នង ចាន់ផល ត្រឡប់មកវិញម្តងទៀតក្នុងចំណាប់អារម្មណ៍របស់សាធារណជន ។ ដំបូងវិទ្យុអាស៊ីសេរីបានធ្វើការផ្សាយកម្មវិធីមួយអំពីសវនាការ ឌុច ដែលខិតជិតមកដល់ ។ បើយោងតាមលោក ជី ទេរិទ្ធិ នៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានមនុស្សម្នាក់បានទូរស័ព្ទចូលមកក្នុងកម្មវិធីវិទ្យុអះអាងថាខ្លួនគឺជាកុមារដែលរួចរស់ជីវិតពីស-២១ ហើយសុំព័ត៌មានបន្ថែមទៀតអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោក ជី ទេរិទ្ធិ បានស្តាប់កម្មវិធីនេះ ហើយព្យាយាមរកលេខទំនាក់ទំនងដើម្បីទាក់ទងទៅវិញ ប៉ុន្តែ ជី ទេរិទ្ធិ មិនអាចទាក់ទងអ្នកទូរស័ព្ទចូលកម្មវិធីនោះ ហើយខ្លាចថាកុមារដែលរួចរស់មានជីវិតត្រូវបាត់ទៅវិញម្តងទៀត ។

បន្ទាប់ពីបានមើលកម្មវិធីទូរទស្សន៍អំពីការដាក់ពាក្យបណ្តឹងធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៩ នង ចាន់ផល បានធ្វើដំណើរមកកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ បុគ្គលិកនៅទួលស្លែងបានប្រាប់គាត់ឲ្យទាក់ទងសាលាក្តីខ្មែរក្រហមឬមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ពេល នង ចាន់ផល មកដល់អង្គភាពជនរងគ្រោះរបស់សាលាក្តីខ្មែរក្រហម គាត់មានបំណងដាក់ពាក្យបណ្តឹងធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ដោយអះអាងថា គាត់គឺជាកុមាររងគ្រោះនៅមន្ទីរស-២១ ។ ទោះជាយ៉ាងនេះក៏ដោយ អង្គភាពជនរងគ្រោះមិនអាចធ្វើការដាក់ពាក្យបណ្តឹងឲ្យគាត់បានទេ ដោយសារតែការដាក់ពាក្យបណ្តឹងនេះហួសពេលកំណត់ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៩ រយៈពេល២ថ្ងៃទៅហើយ ។ បុគ្គលិកអង្គភាពជនរងគ្រោះ កញ្ញា ហ៊ុយ សម្ផស្ស ក៏បានផ្តល់យោបល់ទៅ នង ចាន់ផល ថា គាត់គួរតែទៅរកមើលឯកសារប្រវត្តិរូបរបស់ឪពុកម្តាយគាត់នៅការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជានិងអាចស្វែងរកព័ត៌មានដើម្បីក្លាយជាសាក្សីចំពោះហេតុការណ៍នោះ ។ នៅពេលដែលចាន់ផលមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ បានសួរនាំគាត់អំពីរឿងរ៉ាវលម្អិតនិងបញ្ជាក់ថាគាត់គឺជាពិតជាកុមារដែលរួចរស់ជីវិតពីមន្ទីរស-២១ មែនឬមិនមែន ។ បន្ទាប់មក លោក ឆាំង យុ បានបង្ហាញ នង ចាន់ផល នូវខ្សែវីដេអូមន្ទីរស-២១ដែលទើបនឹង ទទួលបានថ្មីៗ ពេលនោះ នង ចាន់ផល បានបញ្ជាក់ថាគាត់ពិតជាកុមារម្នាក់ដែលមានអាយុច្រើនជាងគេនៅក្នុងវីដេអូនិងបានកត់សម្គាល់អំពីការស្ម័គ្រចិត្តរបស់គាត់ក្នុងការធ្វើជាកសិណសាក្សីប្រសិនបើចាំបាច់ ។ មួយថ្ងៃក្រោយមក មជ្ឈមណ្ឌលឯកសារបានរកឃើញប្រវត្តិរូបរបស់ឪពុកគាត់នៅមន្ទីរស-២១ ។

នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រកាសជាសាធារណៈថា នង ចាន់ផល និងប្អូនប្រុសរបស់គាត់ នង ចាន់លី ត្រូវបានរកឃើញនិងបញ្ជាក់ថាជាបងប្អូនដែលជាកុមារក្នុងចំណោមកុមារទាំង៥នាក់នៅក្នុងខ្សែវីដេអូមន្ទីរស-២១ ដែលផ្តល់ជូនដោយវៀតណាម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាថែមទាំងបានធ្វើការកត់សម្គាល់ថា នង ចាន់ផល បានដឹងពីការស្លាប់របស់កុមារម្នាក់ក្នុងចំណោមកុមារទាំង៥នាក់នៅក្នុងវីដេអូ ។ ជាភ័ស្តុតាងបញ្ជាក់បន្ថែមថា នង ចាន់ផល គឺពិតជាកុមាររងគ្រោះពីមន្ទីរស-២១ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ បីថ្ងៃក្រោយពីចំណាំបាននូវរូបភាពរបស់អតីតកុមាររងគ្រោះនៅមន្ទីរស-២១នៅក្នុងកាសែតក្នុងស្រុកមួយ លោក ខៀវ កូឡា ដែលធ្លាប់ជាបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលនិងជាអ្នកយកព័ត៌មានសាច់រឿងតុលាការប្រជាជនបដិវត្តកម្ពុជា បានទំនាក់ទំនងលោក ឆាំង យុ ពីរឿងដែលគាត់បានធ្វើបទសម្ភាសន៍រួចម្តងមកហើយពីកុមាររងគ្រោះកាលពីឆ្នាំ១៩៧៩ ។ ដើម្បីបញ្ជាក់ថាលោកពិតជាបានសម្ភាសមែន លោក ខៀវ កូឡា បានផ្ញើសារអេឡិចត្រូនិចមកកាន់ លោក យុ ដោយភ្ជាប់នូវរូបថតដែលលោកបានថតជាមួយ នង ចាន់ផល នៅឆ្នាំ១៩៧៩ផង ហើយ នង ចាន់ផល ក្រោយមកបានបញ្ជាក់ពីភាពពិតប្រាកដរបស់រូបថតនេះ ។ ក្រោយមក លោក ខៀវ កូឡា បានមកជួបលោក ឆាំង យុ នៅមជ្ឈមណ្ឌលឯកសារកម្ពុជានិងបានប្រគល់នូវរូបថតដើមរបស់

លោកជាមួយ នង ចាន់ផល និងរូបថត១០សន្លឹកទៀតរបស់មេដឹកនាំខ្មែរក្រហមដែលគាត់បានរកឃើញនៅឆ្នាំ១៩៧៩ក្នុងអគារចាស់មួយក្នុងទីក្រុងភ្នំពេញ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី អាឡែន វើនើ បានដាក់ពាក្យស្នើសុំទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីពន្យារពេលកំណត់ទទួលពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយហេតុថា ស្ថានភាពដ៏កម្ររបស់ចាន់ផលដែលជាកុមាររងគ្រោះនៅមន្ទីរស-២១ និងដោយសារថាគាត់មិនបានដឹងពីដំណើរប្រព្រឹត្តទៅនៃអ.វ.ត.ក ។ ទោះជាយ៉ាងនេះក៏ដោយ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ អង្គជំនុំជម្រះវិសាមញ្ញបានសម្រេចថា «មេធាវីតំណាងឲ្យលោក នង ចាន់ផល មិនទាន់ផ្តល់ជូនអង្គជំនុំជម្រះនូវព័ត៌មានណាមួយដើម្បីស្នើថាមានស្ថានភាពលើកលែងណាមួយដែលរារាំងគាត់មិនឲ្យដាក់ពាក្យបណ្តឹងទៅតាមពេលវេលាដែលកំណត់ដោយអង្គជំនុំជម្រះទេ» ។ ហេតុដូច្នេះ ពាក្យបណ្តឹងរបស់ នង ចាន់ផល ដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធ ។ អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ថា ទោះបីការិយាល័យសហព្រះរាជអាជ្ញាអាចហៅ នង ចាន់ផល មកធ្វើជាសាក្សីបានឬយ៉ាងណានោះ នឹងត្រូវសម្រេចនៅពេលក្រោយ ។ ការតាំងខ្លួនជាសាក្សីរបស់ នង ចាន់ផល ត្រូវបានសម្រេចដោយអង្គជំនុំជម្រះនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោក ការីម ខាន់ និង អាឡែន វើនើ បានសម្រេចថាបន្ទាប់ពី នង ចាន់ផល ត្រូវបានសម្រេចឲ្យធ្វើជាសាក្សីរួចហើយនោះ វានឹងមិនសូវសមរម្យក្នុងការបន្តជួយ នង ចាន់ផល ទៀតទេ ព្រោះគាត់មិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី ។

នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ ដោយមានការផ្តួចផ្តើមពីមជ្ឈមណ្ឌលឯកសារខ្លួនឯង ជី ទេវិទ្ធិ និង វ៉ាន់ថាន់ ពៅដារ៉ា បានធ្វើការសម្ភាសន៍ នង ចាន់ផល ហើយបន្ទាប់មកបានផ្តល់នូវឯកសារនេះទៅឲ្យសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាបានផ្តល់ចម្លើយរបស់ នង ចាន់ផល ទៅក្រុមការពារក្តីនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ មួយថ្ងៃមុននឹង នង ចាន់ផល កំណត់ឡើងធ្វើសក្ខីកម្ម ។ នៅសវនាការនាថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិ វីលៀម ស្មីត ស្នើសុំទៅកាន់អង្គជំនុំជម្រះដើម្បីធ្វើសេចក្តីកត់សម្គាល់ទៅលើសេចក្តីស្នើសុំដែលខ្លួនបានដាក់ទៅកាលពីព្រឹកប៉ុន្មាននាទីមុនម៉ោងប្រាំបួនព្រឹក ។ សំណើពីសហព្រះរាជអាជ្ញាគឺសុំឲ្យអង្គជំនុំជម្រះដាក់បន្ថែមនូវបទសម្ភាសន៍របស់ នង ចាន់ផល នៅខែកុម្ភៈចូលទៅក្នុងសំណុំរឿងដោយយោងទៅតាមវិធាន៨៧ ។ ការិយាល័យសហព្រះរាជអាជ្ញាទទួលស្គាល់ថា «ចម្លើយរបស់ចាន់ផល គួរតែត្រូវបានប្រគល់ជូនដោយការិយាល័យសហព្រះរាជអាជ្ញា ប៉ុន្តែដោយសារតែភាពមិនទាក់ទងគ្នារវាងបណ្តឹងរដ្ឋប្បវេណីនិងការផ្តល់នូវឋានៈជាសាក្សីដល់ នង ចាន់ផល ដែលមិនមានទំនាក់ទំនង ហើយការផ្តល់ជូននូវបទសម្ភាសន៍ត្រូវបានមើលរំលង» ។ បន្ថែមពីលើនោះទៀត សហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ជាពិសេសពីសារសំខាន់ក្នុងការអនុញ្ញាតឲ្យគ្រប់ភាគីទាំងអស់យោងទៅលើបទសម្ភាសន៍ក្នុងពេល នង ចាន់ផល ធ្វើសក្ខីកម្ម ។

លោកមេធាវីការពារក្តីកម្ពុជា កា សាវុត្ថ និងអន្តរជាតិ កញ្ញា ខេននីហ្សា បានប្រឆាំងដោយជោគជ័យជាមួយនឹងអង្គជំនុំជម្រះថា បទសម្ភាសន៍នេះមិនគួរបញ្ចូលទៅក្នុងសំណុំរឿង ឬក៏ធ្វើជាឯកសារយោងក្នុងពេលធ្វើសក្ខីកម្មនោះទេ ។ លោក កា សាវុត្ថ បានលើកឡើងថា មេធាវីការពារក្តីបានទទួលនូវបទសម្ភាសន៍មួយថ្ងៃមុនពេលចាន់ផលធ្វើសក្ខីកម្ម ទោះបីជាសហព្រះរាជអាជ្ញាមានឯកសារនៅក្នុងដៃតាំងពីខែកុម្ភៈ ឆ្នាំ២០០៩ ក៏ដោយ ហេតុនេះមេធាវីការពារក្តីពុំមានពេលវេលាដើម្បីអានបទសម្ភាសន៍ឡើងវិញនិងរៀបចំទុកជាមុនទេ ។ បន្ថែមពីលើនោះ កញ្ញា ខាននីហ្សា បញ្ជាក់ថាឯកសារនេះមិនគួរអនុញ្ញាតឲ្យដាក់នៅក្នុងសំណុំរឿងទេ ពីព្រោះមជ្ឈមណ្ឌលឯកសារដែលជាអង្គការក្រៅរដ្ឋាភិបាលមួយបានធ្វើការសម្ភាសយករឿងរ៉ាវរបស់សាក្សីជំនួសឲ្យមន្ត្រីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៅហើយ ដែលសាក្សីត្រូវតែធ្វើពាក្យសម្បថ ។ ហេតុដូចនេះ ចាន់ផល បានឡើងធ្វើសក្ខីកម្មនៅថ្ងៃទី២ ខែកក្កដា ដោយគ្មានឯកសារជំនួយ ។

## សក្ខីកម្មរបស់ នង ចាន់ផល

ឪពុករបស់ នង ចាន់ផល គឺជាសមាជិកមួយរូបក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយនៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានបញ្ជូនគាត់មកភ្នំពេញ ។ ពីរខែក្រោយមក នង ចាន់ផល ម្តាយរបស់គាត់និងប្អូនប្រុសរបស់គាត់ត្រូវខ្មែរក្រហមបញ្ជូនមកភ្នំពេញដែរ

ដោយសន្យាថានឹងឲ្យគាត់ជួបឪពុកគាត់ ។ ក្រោយពីស្នាក់នៅស្ថានីយរថភ្លើងចំនួនបីថ្ងៃ គ្រួសារ និង នង ចាន់ផល ផ្ទាល់ត្រូវខ្មែរក្រហមបញ្ជូនទៅមន្ទីរស-២១ ជាមួយស្ត្រីបីនាក់ផ្សេងទៀត និងកូនតូចរបស់ស្ត្រីនោះ ។ នៅពេលទៅដល់មន្ទីរស-២១ នង ចាន់ផល មើលឃើញម្តាយគាត់កំពុងតែត្រូវឆ្មាំគុកវាយរហូតដល់សន្លប់ ។ អ្នកធ្វើការនៅក្នុងគុកបានចាប់ទាញសក់ក្បាលគាត់ឲ្យងើបពីដី ហើយបន្ទាប់មកទះកំផ្លៀងនិងទាត់គាត់ ។ ចុងក្រោយទើបបុគ្គលិកម្នាក់របស់មន្ទីរស-២១ ថតរូបគាត់ដើម្បីធ្វើប្រវត្តិរូប ។ នង ចាន់ផល និងគ្រួសារមិនត្រឹមតែមិនបានជួបឪពុកទេ តែថែមទាំងត្រូវជាប់ឃុំឃាំងនៅក្នុងបន្ទប់ធំមួយជាមួយស្ត្រីពីរនាក់និងកូនទាំងបីរបស់ស្ត្រីនោះថែមទៀត ។ នង ចាន់ផល បានធ្វើការកត់សម្គាល់ថា ក្មេងម្នាក់ក្នុងចំណោមក្មេងទាំងបី មានអាយុប្រហែល៣ឆ្នាំម្នាក់ទៀតមានអាយុតិចជាងបីឆ្នាំ និងចុងក្រោយគឺជាទារកដែលនៅបៅដោះនៅឡើយ ។ ក្រោយពីសម្រាកនៅលើឥដ្ឋមួយយប់ដោយគ្មានម្ហូបអាហារបន្តិចចូលពោះសោះនោះ នង ចាន់ផល ប្អូនប្រុសរបស់គាត់ និងកុមារដទៃទៀតត្រូវខ្មែរក្រហមបំបែកចេញពីម្តាយរបស់ខ្លួន ។ នង ចាន់ផល មានអាយុ៩ឆ្នាំ អាយុបងគេបង្អស់ក្នុងចំណោមកុមារទាំង៥នាក់នៅមន្ទីរស-២១ ។ ក្រោយមកខ្មែរក្រហមបានយកគាត់ទៅដាក់នៅកន្លែងរោងជាងក្រោយអគារ «គ» របស់មន្ទីរស-២១ ដែលមានជាងឈើនិងជាងស្មិតធ្វើការនៅកន្លែងកខ្វក់នោះ ។ កុមារទាំងអស់ត្រូវសម្រាកនៅក្រោយរោងជាងដោយមានស្ត្រីចំណាស់ម្នាក់ជាអ្នកមើលថែរក្សាគាត់ ។ នង ចាន់ផល អាចមើលទៅកាន់បង្អួចបន្ទប់ដែលដាក់កន្លែងគាត់ជាប់ឃុំជាមួយម្តាយគាត់ពីកន្លែងរោងជាងនោះ ។ នង ចាន់ផល បានឆ្លើយថា «ពេលខ្ញុំនៅក្រោយរោងជាង ខ្ញុំអាចមើលទៅក្រោយឃើញម្តាយខ្ញុំកំពុងតែឈរកាន់ចម្រឹងបង្អួចមើលមកខ្ញុំ ។ ខ្ញុំដឹងថាគាត់ចង់និយាយមករកខ្ញុំពីរឿងអ្វីមួយ ប៉ុន្តែកន្លែងដែលគាត់ឈរនិងកន្លែងខ្ញុំនៅវាឆ្ងាយពីគ្នាពេក ។ ខ្ញុំឃើញគាត់បានតែមួយភ្លែតប៉ុណ្ណោះ ហើយខ្ញុំមិនដែលបានឃើញគាត់ទៀតទេតាំងពីពេលនោះមក ។

ពេលដែលមានការរត់ចេញពីមន្ទីរស-២១នៅដើមខែមករា ឆ្នាំ១៩៧៩ ស្ត្រីចំណាស់ដែលថែរក្សាកុមារ បានប្រាប់ឲ្យ នង ចាន់ផល ចាកចេញពីមន្ទីរស-២១ជាមួយគាត់ ប៉ុន្តែ នង ចាន់ផល មិនអាចចាកចេញដោយគ្មានម្តាយគាត់ទេ ។ នង ចាន់ផល មិនអាចបីកូនក្មេងដែលឈឺទាំងអស់បាន គាត់ក៏លាក់កុមារផ្សេងទៀតនៅក្នុងគំនរខោអាវនៅរោងជាងនោះ ។ ដោយចង់រង់ចាំម្តាយគាត់នៅក្បែរអគារដែលគាត់គិតថាម្តាយគាត់ជាប់ឃុំនោះ នង ចាន់ផល ប្អូនប្រុសគាត់ និងកុមារអាយុ៣ឆ្នាំម្នាក់ទៀតដែលអាចដើរបានបានលាក់ខ្លួននៅជិតគំនរខោអាវ និងគ្រឿងសង្ហារិមបាក់បែក ។ ក្រោយមក នង ចាន់ផល បានប្រថុយចេញពីកន្លែងលាក់ខ្លួនទៅរកម្តាយរបស់គាត់ ប៉ុន្តែគាត់តក់ស្លុតជាខ្លាំងដោយឃើញសាកសពជាប់ច្រវាក់នៅលើគ្រែ ។ ដោយហេតុនេះ គាត់ក៏ត្រឡប់ទៅរោងជាងវិញ ហើយនៅជាមួយកុមារដទៃទៀត ។ កុមារទាំងអស់ផឹកទឹកភ្លៀងដែលនៅសល់ បរិភោគបបរដួម រហូតទាល់តែទាហានវៀតណាមពីរនាក់រកឃើញ ហើយបានកាប់ទានិងដាំបាយឲ្យគាត់ហូប ។ មួយថ្ងៃក្រោយមក ទាហានវៀតណាមនិងកម្ពុជាមួយក្រុមធំបានមកដល់មន្ទីរស-២១ ។ ក្រោយពីស្នាក់នៅជាមួយទាហានវៀតណាមមួយរយៈ នង ចាន់ផល បានទៅរស់នៅក្នុងមណ្ឌលកុមារកំព្រាមួយនៅជិតពហុកីឡដ្ឋានជាតិអូឡាំពិក ។

ក្នុងចំណោមកុមារដែលជាប់នៅមន្ទីរស-២១នាពេលនោះ កុមារដែលមានអាយុតិចជាងគេបានស្លាប់នៅក្នុងគុក ប្រហែលជាដោយសារភាពអស់កម្លាំងនិងអត់ឃ្លាន ។ ចំណែកឯកុមារ៤នាក់ផ្សេងទៀតនៅរស់ ។ ចាន់ផល និងប្អូនប្រុសគាត់ត្រូវគេដាក់ឲ្យនៅក្នុងមណ្ឌលកុមារកំព្រាផ្សេងៗគ្នានៅភ្នំពេញ ហើយក្មេងស្រីពីរនាក់ទៀតប្រហែលជារស់នៅប្រទេសអាល្លឺម៉ង់ ឬក៏ជប៉ុន ក្រោយពីជនជាតិអាល្លឺម៉ង់ម្នាក់បានរើសយកទៅចិញ្ចឹម ។ មជ្ឈមណ្ឌលឯកសារកម្ពុជានៅបន្តស្រាវជ្រាវរកក្មេងស្រីទាំងពីរនាក់នោះទៀត ។

## ប្រវត្តិរូបអ្នកទោសនៅមន្ទីរស-២១

ក្នុងពេលដំណើរការ មន្ទីរស-២១ដែលជាមន្ទីរឃុំឃាំងនិងសួរចម្លើយ បុគ្គលិកមន្ទីរស-២១ បានធ្វើការកត់ត្រាប្រវត្តិរូបរបស់អ្នកទោសយ៉ាងល្អិតល្អន់និងធ្វើការសួរចម្លើយដោយប្រយ័ត្នប្រយែងបំផុត ។ ដោយសារកងទ័ពវៀតណាមសម្រុកចូលមកក្នុងទីក្រុងភ្នំពេញលឿនពេកនៅដើមខែមករា ឆ្នាំ១៩៧៩ ឌុច និង

បុគ្គលិកស-២១ មិនមានពេលវេលាគ្រប់គ្រាន់ដើម្បីកម្ទេចឯកសារទាំងអស់បានទេ ។ បច្ចុប្បន្នឯកសារប្រវត្តិរូបអ្នកទោសត្រូវបានប្រើប្រាស់ធ្វើជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់អ្នកដែលជាប់ឃុំឃាំងនៅមន្ទីរស-២១ ។

ពេល នង ចាន់ផល ធ្វើដំណើរទៅការិយាល័យមជ្ឈមណ្ឌលឯកសារនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៩ បុគ្គលិកមជ្ឈមណ្ឌលបានរកឃើញប្រវត្តិរូបឪពុកគាត់ដែលជាប់នៅស-២១ ឈ្មោះ នង ចិន និងបានផ្តល់ឯកសារនេះទៅការិយាល័យសហព្រះរាជអាជ្ញា ។ ប្រវត្តិរូបរបស់ នង ចិន មានឈ្មោះប្រពន្ធរបស់គាត់ឈ្មោះ មុំ យ៉ោង ប៉ុន្តែមជ្ឈមណ្ឌលឯកសារមិនអាចស្រាវជ្រាវរកប្រវត្តិរូបសង្ខេបរបស់ម្តាយគាត់បានទេ ។

## ឌុចបដិសេធសក្ខីកម្មរបស់ នង ចាន់ផល

នៅពេលដែលសហព្រះរាជអាជ្ញាបានដាក់ជូនអង្គជំនុំជម្រះនូវប្រវត្តិរូបឪពុកចាន់ផល នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ ឌុចបានទទួលស្គាល់ថា ប្រសិនបើប្រវត្តិរូបនរណាម្នាក់សល់ពីស-២១ នោះគាត់នឹងទទួលស្គាល់ថាអ្នកនោះពិតជាបានជាប់នៅស-២១ និងពិតជាបានសម្លាប់មែន ។ ហេតុនេះ ឌុចបានទទួលស្គាល់នូវការទទួលខុសត្រូវចំពោះការជាប់ឃុំឃាំងនិងការស្លាប់របស់ឪពុក នង ចាន់ផល ។ ទោះជាយ៉ាងនេះក៏ដោយ ដោយសារថា ឪពុកម្តាយរបស់ នង ចាន់ផល មិនត្រូវបានយកទៅមន្ទីរស-២១ ទាំងអស់គ្នា ឌុច បានធ្វើការសន្និដ្ឋានថាឪពុករបស់គាត់ត្រូវគេបញ្ជូនទៅស-២១ ដែលមានប្រវត្តិរូបជាភស្តុតាង រីឯម្តាយនិងកូនប្រហែលជាបញ្ជូនទៅមន្ទីរឃុំឃាំងណាផ្សេង ពីព្រោះតែគ្មានប្រវត្តិរូបម្តាយនៅសល់ ។ ឌុច បានធ្វើការបកស្រាយថា «ប្រហែលជាម្តាយរបស់គាត់បានរងគ្រោះនៅមន្ទីរសន្តិសុខណាផ្សេងទៀត ឬក៏ប្រហែលជាម្តាយគាត់ត្រូវគេបញ្ជូនទៅមន្ទីរស-២៤ ។ ហេតុនេះ យើងចង់ឲ្យការិយាល័យសហព្រះរាជអាជ្ញាជួយតាមដានរកឯកសារឲ្យឃើញផង» ។ ឌុច បន្ថែមទៀតថា «ប្រសិនបើយើងអាចរកឃើញឯកសារប្រវត្តិរូបរបស់ម្តាយផល ចេញពីមន្ទីរស-២១នោះ ខ្ញុំនឹងទទួលស្គាល់សក្ខីកម្មរបស់ នង ចាន់ផល ដោយគោរព» ។

## ការរកឃើញប្រវត្តិរូបរបស់ម្តាយ នង ចាន់ផល

ហ៊ិន សុផានី បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលធ្លាប់បានឮឈ្មោះ នង ចាន់ផល និងរឿងរ៉ាវរបស់គាត់នៅមន្ទីរស-២១ ដោយសារនាងធ្លាប់វាយពាក្យសុំធ្វើជាជនរងគ្រោះរបស់គាត់ ។ ហ៊ិន សុផានី បានចូលរួមស្តាប់សវនាការនៅថ្ងៃដែល នង ចាន់ផល ធ្វើសក្ខីកម្មអំពីរឿងរ៉ាវឈឺចាប់របស់គាត់នៅមន្ទីរស-២១ដែលកាលនោះគាត់នៅជាកុមារនៅឡើយ និងដំណើររឿងដែលនាំឲ្យគ្រួសារគាត់បែកបាក់គ្នានៅជំនាន់ខ្មែរក្រហម ។ ដោយមានការអាណិតអាសូរចំពោះ នង ចាន់ផល ដែលបានធ្វើសក្ខីកម្មចំពោះរឿងរ៉ាវដ៏គួរឲ្យរន្ធត់ផ្ទាល់ខ្លួន ហើយត្រូវ ឌុច បដិសេធសក្ខីកម្មរបស់គាត់នៅមន្ទីរស-២១ ហ៊ិន សុផានី បានពុះពារជាថ្មីម្តងទៀតក្នុងការស្វែងរកប្រវត្តិរូបម្តាយគាត់ ។ ហ៊ិន សុផានី មើលប្រវត្តិរូបរបស់ឪពុក នង ចាន់ផល ជាពិសេសតួអក្សរឈ្មោះរបស់ម្តាយ នង ចាន់ផល ។ ដោយនៅក្នុងសវនាការ ហ៊ិន សុផានី បានឮ នង ចាន់ផល ហៅឈ្មោះម្តាយគាត់ខុសគ្នាបន្តិចពីឈ្មោះដែលនាងបានចាំពេលអានប្រវត្តិរូបឪពុករបស់ នង ចាន់ផល ហ៊ិន សុផានី គិតថា


TSL 6245

7

ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង

១- ឈ្មោះដើម ឈ្មោះថ្មី
២- អាយុ ៥០ ឆ្នាំ ភេទ ជនជាតិ
៣- ក្រសួងនិងឋានៈមុខងារពីថ្ងៃចូលបដិវត្តន៍រហូតបច្ចុប្បន្ន
៤- កើតនៅភូមិ ឃុំ ស្រុក តំបន់ ៣៥
៥- ឪពុកឈ្មោះ ម្តាយឈ្មោះ
៦- របរឪពុកម្តាយពីមុនមក
៧- ប្តី ឬ ប្រពន្ធ ឈ្មោះដើម ឈ្មោះថ្មី
៨- កើតនៅភូមិ ឃុំ ស្រុក តំបន់ ៣៥
៩- ក្រសួង-នាទី និងកន្លែងរស់នៅបច្ចុប្បន្ន
១០- មានកូនប្រុសចំនួន ៤ នាក់ កូនស្រី ៣ នាក់
១១- ទីកន្លែងចាប់ខ្លួន
១២- ចាប់ខ្លួន ថ្ងៃទី ១ ខែ ១ ឆ្នាំ ១៩៧៨ ។ ផ្ទះ 53 បន្ទប់ធំ 2

ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា K08732

នេះប្រហែលជាមានការប្រកបឈ្មោះខុសពីឈ្មោះម្តាយ នង ចាន់ផល ពិតប្រាកដ ។ ដោយធ្វើការឆ្លាស់តួអក្សរលើឈ្មោះរបស់ម្តាយ នង ចាន់ផល ធ្វើឲ្យ ហ៊ុន សុធានី អាចរកឃើញឈ្មោះនៅក្នុងប្រព័ន្ធទិន្នន័យកុំព្យូទ័រ មុំ យ៉ូវ (ឯកសារK០៨៧៣២) ដែលប្រហែលជាម្តាយរបស់ នង ចាន់ផល ។ ហ៊ុន សុធានី បានយកប្រវត្តិរូបនេះចេញពីឯកសារដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានធ្វើការពិភាក្សាជាមួយ សុខ វណ្ណៈ ដែលជាសមាជិកក្នុងគម្រោងជំរុញឲ្យមានការទទួលខុសត្រូវនិងជាអ្នកដែលមានបទពិសោធន៍យ៉ាងច្រើនជាមួយប្រវត្តិរូបអ្នកទោស ។ ហ៊ុន សុធានី សុខ វណ្ណៈ និងបុគ្គលិកមជ្ឈមណ្ឌលឯកសារផ្សេងៗទៀតបានសន្និដ្ឋានថា ប្រវត្តិរូបមួយនេះពិតជារបស់ម្តាយ នង ចាន់ផល និងជាប្រពន្ធរបស់ នង ចិន ។ ជាភ័ស្តុតាងទៅលើការសន្និដ្ឋាននេះ ហ៊ុន សុធានី និង សុខ វណ្ណៈ សន្និដ្ឋានថាឯកសារស-២១ ទាំងពីរនេះមានទីកន្លែងកំណើតតែមួយ មានឈ្មោះប្តីប្រពន្ធស្រដៀងគ្នា និងត្រូវបានចាប់ខ្លួននៅកន្លែងតែមួយ ។ លោក ឆាំង យុ បានផ្ញើសារអេឡិចត្រូនិចដោយមានភ្ជាប់ប្រវត្តិរូបម្តាយ នង ចាន់ផល ទៅលោក បឺល ស្មិត នៅការិយាល័យសហព្រះរាជអាជ្ញា នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ។

នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩ ការិយាល័យសហព្រះរាជអាជ្ញាបានស្នើសុំឲ្យប្រវត្តិរូបម្តាយ នង ចាន់ផល ដែលទើបនឹងរកឃើញបញ្ចូលទៅក្នុងសំណុំរឿង និងសុំឲ្យពិចារណាដាក់ឯកសារនេះចំពោះអង្គជំនុំជម្រះសាលាដំបូង ។ ឌុច បានទទួលស្គាល់ប្រវត្តិរូបរបស់ មុំ យ៉ូវ នៅមន្ទីរស-២១ វត្តមានរបស់ម្តាយ នង ចាន់ផល នៅមន្ទីរស-២១ និង របស់កូនៗរបស់គាត់ ។ បន្ទាប់មកគាត់បានបញ្ជាក់ថា «ខ្ញុំចង់ឲ្យ នង ចាន់ផល អភ័យទោសឲ្យខ្ញុំផង» ។

## ដំណើរការកាត់ក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ច្បាប់ស៊ីវិលឡូរបស់អង្គជំនុំជម្រះក្នុងការធ្វើការស៊ើបអង្កេតមានលក្ខណៈខុសប្លែកទៅនឹងអ្វីដែលតុលាការអន្តរជាតិនានាបានធ្វើនាដំណាក់កាលស៊ើបអង្កេតដូចគ្នា ។ តាមរយៈតុលាការដែលរៀបចំឡើងមិនបានគ្រោងទុកនាពេលបច្ចុប្បន្ននេះដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការពិសេស សម្រាប់ប្រទេសសៀរ៉ាឡេអូន និងតុលាការពិសេសសម្រាប់លីបង់ មានតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមួយគត់ដែលបានប្រើប្រាស់ធនធានចៅក្រមស៊ើបអង្កេតដើម្បីធ្វើការស៊ើបអង្កេតគ្រប់ករណីអង្គហេតុទាំងអស់ ។ ករណីអង្គជំនុំជម្រះថ្មីៗនេះ វិធានផ្ទៃក្នុងបានបង្កើតរចនាសម្ព័ន្ធមួយដែលលើកទឹកចិត្តមិនចង់ឲ្យមានការ «ផ្លាស់ប្តូរវិធីស៊ើបអង្កេត» ក្នុងអំឡុងពេលដំណើរការតុលាការ ។ ខុសពីតុលាការដែលបានប្រើប្រាស់ច្បាប់ខមិនឡូដែលក្នុងនោះព្រះរាជអាជ្ញា និងមេធាវីចុងចោទត្រូវមើលឃើញថាជា «ម៉ាស៊ីននៃការស៊ើបអង្កេត» ពេញអង្គសវនាការនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គ្មានភាគីណាមួយអាចបន្តស៊ើបអង្កេតភ័ស្តុតាងថ្មីនិងដឹកនាំការស៊ើបអង្កេតថ្មីទៀតទេក្រោយពីតុលាការបានចាប់ផ្តើមហើយ ។ បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេតក្នុងដំណាក់កាលដំបូងដោយព្រះរាជអាជ្ញាក្នុងខែសីហា ឆ្នាំ២០០៧ វិធានផ្ទៃក្នុងបានអនុញ្ញាតឲ្យតែការិយាល័យសហព្រះរាជអាជ្ញាស៊ើបអង្កេតតែមួយគត់ដើម្បីធ្វើការស៊ើបអង្កេត ។ ការិយាល័យសហព្រះរាជអាជ្ញាស៊ើបអង្កេតបានបញ្ចប់កិច្ចការស៊ើបអង្កេតដែលមានរយៈពេលដប់ខែរបស់ខ្លួនអំពីករណី ឌុច នៅខែឧសភា ឆ្នាំ២០០៨ ។ ភ្លាមៗក្រោយពីការិយាល័យស៊ើបអង្កេតបានដាក់ជូនឯកសារនៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ក្រុមការពារក្តី ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងការិយាល័យសហចៅក្រមស៊ើបអង្កេតមិនត្រូវបានផ្តល់សិទ្ធិក្នុងការស៊ើបអង្កេតទៅលើករណី០០១នេះបន្ថែមទៀតទេ ។ ត្រង់ចំណុចនេះ ករណីនេះគឺឋិតក្នុងដំណើរការតុលាការ ហើយជាសិទ្ធិរបស់អង្គបុរេជំនុំជម្រះថាតើត្រូវឲ្យមានការស៊ើបអង្កេតបន្ថែមទៀតឬអត់ ។

## វិធានផ្ទៃក្នុង៩៣របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា -ការស៊ើបអង្កេតបន្ថែម

តាមវិធានផ្ទៃក្នុង៩៣របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានតែអង្គបុរេជំនុំជម្រះមួយគត់ដែលអាចផ្តល់ឲ្យមានការស៊ើបអង្កេតបន្ថែមៈ

១) នៅពេលដែលអង្គបុរេជំនុំជម្រះយល់ឃើញថា ការស៊ើបអង្កេតថ្មីជាកិច្ចការចាំបាច់នៅពេលណាមួយនោះអង្គបុរេ

ជំនុំជម្រះនិងបង្គាប់ឲ្យមានការស៊ើបអង្កេតបន្ថែម ។ ការបង្គាប់បញ្ជានោះនឹងបញ្ជាក់ប្រាប់ថាតើចៅក្រម (ម្នាក់) ឬសហចៅក្រម (ច្រើននាក់) គួរតែធ្វើការស៊ើបអង្កេតថ្មីបន្ថែមទៀតដែរឬទេ ។

២) ក្រោមលក្ខខណ្ឌដូចគ្នានឹងសហចៅក្រមស៊ើបអង្កេតដែរ ចៅក្រមទាំងនោះអាច ក) នឹងធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងដែនសមត្ថកិច្ចច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញ ខ) ធ្វើសម្ភាសន៍សាក្សី គ) ធ្វើការស្រាវជ្រាវ ឃ) ប្រមូលភស្តុតាង ឬ ង) សុំយោបល់ពីអ្នកជំនាញ ។

មកដល់ខែសីហា ឆ្នាំ២០០៩នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានយកវិធានផ្ទៃក្នុង៩៣មកប្រើប្រាស់ទេក្នុងការធ្វើការស៊ើបអង្កេតបន្ថែមក្នុងអំឡុងពេលដំណើរការតុលាការ ។ បែរជាមជ្ឈមណ្ឌលឯកសារកម្ពុជាទៅវិញដែលជាអ្នកធ្វើការស៊ើបអង្កេតបន្ថែម ឬធ្វើការសម្ភាសន៍ជនរងគ្រោះ ហើយប្រគល់ព័ត៌មានទាំងនោះទៅឲ្យអង្គជំនុំជម្រះ ។ ឧទាហរណ៍ដូចជា បើសិនជាមជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានធ្វើការស្រាវជ្រាវបន្ថែមទៅលើប្រវត្តិរូបម្តាយរបស់ នង ចាន់ផល ហើយអង្គជំនុំជម្រះនៅតែរក្សាជំហររបស់ខ្លួនក្នុងការមិនធ្វើការស៊ើបអង្កេតបន្ថែមទេនោះ ម្ល៉េះប្រវត្តិរូបម្តាយរបស់ នង ចាន់ផល មិនត្រូវបានរកឃើញទេ ហើយ នង ចាន់ផល នេះ ក៏មិនត្រូវបានជឿថាជាអ្នកទោសនៅមន្ទីរស-២១ដែរ ។ ជំនួសឲ្យការប្រើប្រាស់វិធានផ្ទៃក្នុង៩៣ ក្នុងការស៊ើបអង្កេតបន្ថែមអំពីខ្សែវីដេអូរបស់មន្ទីរស-២១ និងបុគ្គលដែលមាននៅក្នុងខ្សែវីដេអូនោះ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាម្នាក់បានខំប្រឹងប្រែងយ៉ាងស្វិតស្វាញ ហើយបានរកឃើញប្រវត្តិរូបម្តាយរបស់ នង ចាន់ផល ប្រាកដមែន ក្រោយពីសាក្សី នង ចាន់ផល បានធ្វើសក្ខីកម្មនៅចំពោះមុខតុលាការរួចហើយ ។ ក្រោយពីខ្សែវីដេអូរបស់មន្ទីរស-២១ត្រូវបានរកឃើញ ប្រសិនបើអង្គជំនុំជម្រះបើកការស៊ើបអង្កេតបន្ថែមទៅលើករណីមន្ទីរស-២១នេះ ចៅក្រមអាចបង្គាប់ឲ្យមានការស៊ើបអង្កេតបន្ថែម ហើយអាចទៅយកខ្សែវីដេអូនោះពីមជ្ឈមណ្ឌលឯកសារកម្ពុជាបាន ឬក៏អាចតាមដានសម្ភាសន៍អ្នកដែលមាននៅក្នុងខ្សែវីដេអូនោះមានដូចជា ទាហាន ឬកូនក្មេង ដែលបានអនុញ្ញាតដោយវិធានផ្ទៃក្នុង៩៣(២)(ខ) ។ ព័ត៌មានបន្ថែមទៀតដែលទាក់ទងទៅនឹងឪពុកម្តាយរបស់កុមារដែលរស់រានមានជីវិតគួរតែត្រូវបានស៊ើបអង្កេត ហើយប្រវត្តិរូបរបស់មន្ទីរស-២១ គួរតែត្រូវបានរកឃើញដោយអ្នកស៊ើបអង្កេតដោយមានជំនួយពីសាក្សីនិងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកថតខ្សែវីដេអូឈ្មោះ ហូ វ៉ាន់តៃ បានចូលរួមសហការយ៉ាងពេញលេញជាមួយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយក៏អាចប្រាប់ឲ្យកាន់តែច្បាស់អំពី អត្ថន័យរបស់ខ្សែវីដេអូនោះផងដែរ ។

ជាការពិត ក៏មានគុណវិបត្តិជាច្រើនទាក់ទងនឹងការស៊ើបអង្កេតបន្ថែមក្រោមវិធានផ្ទៃក្នុង៩៣ដែរ ។ ចំណុចដែលរាំងស្ទះគួរឲ្យកត់សម្គាល់បំផុតនោះគឺថាធនធានច្បាប់ដែលមានលក្ខណៈមិនគ្រប់គ្រាន់ តម្រូវឲ្យមានការស៊ើបអង្កេត ប៉ុន្តែក៏មានក្តីបារម្ភមួយដែរថា ការស៊ើបអង្កេតបន្ថែមអាចបណ្តាលឲ្យមានការពន្យារពេលដល់ដំណើរការកាត់ក្តី ។ អង្គសវនាការក៏បានកត់ចំណាំផងដែរថាការពន្យារពេលនៃ ដំណើរការកាត់ក្តីអាចកើតមានបើសិនជា «អង្គសវនាការតម្រូវឲ្យធ្វើការស៊ើបអង្កេតទៅលើរឿងរ៉ាវបន្ថែម» ទៅលើការសម្រេចចិត្តក្នុងការប្រើប្រាស់ខ្សែភាពយន្តរបស់វៀតណាមដូចជាខ្សែវីដេអូរបស់មន្ទីរស-២១ជាដើម ។ ទោះជាមានការអះអាងបែបនេះក្តី ដូចបានបញ្ជាក់កាន់តែច្បាស់តាមការស៊ើបអង្កេតរបស់ ហ៊ុន សុធានី នេះជាការស្វែងរកបន្ថែមអំពីភស្តុតាងឬសាក្សីដែលអាចលាតត្រដាងឯកសារដែលមានតម្លៃមួយចំនួនដូចជាប្រវត្តិរូបម្តាយរបស់ នង ចាន់ផល ជាដើម ។ ក្នុងករណីដែលការបង្គាប់ឲ្យមានការស៊ើបអង្កេតបន្ថែមដោយអង្គជំនុំជម្រះទំនងជាត្រូវបំពេញកិច្ចការនិងធនធានច្បាប់ច្រើននោះកិច្ចការនេះអាចនឹងធ្វើការខាងក្រៅតុលាការ ហើយការធ្វើបែបនេះក៏បានអនុញ្ញាតឲ្យតុលាការដំណើរការដូចប្រក្រតីដែរ ។ ចំណាយដ៏សន្ធឹកសន្ធាប់សម្រាប់កិច្ចការទាំងនោះដែលត្រូវធ្វើជាចាំបាច់ក្នុងនោះក៏ទទួលបាននូវភស្តុតាងច្រើន ឬក៏អាចបង្កើតជាសំណួរច្រើនសម្រាប់សាក្សីនៅឯតុលាការផងដែរ ព្រោះចៅក្រមអាចនឹងបានដឹងពីបញ្ហានេះរួចហើយ ។ ប៉ុន្តែក្តីបារម្ភសំខាន់បំផុតនោះគឺនៅតែជាបញ្ហាដដែលត្រង់ថាតើចៅក្រមដែលតែងតាំងដោយអង្គជំនុំជម្រះនោះអាចនឹងមានចំណាប់អារម្មណ៍ដូចភាគីផ្សេងទៀតក្នុងការស៊ើបអង្កេតបន្ថែមដែរឬអត់ ។

នៅពេលដែលខ្សែវីដេអូរបស់មន្ទីរស-២១លេចចេញជារូបរាងឡើងជាសាធារណៈនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ ជាជាងអង្គជំនុំជម្រះបានបង្កើតឲ្យមានការស៊ើបអង្កេតបន្ថែមក្រោមវិធានផ្ទៃក្នុង៩៣ អ្នកស៊ើបអង្កេតរបស់ការិយាល័យសហព្រះរាជអាជ្ញាឈ្មោះ គ្រេក អេតនេសាន់ និងព្រះរាជអាជ្ញាជាន់ខ្ពស់ តាន់ សេណារ៉ុង បានចាក់ខ្សែវីដេអូមើលនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីដើមខែមករា ឆ្នាំ២០០៩ ។ ករណីនេះនៅតែមិនច្បាស់ត្រង់ថាតើវិធានផ្ទៃក្នុងជាអ្នកផ្ដល់សិទ្ធិឲ្យ អេតនេសាន់ និង តាន់ សេណារ៉ុង ក្នុងការមើលសាកល្បង ឬការមើលខ្សែភាពយន្តនេះជាការស៊ើបអង្កេតបន្ថែម ដើម្បីរកភស្តុតាងថ្មី ។ ប៉ុន្តែ ពេលដែលក្រុមព្រះរាជអាជ្ញាយល់ឃើញថា វីដេអូគឺជាការសាកល្បង ពេលនោះក្រុមព្រះរាជអាជ្ញាមានជម្រើសតិចណាស់ក្នុងការចាត់ទុកខ្សែវីដេអូទាំងនោះជាភស្តុតាងតែត្រូវតែព្យាយាមសារភាពថា ការទទួលយកវីដេអូនោះជាភស្តុតាង គឺឋិតនៅក្រោមវិធានផ្ទៃក្នុង៩២ ដែលចែងថា «រហូតដល់ថ្ងៃបិទសេចក្ដីថ្លែងការណ៍ ភាគីទាំងអស់ត្រូវដាក់សំណើជូនជាលាយលក្ខណ៍អក្សរ ...ហើយប្រគល់ជូនទៅចំពោះមុខអង្គសវនាការនូវរាល់ភស្តុតាងទាំងអស់ដែលចាត់ទុកថាជាយន្តការដែលអាចផ្ដល់ការពិតបាន» ហើយវិធានផ្ទៃក្នុង៣៩(៤) ដែលចែងអំពីភាពយឺតយ៉ាវ ក្នុងការផ្ដល់ជូនភស្តុតាងនិងការពន្យារពេលនៃការបំពេញបែបបទ» ។

### វិធានផ្ទៃក្នុង៨៧(៤) ការបង្ហាញភស្តុងតាងថ្មីក្នុងអំឡុងពេលសវនាការ

ក្នុងខែមីនា ឆ្នាំ២០០៩ គណៈកម្មការវិន័យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុម័តវិធានផ្ទៃក្នុង៨៧ ស្ដីអំពីវិធាននៃភស្តុតាងដោយដាក់បន្ថែមចំណុចមួយចំនួនៈ

**វិធានផ្ទៃក្នុង៨៧(៤)ៈ**

ក្នុងអំឡុងសវនាការ តាមគំនិតផ្ដួចផ្ដើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅឬស្ដាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សីឬទទួលយកនូវភស្តុតាងថ្មីដែលមាន ប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ។ គ្រប់ភាគីណាដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់....។ ភាគីដែលបានស្នើសុំ ត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្មឬភស្តុតាងដែលបានស្នើសុំនោះពុំអាចរកបាននៅមុនពេលការចាប់ផ្ដើមជំនុំជម្រះ ។

មកដល់ឥឡូវនេះ វិធានផ្ទៃក្នុងលេខ៨៧(៤) គឺជាមធ្យោបាយតែមួយគត់ ក្នុងការដាក់ជូនភស្តុតាងថ្មីសម្រាប់ការដាក់បញ្ចូល ឬសាក្សីថ្មីក្នុងអំឡុងពេលសវនាការ ។ ដូច្នេះការិយាល័យសហព្រះរាជអាជ្ញាគ្មានជម្រើសអ្វីផ្សេងទៀតទេ ប៉ុន្តែត្រូវតែដាក់ជូនភស្តុតាងដែលទើបតែរកឃើញថ្មីដោយអនុលោមតាមវិធាន៨៧(៤) ។ ប៉ុន្តែវិធាន៨៧(៤) មិនបានផ្ដល់ជូនអ្វីមួយដែលអាចផ្ដល់សិទ្ធិឲ្យភាគីទាំងសងខាង ដើម្បីធ្វើការស៊ើបអង្កេតបន្ថែមក្នុងការរុករកភស្តុតាងនិងសាក្សីថ្មីឡើយ ។ លើសពីនេះទៅទៀត តាមវិធាន៩៣ ទាំងភាគីព្រះរាជអាជ្ញានិងភាគីដទៃទៀត មិនត្រូវអនុញ្ញាតឲ្យដាក់សំណើទៅអង្គជំនុំជម្រះដើម្បី ធ្វើការស៊ើបអង្កេតបន្ថែមទេ ។ នៅពេលដែលវិធាន៨៧(៤)អនុញ្ញាតឲ្យភាគីមួយដើម្បីសុំបន្ថែមសាក្សីថ្មីមួយ ដោយបញ្ជាក់ពីហេតុផលក្នុងការបន្ថែមនោះ នៅតែមិនមានភាពច្បាស់លាស់ដដែលថាតើព័ត៌មានច្រើនប៉ុន្មានដែលត្រូវការដើម្បីឲ្យសំណើនោះត្រូវបានយកទៅពិចារណាថា «ជាសំណើមានហេតុផល» ។ ប្រសិនបើភស្តុតាងថ្មីមួយលេចឡើង លក្ខណៈនៃការស៊ើបអង្កេតខ្វះដោយភាគីទាំងសងខាងគឺអាចនឹងតម្រូវឲ្យមានការដាក់សុំដោយបញ្ជាក់ហេតុផលច្បាស់លាស់ ។ ក្នុងស្ថានភាពនោះ អ្វីជាវិធានដែលអាចផ្ដល់សិទ្ធិឲ្យភាគីព្រះរាជអាជ្ញា ភាគីចុងចោទឬដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីធ្វើការស៊ើបអង្កេតបន្ថែម? ហើយប្រសិនបើវិធាននោះ មិនបានផ្ដល់សិទ្ធិឲ្យទេ តើមជ្ឈមណ្ឌលឯកសារកម្ពុជាឬអង្គការផ្សេងទៀតនឹងត្រូវបង្ខាប់ឲ្យធ្វើការស៊ើបអង្កេតបន្ថែមសម្រាប់ភាគីទាំងនោះបានដែរឬទេ?

វិធាន៨៧(៤) បានអនុញ្ញាតឲ្យមានការដាក់ជូននូវភស្តុតាងនិងសាក្សីថ្មីបានក៏ពិតមែន តែមិនមានទម្រង់បែបបទច្បាស់លាស់ណាមួយក្នុងការផ្ដល់សិទ្ធិឲ្យអ្នកស៊ើបអង្កេតដែលតែងតាំងដោយអង្គសវនាការ ក្នុងការស្វែងរកភស្តុតាំងនិងសាក្សីទេ ។ វិធានដែលបានធ្វើវិសោធនកម្មនេះហាក់បីដូចជាមានលក្ខណៈស្រដៀងគ្នាច្រើនទៅនឹងប្រព័ន្ធច្បាប់**ខំមិនឡ** ត្រង់ថាភស្តុតាងគឺត្រូវបានបង្ហាញលើកទីមួយនៅឯតុលាការ ហើយត្រូវបានសួរដេញដោល

ដោយភាគីទាំងសងខាងនៅតុលាការ ។ កន្ទះខាតនៃកិច្ចការស៊ើបអង្កេតអាចនឹងនាំឲ្យតុលាការចំណាយពេលយូរ ព្រោះសាក្សីថ្មីឬភ័ស្តុតាងដែលបានដាក់ជូននឹងត្រូវយកមកពិភាក្សា និងពិគ្រោះដោយអង្គសវនាការ ការិយាល័យសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមការពារក្តីនៅពេលសវនាការលើកទីមួយ ។

## ការរកឃើញខ្សែវីដេអូបន្ថែមថ្មីពីជំនាន់កម្ពុជាប្រជាធិបតេយ្យ

ពេលអនាគតដ៏ខ្លីខាងមុខនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងបង្ហាញនូវខ្សែភាពយន្តឯកសារបន្ថែមទៀតដែលអាចជាភ័ស្តុតាងដ៏មានសក្តានុពលក្នុងការរកសាក្សីថ្មីបើអាច ។ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ វៀតណាមបានអះអាងបញ្ជាក់ប្រាប់លោក ឆាំង យុ ថា កាលពីឆ្នាំ១៩៧៩ រថយន្តយោធាធំមួយគ្រឿងរបស់វៀតណាមដែលដឹកទៅដោយហ៊ីលឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ បានដឹកពីភ្នំពេញឆ្ពោះទៅកាន់ទីក្រុងហូជីមិញ ។ ពេលមកដល់ប្រទេសវៀតណាមភ្លាម ខ្សែភាពយន្តទាំងនោះ ត្រូវបានតម្កល់ទុកនៅក្នុងបណ្ណសារដ្ឋានរដ្ឋរបស់វៀតណាម ។ លោក ឆាំង យុ បានកត់សម្គាល់ថា កាលពីដំបូងបុគ្គលិករបស់បណ្ណសារដ្ឋានមានការស្ទន់ស្ទើរ នៅពេលដែលគាត់សួរនាំអំពីខ្សែភាពយន្តទាំងនោះ ព្រោះថាទីតាំងពិតប្រាកដរបស់ខ្សែភាពយន្តទាំងនោះមិនត្រូវបានរកឃើញទេ ។ រយៈពេល៣០ឆ្នាំកន្លងមកនេះ បណ្ណសារដ្ឋានត្រូវបានផ្លាស់ប្តូរទីតាំង ចំណែកឯខ្សែភាពយន្តត្រូវវង្វេងបាត់ឬដាក់ច្រឡំកន្លែង ។ ប៉ុន្តែដោយចំណាយពេលរកពេញមួយថ្ងៃ លោក ឆាំង យុ និងបុគ្គលិកបណ្ណសារដ្ឋានបានរកឃើញខ្សែវីដេអូទាំងនោះ ។ ខណៈពេលដែលដុំហ្វីលជាច្រើនបានពុកខូចនិងបាត់ពេលដឹកតាមរថយន្ត យ៉ាងហោចណាស់ក៏មានដុំហ្វីល៣១ដុំដែរដែលស្ថិតក្នុងលក្ខណៈល្អប្រសើរ ។ ជាភ័ព្វវាសនាល្អ មានការជឿជាក់ថាខ្សែភាពយន្តដែលពុកផុយត្រូវបានដាក់ទុកនៅកន្លែងផ្សេងគ្នា ហើយក៏មាននៅកន្លែងផ្សេងទៀតដែរ ។ ថ្ងៃណាមួយ ដុំហ្វីលដែលហៀបនឹងពុកខូចនឹងត្រូវបានយកមកពិនិត្យដើម្បីជួយសង្គ្រោះខ្សែភាពយន្តទាំងនេះ ។

ខ្សែភាពយន្តចំនួន៣១ដុំស្ថិតក្នុងលក្ខណៈយ៉ាងល្អប្រសើរ ហើយខ្សែភាពយន្តទាំងអស់នោះ សុទ្ធតែមានទាក់ទងនឹងរបបកម្ពុជាប្រជាធិតេយ្យ ។ ខ្សែភាពយន្តចំនួន៣១ដុំនេះ គ្រាន់តែជាផ្នែកដ៏តូចមួយប៉ុណ្ណោះ ។ ខ្សែភាពយន្តរាប់រយទៀត អាចនឹងលេចចេញជារូបរាងឡើង ។ កាលពីថ្ងៃសុក្រ ទី៣១ ខែកក្កដា ឆ្នាំ២០០៩ លោក ឆាំង យុ គ្រោងនឹងនាំយកមកប្រទេសកម្ពុជានូវខ្សែភាពយន្តចំនួន៩ ក្នុងចំណោមខ្សែភាពយន្តទាំង៣១នោះ ។ ខ្សែភាពយន្តទាំង៩នេះពិពណ៌នាអំពីៈ គណៈប្រតិភូមួយក្រុមរួមមាន អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ ជួបសំណេះសំណាលជាមួយមេដឹកនាំចិន ម៉ៅ សេទុង ការលុកលុយរបស់ខ្មែរក្រហមចូលក្នុងទឹកដីវៀតណាម និងឈុតឆាកកងទ័ពវៀតណាមជាច្រើនឈុត នៅក្នុងប្រទេសកម្ពុជាកាលពីចុងទសវត្សរ៍៧០ ។ ក្រៅពីខ្សែភាពយន្តដែលបានរកឃើញក៏មានរូបថតចំនួនពីររយសន្លឹកទៀត ត្រូវបានរកឃើញផងដែរនៅក្នុងធុងសំរាម ក្នុងបន្ទប់ក្រោមដី នៃអគាររបស់បណ្ណសារដ្ឋាន ដែលរូបថតទាំងនេះប្រហែលជាគេមិនដឹងថានៅទីនោះទេ ។ រូបថតទាំងនេះទាក់ទងនឹងសម័យកម្ពុជាប្រជាធិតេយ្យដែរ ។ ឥឡូវនេះ រូបថតទាំងនោះកំពុងតែត្រូវបានសម្អាត ស្កេនទុកជាឯកសារ និងចុះក្នុងបញ្ជី ។

ខ្សែភាពយន្តនិងរូបថតទាំងអស់នោះនឹងបញ្ជូនទៅកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្សែវីដេអូទាំងនេះ ក៏នឹងត្រូវបានយកទៅវិភាគដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ដើម្បីស្វែងយល់អំពីតម្លៃរបស់ខ្សែភាពយន្តនោះ ។ បុគ្គលមួយចំនួនដែលមាននៅក្នុងខ្សែវីដេអូនេះ ព្រមទាំងអ្នកថតខ្សែភាពយន្តផ្ទាល់អាចជាសាក្សីផងដែរ ។ សំណួរដែលត្រូវចោទសួរគឺថាៈ តើនរណាជាអ្នកធ្វើការស៊ើបអង្កេតទៅលើខ្សែភាពយន្ត ដែលទើបតែរកឃើញនេះ ដើម្បីកំណត់ថាតើខ្សែភាពយន្តទាំងនេះអាចយកមកប្រើប្រាស់សម្រាប់កាត់ទោស ឌុច បានឬទេ? យោងទៅតាមច្បាប់**ស៊ីវិលឡ**របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការិយាល័យសហព្រះរាជអាជ្ញា មិនត្រូវបានផ្តល់សិទ្ធិឲ្យធ្វើការស៊ើបអង្កេតក្នុងអំឡុងពេលសវនាការកំពុងតែកើតហើយនោះទេ ។ មានតែអង្គសវនាការប៉ុណ្ណោះ ដែលអាចបង្គាប់ឲ្យធ្វើការស៊ើបអង្កេតបន្ថែមបានក្រោមវិធាន៩៣ ។ ប៉ុន្តែអង្គសវនាការមិនបានបង្ហាញការបដិសេធណាមួយស្តីពីការបង្គាប់បញ្ជាឲ្យមានការស៊ើបអង្កេតបន្ថែមនោះទេ ដោយសារតែដំណើការតុលាការមានការពន្យារពេល ។ ប្រសិនបើអង្គសវនាការមិនបានបង្គាប់ឲ្យមានការស៊ើប

អង្កេតបន្ថែម នៅពេលភស្តុតាងថ្មីលេចចេញជារូបរាងឡើង ការស៊ើបអង្កេតនាដំណាក់កាលមុនដោយភាគីនោះត្រូវតែដាក់សំណើអំពីហេតុផលជាកិច្ចការចាំបាច់បំផុត ។ ដូចបានរៀបរាប់ខាងលើរួចហើយ វិធានផ្ទៃក្នុងមិនអាចបង្គាប់បញ្ជាព្រះរាជអាជ្ញា ក្រុមការពារក្តី និងភាគីរដ្ឋប្បវេណីដើម្បីឲ្យធ្វើការស៊ើបអង្កេតបានទេ ។

**តើការស៊ើបអង្កេតបន្ថែមពិតជាច្រើនហួសតម្រូវការមែនដែរឬទេ?**

ទាក់ទិននឹងសេចក្តីសម្រេចលើខ្សែវីដេអូដកស្រង់របស់វៀតណាម ចៅក្រមបានបញ្ជាក់យ៉ាងច្បាស់ថា ការស៊ើបអង្កេតបន្ថែមណាក៏ដោយ អាចនឹងមានច្រើនហួសពីតម្រូវការ ហើយអាចពន្យារដំណើរការនីតិវិធីបាន ។ យ៉ាងណាមិញ ការស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹងខ្សែវីដេអូ មន្ទីរស-២១ បានកែប្រែលទ្ធផលនៃដំណើរការនីតិវិធី ហើយទោះបីជាគ្មានការស៊ើបអង្កេត និងការរកឃើញនូវប្រវត្តិរូបម្តាយរបស់ នង ចាន់ផល នៅមន្ទីរស-២១ក៏ដោយ ក៏ខ្សែវីដេអូ ឬរូបភាពនៅមន្ទីរស-២១ អាចក្លាយជាភស្តុតាងដ៏សំខាន់មួយ សម្រាប់បញ្ហាវិវាទដ៏ក្តៅគគុកថាតើកូនរបស់អ្នកទោសបានមានវត្តមាននៅមន្ទីរស២១ដែរឬទេ ។ ទោះបីជាសេចក្តីសម្រេចរបស់ចៅក្រម បានកត់សម្គាល់លើមូលហេតុត្រឹមត្រូវជាច្រើននៃការមិនចង់រៀបចំការស៊ើបអង្កេតបន្តទៀតក៏ដោយ ក៏សេចក្តីសម្រេចនេះមិនបានដោះស្រាយបញ្ហាឫសគល់ គឺភាពខ្វះឆន្ទៈក្នុងការស៊ើបអង្កេត ដែលបានកើតមានឡើងក្នុងដំណើរការកាត់ក្តីជាបន្តបន្ទាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ពីព្រោះថាមានតែចៅក្រមប៉ុណ្ណោះដែលអាចបញ្ជាឲ្យមានការស៊ើបអង្កេតបន្ថែមក្នុងពេលនោះបាន ។

សេចក្តីសម្រេចលើខ្សែវីដេអូដកស្រង់របស់វៀតណាម បានខកខាននិយាយថា កញ្ញា ហ៊ិន សុធានី បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ជាអ្នករកឃើញប្រវត្តិរូបម្តាយរបស់ នង ចាន់ផល នៅ មន្ទីរស-២១ ក្រោយពី ចាន់ ផល បានផ្តល់សក្ខីកម្មរួចមក ។ ប្រសិនបើគ្មានការស៊ើបអង្កេតរបស់របស់កញ្ញា សុធានី ក៏គ្មានប្រវត្តិរូបម្តាយរបស់ ចាន់ ផល ដែរ ហើយប្រសិនបើគ្មានប្រវត្តិរូបម្តាយ នង ចាន់ផល ឌុច នឹងមិនបានទទួលស្គាល់ថា ចាន់ ផល ពិតជាមានវត្តមាននៅមន្ទីរស-២១ឡើយ ។ ហើយប្រសិនបើគ្មានការទទួលស្គាល់របស់ ឌុច ទេ ខ្សែវីដេអូនៅមន្ទីរស-២១ (ឬឯកសារក្នុងសំណុំរឿងដែលប្រើរូបភាព) អាចក្លាយជាភស្តុតាងមួយដែលអាចសម្រេចបាន ។ លទ្ធផលនេះ គឺដោយសារតែការស៊ើបអង្កេតដែលធ្វើឡើងដោយខ្លួនឯងរបស់កញ្ញា សុធានី កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩ ខណៈពេលដែលសហព្រះរាជអាជ្ញាបានស្នើថាប្រវត្តិរូបម្តាយ នង ចាន់ផល ដែលរកឃើញថ្មី អាចយកមករួមបញ្ចូលក្នុងសំណុំរឿងបានហើយអាចពិចារណាដោយដាក់ក្នុងការពិភាក្សាក្នុងអង្គសវនាការដែលធ្វើឲ្យ ឌុច ទទួលស្គាល់ប្រវត្តិរូបម្តាយ ចាន់ ផល នៅមន្ទីរស-២១ វត្តមានរបស់ម្តាយ នង ចាន់ផល នៅមន្ទីរស-២១ នឹងទទួលស្គាល់វត្តមានរបស់ នង ចាន់ផល ផ្ទាល់នៅមន្ទីរស-២១នេះផងដែរ ។

ការព្រួយបារម្ភរបស់ចៅក្រមដែលថា ការពន្យារដំណើរការកាត់ក្តីអាចក្លាយជាលទ្ធផល ប្រសិនបើចៅក្រមត្រូវតែធ្វើការពិចារណាលើសេចក្តីស៊ើបអង្កេតបន្ថែមមួយចំនួន និងមានភាពត្រឹមត្រូវតាមផ្លូវច្បាប់ ។ ប៉ុន្តែ ដូចដែលបានបង្ហាញតាមរយៈការស៊ើបអង្កេតរបស់កញ្ញា ហ៊ិន សុធានី ការស៊ើបអង្កេតបន្ថែមធម្មតាទាក់ទងនឹងភស្តុតាង ឬសាក្សីថ្មីមួយចំនួន អាចនឹងស្វែងរកឃើញនូវឯកសារដែលមិនអាចប្រកែកតវ៉ាបាន ។ ភស្តុតាងដែលមិនអាចប្រកែកតវ៉ាបាននឹងតម្រូវឲ្យភាគីមួយសារភាពនូវការពិតនៃហេតុការណ៍វិវាទដែលកើតមានឡើងកាលពីមុន ។ នៅពេលដែលហេតុការណ៍វិវាទត្រូវបានទទួលស្គាល់ជាការពិត ចៅក្រមបានជួបនូវបញ្ហាដែលមិនស្ញូវចម្រូងចម្រាសមួយមុននេះ ។ ដើម្បីធានាអះអាងថា ខ្សែវីដេអូនៅមន្ទីរស-២១ មានច្រើនហួសតម្រូវការ គឺមិនមែនជារបាយការណ៍ដែលប្រកបដោយសមភាពមួយទេ ហើយចៅក្រមបានបន្ទុំទុកមិនឲ្យនរណាដឹងពីការស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទង្វើនេះបានធ្វើឲ្យមានការចាំបាច់មួយដើម្បីធ្វើឲ្យខ្សែវីដេអូនៅមន្ទីរស២១មានច្រើនហួសតម្រូវការ ។

បន្ថែមលើនេះ ចៅក្រមបាននិយាយថា ដើម្បីបញ្ជាក់ថាខ្សែវីដេអូនៅមន្ទីរស-២១មានភាពពិតប្រាកដ អាចនឹងតម្រូវឲ្យមានការស៊ើបអង្កេតបន្ថែម រួមមានការបង្ហាញនូវអត្តសញ្ញាណនិងការកោះហៅសាក្សីបន្ថែមទៀតហើយការធ្វើបែបនេះអាចនាំឲ្យមានភាពយឺតយ៉ាវដល់ដំណើរការកាត់ក្តី ។ វាមិនមានភាពច្បាស់លាស់ថាហេតុអ្វីបានជាការបង្ហាញអត្តសញ្ញាណឬការកោះ

ហៅសាក្សី អាចនឹងមានសារសំខាន់ បើលោក ហូ វ៉ាន់តៃ បានប្រកាន់ជំហរថាគាត់នឹងស្ម័គ្រចិត្តចូលរួមសហការនៅគ្រប់កាលៈទេសៈសំខាន់ទាំងអស់តាំងពីដើមឆ្នាំ២០០៩មក ហើយថ្មីៗនេះលោក ហូ វ៉ាន់តៃ ក៏បានអះ អាងសាជាថ្មីម្តងទៀតកាលពីខែកក្កដាឆ្នាំ២០០៩នេះថែមទៀត ។ លើសពីនេះ វាក៏មិនមានភាពច្បាស់លាស់ផងដែរថាហេតុអ្វី «សេចក្តីសម្រេចបញ្ជាក់ពីភាពដែលអាចជឿបាន» នៃខ្សែវីដេអូដកស្រង់នេះ អាចនឹងមិនទទួលបាននូវពេលវេលាមួយដ៏សមរម្យនោះទេ ។ ចៅក្រមអាចកោះហៅលោក ហូ វ៉ាន់តៃ ដើម្បីចូលខ្លួនមកផ្តល់សក្ខីកម្មនៅដើមឆ្នាំ២០០៩នេះ ហើយប្រសិនបើចៅក្រមដែលតែងតាំងថ្មីនេះបានធ្វើការពិចារណាលើលោក ហូ វ៉ាន់តៃ មុនដំណើរការកាត់ក្តី នោះការផ្តល់សក្ខីកម្មរបស់លោក ហូ វ៉ាន់តាយ នៅក្នុងអង្គសវនាការអាចនឹងពិភាក្សាពីបញ្ហាមួយតែប៉ុណ្ណោះគឺការបញ្ជាក់ពីភាពពិតប្រាកដ និងភាពដែលអាចជឿបានលើខ្សែវីដេអូនៅមន្ទីរស-២១នេះ ។

ដើមហេតុនៃបញ្ហានេះគឺបណ្តាលមកពីកង្វះឆន្ទៈក្នុងការស៊ើបអង្កេតក្នុងដំណើរកាត់ក្តីជាបន្តបន្ទាប់ ។ ប្រសិនបើចៅក្រមមិនបានបញ្ជាឲ្យមានការស៊ើបអង្កេតបន្ថែមខណៈពេលដែលភ័ស្តុតាងថ្មីមួយចំនួនបានដាក់បញ្ចូលជាឧទាហរណ៍ ដុំហ្វីលចំនួន៣១ ដែលបន្សល់ទុកតាំងពីសម័យកម្ពុជាប្រជាធិបតេយ្យ ដែលរកឃើញកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ នោះរបៀបនៃការស៊ើបអង្កេតដែលផ្តើមពីដំបូងដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី អាចសន្មតថាពិតជាភាពចាំបាច់ដើម្បីអនុញ្ញាតឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីដាក់ជូននូវសេចក្តីសន្និដ្ឋានដ៏សមហេតុផលមួយក្រោមវិធាន៨៧(៤) បាន ។ ដោយសារតែភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឲ្យធ្វើការស៊ើបអង្កេត ហើយតុលាការហាក់បីដូចជាមិនមានឆន្ទៈដងនោះ តើខ្សែវីដេអូនិងរូបភាពដែលរកឃើញថ្មីៗទាំងនេះអាចនឹងមិនទទួលស្គាល់ក្រោមវិធាន៨៧(៣)ដែរឬទេ? តើខ្សែវីដេអូ និងរូបភាពទាំងនេះនឹងអាចចាត់ទុកថាច្រើនហួសហេតុពេក និងជួនគ្នាដោយសារតែខ្សែវីដេអូនិងរូបភាពទាំងនេះអាចនាំឲ្យមានការស៊ើបអង្កេតបន្ថែម ឬនាំឲ្យមានភាពយឺតយ៉ាវដល់ដំណើរការកាត់ក្តីមែនឬទេ? ការពិនិត្យលើភ័ស្តុតាងនិងសាក្សីថ្មីនៅខាងក្រៅអង្គសវនាការ ខណៈពេលដែលខ្សែវីដេអូនិងរូបភាពទាំងនេះត្រូវបានរកឃើញតាំងពីដំបូងនោះ មិនមែនជាមូលហេតុដែលនាំឲ្យមានភាពយឺតយ៉ាវនោះទេ ។ ជាក់ស្តែងភាពយឺតយ៉ាវបណ្តាលមកពីការអនុញ្ញាតឲ្យមានប្រធានបទផ្សេងៗនិងការចំណាយធនធាន និងពេលវេលាចាំបាច់នៅក្នុងអង្គសវនាការលើពិភាក្សាពីមូលហេតុថាតើភស្តុតាងគួរ ឬមិនគួរទទួលស្គាល់ខណៈពេលដែលសេចក្តីរាយការណ៍ឬសាក្សីមិនទាន់ត្រូវបានស៊ើបអង្កេតត្រឹមត្រូវនៅឡើយនោះ ។

## សេចក្តីសន្និដ្ឋាន

ការដោះស្រាយភាពខ្វះខាតនូវឆន្ទៈក្នុងការស៊ើបអង្កេតដែលកើតមានឡើងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាពេលនេះដែលធ្វើឡើងតាមរយៈវិសោធនកម្មលើវិធានផ្ទៃក្នុងដើម្បីអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការស្នើសុំការស៊ើបអង្កេតបន្ថែមទៀត ឬការបញ្ជាក់ដោយចៅក្រមពីទំនួលខុសត្រូវរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺស្ថិតនៅឃ្លាតឆ្ងាយពីការស្វែងរកក្របខណ្ឌពិតប្រាកដណាស់ ។ ខ្សែវីដេអូនៅមន្ទីរស-២១ ម៉ាស៊ីនរ៉ូវ៉ៃខ្សែភាពយន្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលទើបរកឃើញថ្មី និងអត្ថបទបន្ថែមនានាស្តីពីខ្សែភាពយន្តដែលបានបាត់កាលពីសម័យកម្ពុជាប្រជាធិបតេយ្យនៅប្រទេសបារាំងបានជួយគាំទ្រដល់ការជជែកវែកញែកនេះ ។

ទោះបីជាធនធាន និងពេលវេលាមានកំណត់ ជាឧបសគ្គតាំងពីដើមមករបស់តុលាការក៏ដោយ ក៏ដំណោះស្រាយមិនបានរារាំងភ័ស្តុតាងថ្មីរបស់តុលាការឡើយ ។ ដើម្បីបដិសេធថាការស៊ើបអង្កេតបន្ថែមពិតជាមានសារសំខាន់ដើម្បីចៀសវាងបញ្ហាដែលអះអាងថាការរកឃើញជាបន្តបន្ទាប់ឥតឈប់ឈរ មិនមាននៅក្នុងវិវាទនេះឬដើម្បីធ្វើឲ្យដំណើរការនីតិវិធីមិនមានសារសំខាន់ នោះគឺជាចម្លើយដ៏ងាយស្រួលមួយនាពេលនេះដើម្បីធ្វើការចៀសវាងឫសគល់នៃបញ្ហានេះ ។ ជាក់ស្តែង នីតិវិធីនៃការស៊ើបអង្កេតដែលជាប់ពាក់ព័ន្ធគ្នាដ៏សំខាន់មួយក្នុងដំណើរការកាត់ទោសឌុច និងដំណើរការកាត់ទោស ករណី០០២ ដ៏ស្មុគស្មាញបំផុតនេះ នឹងជួយបង្កើនគុណភាពភ័ស្តុតាងដែលបង្ហាញជូនដល់ចៅក្រម និងជាចុងបញ្ចប់នឹងនាំមកនូវដំណើរការកាត់ក្តីដ៏ទាន់ពេលវេលាមួយ ។

**ស្បេនស៊ើ ខ្វារ៉េឌ**

# ហេតុអ្វីបានជាវិប្បដិសារីមិនចោទជាបញ្ហា នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា?

*«រាល់ពេលដែលខ្ញុំភ្ញាក់ពីអតីតកាល ខ្ញុំនៅតែជិតជាប់នឹងវិប្បដិសារីដែលខ្ញុំធ្លាប់មានជានិច្ច ។ ខ្ញុំនឹងមិនក្បត់វិប្បដិសារីរបស់ខ្ញុំ ហើយខ្ញុំនឹងមិនបណ្តោយឲ្យវិប្បដិសារីនេះសាបសូន្យឡើយ ។ ខ្ញុំនឹងចងចាំវាជានិច្ច ។ ខ្ញុំពិតជាឈឺចាប់ណាស់ ។» កាំង ហ្គេកអ៊ាវ (ហៅ ឌុច)*

តាមការរៀបរាប់ដែលហាក់បីដូចជាមានភាពស្មោះត្រង់ លោក កាំង ហ្គេកអ៊ាវ (ហៅ ឌុច) បានសម្តែងពីវិប្បដិសារីសម្រាប់ឧក្រិដ្ឋកម្មដ៏សាហាវដែលបានកើតឡើងក្រោមបញ្ជារបស់ខ្លួនក្នុងនាមជាប្រធានគុកទួលស្លែង(ស-២១) ក្នុងអំឡុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ។ ឌុច បានទទួលស្គាល់ទំនួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងនោះ និងមិនបានស្តីបន្ទោសដល់អ្នកនៅក្រោមបញ្ជាសម្រាប់ទង្វើដ៏សាហាវឃោរឃៅនិងថោកទាបបំផុតដែលបានប្រព្រឹត្តិលើអ្នកទោសរបស់មន្ទីរស-២១ឡើយ ។ យ៉ាងណាមិញ ឌុច នៅតែប្រកាន់គោលជំហរថាគាត់បានប្រព្រឹត្តឧក្រិដ្ឋកម្មនេះតាមការបង្ខិតបង្ខំតែប៉ុណ្ណោះ ។ ឌុចបានអះអាងថា ប្រសិនបើគាត់មិនអនុវត្តតាមបញ្ជានៃរបបនេះ ដោយមិន«កម្ទេច» អ្នកទោសនៅមន្ទីរស-២១ទេ នោះគាត់និងគ្រួសារគាត់អាចនឹងត្រូវសម្លាប់ក្នុងរបបនេះជាមិនខាន ។

ដូច្នេះ ឌុច ហាក់បីដូចជាបានស្វែងយល់ពីយុត្តិសាស្ត្រដំណោះស្រាយពីរបៀបសម្រាប់ការពារខ្លួន ។ ដោយដឹងពីបន្ទុកនៃភ័ស្តុតាងដែលចោទប្រកាន់ ឌុច ថាជាអ្នកមានអំណាចដ៏សំខាន់បំផុតក្នុងមន្ទីរស-២១ ឌុច ក៏មិនបានជំទាស់នឹងកំហុសរបស់ខ្លួនដែរ ។ ឌុច បានសង្កត់ធ្ងន់លើហេតុផលដែលធ្វើឲ្យភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់ខ្លួនមានភាពធូរស្រាលដោយការសម្តែងនូវវិប្បដិសារី ស្របពេលដែល ឌុច នៅតែបន្តអះអាងថាខ្លួនបានប្រព្រឹត្តឧក្រិដ្ឋកម្មនេះក្រោមការបង្ខិតបង្ខំជានិច្ច ។ ឌុច ហាក់បីដូចជាអត់ធ្មត់ នៅពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់កំហុសរបស់គាត់ ។ ប៉ុន្តែ ឌុច នៅតែប្តេជ្ញាចិត្តដើម្បីធ្វើឲ្យការកាត់ទោសរបស់គាត់មានភាពធូរស្រាល ។ ច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនអនុញ្ញាតឲ្យមានការបន្ធូរបន្ថយក្នុងការកាត់ទោសឡើយ ប៉ុន្តែតុលាការប្រហែលជានឹងដកយកនូវយុត្តិសាស្ត្រមួយចំនួនពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលជាវិប្បដិសារីមួយដ៏ពិតប្រាកដទាក់ទិននឹងការបន្ធូរបន្ថយការកាត់ទោសនេះ ។

ក្នុងបរិបទនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យុត្តិសាស្ត្រដែលទិតជិតនេះ អាចនឹងនាំទៅកាន់ផ្លូវខុស ។ ជាពិសេសទាក់ទងជាមួយនឹង ឌុច វិប្បដិសារីមិនគួរក្លាយជាកត្តាបន្ធូរបន្ថយទោសបានឡើយ ពីព្រោះថា ៖

១) វាមិនជាប់ទាក់ទង (ហើយដែលខុស) នឹងការសម្តែងនូវវិប្បដិសារី និងការអះអាងពីការគំរាមគំហែងដែលកើតមានលើសកម្មភាពរបស់បុគ្គលម្នាក់

២) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនត្រូវបានរៀបចំខ្លួនសម្រាប់ប៉ាន់ស្មានលើសមាសភាពពិតនៃវិប្បដិសារីរបស់ជនជាប់ចោទនៅឡើយទេ

៣) វិប្បដិសារីមិនបានជួយពង្រីកទិសដៅសម្រាប់យុត្តិធម៌របស់ឧក្រិដ្ឋកម្មដូចជា នីតិសម្បទា ការអស់សមត្ថភាព ការការពារមិនឲ្យកើតមានម្តងទៀត ការសម្រេចកាត់ទោស ឬយុត្តិធម៌ដែលជានិមិត្តរូប ឬដែលកែច្នៃឡើងទេ ។

### វិប្បដិសារី និងការបង្ខិតបង្ខំមិនស៊ីសង្វាក់គ្នាឡើយ

តាមផ្លូវច្បាប់ ភាពទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាមទារឲ្យមានទាំងការប្រព្រឹត្ត (ពិរុទ្ធភាព) និងគំនិតដែលទទួលខុសត្រូវ (ចេតនាឧក្រិដ្ឋ) ។ ឧទាហរណ៍នៅសហរដ្ឋអាមេរិក ដើម្បីចាប់កំហុសជនជាប់ចោទពីបទធ្វើឃាតបាន សហព្រះរាជអាជ្ញាត្រូវតែបង្ហាញភ័ស្តុតាងឲ្យឃើញថាជនជាប់ចោទបានប្រព្រឹត្ត (ឧទាហរណ៍ ជនជាប់ចោទបានបាញ់កាំភ្លើង) ដោយមានចេតនាសម្លាប់ ឬបង្កនូវគ្រោះ

ថ្នាក់ធ្ងន់ធ្ងរលើជនរងគ្រោះ ។ ប្រសិនបើជនជាប់ចោទបានបាញ់ កាំភ្លើងដោយអចេតនា (មិនមែនប្រព្រឹត្ត) ឬក៏មិនមានបំណងបង្ក នូវគ្រោះថ្នាក់លើជនរងគ្រោះ (មិនមានចេតនាឧក្រិដ្ឋ) នោះការ ជាប់ទោស និងការសម្រេចកាត់ទោសអាចបន្ធូរបន្ថយបាន ឬក៏ លើកលែងទោសទាំងស្រុងតែម្តង ។

ដូច្នេះ ខណៈពេលដែល ឌុច អះអាងថាខ្លួនបានប្រព្រឹត្ត ឧក្រិដ្ឋកម្មដោយការបង្ខិតបង្ខំ ឌុច បានទទួលស្គាល់យ៉ាងច្បាស់លាស់ ថាខ្លួនបានប្រព្រឹត្ត ប៉ុន្តែ ឌុច មិនមានគំនិតនឹងទទួលខុសត្រូវដែល ចាំបាច់ដើម្បីចាប់កំហុសឡើយ ។ ឌុច បានទទួលស្គាល់ថាបានបញ្ជា ឲ្យធ្វើទារុណកម្ម និងសម្លាប់ជនស៊ីវិលរាប់ពាន់នាក់នៅមន្ទីរស-២១ ប៉ុន្តែ ឌុច បានអះអាងថាខ្លួនបានធ្វើបែបនេះទាំងស្ទាក់ស្ទើរនិង គ្រាន់តែធ្វើតាមបញ្ជាថ្នាក់ប៉ុណ្ណោះ ។ ប្រសិនបើ ឌុច ជ្រើសរើស មិនប្រព្រឹត្ត ឌុច នឹងមិនអាចត្រូវបានចោទប្រកាន់ពីបទមានគំនិត អាក្រក់ (ចេតនាឧក្រិដ្ឋ) ក្នុងអំឡុងពេលដែល ឌុច បម្រើការងារ នៅមន្ទីរស-២១ ដែលយើងបញ្ចូលករណី ឌុច ជាមួយនឹង ជនល្មើសនៃឧក្រិដ្ឋកម្មសាហាវបំផុត ។ ជាងនេះ តាមរយៈការ អះអាងថាត្រូវបាន «បង្ខិតបង្ខំ» ជាលេសដោះសាមួយដែលចាត់ ទុកថាទទួលស្គាល់តាមផ្លូវច្បាប់បាននោះ ឌុច កំពុងតែអះអាង យ៉ាងច្បាស់លាស់ថា សកម្មភាពរបស់ខ្លួនពិតជាប្រព្រឹត្តឡើងដោយ សមហេតុផលយោងតាមកាលៈទេសៈនោះ ។ ប្រសិនបើអង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទទួលយកនូវការវែកញែកនេះ នោះវាអាចធ្វើឲ្យ ឌុច រួចខ្លួន ឬក៏អាចចាប់កំហុស ឌុច បាន ប៉ុន្តែ វាបែរជាបន្ធូរបន្ថយសេចក្តីសម្រេចកាត់ទោសទៅវិញទេ ។

បញ្ហាទាក់ទិននឹងការការពារខ្លួនដោយភាពបង្ខិតបង្ខំនៅក្នុង ស្ថានភាពនេះគឺថា ឌុច កំពុងតែលើកឡើងនូវហេតុផលដើម្បីការពារ ខ្លួនតាមរយៈការសម្តែងនូវវិប្បដិសារីដ៏ពិតប្រាកដដែលប្រឌិត ឡើងតែប៉ុណ្ណោះ ។ ប៉ុន្តែប្រសិនបើ ឌុច ត្រូវបានបង្ខំឲ្យប្រព្រឹត្ត ឧក្រិដ្ឋកម្មដែលប្រឆាំងនឹងឆន្ទៈរបស់ខ្លួន ចុះហេតុអ្វីបានជា ឌុច ធ្វើការសុំទោសចំពោះឧក្រិដ្ឋកម្មរបស់ខ្លួនទៅវិញ? ប្រសិនបើ ឌុច ពិតជាជឿជាក់ថា ឌុច និងគ្រួសាររបស់ ឌុច នឹងត្រូវបានសម្លាប់ បើ ឌុច មិនបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះតាមបញ្ជារបស់របបនេះ តើ ឌុច ច្បាស់ជានឹងមិនប្រព្រឹត្តនូវឧក្រិដ្ឋកម្មបែបនេះដែរឬទេ ប្រសិនបើ ឌុច ត្រូវបានផ្តល់ឲ្យនូវជម្រើសដ៏អាក្រក់បែបនេះម្តង ទៀត? ប្រសិនបើជាដូច្នោះមែននោះ តើការសម្តែងនូវវិប្បដិសារី របស់ ឌុច នឹងមិនជាប់ពាក់ព័ន្ធនឹងការបង្ខិតបង្ខំមែនដែរឬទេ ប្រសិន បើវិប្បដិសារីនេះជាការមិនពិត?

វាពិតជាសមហេតុផលណាស់ដែល ឌុច បាននិយាយសុំ ទោសសម្រាប់ទុក្ខវេទនាដែលទទួលរងដោយអ្នកជាប់ឃុំឃាំង អ្នក ដែលបានសម្លាប់នៅមន្ទីរស-២១ និងសាច់ញាតិជាទីស្រឡាញ់ របស់អ្នកទាំងនោះ ។ ទោះបីជាយ៉ាងនេះក្តី ការយល់ពីអារម្មណ៍ ប្រភេទនេះ គឺខុសពីវិប្បដិសារី (វិប្បដិសារីសម្រាប់ទង្វើរបស់ខ្លួន) ដែល ឌុច បាននិយាយនៅក្នុងតុលាការ ។ ទោះបីជាការបង្ខិតបង្ខំ គឺជាការការពារខ្លួនតាមផ្លូវច្បាប់ក៏ដោយ ក៏ការបង្ខិតបង្ខំនេះមិន ស៊ីសង្វាក់គ្នានឹងវិប្បដិសារីឡើយ ។ តាមពិត វាគ្មានហេតុផលអ្វី ដើម្បីសុំទោសសម្រាប់ការប្រព្រឹត្តឧក្រិដ្ឋកម្មលើភាពឈឺចាប់ខ្លោច ផ្សានៃការស្លាប់ដែលប្រព្រឹត្តិតាមបញ្ជាអ្នកមានអំណាចថ្នាក់លើ ឡើយ ។ នៅក្នុងខ្លឹមសារសំខាន់នេះ ការបង្ខិតបង្ខំដែលជនជាប់ចោទ បានទាញយកចេញពីការទទួលស្គាល់ថាជនជាប់ចោទបានប្រព្រឹត្ត ឧក្រិដ្ឋកម្មដោយអនុលោមទៅតាមការគាបសង្កត់ គឺមិនស្ថិតក្នុង លក្ខខណ្ឌសតិអារម្មណ៍ដែលសមនឹងទទួលបានប្រយោជន៍ពីការ ដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តឡើយ ។ ក្នុងន័យ ផ្សេង ការបង្ខិតបង្ខំនេះបានទទួលស្គាល់ថាជនជាប់ចោទមិនបាន ទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលខ្លួនមិនបានជ្រើសរើសប្រព្រឹត្ត នោះទេ ។ ដូច្នេះតាមទស្សនៈផ្លូវច្បាប់ ការបង្ខិតបង្ខំ គឺមិនជាប់ទាក់ ទងនឹងការសម្តែងនូវវិប្បដិសារីសម្រាប់ឧក្រិដ្ឋកម្មដែលឧក្រិដ្ឋជន បានប្រព្រឹត្ត ហើយមកអះអាងថាត្រូវបានបង្ខិតបង្ខំនោះទេ ។

ជាទូទៅ ប្រសិនបើមិនអាចសម្តែងនូវភាពសោកស្តាយឲ្យ សមហេតុផលលើទង្វើដែលត្រូវបានគាបសង្កត់ក្រោមការបង្ខិត បង្ខំទេនោះ ការសូមអភ័យទោសរបស់ ឌុច ក៏មិនបានផ្តល់នូវ យុត្តិធម៌ដែលជានិមិត្តរូប ឬដែលស្ថាបនាឡើងដែលតម្រូវឲ្យផ្តល់ ដល់ប្រជាជនខ្មែរនោះដែរ ។ ការសូមអភ័យទោសដ៏ស្មោះត្រង់អាច នឹងផ្តល់នូវភាពធូរស្បើយ ឬផ្តល់នូវស្មារតីនៃការអត់ឱនទោសពី សំណាក់សាច់ញាតិជនរងគ្រោះនិងជនរស់រានមានជីវិតពីមន្ទីរ ស-២១ដ៏តិចតួចបំផុតនេះបាន ។ ជាលទ្ធផល ការសូមអភ័យទោស

នេះអាចនឹងជួយសម្រួលដល់ដំណើរការព្យាបាលរបួសផ្លូវចិត្តរបស់កម្ពុជាដែលកំពុងតែមានដំណើរការបន្ត ។ យ៉ាងណាមិញ តាមនិយមន័យ ការសូមអភ័យទោសដែលរួមជាមួយការអះអាងពីការបង្ខិតបង្ខំ គឺពិតជាមិនមានភាពស្មោះត្រង់ឡើយ ហើយវាក៏ប្រឆាំងនឹងគោលដៅរបស់យុត្តិធម៌ដែលស្ដាបនាឡើងដែរ ។

ការសូមអភ័យទោសរបស់ ឌុច ហាក់បីដូចជាមានចន្លោះនៅឡើយ ខណៈពេលដែល ឌុច បាននិយាយបន្ថែមថាខ្លួនត្រូវតែប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ ពីព្រោះតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបង្ខំគាត់ប៉ុណ្ណោះ ។ ដើម្បីឲ្យមានអត្ថន័យជ្រាលជ្រៅ ការសូមអភ័យទោសត្រូវតែភ្ជាប់ជាមួយនឹងស្មារតីនៃការទទួលស្គាល់និងទំនួលខុសត្រូវលើទង្វើរបស់ខ្លួន ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាត់ទុកវិប្បដិសារីថាជាកត្តាបន្ធូរបន្ថយទោសនៅក្នុងករណីនេះ នោះវាពិតជាមិនត្រឹមតែធ្វើឲ្យមានបញ្ហាតាមផ្លូវច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងធ្វើឲ្យយុត្តិធម៌ដែលជានិមិត្តរូបដែលស្ដាបនាឡើងនេះបាត់បង់នូវសារសំខាន់ដែលតុលាការបានអះអាងថានឹងផ្ដល់យុត្តធម៌នេះជូនដល់សង្គមប្រជាជនខ្មែរផង ។

**តើយើងអាចប៉ាន់ស្មានពីភាពស្មោះត្រង់នៃវិប្បដិសារីបានដោយរបៀបណា?**

យោងតាមការសង្កេតទាំងស្រុងលើតុលាការកាត់ទោស ឌុច ភាពស្មោះត្រង់នៃវិប្បដិសារីរបស់ជនដែលត្រូវជាប់ចោទ



រូបថតជនរងគ្រោះនៅមន្ទីរស-២១

ជាទូទៅគឺមានផលវិបាកក្នុងការប៉ាន់ស្មានមើល ទោះបីជាវិប្បដិសារីនេះមិនបានសម្តែងចេញឲ្យជាប់ទាក់ទងនឹងការបង្ខិតបង្ខំក៏ដោយ ។ ជាពិសេសអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហាក់បីដូចមិនបានរៀបចំខ្លួនឲ្យល្អដើម្បីធ្វើការកំណត់ពីភាពស្មោះត្រង់នៃវិប្បដិសារីនេះទាល់តែសោះ ។

តាមធម្មតា វិប្បដិសារី គឺត្រូវបានវិនិច្ឆ័យតាមគំនិតបុគ្គលម្នាក់ៗ ។ មិនដូចការបង្ខិតបង្ខំដែលជាការការពារខ្លួនពីផ្លូវទាក់ទិននឹងកាលៈទេសៈជាក់ស្តែងដែលកើតមានជុំវិញឧក្រិដ្ឋកម្ម ទោះបីជាបុគ្គលនោះបានប្រព្រឹត្ត ឬមិនបានប្រព្រឹត្តក្រោមការបង្ខិតបង្ខំក៏ដោយ ក៏ការអះអាងពីវិប្បដិសារីអាចទទួលជោគជ័យបាន លុះត្រាតែវិប្បដិសារីនេះត្រូវបានបង្ហាញភាពគួរឲ្យជឿបានពីសំណាក់មនុស្សទូទៅ ហើយវិប្បដិសារីនេះត្រូវតែបង្ហាញពីភាពជឿជាក់ដល់ចៅក្រម ។ បញ្ហានេះអាចចោទជាបញ្ហាពីរ ។

ដំបូងមនុស្សម្នាក់ៗបានសម្តែងនូវវិប្បដិសារីខុសៗគ្នាតាមស្ថានភាពរបស់គេរៀងៗខ្លួន ។ ឌុច ហាក់បីដូចជាមនុស្សឆ្លាតបានរៀបចំខ្លួនបានល្អនិងបានគោរពឱនលំទោនចំពោះតុលាការ ។ ប៉ុន្តែ ឌុច ហាក់បីដូចជាមិនមែនជាមនុស្សគួរឲ្យរាប់អាន ឬក៏ជាមនុស្សមានមនោសញ្ចេតនាឡើយ ។ ដូច្នេះ ការសម្តែងនូវវិប្បដិសារីរបស់ឌុច ហាក់បីដូចជាមិនស្មោះត្រង់ចេញពីដួងចិត្តដូចវិប្បដិសារីដែលកើតចេញពីបុគ្គលម្នាក់ដែលភាគច្រើនបណ្តាលមកពីការសម្តែង ឬ









ការកើតចេញពីមនោសញ្ចេតនាពិតប្រាកដនោះទេ ។ ខ្ញុំបានមានវត្តមាននៅក្នុងអង្គសវនាការនៅថ្ងៃដែល ឌុច បាននិយាយពីការសូមអភ័យទោសដ៏គួរឲ្យសោកស្តាយ (ដែលក្នុងគំនិតរបស់ ឌុច គិតថាវាជាការសូមអភ័យទោសដ៏ពិតប្រាកដមួយ) សម្រាប់ឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងដែលបានកើតឡើងនៅមន្ទីរស-២១ ។ យ៉ាងណាមិញ ដោយសារតែ ឌុច បាននិយាយសូមអភ័យទោសនៅក្នុងសម្តីដែលពោរពេញដោយអំណាច និងរបៀបដូវការដែល ឌុច បានប្រើរហូតមកក្នុងសក្តីកម្មរបស់ខ្លួននោះ សម្រាប់ខ្ញុំការសូមអភ័យទោសនេះហាក់បីដូចជាមិនមានភាពស្មោះត្រង់ ឬពិតប្រាកដប៉ុន្មានទេ ។ ខ្ញុំបានរំពឹងថាការសូមអភ័យទោសនេះគួរតែធ្វើឡើងឲ្យដូចក្នុងភាពយន្តហូលីវូដដែលសម្តែងដោយមានការសម្រក់ទឹកភ្នែក និងមនោសញ្ចេតនាដ៏ជ្រាលជ្រៅ ។

ជាមួយគ្នានេះ ចៅក្រមប្រហែលជាមានការសន្មតទុកជាមុននូវអ្វីដែលបង្កើតឲ្យមានវិប្បដិសារីដ៏ពិតប្រាកដដែលមិនត្រឹមតែមានភាពខុសគ្នាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានភាពប្រហាក់ប្រហែលនឹងជំនឿនៃវិប្បដិសារីដ៏ខុសប្លែករបស់ខ្ញុំជាងរបៀបបទនៃវិប្បដិសារីដែលធ្វើឡើងដោយបន្ទុំរបស់ ឌុច ។ វាហាក់បីដូចជាមិនស្មើភាពក្នុងការផ្តល់ឲ្យជនជាប់ចោទនូវលក្ខខណ្ឌដែលមិនត្រឹមត្រូវនិងដែលលម្អៀងនេះទាល់តែសោះ ។ ជនជាប់ចោទមិនសមនឹងត្រូវសម្រេចផ្តន្ទាទោសដោយយោងតាមតែឥរិយាបថនិងបុគ្គលិកលក្ខណៈដែលមិនប្រកាន់ខ្ជាប់ជាមួយនឹងការរំពឹងទុករបស់យើងទាំងអស់គ្នាឡើយ ។

នៅក្នុងបែបផែនប្រហាក់ប្រហែលគ្នានេះ ជនជាប់ចោទក៏មិនគួរត្រូវបានផ្តល់ឲ្យនូវលក្ខខណ្ឌវប្បធម៌ដែលមិនត្រូវបានទទួលស្គាល់នេះទេ ។ ដូចគ្នានេះដែរ វាហាក់បីដូចជាសមហេតុផលដែលថាចៅក្រមអន្តរជាតិបានគិតថាការសូមអភ័យទោសតាមការយល់ឃើញរបស់គេ គឺមានភាពខុសគ្នាពីការយល់ឃើញរបស់ដៃគូចៅក្រមកម្ពុជា ។ វិប្បដិសារីមួយដែលហាក់បីដូចជាមានភាពស្មោះត្រង់ និងពិតប្រាកដសម្រាប់សង្គមមួយអាចនឹងមិនមានភាពស្មោះត្រង់ ឬក្លែងក្លាយសម្រាប់សង្គមមួយផ្សេងទៀត ។ ដូច្នោះខណៈពេលដែលសម្តែងនូវវិប្បដិសារីជនជាប់ចោទនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែប្រព្រឹត្តដោយមិនត្រឹមតែពិចារណាលើការរំពឹងទុកផ្ទាល់ខ្លួនរបស់ចៅក្រមប៉ុណ្ណោះ ទេ ប៉ុន្តែត្រូវតែគិតពីការរំពឹងទុកតាមលក្ខខណ្ឌវប្បធម៌របស់ចៅក្រមផងដែរដើម្បីទទួលបានជោគជ័យ ។ ផ្ទុយពីការខ្វះខាតនូវសត្យានុម័តការរំពឹងទុកជាមុនទាំងនេះគឺមិនអាចបរិយាយបាននិងមិនអាចទទួលស្គាល់បានឡើយ ។ ជាលទ្ធផល ខណៈពេលដែលសម្តែងនូវវិប្បដិសារីជនជាប់ចោទមិនបានឈ្វេងយល់ពីលក្ខខណ្ឌដែលគេត្រូវបានវិនិច្ឆ័យកាត់ទោសនោះទេ ។

បុគ្គលម្នាក់ៗបានសម្តែងនូវមនោសញ្ចេតនារបស់ខ្លួនរួមមានវិប្បដិសារី តាមវិធីផ្សេងៗគ្នារបស់គេ ប៉ុន្តែទាក់ទិននឹងបញ្ហានេះ ទាំងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអង្គសវនាការពិតជាមានសមត្ថភាពជាងខ្ញុំក្នុងការវែកញែកពីសមាសភាពពិតនៃវិប្បដិសារីដែលប្រឌិតឡើង ។ ដូច្នេះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគួរតែប្រកាន់ខ្ជាប់នូវអ្វីដែលខ្លួនដឹងច្បាស់បំផុតជាជាងមានបំណងវិភាគលើសតិអារម្មណ៍របស់ជនជាប់ចោទ ។ ប្រសិនបើចាត់ទុកវិប្បដិសារីជាកត្តាបន្ធូរបន្ថយទោសនោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងដើរខុសពីជំនាញស្ថាប័នរបស់ខ្លួន ហើយអាចនឹងប្រតិបត្តិនូវការវិភាគវែកញែកដែលចាត់ទុកថាមានលក្ខណៈវិទ្យាសាស្ត្រ ។ ដោយសារតែភាពលម្អៀងរបស់បុគ្គល និងលក្ខខណ្ឌវប្បធម៌ដែលបានធ្វើឲ្យមានផលវិបាកក្នុងការសិក្សាស្វែងយល់ពីការវិភាគនេះ ការវិនិច្ឆ័យ និងភាពស្មោះត្រង់នៃវិប្បដិសារី នឹងមិនមែនជាទំនួលខុសត្រូវរបស់តុលាការ ហើយកាន់តែមិនមែនជាកត្តាចម្បងសម្រាប់ការកាត់ទោសជនជាប់ចោទរបស់អង្គជំនុំជម្រះក្នុងតុលាការកម្ពុជាឡើយ ។

## គោលដៅនៃយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ

តាមទ្រឹស្តី ប្រសិនបើយើងពិនិត្យឲ្យទូលំទូលាយលើការដាក់ទោសព្រហ្មទណ្ឌវិញ វាពិតជាពិបាកដើម្បីផ្តល់នូវយុត្តិធម៌ថាវិប្បដិសារីអាចជាកត្តាបន្ធូរបន្ថយទោសបាន ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើការពិចារណាលើវិប្បដិសារីក្នុងការកាត់ទោសនោះ វិប្បដិសារីនឹងមិនបានជួយជំរុញដល់គោលដៅធំៗទាំងប្រាំនៃយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ ដូចជានីតិសម្បទា ការអស់សមត្ថភាព ការការពារមិនឲ្យកើតឡើងម្តងទៀត ការសម្រេចដាក់ទោស និងយុត្តិធម៌ដែលស្តាបនាឡើង ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានយកចិត្តទុកដាក់លើបញ្ហានីតិសម្បទាទេ ។ ផ្ទុយទៅវិញ ប្រព័ន្ធព្រហ្មទណ្ឌក្នុងស្រុកបានយកចិត្តទុកដាក់យ៉ាងម៉ត់ចត់លើការជួយធ្វើឲ្យឧក្រិដ្ឋជនដែលជាប់ផ្តន្ទាទោសពីបទល្មើសឧក្រិដ្ឋកម្មមានសេរីភាពឡើងវិញដើម្បីធ្វើឲ្យគេក្លាយជាសមាជិកដ៏មានប្រយោជន៍សម្រាប់សង្គមដូចសមាជិកដទៃទៀត ។ បើយោងតាមទ្រឹស្តី ការដាក់ទោសព្រហ្មទណ្ឌដូចជាការដាក់ឃុំខ្លួន គឺបានចាត់ទុកថាជាការផ្តល់នូវពេលវេលាសម្រាប់ឧក្រិដ្ឋជនដើម្បីគិតពិចារណានិងអប់រំខ្លួនទៅតាមច្បាប់វិន័យដើម្បីធ្វើការកែប្រែជាថ្មីដែរ ។ សម្រាប់អង្គជំនុំជម្រះវិសាញ្ញក្នុងតុលាការកម្ពុជាវិញ ការកែប្រែជាថ្មី ឬនីតិសម្បទាពុំសូវមានសារសំខាន់ប៉ុន្មានទេ ។

ដោយសារតែនីតិសម្បទាមានតែយុត្តាធិការបណ្តោះអាសន្នក្នុងអំឡុងរបបខ្មែរក្រហម(១៩៧៥ ១៩៧៩) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដាក់ដែនកំណត់ក្នុងការកាត់ទោសឧក្រិដ្ឋជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មកម្រិតធ្ងន់ក្នុងរបបនោះតែប៉ុណ្ណោះ ។ ដូច្នេះបច្ចុប្បន្នជនជាប់ចោទទាំងនោះកំពុងតែឋិតនៅក្នុងវ័យ៦០ឆ្នាំទៅ៨០ឆ្នាំ ហេតុដូចនេះហើយជនជាប់ចោទមិនអាចមានសមត្ថភាពនិងប្រហែលជាមិនមានឆន្ទៈដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មកម្រិតធ្ងន់បែបនេះម្តងទៀតឡើយ ។ បន្ថែមពីនេះទៀតជនជាប់ចោទទាំងនោះក៏បានវិលត្រឡប់មករស់នៅក្នុងសង្គមដូចប្រជាជនធម្មតាដទៃទៀតរួចហើយដែរ ។ ឧទាហរណ៍ ឌុច បានទទួលធ្វើជាគ្រូបង្រៀនម្នាក់មុនពេលដែលគាត់ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៩៩ ។

មិនដូចបរិបទច្បាប់ព្រហ្មទណ្ឌក្នុងស្រុកដែលវិប្បដិសារីរបស់ជនជាប់ចោទដែលធ្វើការសាកល្បងសមត្ថភាពរបស់គេក្នុងការកែប្រែខ្លួនជាថ្មី និងចូលរួមកសាងសង្គមជាតិតាមផ្លូវសុចរិតនោះ ជនជាប់ចោទនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិញមានវ័យជរា ហើយក៏បានចូលរួមជាមួយនឹងសង្គមជាតិសាជាថ្មីម្តងទៀត រួចហើយសម្រាប់វិប្បដិសារីរបស់គេដើម្បីសម្រេចនូវគោលបំណងនេះ ។ បញ្ហាដូចគ្នានេះ ក៏អាចនិយាយពាក់ព័ន្ធនឹងការអស់សមត្ថភាពបានដែរ ។ ផ្ទុយពីបរិបទច្បាប់ព្រហ្មទណ្ឌក្នុងស្រុកដែលមានភាពសមហេតុផលដើម្បីធ្វើការឃុំខ្លួន ឬក៏ធ្វើឲ្យជនល្មើសអស់សមត្ថភាពដើម្បីធ្វើឲ្យសង្គមជាតិមានសុវត្ថិភាពជាមុននោះ យោងតាមលក្ខខណ្ឌបច្ចុប្បន្នរបស់គេ ជនជាប់ចោទនៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានបង្ហាញពីគ្រោះថ្នាក់ណាមួយដល់សង្គមជាតិឡើយ ។ ដូច្នេះការអស់សមត្ថភាពគឺមិនមែនជាគោលបំណងនៃការដាក់ទោសផ្នែកព្រហ្មទណ្ឌរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។ ដោយសារតែជនជាប់ចោទរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានបង្កនូវការគំរាមកំហែងដែលអាចមើលឃើញដល់សង្គមជាតិនោះ វិប្បដិសារីរបស់គេដែលគ្រាន់តែប៉ុនប៉ងថាតើគេអាចសម្របសម្រួលខ្លួនចូលក្នុងសង្គមម្តងទៀតបានដែរឬទេ នោះគឺមិនត្រូវការជាចាំបាច់ក្នុងបរិបទនេះឡើយ ។

ទាក់ទិននឹងការការពារមិនឲ្យកើតឡើងម្តងទៀត វិប្បដិសារីបីដូចជាមិនបានជួយអ្វីទាល់តែសោះ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានជំរុញឲ្យមានការការពារមិនឲ្យកើតឡើងម្តងទៀតទេ ។ ដើម្បីធ្វើឲ្យមេដឹកនាំនយោបាយជាន់ខ្ពស់ទទួលខុសត្រូវលើឧក្រិដ្ឋកម្មរបស់គេ តុលាការកំពុងតែធ្វើការប្រឆាំងនឹងការមិនផ្តន្ទាទោសក្នុងប្រទេសកម្ពុជាដើម្បីធ្វើជានិមិត្តរូបសម្រាប់ប្រទេសគ្រប់ទីកន្លែងក្នុងពិភពលោកដែលរបបនយោបាយបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មដ៏អាក្រក់បំផុតនេះ ។ សារសំខាន់នៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដ៏តូចនេះ បានផ្តល់ជាសញ្ញាណថាសហគមន៍អន្តរជាតិនឹងមិនអង្គុយឱបដៃមើលឡើយ ដោយសារតែរាជរដ្ឋាភិបាលកម្ពុជាបានប្រព្រឹត្តឧក្រិដ្ឋកម្មកម្រិតធ្ងន់ប្រឆាំងនឹងសិទ្ធិបុគ្គល ។ ទោះបីនេះគឺជាទិដ្ឋភាពដ៏សំខាន់នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ក៏ការសម្តែងនូវវិប្បដិសារីរបស់ជនជាប់ចោទមិនបានជួយគាំទ្រច្បាប់ព្រហ្មទណ្ឌអន្តរជាតិនេះបន្តិចឡើយ ។ ការការពារមិនឲ្យកើតឡើងម្តងទៀត អាចនឹងសម្រេចបានដោយសារតែមានតុលាការកាត់ទោសដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានសមត្ថភាពសម្រេចដាក់ទោសព្រហ្មទណ្ឌលើមេដឹកនាំនយោបាយទាំងនោះ ។ វាអាចសម្រេចទៅបានដោយមិនចាំបាច់គិតថាតើ ឌុច ហើយនិងមេដឹកនាំខ្មែរក្រហមដែលជាប់ចោទដទៃទៀតសូមអភ័យទោសសម្រាប់ឧក្រិដ្ឋកម្មរបស់ខ្លួននោះទេ ។

ក្នុងការផ្តល់នូវយុត្តិធម៌សម្រាប់ការផ្តន្ទាទោស អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដូចជាមិនទទួលបានប្រយោជន៍

អ៊ីពីការពិចារណាលើការសម្តែងនូវវិប្បដិសារីឡើយ ។ ផ្អែកលើទស្សនៈច្បាប់ ការផ្តន្ទាទោសគឺសំដៅលើទណ្ឌកម្មដែលសមនឹងទទួលយកសម្រាប់ឧក្រិដ្ឋកម្មដែលជនជាប់ចោទបានប្រព្រឹត្ត ។ វានឹងមានយុត្តិធម៌តាមរយៈពិរុទ្ធភាពផ្នែកសីលធម៌នៃឧក្រិដ្ឋជនដែលទទួលទណ្ឌកម្ម ហើយទណ្ឌកម្មនេះមិនមែនត្រឹមតែមានប្រភពចេញពីមហិច្ឆតារបស់ជនរងគ្រោះសម្រាប់ការសងសឹកប៉ុណ្ណោះទេ ប៉ុន្តែវាក៏កើតចេញពីការមិនទទួលស្គាល់ឧក្រិដ្ឋកម្មរបស់ជនដែលពីសង្គមជាតិផងដែរ ។ ជួសមុខឲ្យសង្គមជាតិ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រេចដាក់ទណ្ឌកម្មដែលសមស្របទៅនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយជនជាប់ចោទតែប៉ុណ្ណោះ ។ ក្នុងការបំពេញតួនាទីនេះ តុលាការបានដើរតួជាអ្នកនាំផ្លូវផ្នែកសីលធម៌ដែលព្យាយាមផ្តល់ឲ្យជនជាប់ចោទនូវភាពឯកោសម្រាប់បទល្មើសប្រឆាំងនឹងសង្គមជាតិរបស់គេ ។

វិប្បដិសារីរបស់ជនជាប់ចោទមិនអាចកាត់បន្ថយកម្រិតធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់គេបានទេ ពីព្រោះការផ្តន្ទាទោសនឹងសម្រេចថាមានយុត្តិធម៌ដោយសង្គមជាតិទាំងមូល ។ ដូច្នេះទោះបីជាជនជាប់ចោទខ្លះបានបង្ហាញពីការសូមអភ័យទោសដ៏ស្មោះត្រង់ដែលអាចធ្វើឲ្យជនរងគ្រោះ និងសាច់ញាតិរបស់ជនរងគ្រោះខ្លះមានភាពជឿជាក់ក៏ដោយ ក៏នឹងមានជនរងគ្រោះដទៃទៀតដែលនឹងមិនជឿ ឬមិនទទួលយកការសូមអភ័យទោសបែបនេះឡើយ ។ លើសពីនេះ ការសូមអភ័យទោសនេះមិនអាចសន្ទនាជាមួយនឹងជនរងគ្រោះរាប់ពាន់នាក់ដែលត្រូវបានសម្លាប់ទៅហើយនោះបានទេ ។ យុត្តិធម៌ក្នុងការផ្តន្ទាទោសត្រូវតែសម្រេចឲ្យបានដើម្បីជាប្រយោជន៍ដល់អ្នកដែលស្លាប់បាត់បង់ជីវិតនិងសម្រាប់សង្គមជាតិទាំងមូល មិនមែនគ្រាន់តែសម្រេចឡើងដើម្បីបំពេញនូវផ្នែកមួយនៃកាតព្វកិច្ចរបស់ខ្លួនឡើយ ។ ក្នុងន័យផ្សេងទោះបីជាស្ថិតនៅក្នុងស្ថានការណ៍ដែលប្រជាជនកម្ពុជានឹងមិនអត់ឱនទោសដល់មេដឹកនាំខ្មែរក្រហមដែលជាប់ចោទ បញ្ហាទីពីរដែលលើកមកពិភាក្សានេះនៅតែអាចធ្វើឲ្យមានការខូចខាតដល់សង្គមជាតិដោយសារតែការសម្លាប់ជីវិតមនុស្សដ៏ច្រើនខុសលក្ខណៈខុសច្បាប់ ។ ប្រសិនបើការផ្តន្ទាទោសជាផ្នែកមួយនៃសីលធម៌របស់សង្គមដែលឆ្លើយតបនឹងការប្រព្រឹត្តខុសរបស់ជនជាប់ចោទនោះវិប្បដិសារីរបស់ជនជាប់ចោទមិនអាចសម្រាលទោសសម្រាប់ឧក្រិដ្ឋកម្មដ៏រន្ធត់និងឥទ្ធិពលដ៏មហន្តរាយដែលបន្សល់ទុកឲ្យសង្គមកម្ពុជាបានឡើយ ។

ចុងក្រោយបង្អស់ តាមគោលការណ៍គោរពយុត្តិធម៌ដែលស្ថាបនាឡើងនេះ វិប្បដិសារីអាចដើរតួដ៏មានប្រយោជន៍ក្នុងការជួយដល់សង្គមកម្ពុជាឲ្យជាសះស្បើយពីរបួសអតីតកាលដ៏អាក្រក់របស់ខ្លួនបាន ។ បើជនជាប់ចោទដែលជាមេដឹកនាំខ្មែរក្រហមដទៃទៀតនឹង សម្តែងនូវវិប្បដិសារី (ប៉ុន្តែនឹងមិនធ្វើឲ្យវិប្បដិសារីនេះមិនជាប់ទាក់ទងគ្នាដោយយកវិប្បដិសារីនេះមកបញ្ចូលជាមួយនឹងការបន្ធូរបន្ថយ) នោះ វិប្បដិសារីនេះអាចនឹងផ្តល់នូវភាពធូរស្បើយដល់ជនរងគ្រោះ និងសាច់ញាតិរបស់ជនរងគ្រោះបាន ។ យ៉ាងណាមិញ ដូចដែលបានពិភាក្សាវែកញែកខាងលើ ការទទួលស្គាល់នូវវិប្បដិសារីពីសំណាក់ប្រជាជនដទៃទៀតប្រាកដជាអាស្រ័យលើទស្សនផ្ទាល់ខ្លួនរបស់គេ ហេតុដូច្នេះយើងមិនអាចធ្វើការទស្សន៍ទាយទុកជាមុនបានទេ ។ តាមរយៈការសូមអភ័យទោសជាសាធារណៈប្រជាជនមួយចំនួនប្រហែលជាជឿលើវិប្បដិសារីនេះ ផ្ទុយទៅវិញប្រជាជនដទៃទៀតនឹងមិនជឿឡើយ ។ ប៉ុន្តែគ្មានជនណាម្នាក់ ឬសូម្បីតែតុលាអាចរំពឹងទុកឲ្យប្រាកដថានឹងមានប្រជាជនប៉ុន្មាននាក់នឹងជឿ ឬមិនជឿលើវិប្បដិសារីរបស់ជនជាប់ចោទទាំងនោះបានណាស់ ។ ដូច្នេះ វាគឺជាការប៉ាន់ស្មានដ៏មិនជាក់លាក់ក្នុងការចាត់ទុកថាវិប្បដិសារីជាកត្តាបន្ធូរបន្ថយទោសដោយគ្រាន់តែផ្អែកលើមូលដ្ឋានដែលថា វិប្បដិសារីអាចផ្តល់នូវយុត្តិធម៌ដែលស្ថាបនាឡើងមួយផ្នែកដល់សង្គមប្រជាជនកម្ពុជាដែលមិនមានសមាសភាពច្បាស់លាស់ ។

ដោយពិចារណាឃើញថា វិប្បដិសារីមិនបានជួយបម្រើដល់គោលដៅនៃយុត្តិធម៌ផ្នែកព្រហ្មទណ្ឌរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបាន វាពិតជាមានភាពលំបាក ប្រសិនបើតុលាការមិនអាចសម្រេចគោលដៅនេះដោយសត្យានុម័ត ។ ហេតុដូច្នេះ យោងតាមតុលាការកាត់ទោស ឌុច វិប្បដិសារីនេះនឹងមិនមានជាប់ទាក់ទងនឹងយុត្តិធម៌ផ្នែកព្រហ្មទណ្ឌឡើយ ។ ដូច្នេះវិប្បដិសារីមិនគួរយកមកជំនុំជម្រះក្នុងការសម្រេចកាត់ទោសនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។ **រីហាន អាប៊ីរ៉ាន**

# អ្វីដែលចាំបាច់សម្រាប់គណៈកម្មការស្វែងរកការពិត?

ទស្សនៈបង្កើតគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា ត្រូវបានលើកឡើង ហើយអាចត្រូវបានពិចារណាថាជាការជំនួស ដល់ដំណើរការនីតិវិធីតាមផ្លូវច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ។

គណៈកម្មការស្វែងរកការពិត និងការផ្សះផ្សាអាចជាដំណើរការដ៏សំខាន់មួយសម្រាប់ការស៊ើបអង្កេតទៅលើការរំលោភសិទ្ធិមនុស្សជាប្រព័ន្ធនិងជាសកលដែលប្រព្រឹត្តឡើងដោយរបបចាស់ ។ ការងាររបស់គណៈកម្មការនេះត្រូវបានជឿជាក់ថាអាចនឹងផ្តល់វិភាគទានដល់ការផ្សះផ្សាជាតិ និងឯកភាពជាតិ ព្រមទាំងជួយដល់ជនរងគ្រោះឲ្យសម្រេចបាននូវកម្រិតដែលអាចទទួលយកបានណាមួយ ប៉ុន្តែមិនមែនទាំងស្រុងនោះទេ ។ ឧទាហរណ៍ ដេមជីបសុន និង ព្រីសស៊ីឡា ហាណឺ បានអះអាងថា «ការពិត» ដែលបង្កើតឡើងដោយគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាអាចជួយជំរុញឲ្យមានការផ្សះផ្សា ។ យ៉ាងហោចណាស់ក៏គណៈកម្មការនេះអាចសម្រេចបាននៅអាហ្វ្រិកខាងត្បូងដែរ ។ ប៉ុន្តែ គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សានៅអាហ្វ្រិកខាងត្បូងត្រូវបានតាក់តែងឡើងទៅតាមចរិតលក្ខណៈវប្បធម៌ដែលមានតែមួយរបស់ប្រទេសនោះ គឺពហុនយោបាយ(ការប្រកួតប្រជែងនយោបាយ) និងវិធានច្បាប់ (បទដ្ឋានជាសកលសម្រាប់ឥរិយាបថរបស់ចៅក្រម) ។ គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាបែបនោះអាចនឹងមានវត្តមាន ហើយទទួលបានជោគជ័យដោយសារតែការគាំទ្រនិងចរិតលក្ខណៈរបស់ស្ថាប័ន និងវប្បធម៌របស់ប្រទេសនោះ ។

គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សានៅអាហ្វ្រិកខាងត្បូងអាចចាត់ទុកថាមានប្រសិទ្ធភាព ពីព្រោះការងារនោះសក្តិសមនឹងគោលនយោបាយនិងការគោរពគ្រិស្តសាសនារបស់ប្រទេសនោះ ។ ប្រទេសដែលធ្លាប់ជួបប្រទះអំពើឃោរឃៅភាគច្រើន បានបង្កើតគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាគឺជាប្រទេសដែលកាន់សាសនាគ្រិស្ត ។ អាស្រ័យហេតុនេះប្រហែលជាមានសំណួរថាតើប្រទេសភាគច្រើនដែលកាន់ព្រះពុទ្ធសាសនាដូចជាប្រទេសកម្ពុជាជាដើមអាចនឹងទទួលបានផលប្រយោជន៍ពីការអនុវត្តទៅតាមទស្សនៈរបស់ប្រទេសអាហ្វ្រិកខាងត្បូងបានដែរឬទេ ។ តើការធ្វើបែបនោះអាចជួយដល់កម្ពុជាឲ្យស្វែងរកការពិតនិងការព្យាបាលដោយរបៀបណា?

មានការគួរឲ្យកត់សម្គាល់ថា មុនពេលបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រជាជនកម្ពុជានិងរដ្ឋាភិបាលបានព្យាយាមអនុវត្តសកម្មភាពតាមបែបវប្បធម៌ ប្រពៃណី សាសនា នយោបាយ និងសង្គមដើម្បីដោះស្រាយនូវកេរដំណែលដែលបន្សល់ទុកដោយខ្មែរក្រហម ។ ទោះបីជាសកម្មភាពនេះមិនមានឈ្មោះថា «គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា»ក៏ដោយ ក៏កិច្ចខំប្រឹងប្រែងនេះត្រូវបានតាក់តែងឡើងដើម្បីជួយដល់ប្រជាជនកម្ពុជាឲ្យយកឈ្នះទៅលើរបួសផ្លូវចិត្ត ការបាត់បង់ ការអស់សង្ឃឹម និងការឈឺចាប់យ៉ាងខ្លាំង ដែលគេបានជួបប្រទះនៅអំឡុងរបបខ្មែរក្រហមដែរ ។

## ការខិតខំប្រឹងប្រែងធ្វើការពីមុន

ជាឧទាហរណ៍ រឿងរ៉ាវរបស់អ្នកនៅរស់រាប់ពាន់នាក់(ដែលស្គាល់ថាជាញត្តិរណសិរ្ស) ត្រូវបានប្រមូលឡើងនៅដើមទសវត្សរ៍ ៨០ ។ ទាំងញត្តិរបស់បុគ្គលនិងញត្តិរួម បានរៀបរាប់ពីការឈឺចាប់នៅសម័យនោះ ការបាត់បង់សមាជិកគ្រួសារនិងសមាជិកសហគមន៍ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនិងការដាក់កំហិតទៅលើវប្បធម៌ សាសនា និងប្រពៃណី ។ ដំណើរការត្រូវបានធ្វើជាសាធារណៈដើម្បីបង្ហាញពីការពិតនៃឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម និងដើម្បីឲ្យសហគមន៍អន្តរជាតិយល់ដឹង ។

ជាងនេះទៅទៀត នៅថ្ងៃប្រារព្ធពិធីរំឭកវិញ្ញាណក្ខន្ធប្រចាំឆ្នាំដែលមានឈ្មោះថា «ទិវាចងកំហឹង ឬការចងចាំ» ប្រជាជនបានប្រមូលគ្នាដើម្បីបង្ហាញពីការបាត់បង់ និងការឈឺចាប់របស់ពួកគេ ព្រមទាំងនិយាយបរិហារពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមជាសាធារណៈ ។

មន្ត្រីរដ្ឋាភិបាលក្នុងស្រុកក៏បានទទួលស្គាល់ការឈឺចាប់និងសេចក្តីលំបាកវេទនារបស់ប្រជាជននៅជំនាន់នោះដែរ ។ នៅពេលប្រជុំគ្នាមានការប្រារព្ធពិធីបង្សុកូលតាមព្រះពុទ្ធសាសនាដើម្បីជួយដល់ផ្លូវចិត្តរបស់ជនរងគ្រោះ ។

ឧទាហរណ៍ទាំងពីរនេះអាចចាត់ទុកថា ទស្សនៈរបស់គណៈកម្មការស្វែងរកការពិតដោយមិនផ្លូវការ ដែលប្រជាជនកម្ពុជាបានចូលរួមចាប់តាំងពីរបបនេះបានបញ្ចប់ ។ រហូតមកដល់ពេលនេះ អ្វីដែលប្រជាជនកម្ពុជាខ្វះខាតបំផុត គឺអារម្មណ៍ដែលទទួលបានយុត្តិធម៌ ។ អាស្រ័យហេតុនេះ ការដាក់ទោសឲ្យមានយុត្តិធម៌នៅអង្គជំនុំជម្រះគួរតែត្រូវបានធ្វើឡើងបន្ថែមទៅលើកិច្ចខំប្រឹងប្រែងរបស់ប្រជាជនក្នុងស្រុកដែលបានធ្វើឡើងបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ។ តាមទស្សនៈ នេះអ្នកដែលចាប់អារម្មណ៍គួរតែបន្តផ្តល់យោបល់ដែលមានប្រយោជន៍ដើម្បីយុត្តិធម៌ដែលត្រូវបានទទួលស្គាល់ដោយជាតិនិងអន្តរជាតិ ។ បន្ទាប់មកនិមិត្តសញ្ញាសំណងជារួមគួរបន្ថែមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលអាចជាអត្ថន័យមួយសម្រាប់ជួយដល់ជនរងគ្រោះក្នុងការបង្កើនអារម្មណ៍ទទួលស្គាល់អ្វីដែលបានកើតឡើង ។

គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាកម្រិតជាតិហាក់ដូចជាមិនអាចជឿទុកចិត្តបាន បើគិតទៅដល់វប្បធម៌កម្ពុជាសាសនា និងការផ្លាស់ប្តូរនយោបាយ ។ អាស្រ័យហេតុនេះ ពិធីដែលប្រារព្ធឡើងជាបន្តបន្ទាប់ ដំណើរការការងារជាមួយប្រជាជនដើម្បីប្រមូលនិងចែករំលែករឿងរ៉ាវដែលកើតឡើងនៅរបបនោះនឹងជំនួយដល់ដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ គឺជាកិច្ចខំប្រឹងប្រែងដែលមានប្រយោជន៍ជាងការជំរុញឲ្យបង្កើតគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាកម្រិតជាតិទៅទៀត ។

**លី សុខឃាង**

# ដំណឹងសួររកប្អូនប្រុសឈ្មោះ គង់ មីត



នាងខ្ញុំឈ្មោះ គង់ ថុល អាយុ៦២ឆ្នាំ រស់នៅភូមិព្រិច ឃុំទ្រាល ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានឪពុកឈ្មោះ ម៉ុន ជាជនជាតិ បារាំង និងម្តាយឈ្មោះ កែវ វ៉ាត់ ។ នាងខ្ញុំសូមប្រកាសសួររកប្អូនប្រុសឈ្មោះ គង់ មីត ដែលបានបាត់ខ្លួននៅក្នុងរដ្ឋប្រហារទម្លាក់ សម្តេច សីហនុ ឆ្នាំ១៩៧០ ។ ប្រហែលជាឆ្នាំ១៩៩៧ ខ្ញុំបានទទួលដំណឹងពីអ្នកភូមិដែលរស់នៅខណ្ឌស្ទឹងមានជ័យ ថា គង់ មីត បានមករកម្តាយរបស់គាត់ កែ វ៉ាត ដែលមានមុខរបរលក់ថ្នាំ ។ ក្រោយមកទៀត ខ្ញុំមិនដែលបានទទួលដំណឹងអ្វីពី គង់ មីត ទៀតទេ ។

ដូច្នេះប្រសិនបើប្អូនប្រុសបានឮ ឬបានអានសេចក្តីប្រកាសនេះ សូមមករកបងតាមអាសយដ្ឋានខាងលើ ឬតាមរយៈទូរស័ព្ទលេខ ០១២ ៧៨៧ ៥៧៥, ០១២ ៨៩៩ ០៧១, ០៩២ ៥៦៣ ០០៧ ។ សូមអរគុណ ។

# សេចក្តីប្រកាសសួររកកូនស្រី ហ៊ាន់ រុំ

នាងខ្ញុំឈ្មោះ ជួប រ៉េម អាយុ៧១ឆ្នាំ រស់នៅភូមិសាមគ្គី ឃុំអង្គរជ័យ ស្រុកអង្គរជ័យ ខេត្តកំពត ។ នាងខ្ញុំសូមប្រកាសសួររកកូនស្រីឈ្មោះ វ៉ាន់ រុំ ដែលសព្វថ្ងៃមានអាយុប្រហែល៣៨ឆ្នាំ បានបាត់ខ្លួននៅឆ្នាំ១៩៧៥ ។ នៅពេលនោះ វ៉ាន់ រុំ ត្រូវបានប្រធានភូមិឈ្មោះ គឿន បញ្ជូនឲ្យធ្វើស្រែអំបិលនៅកែប ។ ក្រោយមកទៀត ខ្ញុំបានទទួលដំណឹងពីម្តាយមីងរបស់ខ្ញុំឈ្មោះ វ៉ាន់ សៀន ថាគាត់បានជួបជាមួយ វ៉ាន់ រុំ ម្តងនៅក្បែរហាងទឹកត្រីមួយ ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងអ្វីទាំងអស់ពី វ៉ាន់ រុំ ។

ដូច្នេះបើកូនបានដំណឹងនេះ សូមមកជួបម្តាយនៅភូមិឃុំខាងលើ ឬទំនាក់ទំនងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ការស្វែងរកយុត្តិធម៌នៅកម្ពុជាដែលពិបាកនឹងយល់

*លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបាន និយាយថា «បន្ទាប់ពី២៥ឆ្នាំ ប្រជាជននៅតែសួរសំណួរដដែលៗ .....។ យើងជាមនុស្ស ដូច្នេះយើងសមនឹងទទួលបានយុត្តិធម៌ ។ ជនរងគ្រោះប្រៀបបីដូចជាកែវដែលបានធ្លាក់បែក ហើយយើងព្យាយាមបិទវាបញ្ចូលគ្នាឡើងវិញ ។ យើងជាប្រជាជនដែលប៉ះពាល់ដំនឹផ្លូវចិត្តដែលរស់នៅក្នុងសង្គមខ្ទេចខ្ទាំ» ។*

*តើយុត្តិធម៌មានរូបរាងយ៉ាងដូចម្តេចសម្រាប់ប្រជាជនដែលនៅរស់ពីអំពើប្រល័យពូជសាសន៍? ខណៈពេលដែលមិនមានអ្វីអាចប្រធ្វើឲ្យមនុស្សដែលស្លាប់ហើយរស់ឡើងវិញ វាពិបាកនឹង-ចាប់ផ្តើមសម្តែងការសុំទោសចំពោះប្រជាជនកម្ពុជាដែលធ្លាប់រងទុក្ខវេទនាណាស់ ។ ទោះបីជាមានការរិះគន់នៅតុលាការនិងមានដំណើរការចាប់ផ្តើមដ៏ពិបាកក៏ដោយ ក៏នៅទីបញ្ចប់យុត្តិធម៌អន្តរកាលសម្រាប់ដាក់ទោសជាលក្ខណៈជាតិ និងការផ្សះផ្សាជាបុគ្គលបានកើតឡើងខណៈពេលដែលអ្នកនៅរស់បានឃើញជនដៃដល់មួយចំនួនត្រូវបានគេយកទៅកាត់ទោស ។ កម្មវិធីយុត្តិធម៌ផ្សះផ្សាសម្រាប់សហគមន៍ដែលធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលបានរួមចំណែកក្នុងដំណើរការព្យាបាលជនរងគ្រោះ ប៉ុន្តែដោយសារតែរបួសដ៏ជ្រៅនេះ មានឥទ្ធិពលទៅលើប្រជាជនយ៉ាងតិចមួយជំនាន់ ឬពីរជំនាន់ទៀត វាបណ្តាលឲ្យដំណើការព្យាបាលនេះនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ លោក ឆាំង យុ បាននិយាយថា «កាដាក់ទោសគឺជាអ្វីដែលប្រជាជនចង់បាន ប៉ុន្តែមកដល់សព្វថ្ងៃនេះមិនមាននរណាម្នាក់ត្រូវបានកាត់ទោសនៅឡើយ ដូច្នេះវានៅមិនទាន់បញ្ចប់ទេ ដោយហេតុនេះទើបយើងពិបាកនឹងធ្វើដំណើរទៅមុខ» ។*



អ្នកភូមិចាកចេញពីបន្ទប់សវនាការ

*អាស្រ័យហេតុនេះ ទើបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតំណាងឲ្យសមិទ្ធផលដ៏សំខាន់មួយនៃកេរដំណែលរបស់កម្ពុជា ។ ខ្មែរក្រហមភាគច្រើនដែលមានឥទ្ធិពលបានស្លាប់មុនពេលដោយមិនត្រូវបានកាត់ទោស ទោះជាយ៉ានេះក្តី ក៏នៅមានមេដឹកនាំខ្មែរក្រហមមួយចំនួនដែរ ។ វាគឺជាឱកាសមួយដែលប្រជាជនកម្ពុជាអាចចែករំលែករឿងរ៉ាវដែលគេបានជួបប្រទះនិងប្រឈមមុខនឹងជនដៃដល់ដែលធ្វើបាបគេ ។ នៅពេលដែលមានការបង្ហាញការពិតជាសាធារណៈ និងការទទួលខុសត្រូវ ប្រទេសអាចចាប់ផ្តើមធ្វើដំណើរទៅមុខម្តងទៀត ។*

*បីទសវត្សរ៍នៃការបែកបាក់ និងការមិនមានការអើពើធ្វើឲ្យការជួបនិងការដាក់បញ្ចូលគ្នានៃការច្នៃប្រឌិតនិងយុត្តិធម៌ដែលបានមកពីការដាក់ទោសនិងយុត្តិធម៌ផ្សះផ្សាដែលមានសារសំខាន់ក្នុងការជួយឲ្យកម្ពុជារួចផុតពីអតីតកាល ហើយចូលរួមនឹងសតវត្សរ៍២១ ។*

*មានមនុស្សជាច្រើនដែលមានចម្ងល់ចំពោះតម្លៃរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលពាក់ព័ន្ធនឹងការចំណាយ ។ ទោះជាយ៉ាងនេះក្តី ស្ថិតិបង្ហាញឲ្យឃើញថាតុលាការ*

មានការគាំទ្រពីប្រជាជនកម្ពុជា ។ សុខ ផាត អតីតកម្មាភិបាលខ្មែរក្រហមម្នាក់ជឿជាក់ថាកម្មាភិបាលថ្នាក់ខ្ពស់ទាំងអស់ត្រូវតែបានយកមកកាត់ទោស ដើម្បីសងនូវជីវិតបងប្រុសរបស់គាត់និងរយៈពេលដែលបានគាត់បានចំណាយនៅក្នុងរបបនោះ គាត់បានអះអាងថា «មានតែតុលាការទេ ដែលអាចបោសសម្អាតយន្តការខ្មែរក្រហមបាន» ។ ជនរងគ្រោះសង្ឃឹមថាមេដឹកនាំជាន់ខ្ពស់ទាំងនោះដែលមិនទាន់ត្រូវបានសួរចម្លើយនៅតុលាការនឹងឆ្លើយនូវសំណួរថា «ហេតុអ្វី» បានជាគេធ្វើបែបនោះ ។ លោក ឆាំង យុ បាននិយាយថា «ជនរងគ្រោះសង្ឃឹមថា ដោយមានអង្គសវនាការនិងការកាត់សេចក្ដីនេះ ទំព័រប្រវត្តិសាស្ត្រកម្ពុជានឹងបញ្ចប់ ហើយវានឹងត្រូវបានកត់ត្រាទុកជាប្រវត្តិសាស្ត្រដើម្បីទុកជាមេរៀនមួយ» ។

ដើម្បីឆ្លើយតបនឹងតម្រូវការនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដែលមានការចូលរួមរវាងតុលាការកម្ពុជានិងអង្គការសហប្រជាជាតិ ។ កម្ពុជាលើកឡើងពីអធិបតេយ្យភាពនិងកន្លែងដែលមានប្រវត្តិសាស្ត្រកើតឡើងរបស់ខ្លួនខណៈពេលដែលអង្គការសហប្រជាជាតិនៅតែប្រកាន់ទៅតាមបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធនឹងអនុសញ្ញាហ្សឺណែវ និងការបដិសេធមិនទទួលស្គាល់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដ៏សាហាវបែបនេះរបស់សហគមន៍អន្តរជាតិ ។

អង្គការសហប្រជាជាតិមានតួនាទីចូលរួមក្នុងការបង្កើតភាពស្របច្បាប់ឲ្យអង្គសវនាការ ប៉ុន្តែជនរងគ្រោះដែលចង់ឲ្យតុលាការផ្ដល់យុត្តិធម៌និងចង់បានសន្តិភាពយល់ឃើញថាតួនាទីរបស់ខ្លួន មិនសូវមានសារសំខាន់ ។ តាមរយៈការសម្ភាសជាមួយជនរងគ្រោះនិងជនដែលផ្ដល់ចម្លើយដែលស្រដៀងគ្នាគឺអ្នកទាំងនោះមិនសូវមានការយល់ដឹងពីតួនាទីរបស់សហគមន៍អន្តរជាតិនៅក្នុងអង្គជំនុំជម្រះទេ ។ ទោះជាយ៉ាងនេះក្ដី វត្តមានរបស់អង្គការសហប្រជាជាតិមិនត្រឹមតែអាចទាក់ទាញការចាប់អារម្មណ៍របស់អន្តរជាតិប៉ុណ្ណោះទេ វាថែមទាំងបម្រើដល់ការអប់រំប្រជាជនសាមញ្ញឲ្យយល់ពីអំពើប្រល័យពូជសាសន៍ដ៏ធ្ងន់ធ្ងរទៀតផង ។ លោក ឆាំង យុ បាននិយាយថា «យើងមិនអាចធ្វើតែម្នាក់ឯងទេចំពោះអំពើប្រល័យពូជសាសន៍ព្រោះវាជាបញ្ហាពិភពលោក ដូច្នេះប្រទេសទាំងអស់មានភារកិច្ចចាត់វិធានការដើម្បីការពារ អប់រំ ស្វែងយល់ព្យាបាល និងព្យាយាមដោះស្រាយបញ្ហានេះ» ។

គោលបំណងសំខាន់របស់អង្គជំនុំជម្រះគឺដើម្បីផ្ដល់យុត្តិធម៌ដល់ប្រជាជន ការបង្កើនការចូលរួមរបស់ជនរងគ្រោះនៅក្នុងសវនាការគឺជាអ្វីដែលតុលាការកំពុងតែព្យាយាមធ្វើ ។ ចំពោះបញ្ហានេះ លោក ឆាំង យុ បានអះអាងថា «តុលាការមិនអាចផ្ដល់នូវអ្វីដែលជនរងគ្រោះបាត់បង់នោះទេ ដូច្នេះចំពោះខ្ញុំអ្វីដែលសំខាន់គឺ យើងមានដំណើរការមួយដែលអ្នកនៅរស់អាចចូលរួមដើម្បីជាសាក្សីនៅក្នុងប្រវត្តិសាស្ត្រ» ។

ប៉ុន្តែ ការធ្វើដំណើរទៅអង្គជំនុំជម្រះជារៀងរាល់ថ្ងៃឬរាល់សប្ដាហ៍ ផ្ដល់ភាពលំបាកដល់ប្រជាជនភាគច្រើន ជាពិសេសអ្នកដែលរស់នៅតាមខេត្ត ។ ជា ម៉ៅ អតីតអ្នកយាមនៅមន្ទីរស-២១ បាននិយាយថា ទោះបីជាគាត់ចង់ចូលរួមនៅក្នុងតុលាការក៏ដោយក៏គាត់មិនអាចរកពេលតាមដានដំណើរការរបស់អង្គជំនុំជម្រះតាមរយៈវិទ្យុដែរ ពីព្រោះគាត់ត្រូវធ្វើស្រែ ។ សុខ ផាត ក៏ដូចជា ជា ម៉ៅ ដែរ គាត់មិនអាចទៅស្ដាប់សវនាការបានឡើយ ពីព្រោះគ្មាននរណានៅមើលគោឬស្រែឲ្យគាត់ ។ ការពិតសម្រាប់មនុស្សភាគច្រើនគេទំនងជាជ្រើសរើសនៅធ្វើការប្រចាំថ្ងៃវិញជាជាងទៅតុលាការ ។

ដោយសារតែប្រជាជនភាគច្រើនមិនអាចចូលរួមក្នុងអង្គសវនាការ គួរតែមានការផ្ដោតទៅលើការផ្ដល់ថវិកាដើម្បីផ្សព្វផ្សាយឲ្យប្រជាជនបានដឹងពីដំណើរការតុលាការ ។ មិនត្រឹមតែទស្សនាវដ្ដីនិងកាសែតទេដែលត្រូវបោះពុម្ពផ្សាយអត្ថបទទាក់ទងនឹងដំណើរការរបស់អង្គជំនុំជម្រះ ប៉ុន្តែអង្គជំនុំជម្រះគួរតែធ្វើការផ្ដល់ព័ត៌មានដល់ប្រជាជនដែលនៅភូមិដាច់ស្រយាលផង ។ ដើម្បីផ្ដល់ព័ត៌មានទៅដល់អ្នកដែលមិនចេះអក្សរ គួរតែបង្កើតជាក្រុមអានអំពីដំណើរការរបស់អង្គជំនុំជម្រះនៅពេលជាក់លាក់ណាមួយនៅពេលយប់រាល់សប្ដាហ៍នៅតាមសាលារៀនឬវត្ត ។ អង្គការក្រៅរដ្ឋាភិបាល និងក្រុមបេសកកម្មខ្លះអាចប្រមែលប្រមូល ផ្ដល់និងចែកចាយ វិទ្យុ និងទូរទស្សន៍ទៅឲ្យគ្រួសារខ្លះដើម្បីជាការលើកទឹកចិត្តឲ្យប្រជាជនតាមដានដំណើរការសវនាការ ។

អង្គជំនុំជម្រះបានធ្វើការផ្សះផ្សាជាលក្ខណៈបុគ្គលនិងជាតិដោយធ្វើការរួមបញ្ចូលសក្ខីកម្មរបស់ជនរងគ្រោះដើម្បីជាភ័ស្តុតាង

នៅតុលាការ ។ ខណៈពេលដែលការរៀបចំតារាងពេលវេលាមានសារសំខាន់ ដំណើរការជាក់ស្តែងរបស់តុលាការមានសភាពយឺត ហើយមិនជាត្រូវនឹងការរៀបចំ ។ ទោះបីជាអង្គជំនុំជម្រះមានភាពទន់ខ្សោយក៏ដោយ ប៉ុន្តែវត្តមានរបស់តុលាការនេះកំពុងតែជួយកែប្រែនិន្នាការដែលកើតមាននៅកម្ពុជាកាលពីប៉ុន្មានទសវត្សរ៍មុនដែរ ។ ដោយមានវត្តមានអង្គជំនុំជម្រះ អាទិភាពនៃយុត្តិធម៌តាមផ្លូវច្បាប់នៅកម្ពុជាកំពុងត្រូវបានបង្កើតឡើង ។ ទោះបីជាមនុស្សមួយចំនួនពិបាកនឹងទទួលស្គាល់ថាដំណើរការនេះតម្រូវឲ្យមានការចូលរួមពីបុគ្គលមួយចំនួនដូចជា ឌុច ដែលបានសារភាពថាខ្លួនបានបញ្ជាឲ្យមានការសម្លាប់ជាច្រើនហើយដែលមិនគួរមានមេធាវីការពារខ្លួនសោះ មានការរំពឹងទុកថានៅអនាគត ប្រជាជននឹងយល់ស្របថាមនុស្សម្នាក់ៗគួរតែមានមេធាវីការពារនិងមានសិទ្ធិទទួលបានការកាត់ទោសដ៏មានយុត្តិធម៌ ពីព្រោះវាគឺជាសិទ្ធិមូលដ្ឋានរបស់មនុស្ស ។

ដោយយោងទៅតាមការបង្កើតតុលាការវិសាមញ្ញដែលមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដំណើរការព្រហ្មទណ្ឌនិងការរួមបញ្ចូលរវាងច្បាប់ស៊ីវិលឡ និងខមិនឡ តុលាការនេះកំពុងតែត្រូវបានតាមដានមើលថាតើមានបញ្ហាអ្វីដែលតុលាការព្រហ្មទណ្ឌអន្តរជាតិនៅពេលអនាគតអាចយកមកសិក្សាតាម ។ ការលំបាកក្នុងការសម្រេចឲ្យមេដឹកនាំខ្មែរក្រហមជាប់ទោសអាចឆ្លុះបញ្ចាំងពីតម្លៃនៃការចោទប្រកាន់បន្ទាប់ពីមានជម្លោះនោះនឹងនាំឲ្យមានការបង្ហាញការពិត ហើយសង្គមនឹងចាប់ផ្តើមដឹងពីការផ្សះផ្សានិងធ្វើដំណើរឆ្ពោះទៅមុខ ។

ប្រសិនបើមានអង្គជំនុំជម្រះនៅដើមទសវត្សរ៍៨០ កម្មាភិបាលថ្នាក់ទាបខ្មែរក្រហមប្រហែលជានឹងត្រូវបានកាត់ទោសដែរ ។ ទោះជាយ៉ាងនេះក្តី ការកាត់ទោសជនដៃដល់នៅពេលបច្ចុប្បន្នអាចធ្វើឲ្យមានការមិនពេញចិត្ត និងការបែកបាក់នៅក្នុងសង្គមជាជាងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ។ បុរសចំណាស់ម្នាក់ដែលយើងបានសម្ភាសន៍ ឈ្មោះ ញឹម សាវ៉ាត់ អតីតទាហាន លន់ នល់ ហើយក៏ជាជនរងគ្រោះនៃរបបដ៏ឃោរឃៅប៉ុល ពតដែរនោះ ជឿជាក់ថាគួរតែសម្លាប់មេដឹកនាំជាន់ខ្ពស់ហើយគាត់យល់ថាកម្មាភិបាលថ្នាក់ក្រោមគ្រាន់តែធ្វើតាមបញ្ជាដើម្បីរស់ប៉ុណ្ណោះ ។ ការសម្លាប់នេះគួរតែធ្វើឡើងតែចំពោះមនុស្សខ្លះបានហើយ ពីព្រោះរបបប៉ុល ពតជារបបដែលកេណ្ឌប្រជាជនឲ្យធ្វើទាហាន ហើយវារឿង «ស្លាប់ ឬក៏សម្លាប់» ។ នេះបង្កើតជាចម្ងល់ថាតើអ្នកណាជាជនរងគ្រោះ ។

ក្រៅពីភាពខឹងសម្បា គាត់មានការយល់ឃើញស្រដៀងនឹងជនរងគ្រោះផ្សេងទៀតដែលយល់ថាជនដៃដល់ធ្វើនេះគឺដើម្បីរស់ដែរ ។ នៅក្នុងសៀវភៅដែលមានចំណងជើងថាហេតុអ្វីបានជាអ្នកទាំងនោះសម្លាប់មនុស្ស? លោក ហ៊ីន គុន បាននិយាយអំពីអារម្មណ៍របស់ភាគីទាំងពីរ ៖

«នៅពេលដែលខ្ញុំសួរថាតើអ្នកនឹងនិយាយអ្វីនៅពេលដែលអ្នកជួបអតីតអ្នកទោសរបស់អ្នកនៅតាមផ្លូវ? ឡូរ ឆ្លើយថា «ខ្ញុំនឹងប្រាប់អ្នកទាំងនោះថា កុំខឹងនឹងខ្ញុំអី ។ ពេលដែលខ្ញុំធ្វើការនៅទីនោះ ខ្ញុំត្រូវតែគោរពតាមបញ្ជា ខ្ញុំពុំមែនជាមនុស្សចិត្តអាក្រក់និងសាហាវទេ ។ ខ្ញុំមិនបានធ្វើអ្វីទៅលើនរណាម្នាក់ឡើយ ។ ប្រសិនបើគេបញ្ជាឲ្យខ្ញុំចាប់នរណាម្នាក់ ខ្ញុំនឹងទៅចាប់អ្នកនោះ ។ ប្រសិនបើគេបញ្ជាខ្ញុំឲ្យទៅធ្វើអ្វីមួយ ខ្ញុំនឹងធ្វើ» ។

អាស្រ័យហេតុនេះ កិច្ចខំប្រឹងប្រែងផ្សះផ្សាកម្រិតថ្នាក់ឃុំត្រូវតែធ្វើយ៉ាងណាឲ្យជនដៃដល់និងជនរងគ្រោះជួបមុខគ្នា ។ ការធ្វើបែបនេះគឺដើម្បីឲ្យជនរងគ្រោះអាចប្រាប់នូវអ្វីដែលគេបានជួបប្រទះទៅដល់ជនដៃដល់ ដើម្បីឲ្យជនដៃដល់យល់ដឹងពីទុក្ខវេទនាដែលកើតឡើងនៅរបបនោះ ។ នេះមិនត្រឹមតែអាចឲ្យជនរងគ្រោះនិយាយនិងបង្ហាញពីការឈឺចាប់របស់ខ្លួនទៅដល់អ្នកដែលធ្វើតាមបញ្ជារបស់ខ្មែរក្រហមទេ វាថែមទាំងផ្តល់ឱកាសឲ្យជនដៃដល់បង្ហាញពីមនុស្សធម៌របស់ខ្លួនដែរ ។ ដូចដែលលោក ឆាំង យុ បាននិយាយនៅក្នុងបទសម្ភាសន៍មួយអំពីអតីតកាលរបស់លោកថា «ជនរងគ្រោះភាគច្រើនមានអារម្មណ៍ធូរស្រាល ។ គេឃើញជនដៃដល់ដូចជាខ្ញុំឃើញដែរ ។ ខ្មែរក្រហមភាគច្រើនមានរូបភាពជាសត្វចម្លែក ប៉ុន្តែ នៅពេលដែលយើងមើលទៅអ្នកទាំងនោះវាប្រៀបបីដូចជាយើងមើលទៅផ្នែកម្ខាងទៀតនៃខ្លួនយើង ។ អតីតខ្មែរក្រហមក៏បែបនេះដែរ នៅពេលដែលគេមើលទៅជនរងគ្រោះ វាប្រៀបដូចជាគេមើលទៅផ្នែកម្ខាងទៀតនៃខ្លួនគេអ៊ីចឹង» ។

ការជួបនិយាយជាមួយគ្នាមិនត្រឹមតែផ្តល់ឱកាសដល់ជនរងគ្រោះឲ្យមានឱកាសនិយាយទេ ជនដៃដល់ថែមទាំងអាចចែក

រំលែកបទពិសោធន៍ផ្ទាល់ខ្លួនហើយ ដំណើរការនេះអាចជំរុញឲ្យមានការអភ័យទោស និងការទទួលស្គាល់របស់កម្មាភិបាលថ្នាក់ទាបដែលមិនមានឱកាសស្តាប់ពីអ្វីដែលជនរងគ្រោះនិយាយ ។ លោក ឆាំង យុ ក៏ទទួលស្គាល់តម្រូវការនេះសម្រាប់ជនដៃដល់ឲ្យមានជាមនុស្សដែរ «ពីព្រោះខ្មែរក្រហមក៏ត្រូវការផ្សះផ្សាដូចគ្នា ។ អ្នកទាំងនោះក៏ជាមនុស្សដែរ ដូច្នេះគេក៏ត្រូវការដំណើរការផ្សះផ្សា... យើងត្រូវផ្តល់ឱកាសឲ្យជនដៃដល់និយាយទៅកាន់ជនរងគ្រោះ ។ វាក៏មានសារសំខាន់ក្នុងការផ្តល់ឱកាសឲ្យអតីតកម្មាភិបាលអាចប្រាប់ពីរឿងរបស់គេទៅកាន់អ្នក» ។ ដោយមានឱកាសចែករំលែករឿងជីវិតរបស់គេ និងអាចទទួលការអភ័យទោស អតីតទាហានខ្មែរក្រហមអាចមានអារម្មណ៍ធូរស្រាលចំពោះអតីតកាលរបស់គេ គឺមានអារម្មណ៍ធូរស្រាលចំពោះកំហុសរបស់គេនិងធូរស្រាលចំពោះការចងចាំដែលមិនអាចបំភ្លេចបាន ។ ការធ្វើបែបនេះអាចធានាថាប្រទេសជាតិនឹងមិនមានអំពើប្រល័យពូជសាសន៍ម្តងទៀត ។ «យុត្តិធម៌ផ្សះផ្សាគឺជាការគិតទៅអនាគត ការព្យាយាមស្វែងយល់ពីឧក្រិដ្ឋកម្មនៅក្នុងបរិបថសង្គម ។ វាតម្រូវឲ្យយើងត្រួតពិនិត្យទៅលើមូលហេតុដំបូងដែលបណ្តាលឲ្យមានអំពើហិង្សានិងឧក្រិដ្ឋកម្មដើម្បីការពារកុំឲ្យរឿងនេះកើតឡើងម្តងទៀត ។ យុត្តិសាស្ត្រនេះនឹងត្រូវយកប្រើដោយមានការសន្មតថាឧក្រិដ្ឋកម្មកើតចេញពីលក្ខខណ្ឌសង្គមនិងមានការទទួលស្គាល់ថាជនដៃដល់ក៏ទទួលរងនូវការឈឺចាប់ដែរ» ។



ដូនជីសួរសំណួរអំពីដំណើរការតុលាការខ្មែរក្រហម

ការជួបមុខគ្នានិយាយអាចធ្វើឲ្យមានការចែករំលែករឿងរ៉ាវរបស់ជនដៃដល់និងជនរងគ្រោះទៅឲ្យអ្នកដទៃ ដើម្បីឲ្យការចែករំលែកក្លាយជាការយល់ចិត្ត ហើយការយល់ចិត្តក្លាយជាប្រព័ន្ធមួយដែលជំរុញឲ្យមានការផ្សះផ្សានៅថ្នាក់ឃុំ ។

កម្មវិធីសង្គមមួយទៀតដែលមានសារសំខាន់គឺការគាំទ្រជនរងគ្រោះដែលមានការលំបាកក្នុងការបំភ្លេចការចងចាំដែលមិនអាចបំភ្លេចបាននិងសុបិនអាក្រក់ ។ ខណៈពេលដែលការព្យាបាលគឺជាដំណោះស្រាយដ៏ល្អមួយ វាក៏អាចបណ្តាលឲ្យមានផលប្រយោជន៍ជាច្រើនដល់ប្រទេសផ្សេងទៀតដែរ ។ ដើម្បីធ្វើឲ្យការព្យាបាលនៅកម្ពុជាកាន់តែប្រសើរឡើង ត្រូវតែមានការបង្កើតក្រុមអ្នកព្យាបាលនៅតាមវត្តដែលមានការសម្របសម្រួលដោយប្រធានភូមិឬចៅអធិការ ។ កម្មវិធីនេះគួរតែត្រូវបានជំរុញដោយអង្គការក្រៅរដ្ឋាភិបាលដែលអាចបញ្ជូនអ្នកជំនាញខាងចិត្តសាស្ត្រ ឬជួលអ្នកដែលមានជំនាញនេះឲ្យទៅធ្វើការនៅក្នុងភូមិផ្សេងៗគ្នា ។ ដោយមិនគិតពីរបៀបនៃការឧបត្ថម្ភកម្មវិធីនេះ កម្មវិធីនេះគួរតែផ្តោតទៅលើការផ្តល់ការគាំទ្រផ្នែកសង្គម ស្មារតី និងសម្ភារៈនិងជំនួយនៅពេលព្យាបាល» ។ បន្ទាប់មកក្រុមអ្នកព្យាបាលអាចមានបទពិសោធន៍ហើយរាល់សកម្មភាពនេះអាចបម្រើជាផ្នែកមួយក្នុងការផ្សះផ្សាថ្នាក់ជាតិនិងថ្នាក់ឃុំ ។

ខណៈពេលវាជាតម្រូវការដ៏ចាំបាច់មួយសម្រាប់ព្យាបាលសហគមន៍ អ្នកនៅរស់ផ្សេងទៀតមានអារម្មណ៍ថា ដំណើរការនេះមិនអាចជួយដល់បុគ្គលស្វែងរកសន្តិភាពទេ ។ ជាឧទាហរណ៍ ជា ម៉ៅ មានអារម្មណ៍ថាអ្នកដែលស្លាប់ក្នុងរបបខ្មែរក្រហម គឺស្លាប់ដោយស្ងៀមស្ងាត់ ប៉ុន្តែ អ្នកដែលនៅរស់តែងតែនឹងឃើញពីអតីតកាលដែលមិនមានយុត្តិធម៌ និងសន្តិភាព ។ ទោះបីជាការចូលរួមក្រុមដោះស្រាយបញ្ហាសង្គមមិនអាចផ្តល់សន្តិភាពក្នុងចិត្តរបស់គាត់ផ្ទាល់ក៏ដោយ ក៏ ម៉ៅ និយាយថា គាត់នឹងទទួលបានយុត្តិធម៌ខណៈពេលដែលគាត់រស់នៅក្រោមខ្សែបន្ទាត់ក្រីក្រ ។ រីឯ ញឹម សារ៉ាត់ គាត់បានរកឃើញសន្តិភាពហើយខណៈពេល

ដែលគាត់ដឹងថាគាត់មិនមែននៅម្នាក់ឯងទេ ទោះបីជានៅពេលដែលនឹកឃើញនិងនិយាយអំពីរឿងនេះធ្វើឲ្យគាត់មានអារម្មណ៍អស់កម្លាំងនិងភ័យខ្លាចក៏ដោយ ។ សម្រាប់អ្នកខ្លះដូចជា ឆាំង យុ ជាដើម នៅពេលលោកបានចែករំលែករឿងរ៉ាវរបស់លោក ធ្វើឲ្យលោកមានអារម្មណ៍ធូរស្រាល ។ លោកបាននិយាយថា របស់សំខាន់បំផុតដែលជនរងគ្រោះកំពុងទន្ទឹងរង់ចាំគឺរង់ចាំអ្នកស្តាប់រឿងរ៉ាវខ្លួន ។ គ្រាន់តែស្តាប់រឿងរ៉ាវនោះជនរងគ្រោះចង់និយាយប្រាប់អំពីរឿងរបស់ខ្លួនណាស់ ។ ហើយនៅពេលដែលអ្នកស្តាប់រឿងរបស់ខ្លួនគេវាពិតជាអាចជួយខ្លួនបានច្រើនណាស់ ។ អ្នកមិនចាំបាច់ធ្វើអ្វីទៀតទេ នេះជារឿងរបស់មនុស្ស ការយល់ចិត្តគ្នារបស់មនុស្ស និងការពិតរបស់មនុស្ស ។ ប្រាក់មិនអាចនាំឲ្យមានដំណើរការផ្សះផ្សាបានទេ អ្នកអាចសាកល្បងវាបាន ប៉ុន្តែវានឹងមិនដំណើរការទេ ។ ប៉ុន្តែសម្រាប់អ្នកខ្លះដូចជា ហ៊ឹម ហ៊ុយ កាលដែលមានគេសួរអំពីអតីតកាលរបស់គាត់ អាចធ្វើឲ្យគាត់នឹកឃើញការឈឺចាប់ឡើងវិញ ។ នៅពេលដែលសួរថាអ្វីអាចផ្តល់សន្តិភាពដល់គាត់ គាត់ឆ្លើយថា «អ្នកទាំងអស់គ្នាគ្រាន់តែទុកឲ្យខ្ញុំនៅតែឯងហើយឈប់សួរសំណួរខ្ញុំទៀតបានហើយ» ។ សម្រាប់មនុស្សជាច្រើនដែលមិនទាន់ស្វែងរកសន្តិភាពតាមរយៈការចែករំលែករឿងរ៉ាវរបស់គេ ការព្យាបាលជាបុគ្គលគួរតែធ្វើឡើងតាមរយៈការតាំងសមាធិនិងការប្រណិប័ត្តន៍តាមសាសនា ។

ប្រជាជនកម្ពុជាជាច្រើនបានត្រឡប់ទៅរកព្រះពុទ្ធសាសនាដើម្បីបង្កើតអារម្មណ៍ស្ងប់ស្ងាត់ ។ ដោយសារភាគច្រើននៃប្រជាជនគឺជាពុទ្ធសាសនិក នៅកម្រិតជាតិនិងតាមតំបន់ ជំនឿព្រះពុទ្ធសាសនានិងវត្តគួរតែបន្តដើរតួនាទីព្យាបាលនិងផ្សះផ្សាអ្នកនៅរស់ ។ ការអប់រំមួយរបស់ព្រះពុទ្ធសាសនាបានអប់រំប្រជាជនមិនឲ្យមានការចងពៀរ ។ កម្មដែលគេប្រព្រឹត្តខុសក្រិដ្ឋកម្មនៅជាតិនេះនឹងត្រូវបានទូទាត់និងសងវិញនៅជាតិក្រោយតាមទ្រឹស្តីកម្មផល ។ សម្រាប់រយៈពេលជាងបីទសវត្សរ៍ សាសនាបានជួយរំសាយកំហឹងជនរងគ្រោះដោយធ្វើការផ្សះផ្សារជនរងគ្រោះជាមួយនឹងជនដៃដល់ដែររស់នៅជិតគ្នា ។ ដាក់ស្តែង ជា ម៉ៅ បាននិយាយថាការសងសឹកមិនមែនជាចម្លើយនៃយុត្តិធម៌ទេ ប៉ុន្តែកម្មគឺជាយុត្តិធម៌តាមរយៈព្រះពុទ្ធសាសនា ។ ស្រដៀងគ្នានេះដែរ ប្រជាជនភាគច្រើនដែលបាននិយាយជាមួយនៅកម្ពុជាបានសង្កត់ធ្ងន់ទៅលើតួនាទី របស់ព្រះពុទ្ធសាសនានៅក្នុងដំណើរការព្យាបាល ។

ព្រះពុទ្ធសាសនាបានអប់រំថាការអភ័យទោសមានសារសំខាន់សម្រាប់ដំណើរជីវិតឆ្ពោះទៅមុខ ។ ដោយហេតុផលនេះ អ្នកដែលជឿលើសាសនាភាគច្រើននៅកម្ពុជាអាចនិយាយដោយបើកចំហជាមួយអតីតជនដៃដល់ដើម្បីរំសាយកំហឹងរបស់គេដោយធ្វើការអភ័យទោសទៅដល់អ្នកដែលធ្វើបាបខ្លួននិងគ្រួសាររបស់ខ្លួន ។ ស្ត្រីកម្ពុជាម្នាក់និយាយដោយលើកឡើងពីព្រះពុទ្ធថា «កំហឹងមិនអាចរំងាប់កំហឹងបានឡើយ» ទោះបីជាយើងដាក់ទណ្ឌកម្មអ្នកប្រព្រឹត្តខុសក៏ដោយ ក៏យើងមិនធ្វើឲ្យជនរងគ្រោះមានជីវិតវិញបានទេ ។ អារម្មណ៍របស់ស្ត្រីម្នាក់នេះ ឆ្លុះបញ្ចាំងពីជនរងគ្រោះកម្ពុជាភាគច្រើនដែលបានអភ័យទោសដល់ជនដៃដល់ ហើយបានរកឃើញសន្តិភាព ។ នៅក្នុងរឿងភាពយន្ត «ទារកឆ្នាំថ្មី» អ្នកបកប្រែភាសាដឹងថាអតីតពេទ្យស្រីខ្មែរក្រហមដែលគេកំពុងសម្ភាសន៍ធ្វើការនៅមន្ទីរពេទ្យដែលម្តាយរបស់គាត់ស្លាប់ ។ តាមរយៈការសន្ទនាដ៏ឈឺចាប់ ហើយអ្នកទាំងពីរអាចយល់ចិត្តគ្នាតាមរយៈការទទួលស្គាល់រឿងរ៉ាវរបស់គ្នាទៅវិញទៅមកដែលបណ្តាលឲ្យមានការអភ័យទោស ។ ព្រះពុទ្ធសាសនាបានផ្តល់ហេតុផលនិងផ្លូវដល់ប្រជាជនឲ្យធ្វើការអភ័យទោស និងផ្សះផ្សា ។

ទោះបីជាប្រជាជនកម្ពុជាមិនមែនជាពុទ្ធសាសនិក តែជាចាមមូស្លីមដែលនៅរស់ក៏គិតទៅដល់ព្រះអាឡារបស់គេដែរដើម្បីផ្សះផ្សាជាមួយអតីតកាលរបស់ខ្លួន ។ នៅពេលដែលយើងនិយាយជាមួយ ឯល សម អាយុ៧៨ឆ្នាំ ជាជនជាតិចាម គាត់បានប្រាប់យើងថាសាសនារបស់គាត់បានជួយដល់គាត់ ពីព្រោះគាត់បានប្រើប្រាស់ការបង្រៀនអ៊ីស្លាមរបស់គាត់ដើម្បីដំណើរការផ្សះផ្សាមួយកម្រិត ។ ជាមួយនឹងក្មេងៗជំនាន់ក្រោយ៣នាក់ផ្សេងទៀតដែលរស់នៅក្នុងផ្ទះ គាត់បានលើកឡើងពីការអប់រំបែបអ៊ីស្លាមដែលជាផ្នែកមួយសម្រាប់ដំណើរការព្យាបាល ។ បន្ទាប់ពីទទួលរងការធ្វើការងារធ្ងន់ជាង២៥ឆ្នាំតាំងពីស្វាមីរបស់គាត់បានស្លាប់ដោយរបបលន់ នល់ នៅឆ្នាំ១៩៧២ គាត់អាចស្វែងរកសន្តិភាពតាមរយៈ «ការព្យាបាលដោយពឹងផ្អែកទៅលើការសម្រេចរបស់ព្រះអាឡា» ។ ការនិយាយរបស់គាត់បង្ហាញយ៉ាងច្បាស់ថាប្រជាជនកម្ពុជា ក៏

ដូចជាអ្នកមានជំនឿផ្សេងៗនៅលើពិភពលោកដែរបានស្វែងរកក្តីសង្ឃឹម និងភាពធូរស្រាលដោយពឹងផ្អែកលើជំនឿដែលថានឹងផ្តល់យុត្តិធម៌និងនិងការអភ័យទោស ។

ខណៈពេលដែលឃ្លា «មិនដែលកើតមានម្តងទៀត» តែងតែកើតឡើងនៅប្រទេសក្រោយពីមានអំពើប្រល័យពូជសាសន៍មានតែការអនុវត្តតាមឃ្លានេះទើបអាចធ្វើឲ្យប្រជាជនទទួលយកការឈឺចាប់ និងអំពើដ៏ឃោរឃៅនេះ ។ ទោះបីជាកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលផ្សះផ្សាដែលមានការកាត់ទោស កិច្ចខំប្រឹងប្រែងដើម្បីឲ្យមានការចងចាំនៅក្នុងប្រទេសក៏មានសារសំខាន់ដែរ ។ ជាឧទាហរណ៍ ជើងឯកគឺជាវាលពិឃាតដែលរំឭកពីការចងចាំមួយក្នុងចំណោមវាលពិឃាតដែលរំឭកពីការចងចាំទាំង១៦០កន្លែង ។ បូជនីយដ្ឋានដែលមានលលាដ៏ក្បាលដែលមានទីតាំងនៅកណ្តាលភូមិជួយរំឭកដល់ប្រជាជនកម្ពុជាអំពីអំពើប្រល័យពូជសាសន៍ ប៉ុល ពត ប្រឆាំងនឹងប្រជាជនកម្ពុជា ។ គុកទួលស្លែងនៅភ្នំពេញគឺជាកន្លែងរំឭកដល់សាធារណជនអំពីរយៈកាលដ៏ខ្មៅងងឹតចំនួន៤ឆ្នាំ ។ ខណៈពេលដែលកន្លែងរំឭកនេះអាចរំឭកនូវការចងចាំដ៏ឈឺចាប់ដល់អ្នកនៅរស់ វាអាចធ្វើឲ្យក្មេងៗជំនាន់ក្រោយដឹង ហើយអាចជួយរំឭកដល់អ្នកដែលបានឆ្លងកាត់របបខ្មែរក្រហម ។

ដើម្បីបន្ថែមទៅលើកន្លែងរំឭកដែលបន្សល់ទុកពីពេលនោះមក រដ្ឋាភិបាលគួរតែចាត់វិធានការមួយចំនួនដើម្បីទទួលស្គាល់អំពើប្រល័យពូជសាសន៍ដើម្បីជាផ្នែកមួយក្នុងដំណើរការផ្សះផ្សាជាតិ ។ មធ្យោបាយមួយដែលប្រទេសផ្សេងៗប្រើដើម្បីជំរុញឲ្យមានការផ្សះផ្សា គឺប្តូរឈ្មោះអគារសំខាន់ៗ សួនច្បារ និងផ្លូវដើម្បីរំឭកដល់រយៈកាលប្រវត្តិសាស្ត្រ ។ ដោយប្តូរឈ្មោះដើម្បីគោរពដល់មេដឹកនាំសំខាន់ៗដែលបានប្រឆាំងនឹងរបបនេះ មានការជជែកគ្នាខណៈពេលដែលប្រជាជនឃើញការអនុវត្តបែបនេះដែលរំឭកដល់គេ «កម្ពុជាធ្លាប់បានឆ្លងកាត់ ប្រទេសកម្ពុជាក៏បានយកឈ្នះហើយដែរ» ។

រដ្ឋាភិបាលគួរតែគាំទ្រការផ្សះផ្សាជាតិតាមរយៈការបង្កើតថ្ងៃឈប់សម្រាកជាតិ ដែលស្រដៀងនឹងទិវាចងកំហឹងថ្ងៃទី២០ ខែឧសភា ។ នៅថ្ងៃនោះ «កូនសិស្សសម្តែងនូវការធ្វើទារុណកម្មនិងការសម្លាប់ដែលធ្វើឡើងដោយជនកុម្មុយនីស្តជ្រុលនិយម នៅពាក់កណ្តាលទសវត្សរ៍៧០ ដែលបណ្តាលឲ្យប្រជាជនប្រមាណ១.៧លាននាក់ស្លាប់ ។ ការសម្តែងនៅឆ្នាំនេះធ្វើឡើងនៅជិតបូជនីយដ្ឋានដែលមានលលាដ៏ក្បាលជនរងគ្រោះនិងរណ្តៅសពរួមដែលប្រជាជនរាប់ពាន់នាក់ត្រូវបានសម្លាប់និងកប់» ។ ការប្រារព្ធនេះស្រដៀងទៅនឹងការប្រារព្ធមួយដែលធ្វើឡើងនៅទូទាំងប្រទេសនៅថ្ងៃទី២០ ឧសភា ។ ប្រសិនបើរដ្ឋាភិបាលបង្កើត ឬបន្ថែម «ថ្ងៃផ្សះផ្សាជាតិ»ដូចជាទិវាចងកំហឹងដែលភ្ជាប់ទំនាក់ទំនងការផ្សះផ្សាជាបុគ្គល ថ្នាក់ឃុំ និងថ្នាក់ជាតិ យុត្តិធម៌អាចនឹងងាយសម្រេចបានងាយមើលឃើញនៅបានយូរ និងមានអត្ថន័យជាងមុន ។

ដោយសារតែខ្មែរក្រហមមានគោលដៅបោសសម្អាតវណ្ណៈថ្នាក់លើ និងកណ្តាល គេបានសម្លាប់ប្រជាជនកម្ពុជាដែលមានការអប់រំខ្ពស់ជាច្រើន ។ ដោយសារតែហេតុនេះ ទើបបណ្តាលឲ្យមានចលនាចាកចេញពីប្រទេសរបស់បញ្ញវ័ន្តជាច្រើន ។ ការធ្វើបែបនេះបណ្តាលឲ្យមានបញ្ហាសង្គម ដែលរួមមានការបាត់បង់ការដឹកនាំនៅក្នុងប្រទេស ។ ដោយសារតែ ប៉ុល ពត បានបំផ្លាញផ្លូវចិត្តរបស់ប្រជាជន គ្មាននរណាម្នាក់ចង់បង្រួបបង្រួមគ្នាឡើយមានតែមនុស្សប៉ុន្មាននាក់ប៉ុណ្ណោះដែលចង់និយាយរឿងរបស់គេ ។ នៅក្នុងសៀវភៅ «The road of lost innocence» ម៉ម សុមាលី តែងតែនិយាយអំពីការយល់ឃើញរបស់ប្រជាជន ទៅលើលទ្ធផលនៃរបបនោះថា ៖ «ប្រជាជនបានឆ្លងកាត់រយៈកាលនោះដែលធ្វើឲ្យគេមិនអាចជឿលើនរណាម្នាក់ដូចជា មិត្តភក្តិ អ្នកជិតខាង សូម្បីតែគ្រួសាររបស់គេផ្ទាល់ ។ ប្រសិនបើអ្នកកាន់តែចង់ឲ្យគេយល់ដឹងពីខ្លួនអ្នក អ្នកនឹងនិយាយកាន់តែច្រើននៅពេលនោះអ្នកនឹងនាំខ្លួនឯងទៅរកភាពគ្រោះថ្នាក់ ។ យើងចាំបាច់គួរតែកុំឃើញ កុំឮ និងមិនដឹងពីអ្វីដែលបានកើតឡើង ។ នេះគឺជាឥរិយាបថរបស់ប្រជាជនកម្ពុជា» ។

លោក ឆាំង យុ បានសង្កត់ធ្ងន់ថា ប្រជាជនកម្ពុជាត្រូវតែយកចិត្តទុកដាក់ទៅលើការដឹកនាំនិងគ្រប់គ្រងអតីតកាលនិងគ្រប់គ្រងដំណើរការបច្ចុប្បន្ន «រាល់កាលប្រែប្រួលត្រូវតែកើតចេញពីប្រជាជនកម្ពុជា» ។

មធ្យោបាយដ៏ល្អបំផុតសម្រាប់រក្សានូវប្រវត្តិសាស្ត្រដើម្បីកុំឲ្យកើតឡើងម្តងទៀតគឺការអប់រំ ។ អ្នកនៅរស់យល់ឃើញថាតាមរយៈការអប់រំយុវជន វាអាចធានាថាកំហុសដែលកើតឡើង

ពីអតីតកាលនឹងមិនកើតឡើងម្តងទៀតទេ ។ ហ៊ីម ហ៊ុយ បានគាំទ្រគំនិតនេះថា «ការអប់រំគឺជាមធ្យោបាយតែមួយគត់» ។ តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា សាលាបង្រៀននៅកម្ពុជាទើបតែចាប់ផ្តើមបង្រៀនក្មេងៗជំនាន់ក្រោយអំពីរបបខ្មែរក្រហម ។ កាលពីមុនមានតែរឿងរ៉ាវទាក់ទងនឹងរបប ប៉ុល ពត ប្រហែលពីរបីឃ្លាប៉ុណ្ណោះ ត្រូវបានលើកឡើងនៅក្នុងសៀវភៅ ហើយពាក្យថាប្រល័យពូជសាសន៍មិនដែលត្រូវបានយកមកនិយាយទេ ។ ដោយហេតុផលនេះទើបធ្វើឲ្យក្មេងៗជំនាន់ក្រោយយល់ដឹងតែបន្តិចបន្តួចប៉ុណ្ណោះអំពីការបំផ្លិចបំផ្លាញរយៈពេល៤ឆ្នាំនោះ ។ ខណៈពេលដែលសៀវភៅសិក្សាថ្មីអាចជួយឲ្យក្មេងៗជំនាន់ក្រោយយល់ដឹង គ្រូៗគួរតែនិយាយអំពីបទពិសោធន៍របស់ខ្លួនទៅកាន់កូនសិស្សផង ។ ហើយគួរតែមានការចុះតាមមូលដ្ឋានដើម្បីអញ្ជើញសមាជិកសហគមន៍ផ្សេងៗដើម្បីនិយាយអំពីអតីតកាលរបស់គេ ។ សាលារៀនគួរតែបង្កើតជាទស្សនកិច្ចនាំសិស្សមកស្តាប់សវនាការនៅអង្គជំនុំជម្រះរយៈពេលមួយថ្ងៃ ដូច្នេះក្មេងៗមិនត្រឹមតែអាចដឹងពីដំណើរការ និងដឹងពីទុក្ខវេទនារបស់ប្រជាជនប៉ុណ្ណោះទេ គឺថែមទាំងដឹងពីតម្លៃនៃការសិក្សាថ្នាក់វិទ្យាល័យផង ។ ការមើលទៅការងាររបស់មេធាវីនិងចៅក្រមប្រហែលជាអាចជំរុញសិស្សឲ្យមានក្តីស្រមៃនិងចង់ទៅរៀនថ្នាក់មហាវិទ្យាល័យ ។

សម្រាប់ក្មេងៗជាច្រើនដែលមានឪពុកម្តាយប្រាប់ពីរឿងរ៉ាវជីវិតរបស់គាត់នៅក្រោមរបបខ្មែរក្រហម គេមានភាពស្មុកស្មើរនិងការមិនពេញចិត្តនឹងសវនាការ ។ វាមានការលំបាកដល់ក្មេងៗក្នុងការស្តាប់រឿងរ៉ាវរបស់ឪពុកម្តាយដែលពិបាកនឹងយល់ ។ មានអត្រានៃការធ្វើបែបនេះនៅទូទាំងពិភពលោកៈ យុវជនបះបោរប្រឆាំងនឹងឪពុកម្តាយដើម្បីទាមទារឯករាជ្យ សំណាងល្អដែលពិភពលោកបានសិក្សាពីមធ្យោបាយជាច្រើនដើម្បីដោះស្រាយបញ្ហានេះ ។ សុខ ផាត បាននិយាយថា ខណៈពេលដែលគាត់គិតថាការអប់រំយុវជនគឺជាជំហានខ្លាំងបំផុតដើម្បីឆ្ពោះទៅកាន់ការផ្សះផ្សា ក្មេងៗ «មិនយកចិត្តទុកដាក់ និងមិនចង់ដឹងពីអតីតកាលអំពីខ្មែរក្រហមទេ» ។ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពនេះ ក្មេងៗគួរតែត្រូវបានជំរុញឲ្យស្តាប់រឿងរ៉ាវរបស់អ្នកដទៃ ឲ្យគេស្តាប់រឿងរ៉ាវរបស់អ្នកផ្សេងទៀតដែលមិនមែនជាសមាជិកគ្រួសារខ្លួនដើម្បីឲ្យក្មេងៗទាំងនោះដឹងថាឪពុកម្តាយខ្លួនមិនមែនចេះតែនិយាយពីរឿង«គ្រួសារ»ទេ ។ យើងមិនត្រឹមតែផ្តល់ឱកាសឲ្យអ្នកនៅរស់និយាយទេ យើងនឹងបង្រៀនក្មេងជំនាន់ក្រោយអំពីប្រវត្តិសាស្ត្ររួមដែលប្រជាជនកម្ពុជានឹងរក្សាទុកនៅពេលអនាគត ។

អំពើប្រល័យពូជសាសន៍ដ៏សាហាវនៅកម្ពុជានៅមានវត្តមានដោយសម្ងាត់ជាងបីទសវត្សរ៍មកហើយ ។ ជាមួយនឹងការចាប់ផ្តើមការកាត់ក្តីនៅអង្គជំនុំជម្រះ នៅទីបញ្ចប់ប្រជាជនកម្ពុជាកំពុងតែឃើញក្តីសង្ឃឹមដែលថាបក្សពួករបស់ ប៉ុល ពត នឹងត្រូវបានបញ្ចប់ ក្មេងៗជំនាន់ក្រោយនឹងមិនប្រព្រឹត្តកំហុសនេះម្តងទៀតហើយ អនាគតនឹងផ្តល់ឱកាសឲ្យក្មេងៗល្អជាងពេលបច្ចុប្បន្ន ។ លោក ឆាំង យុ សង្ឃឹមថា «នៅសតវត្សរ៍ថ្មីនេះ ជាមួយនឹងបច្ចេកទេសទំនើបយើងអាចធ្វើអ្វីៗបានល្អជាងនេះ ។ សង្គមចាំបាច់ត្រូវតែមានមូលដ្ឋានគ្រឹះនៃវិធានច្បាប់ ប៉ុន្តែប្រជាជនត្រូវតែសម្រេចនិងដឹកនាំជីវិតរបស់គេដោយរបៀបណា ។ ហើយតុលាការគឺជាដំណើរការសំខាន់បំផុត ពីព្រោះប្រជាជនអាចនឹងទៅដល់វា ហើយយើងអាចកត់ត្រាពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបញ្ចប់របបខ្មែរក្រហម ។ ដោយសារតែអំពើប្រល័យពូជសាសន៍នៅតែកើតមាននៅសតវត្សរ៍ចុងក្រោយនេះ យើងនៅតែនិយាយពាក្យថាមិនកើតឡើងម្តងទៀតទេ បន្ទាប់ពីសង្គ្រាមលោកលើកទី១ និងទី២ ។ វានៅតែកើតមាន ដូច្នេះ ខ្ញុំសង្ឃឹមថានៅក្នុងសតវត្សរ៍ថ្មីនេះ យើងអាចធ្វើឲ្យវាក្លាយជាការពិត ។ ហើយខ្ញុំសង្ឃឹមថាតុលាការខ្មែរក្រហមអាចក្លាយជាមេរៀនសំខាន់បំផុតសម្រាប់អំពើអមនុស្សធម៌ទាំងអស់» ។

**ឌីហ្សានី ហេនលី**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

*វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។* **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# អតីតកាលរបស់ម្តាយខ្ញុំ

ខ្ញុំជាកូនច្បងគេបង្អស់ក្នុងចំណោមបងប្អូន៣នាក់នៅក្នុងគ្រួសារ ។ កាលពីខ្ញុំនៅតូច ឪពុកម្តាយរបស់ខ្ញុំតែងតែនិយាយរឿងមួយ ដែលកាលណោះខ្ញុំមិនសូវជាចាប់អារម្មណ៍ប៉ុន្មានទេ ប៉ុន្តែគឺជារឿងមួយដែលខ្ញុំនៅតែចងចាំជានិច្ច ។ ម្តាយរបស់ខ្ញុំបានរៀបរាប់ពីទុក្ខលំបាករបស់គាត់នៅក្នុងរបបខ្មែរក្រហមមកប្រាប់ខ្ញុំថាជីវិតរបស់គាត់ពោរពេញទៅដោយភាពភ័យខ្លាចនិងភាពប្រថុយប្រថាននឹងការបាត់បង់ជីវិត ដោយមិនដឹងថាខ្លួនឯងបានធ្វើអ្វីខុសនោះទេ ។

ម្តាយរបស់ខ្ញុំឈ្មោះ ប្រាក់ អេង មានស្រុកកំណើតនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ ។ ក្រោយពីរដ្ឋប្រហារនៅឆ្នាំ១៩៧០ ជីវភាពគ្រួសាររបស់ជីតាខ្ញុំកាន់តែលំបាកទៅ ។ ដូច្នេះក្នុងអំឡុងឆ្នាំ១៩៧៣ ជីតារបស់ខ្ញុំក៏បានសម្រេចចិត្តផ្លាស់ទៅរស់នៅទីរួមខេត្តបាត់ដំបង (ផ្សារបឹងឈូក) វិញ ដើម្បីងាយស្រួលក្នុងការ



ហ៊ិន សុធានី និងប្អូនស្រី ឆ្នាំ១៩៨៧

ប្រកបរបរចិញ្ចឹមជីវិត ។ ប៉ុន្តែក្នុងចំណោមបងប្អូនរបស់ម្តាយខ្ញុំឈ្មោះ ហៀ ហៅ ទ្រី មិនព្រមចាកចេញពីផ្ទះទេ ដោយសារតែគាត់ត្រូវបន្តការសិក្សានៅវិទ្យាល័យបឹងត្របែក ។

នៅក្នុងឆ្នាំ១៩៧៥ ក្រោយពីយោធាខ្មែរក្រហមចូលដល់ទីរួមខេត្តបាត់ដំបង អ្នកស្រុកស្ទើរតែទាំងអស់ដែលរស់នៅទីរួមខេត្តត្រូវបានជម្លៀសចេញ ។ ប៉ុន្តែគ្រួសាររបស់ម្តាយខ្ញុំនិងអ្នកជិតខាងចំនួន២ទៅ៣គ្រួសារទៀតមិនព្រមចាកចេញទៅតាមការបញ្ជារបស់កងទ័ពខ្មែរក្រហមទេ ព្រោះខ្លាចយោធាខ្មែរក្រហមបញ្ជូនយកទៅដាក់កងការងារ ។ ថ្ងៃមួយ ដោយសារឃ្លានពេកគាត់បានដើររកអីហូបនៅក្បែរៗផ្ទះ រួចក៏ប្រទះឃើញសាកសពអ្នកភូមិមួយចំនួនដែលបានស្លាប់នៅក្បែរនោះ ។ ឃើញដូច្នេះគាត់មានការភ័យខ្លាចជាខ្លាំង ហើយខំរត់ត្រឡប់មកផ្ទះយ៉ាងរហ័ស ។ រយៈពេលមួយសប្តាហ៍ក្រោយមក យោធាខ្មែរក្រហមពីរនាក់បានមកបញ្ជាឲ្យក្រុមគ្រួសារគាត់និងអ្នកជិតខាង២ទៅ៣គ្រួសារទៀតចាកចេញពីផ្ទះទៅរស់នៅកងចល័ត ។ «បើមិត្តណាមានអាយុពី១៥ដល់២០ឆ្នាំ ឲ្យចូលទៅកងចល័តយុវជន មិត្តណាមានអាយុពី១០ឆ្នាំចុះក្រោមឲ្យចូលកងចល័តកុមារ និងអ្នកដែលមានប្តីប្រពន្ធឲ្យចូលទៅក្នុងកងចល័តមនុស្សចាស់» ។ ដោយសារតែកាលពីមុន ម្តាយរបស់ខ្ញុំមិនដែលបែកចេញពីគ្រួសារទេ ពេលនោះគាត់មានអារម្មណ៍ភ័យខ្លាចនិងពិបាកចិត្តជាខ្លាំង ។ បន្ទាប់មកយោធាទាំងពីរនាក់នោះបានចាត់តាំងឲ្យម្តាយរបស់ខ្ញុំធ្វើជាយុទ្ធនារីកងចល័តបន្ទាយរំចេក (នៅក្បែរទីរួមខេត្តបាត់ដំបង) ក្រោមការគ្រប់គ្រងរបស់ប្រធានកងនារីឈ្មោះ វ៉ន ។ ក្រុមរបស់ម្តាយខ្ញុំមានសមាជិកក្រុមចំនួន៣០នាក់ មានតួនាទីធ្វើស្រែ លើកទំនប់ជីកប្រឡាយ កាត់ដេរ និងការងារផ្សេងៗទៀតទៅតាមការបញ្ជារបស់មេកង ។ ការងារនេះ មានការមមាញឹកស្ទើរតែរាល់ថ្ងៃ ហើយថែមទាំងត្រូវចាកចេញពីផ្ទះជាច្រើនខែទៀត ទើបបានត្រឡប់មកសហករណ៍របស់ខ្លួនវិញ ប៉ុន្តែអាហារដែលគាត់ទទួល

បាន គឺហូបមិនបានគ្រប់គ្រាន់នោះទេ ។ ដូច្នេះ ពេលខ្លះ ម្តាយរបស់ខ្ញុំត្រូវដើរបេះស្លឹកឈើណាដែលអាចហូបបានយកមកលាយជាមួយរបបដែលប្រធានរោងបាយបានចែកឲ្យថែម ។ ចំណែកជីតារបស់ខ្ញុំត្រូវប្រធានសហករណ៍ចាត់ឲ្យធ្វើជាអ្នកបើករថយន្តដឹកថ្នាំពេទ្យពីខេត្តបាត់ដំបងទៅពោធិ៍សាត់ ដោយយូរៗម្តងទើបបានជួបមុខកូននិងប្រពន្ធ ។ ជីដូនរបស់ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យធ្វើស្រែដោយសារតែគាត់ជាមនុស្សមានគ្រួសារនិងមានវ័យចំណាស់ ។

នៅឆ្នាំ១៩៧៧ ជីដូនរបស់ខ្ញុំកើតបានកូនប្រុសម្នាក់ ប៉ុន្តែកូននោះត្រូវស្លាប់ទៅវិញបន្ទាប់ពីកើតបានពីរបីថ្ងៃ ដោយសារតែគាត់ពុំមានទឹកដោះគ្រប់គ្រាន់ ។ នៅពេលនោះ ម្តាយរបស់ខ្ញុំក៏បាននៅមើលប្អូនរបស់គាត់ដែរ ប៉ុន្តែគាត់មិនអាចរកចំណីអាហារមកចិញ្ចឹមប្អូនរបស់គាត់បានទេ ។ ដូច្នេះ គាត់មានការសោកស្តាយជាខ្លាំងដែលប្អូនរបស់គាត់ទើបនឹងកើតនោះត្រូវស្លាប់ទៅវិញដូច្នេះ ។ មួយរយៈក្រោយមក ម្តាយរបស់ខ្ញុំត្រូវបានប្រធានកងនារីឈ្មោះ វ៉ន នៅកងចល័តយុវជនបន្ទាយរំចេកចោទប្រកាន់ថា «ជាកូនយួន» ដោយសារតែគាត់មានរូបរាងសស្អាតជាងអ្នកនៅក្នុងកងជាមួយគ្នា ។ ពេលនោះ មេកងបានបណ្តើរម្តាយរបស់ខ្ញុំយកទៅសម្លាប់ចោល ។ ម្តាយរបស់ខ្ញុំមានអារម្មណ៍ភ័យតុកស្លុតជាខ្លាំងដោយគ្មានសង្ឃឹមថានឹងអាចរស់រានមានជីវិតបានឡើយ ។ ប៉ុន្តែជាសំណាងល្អប្រធានសហករណ៍បានប្រទះឃើញដោយចៃដន្យ ហើយបានហៅឈ្មោះ វ៉ន មកសួរនាំដោយនិយាយដោះសាថា «មិត្តនេះជាអ្នកស្រុកអ្នកភូមិជាមួយគ្នា មិនមែនជាជនជាតិយួនដូចពាក្យចោទប្រកាន់ទេ ខ្ញុំហ៊ានធានា» ។ ដោយការអះអាងរបស់ប្រធានសហករណ៍ ទើបម្តាយរបស់ខ្ញុំបានរួចពីសេចក្តីស្លាប់ ។ ដូច្នេះគាត់ស្ទើរតែមិនហ៊ានជឿថា គាត់មានជីវិតរស់នៅទាល់តែសោះ ។

នៅចុងឆ្នាំ១៩៧៨ ដោយសារតែមានការវាយប្រហាររបស់កងទ័ពវៀតណាម ប្រជាជននៅសហករណ៍ កងចល័តបន្ទាយរំចេកទាំងអស់ត្រូវបានខ្មែរក្រហមជម្លៀសឲ្យឡើងលើភ្នំទឹកពុះ ។ ពេលនោះ ម្តាយរបស់ខ្ញុំបានឮសំឡេងគ្រាប់កាំភ្លើងជាច្រើន បាញ់សំដៅមកប្រជាជនដែលរត់ឡើងទៅលើភ្នំ ។ ប៉ុន្តែក្រោយពីស្ថានភាពបានស្ងប់ស្ងាត់ ប្រជាជនទាំងអស់ក៏នាំគ្នាត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ រួមទាំងម្តាយរបស់ខ្ញុំផង ។

ទោះបីជារយៈពេល៣០ឆ្នាំកន្លងផុតទៅហើយក៏ដោយ ក៏ម្តាយរបស់ខ្ញុំមិនដែលភ្លេចអំពីហេតុការណ៍ដែលធ្វើឲ្យគាត់មានការភ័យខ្លាចនិងតក់ស្លុតឡើយ ។ លើសពីនេះទៅទៀត គាត់នៅតែនឹកសោកស្តាយបងប្រុសឈ្មោះ ហៀ ហៅ ទ្រី ដែលបានបាត់ខ្លួននៅក្នុងរបបនោះ ។ ចុងក្រោយ គាត់ក៏នៅតែសង្ឃឹមថាបងរបស់គាត់នៅរស់ហើយនឹងវិលត្រឡប់មកវិញដែរនៅថ្ងៃណាមួយមិនខាន ។

**ហ៊ិន សុធានី**

# សេចក្តីប្រកាសរកប្តី និងបងថ្លៃជីដូនមួយ

នាងខ្ញុំឈ្មោះ មី សយ អាយុ៥៧ សព្វថ្ងៃរស់នៅភូមិគគី ឃុំគគី ស្រុករមាសហែក ខេត្តស្វាយរៀង ។ ខ្ញុំមានកូនប្រុស៥នាក់ ស្លាប់អស់៤នាក់ ។ ខ្ញុំសូមប្រកាសស្វែងរកប្តីឈ្មោះ គឹម ពុធ (សព្វថ្ងៃគាត់មានអាយុ៦៣ឆ្នាំ) និង បងប្អូនជីដូនមួយឈ្មោះ ខ្លង ថន (សព្វថ្ងៃមានអាយុ៤០ឆ្នាំ) មានស្រុកកំណើតនៅភូមិគគី ឃុំគគី ស្រុករមាសហែក ខេត្តស្វាយរៀង ។ នៅឆ្នាំ១៩៧៥ ពេលដែលកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅរស់នៅខេត្តពោធិ៍សាត់ ។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាត់តាំងប្តីរបស់ខ្ញុំឲ្យធ្វើការនៅកន្លែងមួយឆ្ងាយពីភូមិ ។ ក្រោយយក ប្រជាជននៅក្នុងភូមិបានមកប្រាប់ខ្ញុំថា គាត់ត្រូវអង្គការចាប់ដាក់រថយន្ត រួចបញ្ជូនទៅក្រុងភ្នំពេញ ។ ចាប់តាំងពីពេលនោះ ខ្ញុំមិនដែលបានទទួលដំណឹងពីគាត់ឡើយ ។ ចំណែក ថន ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅរស់នៅខេត្តបាត់ដំបង រួចក៏បាត់ខ្លួនរហូតដែរ ។

ប្រសិនបើបងប្អូនណាបានស្គាល់ ឬបានឮដំណឹងពីឈ្មោះទាំងពីរខាងលើនេះ សូមមេត្តាទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ សូមអរគុណ ។



រូបថតក្របមុខ ៖ បង្ហាញអំពីពិធីរៀបការរបស់ នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ (ខាងឆ្វេង) ជាមួយនិង ប្រ៉ុក ខឿន ហៅ ប្រាក់ សាមុធ (ខាងស្តាំ) ។ នុន ហ៊ុយ កើតនៅឆ្នាំ១៩៥១ ហើយបម្រើការងារជាប្រធានមណ្ឌលកសាងខ្លួនព្រៃស ដែលត្រូវបានស្គាល់ថាជាមន្ទីរ ស-២៤ ។ ព្រៃស គឺជាផ្នែកមួយនៃបរិវេណសន្តិសុខមជ្ឈិមផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងនោះក៏មានរួមបញ្ចូលគុកទួលស្លែង (ស-២១) និងវាលពិឃាដនៅជើងឯកផងដែរ ។ ឯកសារគុកមួយចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៧ បានរាយការណ៍អំពីការសម្លាប់អ្នកទោស១៨នាក់នៅមន្ទីរស-២៤ ហើយមានកំណត់សម្គាល់ថា «រួមទាំងកុមារ១៦០នាក់ សរុបថ្ងៃនេះកម្ទេចខ្មាំងបាន១៧៨នាក់» ។ ឌុច ដែលជាអ្នកគ្រប់គ្រងទាំងមន្ទីរស-២៤ និងស-២១ បានផ្តល់សក្ខីកម្មក្នុងសប្តាហ៍នេះថា ហ៊ុយ ត្រូវបានសម្លាប់បន្ទាប់ពីអ្នកផ្សាយវិទ្យុរបស់គាត់គេចខ្លួនចេញពីព្រៃស ។ ប្រពន្ធរបស់ ហ៊ុយ ឈ្មោះ ប្រ៉ុក ខឿន (កើតឆ្នាំ១៩៥៣) គឺជាកម្មាភិបាលនៅមន្ទីរស-២៤ រហូតដល់ខែមិថុនា ឆ្នាំ១៩៧៧ ដោយគាត់ត្រូវបានដំឡើងឋានៈជាអនុប្រធានក្រុមខាងសួរចម្លើយ ដែលហៅថា «ក្រុមក្តៅ» នៅទួលស្លែង ។ ប្រភព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារលេខ D១១៧៥ និង K០៨២៧៣

ដោយបណ្ឌិត ចន ឆរធីអារី

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 118, October 2009 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.